# កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក

# ទិសដៅអនាគត

# Cambodia and WTO:
# Future Direction


រៀបរៀងដោយ

បណ្ឌិត **ចាប សុធារិទ្ធ**

Edited By Chap Sotharith



ឧបត្ថម្ភដោយ មូលនិធិ Friedrich-Ebert-Stiftung

បោះពុម្ពនៅ ព្រះរាជាណាចក្រកម្ពុជា ដោយ

**វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព**

២០០៦

សូមរក្សាសិទ្ធិគ្រប់បែបយ៉ាង។ មិនអនុញ្ញាតឱ្យយកវគ្គ ឬផ្នែកណាមួយ នៃសៀវភៅនេះទៅផលិតជាថ្មី ឬក៏បោះពុម្ពជាថ្មី ដោយគ្មានការអនុញ្ញាត ជាលាយលក្ខ័អក្សរ ពី វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ឡើយ។

**បោះពុម្ពផ្សាយលើកទី១ នៅព្រះរាជាណាចក្រកម្ពុជា ២០០៦**

© Cambodian Institute for Cooperation and Peace
First published in 2006 by Cambodian Institute for Cooperation and Peace
Phum Paung Peay, Sangkat Phnom Penh Thmey, Khan Russey Keo,
Phnom Penh, Kingdom of Cambodia
Mailing Address: P.O. Box 1007
Phnom Penh 12202, Kingdom of Cambodia
Telephone: 855-23-982 559
855-12-819-953 (Mobile)
855-12-835-509 (Mobile)
Fax: 855-23-982 559
E-mail: cicp@everyday.com.kh
Website: http://www.cicp.org.kh

# មាតិកា


មាតិកា ------------------------------------- ១

ការថ្លែងអំណរគុណ ------------------------------------ ៥

សេចក្តីផ្តើម : តើត្រូវធ្វើយ៉ាងណាដើម្បី ទទួលបានផលចំណេញជាអតិបរមា
ពីសមាហរណកម្មសេដ្ឋកិច្ច? ------------------------------ ៧

**បណ្ឌិត ចាប សុថារិទ្ធ------------------------------ ៧**

ផ្នែកទី ១------------------------------------------ ១៥

សុទ្ធរកថា ក្នុងសន្និសីទជាតិ --------------------------- ១៥

ព្រះសុន្ទរកថាស្វាគមន៍ ----------------------------- ១៦

**សម្តេច នរោត្តម សិរីវុឌ្ឍ ---------------------------១៦**

សន្ទរកថាស្វាគមន៍----------------------------------- ២០

**លោក អាក់សែល ស្មីត ---------------------------២០**

សុន្ទរកថាបើក ----------------------------------- ២៥

**សម្តេច ហ៊ុន សែន --------------------------------២៥**

កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលវិបាកផ្នែកច្បាប់
និងផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា -------------------------៣៨

**បណ្ឌិត ហង្ស ពុទ្ធា ------------------------------៣៨**

កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក ផលវិបាកផ្នែកច្បាប់
និងផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា ------------------------------- ៥០
**ឯកឧត្តម ស៊ុម សារ៉ាក់ ------------------------------------៥០**
កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់ពលកម្មកម្ពុជា ៥៤
**ឯកឧត្តម អ៊ុំ ចាន ----------------------------------------៥៤**
កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក "ផលប៉ះពាល់លើកសិកម្ម
និងឧស្សាហកម្មកាត់ដេរកម្ពុជា" ------------------------------- ៦២
**លោក សោម រួន ------------------------------------------៦២**
ផលវិបាកផ្នែកច្បាប់ និងផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា -------------- ៦៨
**លោក សុក សំអឿន --------------------------------------៦៨**
ផ្នែកទី ២ ----------------------------------------------៧៣
សុន្ទរកថា ក្នុងកិច្ចប្រជុំតុមូល -----------------------------------៧៣
តើមានផលវិបាកខាងច្បាប់ និងគោលនយោបាយអ្វីខ្លះ
ដល់សមាជិកភាពរបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក? ------ ៧៤
**លោក តាន់ យុវរដ្ឋ ---------------------------------------៧៤**
អង្គការពាណិជ្ជកម្មពិភពលោក និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា - ៨៥
**លោក សុក សំអឿន --------------------------------------៨៥**
កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់កសិកម្មកម្ពុជា ៨៩
**លោក ទូត សារាវុធ -------------------------------------៨៩**

កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះផលដល់កសិកម្មកម្ពុជា ៩៥
**លោកស្រី ប្រុក វ៉ាន់នី------------------------------------៩៥**

កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : -------------------១០៥
ផលប៉ះពាល់ដល់ពលកម្មកម្ពុជា ------------------------------១០៥
**ឯកឧត្តម អ៊ុំ មាន ------------------------------------១០៥**

តើមានផលប៉ះពាល់យ៉ាងណាចំពោះសមាជិក WTO
របស់កម្ពុជាទៅលើឧស្សាហកម្មកាត់ដេរ ----------------------១១៤
**លោក យា ប៊ុនណា -------------------------------------- ១១៤**

កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក :
តើមានផលប៉ះពាល់អ្វីខ្លះទៅលើកម្មវិធីកាត់បន្ថយភាពក្រីក្រ? ------- ១២១
**លោកស្រី ហ្វួត រតនៈ-----------------------------------១២១**

កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ការប្រើប្រាស់ WTO
ជាឧបករណ៍ជំរុញកំណែទម្រង់ -----------------------------១២៩
**លោក ហៀវ វ៉ាស្នា ------------------------------------១២៩**

ផ្នែកទី ៣---------------------------------------------១៤២
របាយការណ៍សង្ខេបនៃវេទិកាសាធារណៈ----------------------១៤២
របាយការណ៍សង្ខេបនៃវេទិកា ទី ១ ----------------------- ១៤៣
របាយការណ៍សង្ខេបនៃវេទិកា ទី ២ ------------------------១៥២
របាយការណ៍សង្ខេបនៃវេទិកា ទី ៣ ------------------------១៦២

របាយការណ៍សង្ខេបនៃវេទិកា ទី ៤---------------------------១៧០

របាយការណ៍សង្ខេបនៃវេទិកា ទី ៥-------------------------- ១៨១

របាយការណ៍សង្ខេបនៃវេទិកា ទី ៦-------------------------- ១៩៣

របាយការណ៍សង្ខេបនៃវេទិកា ទី ៧ --------------------------២០៦

របាយការណ៍សង្ខេបនៃវេទិកាទី ៨ ---------------------------២១៩

របាយការណ៍សង្ខេបនៃវេទិកា ទី ៩-------------------------- ២៣៨

របាយការណ៍សង្ខេបនៃវេទិកា ទី ១០ -------------------------២៥៥

ឧបសម្ព័ន្ធ ទី ១- កម្មវិធី ស្តីពី "ប្រទេសកម្ពុជាក្នុងការចូលជាសមាជិកភាព

អង្គការពាណិជ្ជកម្មពិភពលោក" -------------------------- ២៧១

ឧបសម្ព័ន្ធ ទី ២- កម្មវិធីវេទិកាទាំង ១០ លើក ស្តីពី "កម្ពុជា និង

អង្គការពាណិជ្ជកម្មពិភពលោក" ---------------------------២៧៥

ឧបសម្ព័ន្ធ ទី ៣ កម្មវិធីសន្និសីទជាតិ --------------------------២៨៨

ឧបសម្ព័ន្ធ ទី ៤ បញ្ជីរាយនាមអ្នករួមចំណែកក្នុងវេទិកា និងសន្និសីទជាតិ - ២៩៩

អំពីអ្នករៀបរៀង ---------------------------------- ៣០៣

# ការថ្លែងអំណរគុណ

តាងនាមឱ្យ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព អ្នករៀបរៀង សូមសម្តែងនូវកតញ្ញូតាធមិដ៏ស្មោះស ចំពោះការចូលរួម ជាគំនិត និងប្រាជ្ញាវាគ្មិន និងអ្នកចូលរួមជាតិ និងអន្តរជាតិ ដែលបានចូលរួមចំណែកក្នុងវេទិកាសាធារណៈ និងអង្គសន្និសីទជាតិ ដែលបានបញ្ចប់ដោយជោគជ័យក្នុងពេលកន្លងទៅនេះ ។

នៅក្នុងឱកាសនេះដែរ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព សូមថ្លែងអំណរគុណដល់អង្គការមូលនិធិ ហ្វ្រិឌ្រិច អេប៊ែត ដែលតំណាងដោយ **លោក អាក់ស៊ីល ស្ទីត** ប្រធានការិយាល័យសម្រាប់សហប្រតិបត្តិការភូមិភាគអាស៊ីអាគ្នេយ៍ ប្រចាំសិង្ហបូរី ដែលបានជួយឧបត្ថម្ភគម្រោងនេះ ជាពិសេសក្នុងការបោះពុម្ពសៀវភៅនេះ សម្រាប់ផ្សព្វផ្សាយចំណេះដឹងដល់សាធារណជនកម្ពុជា។

វិទ្យាស្ថានខ្មែរសហប្រតិបត្តិការ និងសន្តិភាព សូមសម្តែងនូវកតញ្ញូតាធមិដ៏ខ្ពង់ខ្ពស់ ចំពោះវត្តមាន **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល ឯកអគ្គរដ្ឋទូតនានា និងអ្នកតំណាងអង្គការពុំមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិទាំងអស់ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃចូលរួមសន្និសីទជាតិ ស្តីពី "**ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : អត្ថប្រយោជន៍ ការប្រឈមមុខ និងទស្សនវិស័យនៅអនាគត**" ដែលបានបញ្ចប់ជាស្ថាពរ ថ្ងៃទី ២១-២២ ខែ ធ្នូ ឆ្នាំ ២០០៥ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ជាទីបញ្ចប់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព សូមវាយតម្លៃខ្ពស់ និងសូមសរសើរដោយស្មោះ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិកទាំងអស់ ដូចជា **កញ្ញា នេត ច័ន្ទថា លោក ហម សំណាង លោក អ៊ីន តុងអាន លោក អ៊ីន តុងអ៊ឹង លោក នេត ណារ៉ូ លោក អ៊ុក ផល្លី លោក ហ៊ិន សុធី កញ្ញា ចាន់ ធី អ្នកស្រី ប៉ក់ ផារ៉ាណែត និងអ្នកស្រី នេត ណូរ៉ែន** ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការបោះពុម្ពសៀវភៅនេះឡើង។

# សេចក្ដីផ្ដើម : តើត្រូវធ្វើយ៉ាងណាដើម្បី ទទួលបានផលចំណេញជាអតិបរមា ពីសមាហរណកម្មសេដ្ឋកិច្ច?

បណ្ឌិត ចាប សុថារិទ្ធ

## ១. សារចារ

ក្រោយពីចាកផុតពីសង្គ្រាម និងការបំផ្លិចបំផ្លាញ អស់រយៈពេលជាច្រើនទសវត្សរ៍មក កម្ពុជាបានឆ្លងកាត់ដំណើការកំណែទម្រង់សេដ្ឋកិច្ច និងនយោបាយជាបន្តបន្ទាប់ ជាពិសេសចាប់តាំងពីការបង្កើតរដ្ឋធម្មនុញ្ញថ្មីនៅឆ្នាំ ១៩៩៣ ដែលបានបើកឱកាស ដល់ប្រទេសដ៏កម្សត់នេះអាចស្ដារឡើងវិញនូវស្ថិរភាព សន្តិភាព និងការបង្រួបបង្រួមជាតិ។ យើងបានប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងរដ្ឋាភិបាលតាមបែបសភានិយម ដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យជាគោល។

ទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជានៅតែប្រឈមមុខជាមួយនឹងផល-វិបាកជាច្រើន ដែលបន្សល់ទុកដោយប្រវត្តិសាស្ត្រ ដែលពោរពេញទៅដោយភាពចម្រូងចម្រាស វិនាសកម្ម បែកបាក់ ការស្អប់ខ្ពើម និងគុំគួន ព្រោះកម្ពុជាត្រូវបានរងគ្រោះជាទម្ងន់ដោយសង្គ្រាមអស់រយៈពេលដ៏យូរ ធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងធនធានមនុស្សរបស់ប្រទេសនេះ បានខូចខាតយ៉ាងធ្ងន់ធ្ងរ។ ភាពក្រីក្រ និងអំពើពុករលួយនៅតែជាឧបសគ្គដ៏ធំ ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា កាលពីអាណត្តិទី ២ របស់ខ្លួន (១៩៩៧-២០០៣) បានបង្កើតយុទ្ធសាស្ត្រត្រីកោណ ដែលសំដៅស្តារឡើងវិញនូវសន្តិភាព និងស្ថិរភាព ធានាការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍តំបន់ និងពិភពលោក ការអភិវឌ្ឍន៍ ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។ កំណែទម្រង់នានា ត្រូវបានអនុវត្តព្រមៗគ្នាក្នុងវិស័យជាច្រើន រួមមានកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងតុលាការ កំណែទម្រង់ហិរញ្ញវត្ថុ និងកំណែទម្រង់យោធា។ ដោយមានការប្តេជ្ញាចិត្ត ផ្នែកនយោបាយដ៏ខ្លាំងមួយ និងការចូលរួមពីដៃគូទាំងឡាយ កម្ពុជាបានចូលរួមជាសមាជិកអាស៊ានទៅខែ មេសា ឆ្នាំ ១៩៩៩ ដោយបានបញ្ចប់គោលដៅមួយគឺ សមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់។

ក្នុងអាណត្តិទីបីនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដែលសំដៅអនុវត្តកម្មវិធីនយោបាយទាំង ៧៣ ចំណុចរបស់រាជរដ្ឋាភិបាល និងធានាឱ្យបាននូវការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍ ការលូតលាស់ វឌ្ឍនភាព ឯកភាពជាតិ និងសុភមង្គលសម្រាប់ប្រជាពលរដ្ឋ។ ការបន្តធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសេដ្ឋកិច្ចពិភពលោក ក៏នៅតែជាចំណុចគោលដៅមួយ ក្នុងយុទ្ធសាស្ត្រចតុកោណផងដែរ។

ការចូលរួមក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) គឺជាអាទិភាពខ្ពស់បំផុតរបស់រដ្ឋាភិបាល ព្រោះសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក ត្រូវបានចាត់ទុកថាជាឧបករណ៍ដ៏ខ្លាំងក្លាមួយ ដើម្បីកាត់បន្ថយភាពក្រីក្រ និងជាកម្លាំងជំរុញដ៏ចម្បងដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច។ នៅក្នុងការកែទម្រង់ប្រព័ន្ធពាណិជ្ជកម្ម រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ សម្របសម្រួលគោលនយោបាយ និងបែបបទលិខិតបទដ្ឋានទាក់ទងនឹងពាណិជ្ជកម្ម ឱ្យស៊ីចង្វាក់ទៅនឹងគោលការណ៍របស់ WTO ជាពិសេសគោលការណ៍ MFN និងប្រព្រឹត្តិកម្មជាតិ។ ប្រព័ន្ធលេខកូដពន្ធគយមួយ ដែលផ្អែកលើ

ប្រព័ន្ធសុខុដុមនីយកម្ម ឆ្នាំ១៩៩៦ (Harmonized System) ត្រូវបានអនុម័ត ហើយច្បាប់មួយចំនួនត្រូវបានកែសម្រួលព្រាងថ្មី និងអនុម័តដើម្បីធានានូវភាពស៊ីចង្វាក់ជាមួយនឹងគោលការណ៍ WTO ។

## ២. អ្វីជាអង្គការពាណិជ្ជកម្មពិភពលោក?

WTO គឺជាអង្គការអន្តរជាតិសាកលតែមួយគត់ដែលពាក់ព័ន្ធ ជាមួយនឹងក្បួនច្បាប់ពាណិជ្ជកម្មរវាងប្រជាជាតិនានា។ នៅចំណុចកណ្តាលរបស់ WTO គឺជាកិច្ចព្រម-ព្រៀងពាណិជ្ជកម្ម WTO ដែលត្រូវបានចរចា និងចុះហត្ថលេខាដោយក្រុមប្រទេសជាច្រើនក្នុងសកលលោក និងទទួលសច្ចាប័នពីរដ្ឋសភារបស់ប្រទេសទាំងនោះ។ អង្គការនេះមានគោលបំណងជួយអ្នកផលិតទំនិញ និងសេវាកម្ម អ្នកនាំចេញ និងអ្នកនាំចូលដើម្បីដំណើរការអាជីវកម្មរបស់ពួកគេ។

WTO មានមុខងារដូចខាងក្រោមនេះ :

១- គ្រប់គ្រងកិច្ចព្រមព្រៀងពាណិជ្ជកម្ម WTO

២- ជាវេទិកាដើម្បីការចរចាពាណិជ្ជកម្ម

៣- ដោះស្រាយជំលោះពាណិជ្ជកម្ម

៤- ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មជាតិ

៥- ជំនួយបច្ចេកទេស និងបណ្តុះបណ្តាលសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍

៦- សហប្រតិបត្តិការជាមួយអង្គការអន្តរជាតិដទៃទៀត។

## ៣. ផលវិបាកនៃការអនុវត្តកិច្ចព្រមព្រៀង WTO

ប្រទេសកម្ពុជាបានដាក់ជូននូវការយល់ព្រម ទៅតាមលក្ខខ័ណ្ឌ WTO នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ ទៅតាមល័ក្ខខ័ណ្ឌនៃសមាជិកភាពដែលបានចែងក្នុងពិធីសារចូលជាសមាជិក ហើយត្រូវបានអនុម័តដោយសន្និសីទរដ្ឋមន្ត្រីកាលពី ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ហើយត្រូវបានចុះហត្ថលេខាដោយកម្ពុជា ជាកម្មវត្ថុនៃការសុំសច្ចាប័នពីរដ្ឋសភា។ កម្ពុជាបានក្លាយជាសមាជិកទី ១៤៨ របស់ WTO កាលពីថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០០៤ ដូច្នេះ កម្ពុជាជាប្រទេសមានការអភិវឌ្ឍតិចតួចទី ២ បន្ទាប់ពីនេប៉ាល់ដែលបានចូលរួមក្នុង WTO ឆ្លងតាមដំណើរការចរចាភាគីការងារពេញលេញ។[១]

ការអនុវត្តគោលការណ៍ WTO គឺជាដំណើរការដ៏វែងឆ្ងាយ និងលំបាកមួយ ។ ដោយហេតុនេះ តំណាងកម្ពុជាក្នុងពេលចរចាបានស្នើសុំសមាជិកនៃភាគីការងារឱ្យ មេត្តាយោគយល់ដល់កម្ពុជាដែលជាប្រទេសអភិវឌ្ឍតិចតួច (ប្រទេសក្រីក្រ) និងសុំឱ្យគេផ្ដល់ប្រព្រឹត្តកម្មពិសេស និងដាច់ដោយឡែកដល់កម្ពុជា ដូចដែលបានចែងក្នុងកិច្ចព្រមព្រៀង WTO ទាក់ទងនឹងប្រទេសអភិវឌ្ឍតិច (LDC) ។

ប៉ុន្តែ ការដណ្ដើមបាននូវអត្ថប្រយោជន៏អតិបរមា ពីសមាជិក WTO មិនមែនជាការងាយទេ។ ការទទួលបាននូវផលប្រយោជន៏នៃទីផ្សារ ទាមទារកំណែទម្រង់ដ៏ស្រួចស្រាល ដែលអាចហួសពីអ្វីដែលកម្ពុជាបានប្ដេជ្ញាចិត្តក្នុងពេលចរចា។ អ្នកផលិតក្នុងស្រុករបស់កម្ពុជា កំពុងជួបប្រទះនូវឧបសគ្គមួយចំនួន ដូចជាកង្វះខាតពត៌មានទីផ្សារអន្តរជាតិ កង្វះចំណេះដឹងផ្នែកគ្រប់គ្រង និងសហគ្រិនភាព ការផលិតមានថ្លៃដើមខ្ពស់

---

[1] *ប្រទេសខ្លះ បានចូលអង្គការនេះ ដោយស្វ័យប្រវត្តិ មិនបានឆ្លងកាត់ការចរចា ព្រោះគេជាសមាជិក GATT ដែលក្រោយមក ក្លាយជាWTO កាលពីឆ្នាំ ១៩៩៤*

និងកង្វះការត្រួតពិនិត្យគុណភាពទំនិញ។ ពួកគេត្រូវប្រកួតប្រជែងជាមួយទំនិញនាំចូល ដែលមានអត្រាពន្ធគយទាប ដែលអាចឈានទៅធ្វើឱ្យខូចខាតផលប្រយោជន៍នៃការដណ្តើមទីផ្សារ។ ជាឧទាហរណ៍ ស្រូវជាផលិតផលដ៏សំបូរបំផុតរបស់ជាតិនោះ តើធ្វើយ៉ាងណា ទើបកសិករអាចលក់ស្រូវទៅទីផ្សារអន្តរជាតិបាន ប្រសិនបើអ្នកដាំខ្វះពូជស្រូវល្អៗ ខ្វះមធ្យោបាយ និងបច្ចេកទេសនានា ចំណែកឯអ្នកកិនស្រូវក្នុងស្រុកខ្វះទុន ខ្វះបច្ចេកវិទ្យាទំនើប ហើយគាត់ត្រូវបង់ថ្លៃអគ្គិសនី ដែលថ្លៃកប់ពពក បើធៀបទៅនឹងប្រទេសជិតខាងក្នុងតំបន់ ហើយគាត់គ្មានផ្លូវល្អទៅដល់ទីផ្សារ និងត្រូវសូកលុយក្រៅផ្លូវការជាច្រើនកន្លែង ?

ដើម្បីឱ្យមានផលប្រយោជន៍ពិតប្រាកដទៅលើភាពក្រីក្រ កំណែទម្រង់ និងគោលការណ៍អភិបាលកិច្ចល្អ ត្រូវតែអនុវត្តដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម និងបង្កើនលទ្ធភាពប្រកួតប្រជែងរបស់យើង។ គោលនយោបាយពាណិជ្ជកម្មគឺជាជំហានទី១ សំខាន់ដើម្បីគាំទ្រការដណ្តើមទីផ្សារ។

ប្រទេសកម្ពុជា គឺជាប្រទេសដែលមានសេដ្ឋកិច្ចតូចមួយក្នុងតំបន់ ដោយមានមូលដ្ឋានពាណិជ្ជកម្មនៅមានកម្រិត។ ប្រទេសនេះនាំចូលទំនិញ និងសេវាកម្មច្រើនជាងនាំចេញ។ ឱនភាពផ្នែកពាណិជ្ជកម្មមានប្រហែលពី ៣០០ ទៅ ៦០០ លានដុល្លារ ក្នុងមួយឆ្នាំ។ ចរាចររូបិយប័ណ្ណ និងការទូទាត់នានា ប្រហែលជា ៧៥% ធ្វើតាមរយៈប្រាក់ដុល្លារ ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម និងតាមរយៈសាច់ប្រាក់។ ដូចនេះតាមរយៈអ្នកវិភាគជាច្រើន គេយល់ថា ប្រទេសកម្ពុជាមិនទាន់ត្រៀមខ្លួនបានល្អសម្រាប់ការប្រកួតប្រជែង នៅក្នុងពាណិជ្ជកម្មពិភពលោកនៅឡើយ។ ទោះជាកម្ពុជា ឥឡូវនេះជាសមាជិករបស់ WTO ដោយមានប្រទេស ១៤៧ ជាទីផ្សាររបស់ខ្លួន ក៏ដោយ ក៏របៀបឈោងចាប់ទីផ្សារទាំងនោះនៅមិនទាន់ច្បាស់នៅឡើយ។

កម្ពុជាជាប្រទេសក្រីក្រដែលផ្អែកលើកសិកម្ម និងមានតែឧស្សាហកម្មកាត់ដេរសំលៀកបំពាក់មួយគត់ ដែលមានលទ្ធភាពនាំចេញច្រើនជាងគេ ។ ដូច្នេះ សមាជិកភាពនៃ WTO ប្រាកដជាមានផលប៉ះពាល់ចំពោះកម្ពុជាជាមិនខាន។ ទោះបីជារដ្ឋាភិបាលមានជំហរវិជ្ជមាន ចំពោះសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោកក៏ដោយ ក៏ពលរដ្ឋខ្មែរខ្លះ រួមមានវិស័យឯកជន និងសង្គមស៊ីវិលនៅតែខ្វល់ខ្វាយអំពី ការប្រកួតប្រជែងកាន់តែច្រើនឡើងៗ ដែលធ្វើឱ្យកម្ពុជាពិបាកនឹងឈ្នះ។

ការចរចាឱ្យក្លាយជាសមាជិក WTO ជាជំហានដ៏លំបាកមួយ ប៉ុន្តែការអនុវត្តន៍កិច្ចព្រមព្រៀងរបស់ WTO គឺជាជំហានរឹតតែស្មុគស្មាញមួយទៀត។ ប្រជាជនកម្ពុជាគ្រប់រូប គួរតែខិតខំធ្វើការងារជាមួយគ្នា ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមានទាំងឡាយ ដើម្បីទទួលបាននូវផលចំណេញជាអតិបរមាក្នុងរបបពាណិជ្ជកម្មពិភពលោក។

កម្ពុជាត្រូវខាតបង់ថ្លៃខាតខ្លះ ក្រោយចូល WTO ពីការបាត់បង់នៃចំណូលដែលបណ្តាលមកពីការកាត់បន្ថយអត្រាពន្ធគយ ហើយកម្ពុជាក៏ត្រូវបង់ថ្លៃ សម្រាប់ការប្រជុំជាច្រើន និងការបង្កើតស្ថាប័នថ្មីដើម្បីគ្រប់គ្រង និងអនុវត្តកិច្ចព្រមព្រៀង WTO។ ក៏ប៉ុន្តែ ការបង់ខាតនេះ អាចបំពេញបន្ថែមបានតាមរយៈការកើនឡើងនៃទំហំពាណិជ្ជកម្ម វិនិយោគទុន និងការងារដែលកម្ពុជារំពឹងថា នឹងទទួលបានពីឥទ្ធិពលនៃសមាជិកភាពនេះ។

អ្នកខ្លះបានរិះគន់កម្ពុជាចំពោះ ការប្តេជ្ញាចិត្តដ៏ខ្លាំងនិងលឿនពេក ក្នុងការបើកចំហទីផ្សារខ្លួន ជាថ្នូរនឹងសមាជិកភាពក្នុងពេលចរចា។ កម្ពុជាមានកាតព្វកិច្ចរួចហើយតាមរយៈសមាជិកនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ដោយលុបបំបាត់អត្រាពន្ធគយនាំចូលនៅឆ្នាំ ២០១៥ ក៏ប៉ុន្តែត្រូវអនុវត្ត កញ្ចប់ពន្ធគយជាច្រើនមុនពេលនោះដើម្បីឆ្លើយតបទៅនិងតម្រូវការ WTO។ កម្ពុជានឹងមិនអាចយកពន្ធលើផលិតផល

កសិកម្មដែលជាប្រភពចំណូលចម្បង ៨០ % នៃប្រជាជនឱ្យលើសពី ៦០ % បានឡើយ។ ផ្ទុយទៅវិញ សហភាពអឺរ៉ុបអាចយកពន្ធគយពីលើកសិផលរហូតដល់ទៅ ២៥២ % សហរដ្ឋអាមេរិកយកពន្ធរហូតដល់ទៅ ១២១ % និងកាណាដា ១២០ %។[២]

លើសពីនេះទៅទៀត កម្ពុជាមិនអាចទទួលបានផលប្រយោជន៍ ពីសម្បទានដូហា (Doha) ស្ដីអំពី កម្មសិទ្ធិបញ្ញាដែលអនុញ្ញាតឱ្យប្រទេសអភិវឌ្ឍតិចរង់ចាំរហូតដល់ឆ្នាំ ២០១៦ មុនពេលអនុវត្តបញ្ញត្តិនៃពិធីសារ ស្ដីអំពី កម្មសិទ្ធិបញ្ញាទាក់ទងពាណិជ្ជកម្ម (TRIPS)។ កម្ពុជានឹងត្រូវអនុវត្តពិធីសារនោះនៅឆ្នាំ ២០០៧។ ក៏ប៉ុន្តែក្នុងល័ក្ខខ័ណ្ឌជាក់ស្ដែងសមាសភាពខ្លះរបស់ TRIPS ជាពិសេសអ្វីដែលទាក់ទងនឹងការការពារទិន្នន័យ និងទម្រង់ទូទៅនៃផលិតផលនឹងមានសុពលភាពភ្លាម ក្រោយពីកម្ពុជាចូលជាសមាជិក WTO សូម្បីតែសមាជិកបច្ចុប្បន្ន ត្រូវបានគេអនុញ្ញាតឱ្យរង់ចាំដល់ ១០ ឆ្នាំ ទៀត ។

តែទោះជាមានការលំបាក និងការប្រឈមយ៉ាងណាក៏ដោយ ការចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោកនេះ ប្រៀបដូចជាការចូលរួមក្នុងក្លឹបឬការចូល ក្នុងការប្រកួតប្រជែងមួយដូច្នេះដែរ។ បើយើងមិនចូលប្រឡូកក្នុងការប្រកួតប្រជែង ដណ្ដើមទីផ្សារជាមួយគេទេ នោះយើងនឹងមិនដឹងថាសមត្ថភាពយើងមានប៉ុណ្ណាទេ ហើយយើងក៏មិនសូវខិតខំកសាងសមត្ថភាពយើងដើម្បីរត់តាមគេ និងប្រកួតជាមួយគេបានឡើយ ។

ប្រទេសយើងនៅមានសក្ដានុពលភាពច្រើនណាស់ ដោយយើងនៅមិនទាន់បានប្រើប្រាស់អស់ ដូចជា យើងមានផ្ទៃដីធំទូលាយ ដែលអាចអំណោយផលដល់កសិកម្ម

[២] Alan Boyd (2003) The heavy price of WTO membership http://www.atimes.com/atimes/Southeast_Asia/E130Ae02.html accessed on 30 Sep 2003

និងកសិឧស្សាហកម្ម ។ យើងមានតំបន់ឆ្នេរសមុទ្រដែលនៅទំនេរ ដែលអាចអភិវឌ្ឍទៅជាតំបន់សេដ្ឋកិច្ចពិសេស និងនិគមឧស្សាហកម្ម និងពាណិជ្ជកម្មអន្តរជាតិ ។ យើងមានធនធានធម្មជាតិដ៏សំបូរសុក្កសុម្ភ ដែលមិនទាន់ធ្វើអាជីវកម្ម រួមមានរ៉ែ ប្រេងកាត និងឧស្ម័ន ។ វិស័យទេសចរណ៍ សំណង់ សេវាកម្មនានា ក៏នៅតែបន្តជាកម្លាំងចលករដែលអាចជំរុញការលូតលាស់សេដ្ឋកិច្ចកាន់តែខ្លាំងក្លាថែមទៀត ។

ដើម្បីឆ្លើយតបទៅនឹងសំណួរដែលថា *"តើកម្ពុជាត្រូវធ្វើយ៉ាងណាដើម្បីទទួលផលប្រយោជន៍ជាអតិបរមា ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ច"* ខាងក្រោមនេះគឺជាអត្ថបទជម្រើសដែលវាគ្មិនកិត្តិយសយើង បានបង្ហាញក្នុងវេទិកាសាធារណៈ និងអង្គសន្និសីទថ្នាក់ជាតិទាក់ទងនឹង "កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក" ដែលជាគម្រោងពេញមួយឆ្នាំ របស់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ។ អ្នករៀបរៀង បានខិតខំកែសម្រួលពាក្យពេចន៍ និងអក្ខរាវិរុទ្ធខ្លះៗ ដើម្បីងាយស្រួលក្នុងការអាន និងឈ្វេងយល់ ។

# ផ្នែកទី ១

# សមាហរណកម្ម ក្នុងសន្ធិសញ្ញាអន្តរជាតិ

# ព្រះសុន្ទរកថាស្វាគមន៍

## សម្តេច នរោត្តម សិរិវុឌ្ឍ

ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង
ជាព្រះប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

- សូមគោរពសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- សូមគោរពលោក Axel Schmidt, ប្រធានការិយាល័យសហប្រតិបត្តិការតំបន់អាស៊ីអាគ្នេយ៍ Friedrich Ebert Stiftung ដែលមានទីស្នាក់ការនៅសិង្ហបុរី
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សមាជិក សមាជិកា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិនៃសន្និសីទថ្ងៃនេះជាទីគោរព និងជាទីមេត្រី ។

ជាបឋម ក្នុងនាមវិទ្យាស្ថានខ្មែរសម្រាប់ប្រតិបត្តិការ និងសន្តិភាព និងមូលនិធី Friedrich-Ebert Stiftung និងក្រុមលេខាធិការរៀបចំសន្និសីទនេះ ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងរាក់ទាក់ និងកក់ក្តៅបំផុត ចំពោះវត្តមាន សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ដែលបានអញ្ជើញចូលរួមនៅក្នុងសន្និសីទជាតិថ្ងៃនេះ ។

ថ្ងៃនេះជាទិវាដ៏មហានក្ខត្តប្ញក្ស ដោយវិទ្យាស្ថានខ្មែរសម្រាប់ប្រតិបត្តិការ និងសន្តិភាព បានរួមសហការជាមួយអង្គការ Friedrich-Ebert Stifstung រៀបចំ

សន្និសីទជាតិ ស្តីអំពី **កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប្រយោជន៍ ការប្រឈម និងទិសដៅអនាគត** ជាពិសេសដោយយើងបានទទួលកិត្តិយសដ៏ឧត្តុង្គឧត្តម បំផុតចំពោះវត្តមានដ៏ខ្ពង់ខ្ពស់ របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងពិធីបើកសន្និសីទនេះ។

យើងខ្ញុំសូមកោតសរសើរ នូវទឹកចិត្តស្រឡាញ់រាប់អាន និងគាំទ្រដ៏ស្មោះស្ម័គ្រ របស់សម្តេចនាយករដ្ឋមន្ត្រី ដែលជានិច្ចជាកាលតែងតែយកចិត្តទុកដាក់ និងផ្តល់កិត្តិយសជូនវិទ្យាស្ថានខ្មែរសម្រាប់ប្រតិបត្តិការ និងសន្តិភាពយើងខ្ញុំ ហើយពេលនេះទៀតសោត សម្តេចក៏បានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹករបស់សម្តេចចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីនេះ ដែលជាការសរបញ្ជាក់នូវស្មារតីសហប្រតិបត្តិការ និងការគាំទ្រយ៉ាងស្មោះស្ម័គ្រ ដល់សកម្មភាពដ៏មានសារៈប្រយោជន៍នេះរបស់យើងខ្ញុំ។ វត្តមានរបស់សម្តេច ពិតជាជួយជំរុញលើកទឹកចិត្តឱ្យសន្និសីទនេះ រឹតតែមានភាពអធិកអធម និងប្រកបដោយអត្ថន័យ និងខ្លឹមសារយ៉ាងជ្រាលជ្រៅថែមទៀត។

សម្តេច ឯកឧត្តម លោកជំទាវ និងអង្គសន្និសីទទាំងមូល

កម្ពុជាបានសម្រេចជាស្ថាពរ និងអនុវត្តយ៉ាងជោគជ័យនូវការធ្វើសមាហរណ-កម្ម សេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងតំបន់ និងក្នុងពិភពលោក។ ក្រោយពីយើងបានចូលជាសមាជិកអាស៊ាននៅខែមេសា ឆ្នាំ១៩៩៩ ហើយ យើងក៏បានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក កាលពីខែតុលា ឆ្នាំ២០០៤ ក្រោយពីចរចាដ៏តឹងតែងអស់រយៈពេលជាច្រើនឆ្នាំមក។ ដូច្នេះ យើងបានចូលជាសមាជិក WTO ជាងមួយឆ្នាំ ហើយ។ សន្និសីទនេះ ពិតជាធ្វើឡើងយ៉ាងសមស្រប និងទាន់ពេលវេលាដើម្បីបូកសរុប និងវាយតម្លៃពីគុណវិបត្តិ និងគុណសម្បត្តិ និងលើកទិសដៅទៅអនាគតសម្រាប់យើងក្នុងគោលបំណងរៀបចំយុទ្ធសាស្ត្រ ទាញយកផលប្រយោជន៍ឱ្យបានជាអតិបរមាពីសមាជិក

ភាពរបស់អង្គការ WTO នេះ ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិយើង ជាពិសេសគឺការកាត់បន្ថយភាពក្រីក្រ ។

ខ្ញុំសូមឆ្លៀតឱកាសនេះសូមជម្រាបជូនគណៈអធិបតី និងភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិទាំងអស់សូមមេត្តាជ្រាបថា សន្និសីទជាតិនេះគឺជាការបូកសរុបការងារ ដែលវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាពបានធ្វើអស់រយៈពេលពេញមួយឆ្នាំ តាមរយៈការរៀបចំជាវេទិកាសាធារណៈចំនួន១០លើក ដើម្បីពិគ្រោះយោបល់ ពិភាក្សា និងការផ្សព្វផ្សាយ ចំណេះដឹងដល់សាធារណជនទូទៅ ឱ្យយល់ពីផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានដល់ប្រទេសយើង និងស្វែងរកអនុសាសន៍ នានាដើម្បីជម្នះការប្រឈមនានា និងសម្រេចបាននូវគុណប្រយោជន៍ជាអតិបរិមា ពីសមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោក ។

ជាថ្មីម្តងទៀត តាងនាមឱ្យសិក្ខាសាលាទាំងមូល ទូលបង្គំ យើងខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សមាជិក សមាជិកានៃអង្គសន្និសីទទាំងមូល ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញមកចូលរួមចំណែកធ្វើឱ្យពិធីនេះមានសភាពអធិកអធម និងសម្រេចបានជោគជ័យ ។

មុននឹងបញ្ចប់ ខ្ញុំមានមហាកិត្តិយស សូមគោរពជូនពរ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាសមាជិក សមាជិកា សិក្ខាសាលាទាំងមូល សូមប្រកបដោយព្រះពុទ្ធពរ ទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ជាបន្ទាប់តទៅនេះខ្ញុំសូមគោរពអញ្ជើញ លោក Axel Schmidt ដែលជាប្រធានការិយាល័យសហប្រតិបត្តិការតំបន់អាស៊ីអាគ្នេយ៍ FES ដែលពេលនេះ បានរួមសហការ និងឧបត្ថម្ភជាមូលនិធិ ដល់វិទ្យាស្ថានសម្រាប់ប្រតិបត្តិការ និងសន្តិភាព ក្នុងការរៀបចំសន្និសីទជាតិដ៏មានសារៈសំខាន់នេះ ។

# សន្ទរកថាស្វាគមន៍

## លោក អាក់សែល ស្មីត

ដោយសេចក្តីរីករាយ ខ្ញុំសូមចូលរួមជាមួយអស់លោក លោកស្រី ក្នុងសន្និសីទជាតិ ស្តីពី "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប្រយោជន៍ ការប្រឈមមុខ និងទិសដៅទៅអនាគត "។ សន្និសីទនេះគឺជាការផ្តុំឡើង នៃកិច្ចពិភាក្សាតុមូល ជាបន្តបន្ទាប់ ដែលវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បានរៀបចំឡើងក្នុងខែកន្លងមក។ កិច្ចពិភាក្សាតុមូលទាំងនេះ បានលើកយកមកពិភាក្សាទិដ្ឋភាព ពិសេស១នៃសមាជិកអង្គការ WTO របស់ប្រទេសកម្ពុជា។ ដោយហេតុថា សន្និសីទនេះនឹងពិនិត្យមើលពីអនាគតរបស់ប្រទេសកម្ពុជា ក្នុងនាមជាសមាជិកអង្គការ WTO ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីរំលឹកឡើងវិញពីប្រភពកំណើតនៃអង្គការនេះ ក្នុងបទអត្ថាធិប្បាយរបស់ខ្ញុំដូចតទៅ :

នៅថ្ងៃទី ១៣ តុលា ២០០៤ ប្រទេសកម្ពុជា បានចូលជាសមាជិកទី ១៤៨ នៃអង្គការ WTO។ ព្រឹត្តិការណ៍នេះអាចមិនត្រូវបានគេកត់សំគាល់ បើសិនជាវាមិនឆ្លុះបញ្ចាំងការពិត ដែលថាប្រទេសកម្ពុជាមានការអភិវឌ្ឍន៍តិច និងបានឆ្លងកាត់ដំណើរការចរចា ក្នុងក្រុមការងារដ៏ពេញលេញប្រកបដោយការលំបាក តែមានការផ្ចិតផ្ចង់ និងតស៊ូ ក្នុងអំឡុងពេលចរចាជិត ១០ ឆ្នាំ ប្រទេសកម្ពុជាត្រូវធ្វើសម្បទានជាច្រើន ដែលការធ្វើសម្បទានខ្លះអាចមានលក្ខណៈផ្ទុយទៅនឹងផលប្រយោជន៍ជាតិរបស់ខ្លួន។ ខ្ញុំសូមអនុញ្ញាតដកស្រង់នូវសម្បទាន ២ ក្នុងចំណោមសម្បទានទាំងនោះ។

ក្នុងនាមជាសមាជិកថ្មីនៃអង្គការ WTO ប្រទេសកម្ពុជាមិនមានសិទ្ធិឧបត្ថម្ភទុន និងទំនុកបំរុងកសិកម្មរបស់ខ្លួន ដូចប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ហើយថ្មីៗនេះសមាជិក WTO អាចមានសិទ្ធិធ្វើបែបនេះរហូតដល់ឆ្នាំ ២០១៥។ ដូច្នេះ ប្រទេសកម្ពុជា ៨០% នៃប្រជាពលរដ្ឋរបស់ខ្លួន ដែលរស់ដោយកសិកម្ម អាចត្រឹមតែការពារផ្នែកនេះជាមួយកាតព្វកិច្ច និងពន្ធគយ លើផលិតផលកសិកម្មបានចំនួនតែ ៦០% ជាអតិបរមា។ ផ្ទុយទៅវិញ សហភាពអឺរ៉ុបអាចការពារបានជាង ២៥២% និងសហរដ្ឋអាមេរិកបាន ១២០%។

នៅពេលដែលសមាជិក WTO មានពេលរហូតដល់ឆ្នាំ ២០១៥ ប្រទេសកម្ពុជាត្រូវអនុវត្តសន្ធិសញ្ញា TRIPS ឱ្យបានរួចរាល់រហូតដល់ថ្ងៃទី ១ មករា ២០០៧ ។ ដោយគិតពីបញ្ហានេះ ការប៉ាន់ប្រមាណពីអ្នកដែលរងគ្រោះដោយមេរោគហ៊ីវ ដែលមានជាង ១០០.០០០ នាក់ ប្រទេសកម្ពុជានឹងមានការពិបាកក្នុងការផ្តល់ទៅដល់ពួកគេ នូវថ្នាំជំនួយទប់ទល់នឹងជំងឺនេះ ដោយតម្លៃថោកសម្រាប់ព្យាបាល។

ក្នុងការក្លាយជាសមាជិក WTO ក្នុងតម្លៃបែបនេះ ធ្វើឱ្យគេងឿងឆ្ងល់ថា ហេតុអ្វីប្រទេសកម្ពុជា បានត្រៀមខ្លួនរួចរាល់ក្នុងការចំណាយសម្រាប់ការចូលនេះ។ ខ្ញុំអាចស្មានបានថា មានហេតុផល ២ យ៉ាង ដូចតទៅ។

ទី១-គឺជាហេតុផលចិត្តសាស្ត្រ។ ការចរចាសមាជិកភាពរបស់ប្រទេសកម្ពុជាបានចាប់ផ្តើមក្នុងឆ្នាំ ១៩៩៤ គឺមួយឆ្នាំក្រោយ ពីប្រទេសកម្ពុជាបានត្រឡប់ទៅរកភាពធម្មតារបស់ខ្លួនវិញ។ ប្រទេសកម្ពុជាចង់បិទទំព័រខ្មៅងងឹតនៃសង្គ្រាមស៊ីវិល របបប្រល័យពូជសាសន៍ ភាពឯកោ និងអំពើហិង្សារបស់ខ្លួន។ ដូចគ្នានឹងការប្រឹងប្រែងដើម្បីទទួលបានសមាជិកភាពក្នុងសមាគមន៍អាស៊ាន ប្រទេសកម្ពុជាចង់ក្លាយខ្លួនជាម្តង

ទៀត ជាសមាជិកម្នាក់ ដ៏គួរឱ្យគោរពនៃសហគមន៍អន្តរជាតិ តាមរយៈការចូលរួមទៅក្នុងអង្គការ WTO ។

ហេតុផលទី ២ គឺជាហេតុផល ដើម្បីអភិវឌ្ឍន៍។ ប្រទេសកម្ពុជាមិនអាចកសាងឡើងវិញដោយត្រូវហែកហួរដោយសង្គ្រាមរបស់ខ្លួន និងសេដ្ឋកិច្ចដែលត្រូវបានធ្វើឱ្យខ្ទេចខ្ទាំដោយមនោគមវិជ្ជាផ្ទាល់ខ្លួន ដែលទទួលទំនុកបម្រុងពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) រហូតបានឡើយ ។ តាមរយៈការបើកចំហ និងការធ្វើសេរីភាវូបនីយកម្មទីផ្សារ និងពាណិជ្ជកម្មសេរីរបស់ខ្លួនទៅក្នុងក្របខ័ណ្ឌ WTO ប្រទេសកម្ពុជាចង់ទាក់ទាញការវិនិយោគបរទេសក្នុងស្រុក ចង់ធ្វើការកែទម្រង់រចនាសម្ព័ន្ធ អភិវឌ្ឍន៍ធនធានមនុស្ស ជំរុញឧស្សាហកម្មកាត់ដេររបស់ខ្លួន កាត់បន្ថយភាពក្រីក្រ និងរកទីផ្សារនៅឯក្រៅប្រទេសសម្រាប់ផលិតផលទាំងនោះ ។

ប្រទេសកម្ពុជាបានទទួលកំណើនសេដ្ឋកិច្ចដ៏គួរឱ្យកត់សំគាល់ និងបានងើបឡើងវិញក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ សួរថាតើសូចនាករទាំងនេះ អាចកើតឡើងដោយសារតែមាន ការចរចារបស់ប្រទេសកម្ពុជា ឱ្យបានក្លាយជាសមាជិក WTO និងការចូលរួមជាសមាជិកពេញសិទ្ធិរបស់ខ្លួនយ៉ាងណា នោះគឺវាហួសពីការយល់ដឹងរបស់ខ្ញុំ ។

យោងទៅតាមលទ្ធផល នៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃអង្គការ WTO ថ្មីៗនេះនៅទីក្រុងហុងកុង និងកិច្ចប្រជុំនៅទីក្រុងដូហា (Doha Development Round) ដែលមិនសូវមានការអូសទាញ តើវាជាការសម្រេចចិត្តដ៏ត្រឹមត្រូវរបស់ប្រទេសកម្ពុជាក្នុងការចូលអង្គការ WTO ឬទេ? តើមានជម្រើសផ្សេងៗទៀតឬទេ?

ប្រទេសកម្ពុជាអាចស្ថិតនៅក្រៅអង្គការ WTO ហើយបច្ចុប្បន្ននេះផលប្រយោជន៍ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិច (LDC) ពីការចូលជាឯកតោភាគី ដូចជាគំនិតផ្តួចផ្តើមរបស់សហគមន៍អឺរ៉ុប ដែលមានឈ្មោះថា "អ្វីៗទាំងអស់លើកលែងតែ

អារ៉ុធចេញ"។ ទោះជាយ៉ាងនេះក្តី គំនិតផ្តួចផ្តើមនេះមានលក្ខណៈឯកតោភាគី ហើយត្រូវបានតម្រង់ដោយពួកអឺរ៉ុប។ ប្រទេសកម្ពុជា ឬប្រទេសអភិវឌ្ឍន៍តិចតួចដទៃទៀត គ្មានអ្វីត្រូវនិយាយក្នុងការថែងបែបនេះ ចំពោះវិសាលភាព និងមាតិកា (Scope and content) នៃសម្បទានដែលផ្តល់ដោយសហគមន៍អឺរ៉ុប ចំពោះប្រទេសអភិវឌ្ឍន៍ តិចទាំងនោះ។ លើសពីនេះទៀត តាមទ្រឹស្តីគំនិតផ្តួចផ្តើមបែបនេះអាចត្រូវបានគេដកចេញ បើសិនជាសភានៃសហគមន៍អឺរ៉ុបធ្វើការផ្លាស់ប្តូរគំនិតរបស់គេ។

ជម្រើសទី ២ គឺប្រទេសកម្ពុជាអាចធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយប្រទេសធំៗ ឬជាមួយក្រុមប្រទេសសេដ្ឋកិច្ច។ ទោះបីយ៉ាងនេះក៏ដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីផ្តល់ចំណេញដល់ប្រទេសធំៗ ដែលមានអនុភាពខ្លាំងជាងក្នុងការទាញយកសម្បទាន ពីដៃគូពាណិជ្ជកម្មតូចៗរបស់ខ្លួនជាងប្រទេសតូចៗទាំងនោះ។ លើសពីនេះទៅទៀត កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី បានបង្កើននូវភាពចំណុះគេនៃប្រទេសសេដ្ឋកិច្ចតូចៗ ពីប្រទេសសេដ្ឋកិច្ចធំៗ ដែលមានលក្ខណៈត្រួតត្រា។

មានតែប្រព័ន្ធពាណិជ្ជកម្មពហុភាគីតែមួយគត់ ដូចជា WTO ដែលមានច្បាប់ទំលាប់ដូចគ្នា សម្រាប់អ្នកទាំងអស់គ្នា ទើបអាចផ្តល់ឱកាសស្មើភាព ហើយអាចទប់ទល់បានជាមួយមហាអំណាចសេដ្ឋកិច្ច ដូចជាសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកដូច្នោះដែរ។ ដូច្នេះ តាមយោបល់របស់ខ្ញុំ ប្រទេសកម្ពុជាបានសម្រេចចិត្តត្រឹមត្រូវក្នុងការចូលក្នុងក្រុមពាណិជ្ជកម្មពិភពលោកជាដៃគូដ៏វ័យក្មេងម្នាក់។

ខ្ញុំដឹងថា ទស្សនៈរបស់ខ្ញុំអាចអ្នកទាំងអស់គ្នាមិនយល់ស្របហើយថា សន្និសីទស្តីពី"**ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប្រយោជន៍ ការប្រឈមមុខ និងទិសដៅនៅអនាគត**" នឹងទទួលបាននូវគំនិតផ្សេងៗគ្នា។

នេះគឺជាគោលបំណងនៃសន្និសីទ ព្រមទាំងការផ្លាស់ប្តូរទស្សនៈការរៀនដកបទពិសោធន៍ពីគ្នាទៅវិញទៅមក និងពិចារណាឡើងវិញនូវមតិផ្ទាល់របស់បុគ្គលម្នាក់ៗ ។

ក្នុងនាមមូលនិធិ FES ខ្ញុំសូមអរគុណ CICP ដែលមានលោកនាយកប្រតិបត្តិបណ្ឌិត **ចាប សុថារិទ្ធ** និងបុគ្គលិកទាំងអស់ របស់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ដែលបានរៀបចំសន្និសីទនេះ។ ខ្ញុំសូមជូនពរឱ្យអស់លោកទទួលបាននូវការពិភាក្សាគ្នារស់រវើកមានគំនិតថ្មី និងទទួលលទ្ធផលជាវិជ្ជមាន។

# សុន្ទរកថាបើក

## សម្តេច ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

- សម្តេច នរោត្តម សិរីវុឌ្ឍ ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាព្រះប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព
- លោក អាសែល ស្មីត (Axel Schmidt) ប្រធានការិយាល័យសហប្រតិបត្តិការតំបន់អាស៊ីអាគ្នេយ៍នៃមូលនិធិ ហ្វ្រីឌ្រិច អេប៊ែត ស្ទីហ្វទុង (Friedrich Ebert Stiftung)
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សមាជិក សមាជិកា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិនៃសន្និសីទថ្ងៃនេះ ជាទីមេត្រី

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលបានអញ្ជើញចូលរួមក្នុងសន្និសីទជាតិ ស្តីពី "កម្ពុជានិងអង្គការពាណិជ្ជកម្មពិភព លោក : គុណសម្បត្តិ ការប្រឈម និងទិសដៅអនាគតនា" ពេលនេះ។

ខ្ញុំសូមកោតសរសើរ និងគាំទ្រចំពោះកិច្ចសហប្រតិបត្តិការ និងសកម្មភាពដ៏មានសារប្រយោជន៍របស់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) និងមូលនិធិ ហ្វ្រីឌ្រិច អេប៊ែត ស្ទីហ្វទុង (Friedrich Ebert Stiftung) នៃប្រទេស

អាល្លឺម៉ង់ដែលបានផ្តួចផ្តើមគំនិត និងចំណាយមូលនិធិរបស់ខ្លួន ដើម្បីរៀបចំសន្និសីទជាតិនៃកិច្ចប្រឹងប្រែងផ្សព្វផ្សាយចំពោះដឹង និងអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាតែងតែយកចិត្តទុកដាក់ និងរួមសហការក្នុងភាពដៃគូជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងអង្គការមិនមែនរាជរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា ដែលខិតខំធ្វើការងារបម្រើដល់ផលប្រយោជន៍សង្គមយើង ដូចមានវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាពជាគំរូ។ ដោយឡែកសម្រាប់ថ្ងៃនេះ វិភាគទានពេលវេលា និងចំណេះដឹងរបស់លោក លោកស្រីក្នុងការរៀបចំ និងចូលរួមក្នុងសន្និសីទជាតិ ស្តីពី "កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : គុណសម្បត្តិ ការប្រឈម និងទិសដៅអនាគត" ពិតជាមានតម្លៃ មិនត្រឹមតែជួយពិនិត្យមើលបញ្ហាប្រឈម និងគុណសម្បត្តិនានា ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ក្នុងសេដ្ឋកិច្ចពិភពលោកនាពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយរំលេចឡើង នូវទស្សនវិស័យទៅអនាគតរបស់កម្ពុជាក្នុងដំណាក់កាលថ្មីទៀតផង។

សម្តេច ឯកឧត្តម លោកជំទាវ និងអង្គសន្និសីទទាំងមូល

ការចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ត្រូវបានកំណត់យ៉ាងច្បាស់ក្នុងយុទ្ធសាស្ត្រមួយនៃយុទ្ធសាស្ត្រត្រីកោណ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី ២ នៃរដ្ឋសភា។ ជាក់ស្តែងលទ្ធផលនៃការអនុវត្ត យុទ្ធសាស្ត្រត្រីកោណ បានបង្កើតឡើង នូវមូលដ្ឋានដ៏រឹងមាំមួយសម្រាប់ការអភិវឌ្ឍន៍រយៈពេលវែង ក្នុងនោះរួមមាន (១)-ការសម្រេចបាន និងពង្រឹងឱ្យមានចីរភាពនូវសន្តិភាព និងស្ថិរភាពនៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស (២)-សមាហរណកម្មកម្ពុជាយ៉ាងឆាប់រហ័ស និងយ៉ាងពេញលេញទៅក្នុងសហគមន៍តំបន់ និងពិភពលោក និង (៣)-ការវាយសម្រុកទៅលើ

សមរភូមិកំណែទម្រង់សេដ្ឋកិច្ច ដើម្បីជំរុញលើកកម្ពស់កំណើន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

សមិទ្ធផលនៃសមាហរណកម្មកម្ពុជា យ៉ាងឆាប់រហ័ស និងយ៉ាងពេញលេញទៅក្នុងសហគមន៍តំបន់ និងពិភពលោក បញ្ជាក់ឱ្យឃើញច្បាស់ថា រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តផ្នែកនយោបាយយ៉ាងមោះមុត ក្នុងការរៀបចំធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ ទន្ទឹមនឹងការប្រឹងប្រែងធ្វើឱ្យទំនាក់ទំនងកម្ពុជា ជាមួយនឹងសហគមន៍អន្តរជាតិមានភាពល្អប្រសើរជាធម្មតាវិញ រាជរដ្ឋា-ភិបាល បានធ្វើសមាហរណកម្មសេដ្ឋកិច្ច ក្នុងតំបន់បានសម្រេចដោយជោគជ័យ ក្រោយពេលដែលយើងទទួលបានសមាជិកភាព ក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ កាលពីខែមេសា ឆ្នាំ ១៩៩៩។

ច្បាស់ណាស់ថា របៀបវារៈរបស់កម្ពុជា មិនមែនចប់ត្រឹមការចូលជាសមាជិករបស់អាស៊ាន និងការជំរុញអនុវត្តកិច្ចសហប្រតិបត្តិការពាក់ព័ន្ធដទៃទៀតនោះទេ។ កម្ពុជាមានមហិច្ឆិតាធំជាងនេះទៀត។ របៀបវារៈរបស់រាជរដ្ឋាភិបាល គឺសមាហរណកម្មសេដ្ឋកិច្ចជាតិ ទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោកទាំងមូលតែម្តង។ ដើម្បីគោលដៅនេះកម្ពុជា បានប្រឹងប្រែងរៀបចំខ្លួនយ៉ាងអស់ពីសមត្ថភាពនៅក្នុងរយៈពេលជាច្រើនឆ្នាំ ទំរាំបានចូលជាសមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០៣ ក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីនៃអង្គការពាណិជ្ជកម្មពិភពលោក នៅទីក្រុងកាន់គូននៃប្រទេសម៉ិចស៊ិចកូ។

ជាក់ស្តែង សមិទ្ធផលថ្មីនេះធ្វើឱ្យកម្ពុជាទទួលបានការលើកទឹកចិត្ត និងមានមោទនភាពយ៉ាងខ្លាំង ចំពោះសមត្ថភាពរបស់ខ្លួនដែលអាចឆ្លើយតបបានទៅនឹងល័ក្ខខ័ណ្ឌដ៏ច្រើន និងដ៏តឹងរ៉ឹងសម្រាប់បេក្ខភាពនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកនេះ។ ប្រការ

នេះក៏បានគូសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា កម្ពុជាបាននិងកំពុងធ្វើដំណើរនៅលើមាគ៌ាដ៏ត្រឹមត្រូវមួយក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងគោល-ការណ៍តម្លាភាព ព្រមទាំងធ្វើទំនើបកម្ម រចនាសម្ព័ន្ធសេដ្ឋកិច្ច ជាពិសេសគឺសេរី-ភាវូបនីយកម្មពាណិជ្ជកម្ម និងការវិនិយោគដើម្បីឱ្យប្រជាជនយើងអាចទទួលបាននូវផលប្រយោជន៍យ៉ាងសមរម្យពីចរន្តដ៏ខ្លាំងក្លាយនៃសកលភាវូបនីយកម្ម។

ជាមួយគ្នានោះ រាជរដ្ឋាភិបាលមានការយល់ដឹងយ៉ាងច្បាស់ថា ការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាព នូវកាតព្វកិច្ចនៃសមាជិកភាពនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក នឹងមានការពិបាកច្រើនជាងដំណើរនៃការឈានទៅសម្រេចបាន នូវសមាជិកភាពនេះទៅទៀត។ ក្នុងន័យនេះ កម្ពុជាត្រូវតែបង្កើនការខិតខំប្រឹងប្រែងរបស់ខ្លួនឱ្យអស់ពីសមត្ថភាព ដើម្បីដោះស្រាយបញ្ហាប្រឈមការលំបាក និងឧបសគ្គធំតូចទាំងឡាយតាមរយៈកំណែទម្រង់ស៊ីជម្រៅនៅក្នុងគ្រប់ផ្នែក គ្រប់វិស័យទាំងអស់ ជាពិសេសគឺការពង្រឹងមូលដ្ឋានផលិតកម្ម ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្សដែលជាដំណើរការមួយត្រូវការនូវពេលវេលា និងទាមទារនូវការប្តេជ្ញាចិត្តខ្ពស់ និងឆន្ទៈនយោបាយយ៉ាងប្តូរផ្តាច់។

ក្នុងស្មារតីនេះ ការទទួលយកនូវហានិភ័យនៃសមាជិកភាព នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក នឹងផ្តល់ឱ្យកម្ពុជានូវកាលានុវត្តភាពដ៏កម្រ ដើម្បីដោះស្រាយបញ្ហារចនាសម្ព័ន្ធនានា តាមរយៈកញ្ចប់នៃការប្តេជ្ញាចិត្តដ៏ទូលំទូលាយមួយដែលរួមបញ្ចូលនូវទំនិញឧស្សាហកម្ម សេវាកម្ម កសិផល និងការអនុវត្តន៍ពាណិជ្ជកម្មឱ្យមានតម្លាភាពនិងយុត្តិធម៌។ ប្រសិនបើយើងឈរលើទស្សនៈនេះ ការចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោក បាននាំមកនូវសក្តានុពលដ៏ធំធេងលើសពីសេដ្ឋកិច្ច និងពាណិជ្ជកម្មទៅទៀត។ សមាជិកភាពនេះ អាចបម្រើជាមូលដ្ឋានគ្រឹះសម្រាប់ការកសាង និងពង្រឹងវិធានការនៃ

ច្បាប់នៅក្នុងប្រទេសកម្ពុជា ហើយក៏នឹងជួយបង្កើតឡើងនូវទម្លាប់ជាសុឆន្ទៈ ក្នុងការទទួលនិងគោរពតាមក្រមនិយាមអន្តរជាតិនៅក្នុងវិស័យដទៃជាច្រើនទៀត ។

សម្តេច ឯកឧត្តម លោកជំទាវ និងអង្គសន្និសីទទាំងមូល !

ទោះជាផលប៉ះពាល់របស់សមាជិកភាព មិនទាន់កើតឡើងជាដុំកំភួននៅឡើយ សន្និសីទ ស្តីពី កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : គុណសម្បត្តិ ការប្រឈម និងទិសដៅអនាគត ដែលបានរៀបចំឡើងនាពេលនេះពិតជាធ្វើឡើងទាន់ពេលវេលា ដើម្បីបូកសរុបវាយតម្លៃពីគុណវិបត្តិ និងគុណសម្បត្តិ និងលើកទិសដៅទៅអនាគតសម្រាប់យើង ដើម្បីជម្នះឱ្យបាននូវការប្រឈមទាំងឡាយ និងទាញយកឱ្យបានជាអតិបរមានូវផលប្រយោជន៍ពីសមាហរណកម្មនេះ ។

ពិតណាស់ថា សកលភាវូបនីយកម្ម គឺជារលកដ៏ធំមួយដែលយើងមិនអាចគេចវេសបានទេ ។ បណ្តាប្រទេសក្រុមហ៊ុននានា និងសាធារណជនទូទៅត្រូវតែទទួលយកការពិតនេះដូចគ្នា ។ តាមរយៈបទពិសោធន៍ប្រវត្តិសាស្ត្រ និងការស្រាវជ្រាវនានាបានបង្ហាញថាការបិទទ្វារប្រទេសដើម្បីការពារផលិតផលក្នុងស្រុកមិនអាចធ្វើទៅបានជោគជ័យទេ ។ ផ្ទុយទៅវិញ វានឹងធ្វើឱ្យប្រទេសនោះឋិតនៅឯកោនិងឋិតនៅឆ្ងាយពីទំនើបភាវូបនីយកម្ម និងការអភិវឌ្ឍ ។

សម្រាប់ប្រទេសកម្ពុជា សមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោក បង្ហាញឱ្យឃើញនូវដំណាក់កាលថ្មីនៃកំណែទម្រង់សេដ្ឋកិច្ច ដែលបើកចំហទៅកាន់ពិភពលោកខាងក្រៅពីសេរីភាវូបនីយកម្មជ្រើសរើស ទៅជាសេរីភាវូបនីយកម្មទូលំទូលាយពីសេរីភាវូបនីយកម្មឯកតោភាគីទៅជាសេរីភាវូបនីយកម្មពហុភាគី ដែលពឹងផ្អែកលើច្បាប់អង្គការពាណិជ្ជកម្មពិភពលោក ។ ការទទួលបានសមាជិកភាពក្នុងអង្គការពាណិជ្ជកម្ម

ពិភពលោករបស់កម្ពុជា នឹងធ្វើឱ្យមានសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនយ៉ាងពេញលេញជាមួយ នឹងប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ ។

សេរីភាវូបនីយកម្ម នឹងបង្កើនប្រសិទ្ធិភាពសេដ្ឋកិច្ចរបស់កម្ពុជា ហើយក៏នឹងជំរុញការលូតលាស់ផ្នែកកសិកម្ម និងឧស្សាហកម្មផងដែរ ។ ការប្រកួតប្រជែងនឹងជំរុញសហគ្រាសក្នុងស្រុកឱ្យបង្កើនគុណភាព និងបរិមាណនៃផលិតកម្ម និងសេវាកម្មតាមរយៈការបញ្ចូលបច្ចេកវិទ្យា និងសមត្ថភាពគ្រប់គ្រងថ្មីៗ ដែលមានលទ្ធភាពដណ្តើមទីផ្សារក្នុងតំបន់ និងពិភពលោក ។

ពិតណាស់ថា ផលប្រយោជន៍ផ្សេងទៀត ដែលកម្ពុជាអាចទទួលបានពីអង្គការពាណិជ្ជកម្មពិភពលោក គឺផលប្រយោជន៍នយោបាយ ។ ជាក់ស្តែងប្រទេសកំពុងអភិវឌ្ឍន៍ដូចកម្ពុជា បានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក នឹងមានដៃគូអភិវឌ្ឍន៍កាន់តែច្រើនថែមទៀត និងមានការគាំទ្រពីសមាជិកដទៃទៀត ដែលនឹងគាំទ្រយើងដោយផ្តល់ជំនួយកាន់តែច្រើនសម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស ក៏ដូចជាអភិវឌ្ឍន៍សេដ្ឋកិច្ចដែរ ។

ដូច្នេះ សមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក នឹងមានជាប់ទាក់ទងយ៉ាងខ្លាំង ដល់ការបង្កើនការរីកលូតលាស់នៃសេដ្ឋកិច្ចកម្ពុជា ការបង្កើនការងារ និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

សម្តេច ឯកឧត្តម លោកជំទាវ និងអង្គសន្និសីទទាំងមូល

សមាហរណកម្មសេដ្ឋកិច្ច ដែលរួមបញ្ចូលទាំងសមាហរណកម្មក្នុងតំបន់ និងពិភពលោកមកទល់ពេលនេះ នៅតែមានភាពមន្ទិលសង្ស័យ និងគោលគំនិតមិនច្បាស់លាស់នៅឡើយ ជាពិសេសក្នុងចំណោមសាធារណជនទូទៅ ។

ជាការពិត សមាជិកភាពនៅក្នុងអង្គការពាណិជ្ជកម្មអន្តរជាតិ ផ្តល់នូវកាលានុវត្តភាព និងភាពប្រឈមផងដែរ។ ដូចដែលខ្ញុំបានគូសបញ្ជាក់ខាងលើឱកាសចម្បងមួយដែលផ្តល់ជូនដល់សមាជិកទាំងអស់របស់អង្គការនេះ គឺលទ្ធភាពធ្វើពាណិជ្ជ-កម្មជាមួយសមាជិកទាំងអស់ដទៃទៀតនៃអង្គការនេះ នៅក្រោមគោលការណ៍ពាណិជ្ជកម្មនៃប្រជាជាតិ ដែលបានទទួលអនុគ្រោះជាងគេ (MFN)។ ដូច្នេះ វាផ្តល់នូវច្រកសម្រាប់សហគ្រាសនានារបស់កម្ពុជា ដើម្បីធ្វើការនាំចេញ ផ្តល់ការងារឱ្យប្រជាជនធ្វើ និងផ្តល់ប្រាក់ចំណូលដល់ពួកគេ។ តាមរបៀបនេះ កម្ពុជានឹងរកចំណូលបានពីការនាំចេញដែលមានបរិមាណច្រើនលើសលប់ហួសពីការខាតបង់ ឬធ្លាក់ចុះចំណូលពន្ធលើការនាំចូលដែលបណ្តាលមក ពីការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក។

យើងត្រូវចងចាំថា សមាជិកភាពនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកនឹងអនុញ្ញាតឱ្យកម្ពុជាបង្កើនការនាំចេញក៏ពិតមែន ក៏ប៉ុន្តែ កម្ពុជាក៏ត្រូវនាំចូលនូវផលិតផលផ្សេងៗផងដែរ ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជន។ ពាណិជ្ជកម្មដំណើរការ "ផ្លូវពីរ" ហើយនៅពេលច្រកចូលទីផ្សារ ផលិតផលពិភពលោកមានលក្ខណៈកាន់តែប្រសើរឡើង និងភាពកាន់តែអនុគ្រោះឡើង សហគ្រាសកម្ពុជានឹងអាចកាត់បន្ថយបាននូវចំណាយរបស់ខ្លួនលើវត្ថុធាតុដើម ឬធាតុចូល ហើយគ្រួសារកម្ពុជាក៏នឹងមានជីវភាពរស់នៅកាន់តែប្រសើរឡើងតាមនោះដែរ។

ជាការពិត ភាពប្រឈមសម្រាប់យើងគឺត្រូវធានាថា ទំនិញនាំចេញពីកម្ពុជាមានលក្ខណៈប្រកួតប្រជែង។ នេះគឺជាកិច្ចការដែលយើងកំពុងខិតខំធ្វើយ៉ាងសកម្ម ដូចជាវិធានការដើម្បីកាត់បន្ថយចំណាយផលិតកម្មក្នុងស្រុក ចំណាយលើធាតុចូល និងការផ្សព្វផ្សាយពាណិជ្ជកម្ម។ វិធានការទាំងអស់នោះរួមមាន : ការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ទូរគមនាគមន៍ ថាមពល និងប្រព័ន្ធផ្គត់ផ្គង់ទឹកឱ្យបានឆាប់រហ័ស និងមាន

ប្រសិទ្ធិភាព និងការកាត់បន្ថយចំណាយ ទាក់ទងនឹងបែបបទរដ្ឋបាលស្មុគស្មាញ ព្រម ទាំងពាក់ពន្ធ័នឹងការចេញអាជ្ញាប័ណ្ណ និងការអនុញ្ញាតនានាផងដែរ ។

ការប្រឈមធំបំផុតនោះ គឺធ្វើយ៉ាងណាដើម្បីបង្កើនលទ្ធភាពប្រកួតប្រជែង របស់យើង ពោលគឺផលិតផលក្នុងស្រុករបស់យើង ត្រូវប្រកួតប្រជែងនឹងផលិតផល បរទេស ដែលហូរចូលដោយសេរី និងតម្លៃថោក និងគុណភាពល្អជាងរបស់យើង ។ ការធ្វើ សេរីភាវូបនីយកម្មយ៉ាងលឿននៃទីផ្សាររបស់ខ្លួន ធ្វើឱ្យខឿនផលិតកម្មក្នុងដំក្មេងខ្ចីរបស់ យើងដែលត្រូវការពារនឹងងាយរងគ្រោះ ដូចជាកសិកម្មផលិតកម្មធុនតូច និងមធ្យម ក្រុមហ៊ុនក្នុងស្រុករបស់កម្ពុជានានា នឹងប្រឈមមុខជាមួយទំនិញនាំចូលពីបរទេសជា ច្រើន ដែលធ្វើឱ្យអាជីវករយើងអាចនឹងក្ស័យធនបាន ។ ប្រការនេះធ្វើឱ្យការនាំចូលត្រូវ គេរំពឹងថា នឹងកើនឡើងលឿនជាងការនាំចេញ នោះនឹងបណ្តាលឱ្យមានកំណើនយ៉ាង គំហុកនៃអតុល្យភាព ជញ្ជីងពាណិជ្ជកម្ម ។ សហគ្រាសកម្ពុជាជាច្រើន ដែលកំពុងស្ថិត ក្នុងវិស័យប្រកួតប្រជែង តិចតួច ដូចជាផ្នែកគីមី ថ្នាំពេទ្យ ផ្នែកកែច្នៃម្ហូបអាហារ កសិ-ឧស្សាហកម្ម នឹងអាចជួបប្រទះនូវបញ្ហាផលិតកម្មរបស់ខ្លួន ។ លើសពីនេះទៀត ផ្នែក សេវាកម្មខ្លះ ដូចជាពាណិជ្ជកម្ម ដឹកជញ្ជូន ធានារ៉ាប់រង ក៏ដូចជាផ្នែកទូរគមនាគមន៍ដែល ធ្លាប់តែត្រូវបានទទួលការពារនោះ អាចនឹងធ្លាក់ក្នុងស្ថានភាពបាត់បង់ផលប្រយោជន៍ ច្រើនក្នុងការប្រកួតប្រជែងជាមួយក្រុមហ៊ុនបរទេស ។

កម្ពុជាកំពុងតែជួបប្រទះកំណើននៃភាពមិនស៊ីសង្វាក់គ្នា ក្នុងតំបន់និងការកើន ឡើងនៃគម្លាតផ្នែកកម្រិតចំណូល នៃក្រុមប្រជាពលរដ្ឋផ្សេងៗគ្នា ។ រាជធានីភ្នំពេញនឹង ទទួលផលប្រយោជន៍ច្រើនជាងគេ និងរីកចម្រើនទៅមុខជាងគេ បើប្រៀបធៀបទៅនឹង តំបន់ផ្សេងៗទៀត ។ នេះជាផ្នែកមួយនៃបញ្ហាសង្គម ដែលលេចចេញពីដំណើរការ អភិវឌ្ឍ ។ ការបង្កើនល្បឿនសេរីភាវូបនីយកម្ម និងការប្រកួតប្រជែងដែលចេញពី

ការអនុវត្តន៍កិច្ចសន្យានានារបស់កម្ពុជា ចំពោះអង្គការពាណិជ្ជកម្មពិភពលោកនោះ អាចធ្វើឱ្យជួបបញ្ហាខ្លះៗ ជាមិនខាន។

មានសិក្ខាសាលាជាច្រើន និងកម្មវិធីហ្វឹកហ្វឺនដែលត្រូវបានដឹកនាំដោយក្រសួងពាណិជ្ជកម្មសម្រាប់មន្ត្រីកម្ពុជា ដែលទាក់ទិននឹងការចូលសមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ ក៏ចំណេះដឹង និងពត៌មានទាក់ទងនឹងផលប៉ះពាល់នៃអង្គការពាណិជ្ជកម្មពិភពលោកចំពោះសេដ្ឋកិច្ចកម្ពុជា គឺនៅមានកម្រិតនៅឡើយ។

ជាមួយគ្នានោះ ក្របខ័ណ្ឌច្បាប់នៅប្រទេសកម្ពុជាស្ទើរត្រូវបានបំផ្លាញខ្ទេចខ្ទីអស់ក្នុងសង្គ្រាម។ កម្ពុជាត្រូវបង្កើត និងធ្វើវិសោធនកម្មច្បាប់ ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូររបបនយោបាយ។ លក្ខខ័ណ្ឌមុនចូលជាសមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាត្រូវផ្លាស់ប្តូរ ឬបង្កើតច្បាប់ និងលិខិតបទដ្ឋាននានា ដើម្បីឱ្យស្របនឹងពាណិជ្ជកម្មសេរី និងវិធានការនានារបស់អង្គការពាណិជ្ជកម្មពិភពលោក។ ដូច្នេះ វាគឺជាបន្ទុកមួយសម្រាប់ប្រជាជនកម្ពុជា ក្នុងការធ្វើកិច្ចការនេះនៅខណៈដែលចំណេះដឹង និងពេលវេលានៅមានកម្រិតនៅឡើយ នៅក្នុងបរិស្ថានថ្មីនៃសេដ្ឋកិច្ចទីផ្សារ និងរបបពាណិជ្ជកម្មពិភពលោក។ ច្បាប់ និងលិខិតបទដ្ឋានថ្មីៗ ជាច្រើនត្រូវបានព្រាងដោយឆាប់រហ័ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អង្គការពាណិជ្ជកម្មពិភពលោក។ ដូច្នេះ ច្បាប់ទាំងនោះអាចមិនត្រូវបានរៀបចំបានល្អ និងគ្រប់គ្រាន់ឡើយ ហើយនឹងអាចត្រូវធ្វើវិសោធនកម្មនៅក្នុងអនាគតដ៏ខ្លីខាងមុខ នៅពេលដែលរដ្ឋាភិបាលមើលឃើញថា មានចន្លោះប្រហោងដែលនឹងបង្កើតជាក្របខ័ណ្ឌច្បាប់មិនរលូននោះ។

ការអនុវត្តន៍សម្រាប់ចូលសមាជិកភាព អង្គការពាណិជ្ជកម្មពិភពលោកជាបញ្ហាមួយ ប៉ុន្តែ ការធ្វើការក្នុងអង្គការពាណិជ្ជកម្មពិភពលោក នឹងជាការប្រឈមមុខមួយ

ទៀត។ នៅពេលមានជម្លោះពាណិជ្ជកម្មកើតឡើង មន្ត្រីកម្ពុជាត្រូវដោះស្រាយបញ្ហានេះ ហើយត្រូវមានការចរចាជាច្រើន។ នៅពេលមន្ត្រីកម្ពុជា នៅមានចំណេះដឹងមានកម្រិត នៅក្នុងបញ្ហាពាណិជ្ជកម្ម និងច្បាប់ នោះនឹងមានការលំបាកនៅក្នុងការចរចាពាណិជ្ជកម្ម។

សម្តេច ឯកឧត្តម លោកជំទាវ និងអង្គសន្និសីទទាំងមូល

ការប្រឈមជាច្រើនសម្រាប់កម្ពុជា មិនត្រឹមតែចេញពីការផ្លាស់ប្តូរបរិស្ថានពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចេញពីការកើនឡើងនៃឧស្សាហកម្មក្នុងស្រុកទៀតផង។ ទោះបីជាប្រទេសមានកំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាពពីមុនៗ ក៏ដោយក៏ប្រភពសំខាន់ នៃកំណើនសេដ្ឋកិច្ចចេញមក ពីការកៀរគរប្រភពធនធានយ៉ាងច្រើន នៃជំនួយពីក្រៅ និងកត្តាផលិតកម្មផ្សេងៗទៀត ដូចជាទេសចរណ៍ និងសេវាកម្ម។ ការកាត់បន្ថយជំនួយពី ខាងក្រៅនឹងប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច ហើយការអភិវឌ្ឍពាណិជ្ជកម្ម ប្រហែលមិនអាចជំនួសជំនួយពីខាងក្រៅទេ យ៉ាងហោចណាស់ពី ១០ ទៅ ១៥ ឆ្នាំ ទៀតដែរ។

រាជរដ្ឋាភិបាលកម្ពុជា ត្រូវខិតខំជំរុញឱ្យគ្រប់អ្នកចូលរួមទាំងអស់ រួមទាំងវិស័យឯកជនរៀបចំខ្លួនឱ្យបានល្អ និងត្រូវតែយល់ឱ្យបានច្បាស់អំពីការជះឥទ្ធិពលរបស់សមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក។ ពួកគេត្រូវតែយល់ផងដែរថា ការធ្វើសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក នឹងផ្តល់ឱកាសល្អប្រសើរ ឱ្យពួកគេដើម្បីរៀនរបៀបបង្កើនការប្រកួតប្រជែង ដើម្បីកែលម្អគុណភាពផលិតផលក្នុងស្រុក និងដើម្បីឱ្យមានលទ្ធភាពចូលក្នុងទីផ្សារបរទេសធំធេងជាងមុន។ អ្នកជំនួញក្នុងស្រុកក៏មានឱកាសផងដែរនៅក្នុងការពង្រីកសកម្មភាពជំនួញរបស់ពួកគេ។

ក្រសួងពាណិជ្ជកម្មត្រូវមានតួនាទីកាន់តែសកម្ម ក្នុងការស្វែងរកទីផ្សារ ជួយផ្តល់ពតិមានដល់ផលិតកម្មក្នុងស្រុក ពីសក្តានុពលទីផ្សារអន្តរជាតិ និងជួយសម្រួលពាណិជ្ជកម្ម ពិសេសលើការនាំចេញ។ នៅក្នុងស្មារតីនេះ យើងមិនត្រូវមើលរំលងពីសារសំខាន់នៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេសឱ្យបានឆាប់ សម្រាប់ទាក់ទាញវិនិយោគិនមកដាក់ទុន ដើម្បីបង្កើនសមត្ថភាពផលិតក្នុងស្រុក ជាពិសេសផលិតផលសម្រាប់នាំចេញនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវមានតួនាទីសំខាន់ណាស់ក្នុងការទាក់ទាញ និងសម្រួលដល់វិនិយោគគិន។ សព្វថ្ងៃនេះ យើងនៅមានចំណុចខ្វះខាតមួយចំនួនជាពិសេសការជំរុញការផ្សព្វផ្សាយ និងទាក់ទាញវិនិយោគិន។ ម្យ៉ាងទៀត យើងត្រូវតែកែលម្អអនុវត្តរបៀបរបបការងារ លុបបំបាត់ការកេងបសង្កត់វិនិយោគិនតាមវិធីផ្សេងៗ ហួសពីការកំណត់របស់រដ្ឋ ពោលគឺត្រូវតែខិតខំថែមទៀត ដើម្បីពង្រឹងអភិបាលកិច្ចក្នុងផ្នែករដ្ឋបាលសាធារណៈឱ្យបាន។

ជាការពិតណាស់ នៅក្នុងស្មារតីនេះ កម្ពុជាត្រូវខិតខំប្រឹងប្រែងថែមទៀត ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានលក្ខណៈស្របទៅនឹងសេដ្ឋកិច្ចពិភពលោក តាមរយៈការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងជំរុញអភិវឌ្ឍន៍វិស័យឯកជន។ ការធ្វើជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក្នុងស្ថានភាពដែលប្រទេសយើងមានសេដ្ឋកិច្ចទន់ខ្សោយនៅឡើយ យើងនឹងជួបប្រទះការប្រឈមមុខជាច្រើន រួមទាំងការប្រកួតប្រជែងយ៉ាងខ្លាំង និងមានការលំបាកច្រើនក្នុងការធ្វើគ្រាប់តាម ដើម្បីឆ្លើយតបនឹងវិធានការច្បាប់នៃអង្គការពាណិជ្ជកម្មពិភពលោក នៅក្នុងរបបពាណិជ្ជកម្មនេះ។ សម្រាប់រយៈពេលខ្លីប្រទេសកម្ពុជា នឹងជួបការលំបាកនៅក្នុងការដើរតួនាទីនៅក្នុងអង្គការ ដែលពឹងផ្អែកទៅលើច្បាប់នេះ ក៏ប៉ុន្តែ អាចថែរក្សាឱកាសល្អប្រសើរមួយ ក្នុងការពង្រឹងពាណិជ្ជកម្ម និងជំនួញសម្រាប់រយៈពេលវែង។ នៅពេលដែលប្រទេសកម្ពុជាបើកគោលនយោបាយ

ទីផ្សារចំហ វានឹងទាក់ទាញការនាំចូលច្រើនពីខាងក្រៅ ទន្ទឹមនឹងនោះ វាក៏នឹងពង្រឹងការនាំចេញទៅខាងក្រៅផងដែរ។ លើសពីនោះទៅទៀត កម្ពុជានឹងទាក់ទាញការហូរចូលការវិនិយោគដោយផ្ទាល់ពីបរទេសកាន់តែច្រើន។

ទន្ទឹមនឹងនេះ ប្រទេសកម្ពុជាត្រូវសិក្សាភាពប្រកួតប្រជែងរបស់ប្រទេស ដោយរួមទាំងការសិក្សាលើឧត្តមភាពប្រៀបធៀប និងឧត្តមភាពដណ្តើមឈ្នះ ដោយប្រើប្រាស់ជំនួយបច្ចេកទេស ដើម្បីប្រើឱ្យអស់សក្តានុពលសេដ្ឋកិច្ចតំបន់ឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដើម្បីផ្លាស់ប្តូរពាណិជ្ជកម្មជាមួយដៃគូពាណិជ្ជកម្មតំបន់របស់យើង។ ផលិតផលក្នុងស្រុកត្រូវតែកែលម្អគុណភាពទៅតាមតម្រូវការ និងការនិយមចូលចិត្តនៃទីផ្សារ និងការបង្កើតសមត្ថភាព និងគុណភាពផលិតកម្ម ដើម្បីឱ្យផលិតផលទាំងនោះអាចប្រកួតប្រជែងជាមួយផលិតផលក្នុងតំបន់ និងក្នុងពិភពលោក។

ពេលដែលចំណេះដឹង និងពត៌មានដែលទាក់ទងនឹងផលប៉ះពាល់នៃអង្គការពាណិជ្ជកម្មពិភពលោក ចំពោះសេដ្ឋកិច្ចកម្ពុជានៅមានកម្រិតនៅឡើយនោះ ការជាប់ពាក់ព័ន្ធនៃអ្នកទទួលប្រយោជន៍ផ្សេងៗទៀត ក្រៅពីរដ្ឋាភិបាលគឺមានសារសំខាន់ខ្លាំងណាស់។ ការចរចា និងការជជែងគ្នាជាច្រើនទៀត រវាងភាគីទាំងឡាយដែលជាប់ពាក់ព័ន្ធគួរត្រូវបង្កើន ដើម្បីនាំពត៌មានឱ្យសាធារណជន និងប្រមូលគំនិត និងទស្សនៈ ដើម្បីកសាងចំណេះដឹងសម្រាប់ជាតិ ដើម្បីរកឱ្យឃើញថា តើកម្ពុជាអាចទទួលបានផលប្រយោជន៍ច្រើនយ៉ាងណា ពីការធ្វើជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។

ការទាញយកចំណេញពីសមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោកនេះ ត្រូវទាមទារការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋទាំងអស់ ជាពិសេសគឺវិស័យឯកជន ដែលជាអ្នកចូលប្រឡូកផ្ទាល់ក្នុងពាណិជ្ជកម្មអន្តរជាតិ។ រាជរដ្ឋាភិបាលនៅតែ

ចាត់ទុកថា វិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើន ដូច្នេះ យើងត្រូវតែធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើនផលិតកម្ម និងនាំទំនិញរបស់យើងចូលដល់ទីផ្សារពិភពលោក ។

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានជំរុញអនុវត្តយ៉ាងសកម្មជាមួយឆន្ទៈដ៏មោះមុតឥតរាថយ នូវរបៀបវារៈកំណែទម្រង់របស់ខ្លួន ។ កិច្ចខិតខំប្រឹងប្រែងនេះបានបង្កើនចេញជាបរិយាកាសប្រកបដោយជីវភាព ដែលឆ្លុះបញ្ចាំងឡើងតាមរយៈការសម្រេចបាននូវសមិទ្ធផលសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់ ។ ទោះបីយ៉ាងណាក៏ដោយរាជរដ្ឋាភិបាលទទួលស្គាល់ថា កំណែទម្រង់មិនអាចបញ្ចប់ក្នុងរយៈពេលមួយថ្ងៃ ឬក្នុងមួយជំហានលោតផ្លោះបានទេ ក៏ប៉ុន្តែ វាគឺជាដំណើរការមួយសន្សឹមៗ និងបន្តជាប់មិនដាច់ ។

មុននឹងបញ្ចប់ ខ្ញុំសូមជូនពរសម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សមាជិក សមាជិកា សន្និសីទជាតិទាំងមូល សូមប្រកបដោយពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសង្ឃឹមថា សន្និសីទជាតិនឹងប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។ ខ្ញុំសូមប្រកាសបើកសន្និសីទជាតិ ចាប់ពីពេលនេះតទៅ **!**

# កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលវិបាកផ្នែកច្បាប់ និងផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា

**បណ្ឌិត ហង្ស ពុទ្ធា**

**ប្រធានសមាគមវិចិត្រសិល្បៈ**

## ១.សេចក្តីផ្តើម

សង្គ្រាមរ៉ាំរ៉ៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងអស្ថិរភាពខាងនយោបាយ បានធ្វើឱ្យកម្ពុជាជួបវិបត្តិស្ទើរគ្រប់វិស័យក្នុងសង្គមជាតិ ។

វិស័យសេដ្ឋកិច្ចដែលជាវិស័យមួយដ៏សំខាន់ បានធ្លាក់ចុះដល់កម្រិតមួយគួរឱ្យព្រួយបារម្ភ។ ក្នុងពេលដែលភាពក្រីក្រ និងអំពើពុករលួយមិនទាន់អាច ជម្រះចេញពីសង្គមកម្ពុជាបាន តម្រូវឱ្យរដ្ឋាភិបាលទប់ជ្រែង និងត្រូវការកំណែទម្រង់មួយប្រកបដោយប្រសិទ្ធិភាព ។

ដំណើរការវិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចល្អនៅកម្ពុជា បាននាំដល់ការគិតគូរយ៉ាងខ្លាំងទៅលើវិស័យសេដ្ឋកិច្ច ឆ្ពោះទៅរកការអភិវឌ្ឍន៍សង្គមដែលប្រសើរជាងការ "រស់ព្រោះជំនួយអន្តរជាតិ" ។

កាលពីអតីតភាពកម្ពុជាធ្លាប់មានឧត្តមភាពទៅលើការនាំចេញ អង្ករ កៅស៊ូ កសិផល ហើយអនាគត កសិផលនៅតែជាមុខសញ្ញាក្នុងការនាំចេញ ដោយសារប្រជាពលរដ្ឋកម្ពុជាភាគច្រើនជាកសិករ។ ចំណែកឧស្សាហកម្មកាត់ដេរបើតាមមើលឃើញ

សព្វថ្ងៃនេះ យើងមិនអាចទុកចិត្តបានរហូតទេ។ ក៏ប៉ុន្តែយើងក៏អាចសង្ឃឹមដែរថា វិស័យឧស្សាហកម្មជាកត្តាសំខាន់នាពេលអនាគតខ្លី។

រាជរដ្ឋាភិបាលកម្ពុជា បានជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមចរន្តសមាហរណកម្ម សេដ្ឋកិច្ចពិភពលោក ដើម្បីឱ្យផលិតផលកម្ពុជា បានចូលរួមប្រកួតប្រជែងលើទីផ្សារអន្តរជាតិ ហើយប្រជាជនមានការងារធ្វើ និងជីវភាពកាន់តែប្រសើរឡើង។

## ២. ប្រវត្តិ

### ក -កម្ពុជា

- កម្ពុជាបានដាក់សំណើចុងក្រោយ សុំចូលជាសមាជិក WTO នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០០៣
- ការចូលជាសមាជិក WTO ត្រូវបានអនុម័តដោយសន្និសីទរដ្ឋមន្ត្រី WTO នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៣ និងបានចុះហត្ថលេខាផងដែរ ដោយតំណាងនៃប្រទេសកម្ពុជា
- ក្រោយពីធ្វើសច្ចាប័នដោយរដ្ឋសភា កម្ពុជាចូលជាសមាជិកពេលពេញទី ១៤៨ របស់អង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៤ (កម្ពុជាជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ទី២ បន្ទាប់ពី NEPAL)។

### ខ -អង្គការពាណិជ្ជកម្មពិភពលោក (WTO)

- WTO ត្រូវបានគេបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៥ ដើម្បីជំនួសឱ្យ General Agreement on Tariffs and Trade (GATT)។ អង្គការនេះមានគោលបំណងបែរឆ្ពោះទៅរកការកាត់បន្ថយតម្លៃពន្ធ លើទំនិញនាំចេញនាំចូល ដើម្បីបង្កើនការធ្វើពាណិជ្ជកម្មជាអន្តរជាតិ។ សមាជិកទាំងអស់ត្រូវប្រជុំគ្នា

យ៉ាងតិចម្តងក្នុងរយៈពេលពីរឆ្នាំ។ កិច្ចព្រមព្រៀងនៃ WTO គឺជាកិច្ចសន្យាដែលមានតម្លៃ តាមច្បាប់រវាងបណ្តាប្រទេសជាសមាជិក។ កិច្ចព្រមព្រៀងទាំងនេះបានដាក់ចេញនូវការសន្យា និងវិធានការនានាដែលប្រទេសទាំងឡាយត្រូវគោរពតាម។ ក្នុងករណីប្រទេសទាំងឡាយមានវិវាទពាណិជ្ជកម្មគ្នា កិច្ចសន្យានេះត្រូវអនុវត្តតាមរយៈប្រព័ន្ធដោះស្រាយវិវាទដ៏ សមស្របមួយដែលមានអំណាចតាមផ្លូវច្បាប់ និងតាមផ្លូវ ពាណិជ្ជកម្ម។ មកដល់ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៥ WTO មានប្រទេស ១៤៩ ជាសមាជិក។ WTO មានទីតាំងនៅទីក្រុង GENEVA នៃប្រទេស SWITZERLAND ។

- ការចូលជាសមាជិក WTO គឺជាបំណងល្អរបស់រដ្ឋាភិបាល ប៉ុន្តែ វាអាចនាំមកនូវគុណប្រយោជន៍ផងនិងគុណវិបត្តិផង ប្រសិនបើកម្ពុជារៀបចំខ្លួនមិនបានល្អ។

## ៣. គុណប្រយោជន៍

- ទទួលបានការធ្វើពាណិជ្ជកម្មទូលាយលើពិភពលោក តាមរយៈការស្វែងរកទីផ្សារឱ្យផលិតករ និងពិសេសមានការកែទម្រង់ច្បាប់នានារបស់ជាតិ
- មានការសន្យាជាក់លាក់អំពីការកែទម្រង់ច្បាប់ និងការធ្វើវិសោធនកម្ម ដូចជាកិច្ចសន្យាបង្កើត "**តុលាការពាណិជ្ជកម្ម**" ជាដើម។
- មានបរិយាកាសអាជីវកម្មថ្មី ដែលអាជីវករជាតិ និងអន្តរជាតិចង់បាន
- នៅពេលមានច្បាប់ថ្មីដ៏ល្អប្រសើរដើម្បីឱ្យអាជីវករ និងគ្រប់ស្ថាប័នអនុវត្តតាមនោះ អ្នកវិនិយោគនឹងមានការកើនឡើងច្រើនជាងមុន
- ការបង្កើតច្បាប់ថ្មីទាំងនោះ អាជីវករទទួលបានអត្ថប្រយោជន៍ដោយទទួលបាននូវការរក្សាសិទ្ធិទៅលើផលិតផលរបស់ខ្លួន ឬអាចនិយាយថាជាសិទ្ធិបញ្ញា និង

ការលុបបំបាត់ចោលនូវអាជីវកម្មផ្ដាច់មុខ ដែលបង្កជាវិបត្តិសម្រាប់អ្នកប្រើ-ប្រាស់ផលិតផលគ្រប់រូប

- ទាក់ទាញអ្នកវិនិយោគពីក្រៅប្រទេសតាមរយៈចូលជាសមាជិក WTO
- ដោយកម្ពុជា ជាប្រទេសដែលមានការអភិវឌ្ឍន៍តិច ឆ្លងកាត់ការចរចាជាច្រើនមកមានប្រទេសខ្លះ ដូចជាសហរដ្ឋអាមេរិកបានអនុញ្ញាតឱ្យកម្ពុជា នាំចូលនូវសម្លៀកបំពាក់ទៅក្នុងប្រទេសនោះ ដោយមិនមានការបង់ពន្ធ ឬបង់ពន្ធតិចបំផុត។ ដូច្នេះ វាគឺជាផលប្រយោជន៍មួយយ៉ាងធំទៅលើការបង់ពន្ធតិច ព្រោះថា ប្រទេសយើងមានកម្លាំងពលកម្មច្រើន និងមានតម្លៃថោកដែលធ្វើឱ្យទំនិញរបស់កម្ពុជាអាចប្រកួតប្រជែងជាមួយ និងទំនិញឯទៀតបានដោយស្រួលផងដែរ។ រីឯប្រទេសកាណាដា និងសហរដ្ឋអាមេរិកដដែល មិនយកពន្ធលើផលិតផលត្រី ដែលសំបូរហូរហៀរនៅក្នុងប្រទេសកម្ពុជា ចូលទៅក្នុងប្រទេសរបស់ពួកគេ។
- អាចនាំចេញបានទាំងផលិតផលឧស្សាហកម្ម និងកសិកម្ម
- ធ្វើឱ្យវិស័យសេដ្ឋកិច្ចមានការកើនឡើងបូកផ្សំ និងជំនួយពីបរទេសទៀតនោះធ្វើឱ្យកម្ពុជាមានការប្រែផ្លាស់មុខមាត់យ៉ាងឆាប់រហ័ស។

## ៤. ផលប៉ះពាល់

ក្នុងការចូលជាសមាជិករបស់កម្ពុជា ទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកនេះមានការប៉ះពាល់ ដូចជា :

- អាជីវករក្នុងស្រុកមានការព្រួយបារម្ភ ដោយហេតុថា ប្រទេសកម្ពុជាបើកចំហទីផ្សារ ដូច្នេះ នឹងមានការប្រកួតប្រជែងពីអាជីវករបរទេសធំៗ ដែលអាចឱ្យអាជីវករក្នុងស្រុកក្ស័យធនបាន។
- ការអនុគ្រោះពន្ធ គឺលុះត្រាតែក្រុមហ៊ុនកម្ពុជាមានប្រៀបលើការប្រកួតប្រជែង ដោយមានលទ្ធភាពផ្តល់នូវផលិតផល ដែលប្រកបដោយគុណភាពទាន់ពេល ដែលតម្លៃប្រកបដោយភាពប្រកួតប្រជែង ហើយគោរពនូវបទបញ្ញត្តិទាក់ទងនឹងសន្តិសុខស្បៀងរបស់ប្រទេសដែលអនុគ្រោះពន្ធ។
- ការអនុគ្រោះពន្ធធ្វើឱ្យកម្ពុជាមានកំណើនថវិកា និងសេដ្ឋកិច្ច ក៏ប៉ុន្តែនឹងជួបបញ្ហានៅពេលដែលការអនុគ្រោះពន្ធត្រូវបានបញ្ចប់ ដូចជា ឆ្នាំ២០០៤ កូតាក្នុងការមិនយកពន្ធរបស់សហរដ្ឋអាមេរិកត្រូវបានបញ្ចប់ ដូច្នេះ សម្រាប់កម្មករនិងកម្មការិនីដែលធ្វើការនៅរោងចក្រភាគច្រើន ត្រូវបានបញ្ឈប់ការងារ (តាមរបាយការណ៍បានឱ្យដឹងថាកម្មករ និងកម្មការិនីចំនួន ២២០,០០០ នាក់ ដែលប្រឈមមុខនឹងបញ្ហានេះ)។ ដូច្នេះ យើងឃើញថាពេលនេះកម្ពុជា ជួបនឹងបញ្ហា ដែលអ្នកស្វែងរកការងារធ្វើមានចំនួនច្រើនលើសលុប (កម្ពុជាធ្វើការកាត់បន្ថយជនក្រីក្រ បើមានជម្រើសអ្វីដែលល្អ និងអំណោយផលទៅថ្ងៃអនាគតកម្ពុជានឹងចាប់យកឱកាសនោះភ្លាម)។
- ក្រោយការអនុគ្រោះពន្ធត្រូវបានបញ្ចប់ ទំនិញនឹងជួបជាមួយនឹងគូរប្រកួតប្រជែងជាមួយប្រទេសខ្លាំងៗ ដូចជា ចិន ឥណ្ឌា ជាដើម ប្រសិនបើប្រកួតមិនឈ្នះអាចបញ្ចប់អាជីវកម្មរបស់ខ្លួន។

- ប្រទេសកម្ពុជានៅមានការខ្វះខាតខាងបច្ចេកវិទ្យា ដើម្បីបង្កើនប្រសិទ្ធិភាព និងគុណភាពទំនិញ សេវាកម្ម និងផលិតផល ដែលបណ្តាលឱ្យការនាំចេញនៅមានកម្រិតទាប និងពុំទាន់បំពេញតម្រូវការរបស់បរទេសបាន ។
- មានការអនុវត្តន៍ទៅលើការកាត់បន្ថយពន្ធនាំចូល រីឯពន្ធគយគឺនៅធ្វើការចរចាតាមប្រទេសនីមួយនៅឡើយ ។ ដូច្នេះ វានៅតែជាការលំបាកសម្រាប់អាជីវករខ្មែរក្នុងការនាំចេញទំនិញ និងផលិតផលទៅកាន់បរទេស ។ ( អត្រាពន្ធគយនៅតែជាបញ្ហាសម្រាប់ប្រទេសទន់ខ្សោយ ព្រោះពន្ធ គឺជាចំណូលដ៏ធំរបស់ប្រទេស) ។
- បញ្ហាវត្ថុធាតុដើមនៅមានប្រទេសមួយចំនួនមកចរចាថា គេនឹងអនុគ្រោះពន្ធបើកម្ពុជា អាចផ្គត់ផ្គង់វត្ថុធាតុដើមគ្រប់គ្រាន់សម្រាប់ផលិតផលនាំចេញ ដោយមិនចាំ បាច់នាំចូលវត្ថុធាតុដើម ពីបរទេសនោះ ឧទាហរណ៍ ដូចជាអំបោះសូត្រមួយភាគធំត្រូវនាំចូលពីបរទេស ដូច្នេះ កម្ពុជាមិនអាចបំពេញល័ក្ខខ័ណ្ឌដែលធ្វើឱ្យផលិតផលសូត្រកម្ពុជាមិនអាចនាំចេញទៅបរទេសបាន ។

## ៥.ផលវិបាកផ្នែកច្បាប់ និងផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា

ក្នុងការចូលជាសមាជិក WTO មិនថាតែប្រទេសកម្ពុជាទេ ដែលមានផលវិបាកទៅលើផ្នែកច្បាប់នោះ គ្រប់សមាជិកទាំងអស់របស់អង្គការ ត្រូវជួបនូវបញ្ហានេះដូចគ្នា ដោយហេតុថា គេតម្រូវឱ្យសមាជិកនីមួយៗ ធ្វើវិសោធនកម្មទៅតាមច្បាប់ដែលអង្គការនេះមានរួចហើយ :

១- ប្រទេសជាសមាជិកនីមួយៗ ប្រកាន់យកនូវអធិបតេយ្យភាពរៀងៗ ខ្លួន

២- គឺជាទំនាស់អំពីអត្ថប្រយោជន៍របស់ប្រទេសដែលមានការអភិវឌ្ឍន៍ខ្លាំង និង ប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

៣- នៅតែជាឧបសគ្គក្នុងការឈានទៅរកការអនុវត្តន៍ច្បាប់រួមមួយ។

៤- ប្រទេសនីមួយៗ មានច្បាប់របស់ប្រទេសរៀងៗខ្លួន ដូច្នេះ ច្បាប់ដែលគេធ្វើការ ចងក្រងឡើង គឺដើម្បីការពារផលប្រយោជន៍ឱ្យប្រជាពលរដ្ឋរៀងៗ ខ្លួនដែរ។

៥- ម្យ៉ាងប្រទេសនីមួយៗ មានរបបគ្រប់គ្រង ទស្សនវិស័យ ឬសាសនាខុសៗគ្នា ដែលជា ការពិបាកក្នុងការចាប់បង្ខំគេឱ្យអនុវត្តន៍តាមច្បាប់រួម។

ដូច្នេះ ទើបតម្រូវឱ្យពាណិជ្ជករត្រូវធ្វើការសម្រេចចិត្តដោយខ្លួនឯងឱ្យច្បាស់ថា ពេលធ្វើពាណិជ្ជកម្មពីប្រទេសមួយទៅប្រទេសមួយ គួរត្រូវប្រើនូវកិច្ចសន្យា ដែលមាន លក្ខណៈជាពាណិជ្ជកម្មអន្តរជាតិ ឬយ៉ាងណា?

កម្ពុជាបានសន្យាថា នឹងធានាធ្វើឱ្យមានការកែប្រែទៅលើប្រព័ន្ធច្បាប់ និង បញ្ញោរបស់ខ្លួន ដើម្បីឱ្យមានការស្របគ្នាទៅនឹងបទបញ្ញោរបស់ WTO ត្រឹមថ្ងៃទី ០១ ខែឧសភា ឆ្នាំ ២០០៥ នេះ។ នេះហើយគឺជាការប៉ះពាល់ទៅលើផ្នែកច្បាប់របស់កម្ពុជា ព្រោះថា នេះគឺជាតម្រូវការរបស់ WTO ដើម្បីអាចចូលជាសមាជិកបាន។

ចំពោះផលប៉ះពាល់លើកម្មសិទ្ធិបញ្ញាវិញ ជាការសន្យាមួយរវាងកម្ពុជា និង អង្គការ WTO ផងដែរ ដោយប្រទេសកម្ពុជាសន្យាថា នឹងអនុវត្តន៍ឱ្យបានទាំងស្រុងនូវ កិច្ចព្រមព្រាងអង្គការពាណិជ្ជកម្មពិភពលោក ស្តីពីកម្មសិទ្ធិបញ្ញា ដែលហៅថា កិច្ចព្រម ព្រាង ស្តីអំពី "ទិដ្ឋភាពនៃកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម" Trade Related Aspects of Intellectual Property Rights (TRIPS) ត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ ២០០៧ ។

- ប្រទេសកម្ពុជាធ្លាប់បានស្នើសុំផងដែរ ក្នុងការកំណត់ពេលវេលាមួយសមស្រប របស់ខ្លួនរហូតដល់ ឆ្នាំ២០០៩ ដើម្បីអនុវត្តន៍នូវកិច្ចព្រមព្រៀងខាងលើ ប៉ុន្តែ ការចរចា គឺធ្លាក់មកត្រឹមឆ្នាំ ២០០៧ ។
- ច្បាប់កម្មសិទ្ធិបញ្ញា រដ្ឋសភាជាតិ អនុម័តច្បាប់នេះតាំងពី ឆ្នាំ ២០០២ មកម្ល៉េះ
- កម្ពុជាបានអនុម័ត និងប្រកាសឱ្យប្រើនូវច្បាប់មួយចំនួនរួចទៅហើយ ដូចជា ប៉ាតង់ទៅលើថ្នាំពេទ្យ ដែលទាំងនេះគឺជាកិច្ចសន្យារហូតដល់ ឆ្នាំ ២០១៦ នៅឯ Doha ប្រទេស Qata ។

បន្ថែមទៀតនោះច្បាប់ថ្មីនេះ មានផលលំបាកចំពោះតែផលិតករដែល ធ្វើការលួចបន្លំនូវផលិតផលរបស់គេតែប៉ុណ្ណោះដែលមានបញ្ហា គឺដូចជា :

- ការក្លែងបន្លំទំនិញ
- លួចថតចម្លងខុសច្បាប់ ( ភាពយន្ត ចម្រៀង ឬកម្មវិធីកុំព្យូទ័រ)
- ការបំពានទៅលើពាណិជ្ជកម្មសញ្ញា ( ក្រុមហ៊ុនភេសជ្ជៈ) ដែលទាំងនេះវាជា ផលល្អទៅវិញទេ ដល់ផលិតករដែលមានច្បាប់ត្រឹមត្រូវគោរព និងអនុវត្តន៍ ច្បាប់នេះ។ ច្បាប់នេះបានជួយដល់ផលិតករក្នុងការទទួលបានសិទ្ធិធ្វើអាជីវកម្ម លើគំនិតថ្មីៗ ដោយមិនមានការខ្លាចក្រែងពីការលួចបន្លំពីអ្នកដទៃ។

## ៦.ឧស្សាហកម្មសម្រាប់អនាគត

ដោយហេតុថាប្រទេសកម្ពុជា ជាប្រទេសដែលមានការអភិវឌ្ឍន៍តិច ដូចនេះ កម្ពុជាត្រូវមានការអនុគ្រោះពាណិជ្ជកម្មពីប្រទេសមួយចំនួន។ ក៏ប៉ុន្តែ មានការលំបាកខ្លះ ដែរក្នុងការទទួលទីផ្សារថ្មីពិតជាពិបាកក្នុងការធ្វើពាណិជ្ជកម្ម។ កម្ពុជាបានបើកចំហទីផ្សារ របស់ខ្លួនតាំងពីឆ្នាំ ២០០១ មកម្ល៉េះ ដូច្នេះការប្រកួតប្រជែងពីខាងក្រៅ និងការនាំចូលនូវ

ផលិតផលរបស់បរទេសជាកត្តាមួយដ៏គួរឱ្យបារម្ភណាស់ដល់ផលិតផលក្នុងស្រុក។ ក្នុងការចូលជាសមាជិករបស់កម្ពុជាទៅក្នុង WTO មិនប្រាកដថានឹងទទួលបានជោគជ័យក្នុងការធ្វើពាណិជ្ជកម្មក្រៅប្រទេសនោះទេ។ ការចូលជាសមាជិកនេះគឺជំរុញឱ្យមានការធ្វើកំណែទម្រង់ដើម្បីឱ្យអាជីវកម្មកម្ពុជា អាចធ្វើការប្រកួតប្រជែងជាមួយគូរប្រកួតបរទេស។ ទន្ទឹមនឹងនោះដែរការចូលជាសមាជិករបស់ WTO នេះយើងអាចបង្កជាបរិយាកាសមួយដែលអាចធ្វើការទាក់ទាញអ្នកវិនិយោគទុនបរទេស ឱ្យមកវិយោគក្នុងស្រុកប្រទេសកម្ពុជា។ ទៅក្នុងថ្ងៃអនាគត ឱកាសជាច្រើននឹងកើតមកដល់អាជីវករ និងក្រុមហ៊ុននានាក្នុងកម្ពុជា និងអាចមានការកើនឡើងយ៉ាងច្រើន។ ក្ដីរំពឹងទុក គឺសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានឹងមានការកើនឡើង ហើយចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់ក្រីក្រនឹងត្រូវកាត់បន្ថយជាអតិបរិមា ការរំលោភសិទ្ធិ ការកេងប្រវ័ញ្ចន៍ និងអំពើពុករលួយដ៏នឹងត្រូវត្រួតពិនិត្យផងដែរ។

## ៧.អនុសាសន៍របស់ NGOs

Fine Arts Association សូមផ្ដល់អនុសាសន៍ជាបឋមថា :

- កម្ពុជាត្រូវធ្វើការជំរុញឱ្យមានការវិនិយោគឱ្យបានខ្លាំងនៅក្នុងស្រុក។
- ទាក់ទាញឱ្យបាននូវអ្នកវិនិយោគបរទេសធំៗ ឱ្យមកវិនិយោគស្រុកខ្មែរ ដោយធ្វើកំណែទម្រង់ឱ្យបានល្អនូវបែបផែននានា និងការអនុវត្តន៍ច្បាប់ ជាពិសេសគឺត្រូវកាត់បន្ថយ និងឈានទៅរកការលប់បំបាត់ចោលនូវអំពើពុករលួយ។
- ផ្ដល់នូវការលើកទឹកចិត្តដល់កសិករ ផលិតករនានា ឱ្យមានកម្លាំងចិត្តក្នុងរកឃើញនូវផលិតផលថ្មីៗ ដែលមានប្រយោជន៍ដល់វិស័យសេដ្ឋកិច្ចកម្ពុជា។

- ជំរុញមានការផ្តល់នូវបច្ចេកទេសវិទ្យាជូនដល់កសិករបន្ថែមទៀត ក្នុងបំណង ធ្វើឱ្យផលិតផលកម្ពុជា អាចឈានដល់កម្រិតស្តង់ដារបរទេស ដើម្បីយើងរក ទីផ្សារជូនផលិតករ ។
- បង្កឱ្យបាននូវស្ថានភាពសេដ្ឋកិច្ចដែលមានលំនឹង ។
- យើងត្រូវជំរុញឱ្យមាននូវទំនុកចិត្ត ក្នុងការប្រើប្រាស់ផលិតផលក្នុងស្រុកដើម្បី ឈាន ឱ្យបាននូវការនាំចេញទៅបរទេស ។
- ផ្តល់ជាដើមទុនខ្លះៗ ដល់អ្នកដែលមានគំនិត និងមានឆន្ទៈខ្ពស់ក្នុងការធ្វើ អាជីវកម្ម និងទទួលទិញផលិតផលពួកគាត់ធ្វើយ៉ាងនេះ យើងអាចបង្កើននូវ វត្ថុធាតុដើមនៅក្នុងស្រុកដោយមិនចាំបាច់ចូលពីបរទេស ហើយតម្លៃផលិតផល របស់យើងក៏អាចមានតម្លៃទាប ដែលធ្វើឱ្យប្រជាពលរដ្ឋអាចមានលទ្ធភាព ទិញទំនិញបានហើយវិស័យ សេដ្ឋកិច្ចក៏មានការកើនឡើងទៀត ។ (តាមពិត ផលិតផលកម្ពុជាមានកេរ្តិ៍ឈ្មោះតាំងពីយូរលង់ណាស់មកហើយ ដូចជាផលិត-ផលសូត្រជាដើម) ។
- អាជីវកម្មទាំងអស់ ត្រូវផលិតនូវផលិតផលដែលមានគុណភាពខ្ពស់ ដើម្បី ដណ្តើមនូវកេរ្តិ៍ឈ្មោះទាំងក្នុងស្រុក និងក្រៅស្រុកផងដែរ ។
- ធ្វើការបន្ធូរបន្ថយនូវពន្ធគ្រប់ប្រភេទដល់ផលិតផល ក្នុងស្រុកជំរុញយ៉ាងណា ឱ្យផលិតផលក្នុងស្រុកទទួលបាននូវការចាប់អារម្មណ៍ គុណភាពខ្ពស់តម្លៃថោក ហើយអាចធ្វើការប្រកួតប្រជែងជាមួយនឹងផលិតផលបរទេសបាន ។
- បញ្ហានយោបាយ ការគោរពសិទ្ធិមនុស្ស តុលាការឯករាជ្យ គឺត្រូវតែមាន ស្ថិរភាព ព្រោះរាល់អ្នកវិនិយោគតែងតែគិតពីបញ្ហានេះ ។

- ធ្វើការកាត់បន្ថយជាបណ្ដើរៗនូវការនាំចូលទំនិញបរទេសខុសច្បាប់ដើម្បីបង្កើន នូវផលិតភាពក្នុងស្រុក។

## ៨. សេចក្តីសន្និដ្ឋាន

ការដែលកម្ពុជាចូលជាសមាជិក WTO ដោយសារតែកម្ពុជាមើលឃើញនូវអត្ថប្រយោជន៍ អំពីការនាំចេញនូវផលិតផលសម្លៀកបំពាក់ និងផលប្រយោជន៍ខាងនយោបាយផងដែរ។ ដូច្នេះ យើងអាចមើលឃើញថា ការដែលចូលជាសមាជិក WTO វាពិតជាបានផ្តល់នូវផលប្រយោជន៍ដល់កម្ពុជា ទោះបីជាកម្ពុជាជាប្រទេសក្រីក្រ ហើយនៅមានការខ្វះខាតនូវបច្ចេកវិទ្យា ក្នុងការធ្វើឱ្យគុណភាពទំនិញតាមបែបស្តង់ដារពិភពលោកនៅមានកម្រិត ក៏ក្នុងពេលដែលកម្ពុជាទទួលនូវលាភសំណាងមួយរយៈ ដោយមានការអនុគ្រោះពន្ធ កម្ពុជាអាចធ្វើឱ្យប្រជាជន ២២០,០០០ នាក់មានការងារធ្វើផងដែរ។ ប្រជាជនមានការងារធ្វើក្នុងរយៈពេលខ្លី គឺវាប្រសើរជាងការដែលទុកឱ្យកម្លាំងពលកម្មទាំងនោះទំនេរចោលដោយគ្មានផលប្រយោជន៍អ្វីសោះ។

ផលប្រយោជន៍ពីសមាជិកភាពនេះ អាចនឹងមានទៅថ្ងៃមុខទៀត អាចនឹងច្រើនជាង អ្វីដែលយើងធ្វើការប៉ាន់ស្មានទៀតក៏ថាបាន។ ក្នុងនេះដែរអាជីវករគ្រប់រូបត្រូវពង្រឹងនូវយុទ្ធសាស្ត្រ ក្នុងការលក់របស់ខ្លួនដើម្បីធ្វើការប្រកួតប្រជែង មិនថាក្នុងស្រុក ឬក្រៅស្រុកនោះទេ។ យើងធ្វើការបើកចំហទីផ្សារយ៉ាង ធំទូលាយទៅហើយ ដូច្នេះ ការប្រកួតប្រជែង គឺជាគន្លឹះសំខាន់ក្នុងការរុញច្រានទៅរកជោគជ័យ។ ក៏ប៉ុន្តែ ការប្រកួតប្រជែង គឺឋិតនៅក្នុងរង្វង់នៃច្បាប់ ពោលគឺត្រូវតែគោរពច្បាប់។ ច្បាប់នេះហើយដែលធ្វើឱ្យអ្នកវិនិយោគក្រៅប្រទេសហ៊ានមកបណ្តាក់ទុនក្នុងប្រទេសកម្ពុជា។

សមាគមវិចិត្រសិល្បៈ Fine Arts Association-FAA សង្ឃឹមយ៉ាងមោះមុតថា ការធ្វើអត្ថាធិប្បាយនេះនឹងបានជាគតិសម្រាប់ការពិចារណា សម្រាប់មន្ត្រីសំខាន់ៗរបស់ជាតិ អាជីវករដែលប្រកបរបរបអាជីវកម្មនៅក្នុងប្រទេសកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ។

# កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក ផលវិបាកផ្នែកច្បាប់ និងផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា

**ឯកឧត្តម ស៊ឹម សារ៉ាក់**

អគ្គនាគយ អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រវត្តិសាស្ត្រកម្ពុជាបានបង្រៀនខ្មែរឱ្យចងចាំថា វឌ្ឍនភាពសង្គមកម្ពុជាកើតមានឡើងដោយសារបុព្វការីយើង មានចំណេះដឹង ឆ្លាតវាងវៃ ចូលចិត្តការបង្កើថ្មី ស្រឡាញ់រួបរួមគ្នា ទើបមានសមិទ្ធផលវប្បធម៌ច្រើនអនេកបន្សល់ទុកឱ្យយើង ធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមសព្វថ្ងៃ។ ព្រះរាជាណាចក្រកម្ពុជាបានក្លាយជាសមាជិកទី១៤៨ នៃអង្គការពាណិជ្ជកម្មពិភពលោក នាថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៤ ក៏ជាពេលដែលជនកម្ពុជាត្រូវបង្កើនភាពវៃឆ្លាតបង្កបង្កើតផលិតផលមានគុណភាព ដើម្បីប្រកួតប្រជែងលើទីផ្សារអន្តរជាតិ។ សមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោក ធ្វើឱ្យមជ្ឈដ្ឋានអ្នកវប្បធម៌យើងខ្លះ មានក្តីសប្បាយរីករាយ អបអរសាទរ ខ្លះមានក្តីកង្វល់ចំពោះអនាគតនៃទីផ្សារវប្បធម៌នៅកម្ពុជា ព្រោះយើងខ្វះមូលដ្ឋានសម្ភារៈ និងធនធានមនុស្ស។ សមាជិកភាពនៃអង្គកាពាណិជ្ជកម្មពិភពលោក នាំកម្ពុជាឱ្យជួបផលវិបាកផ្នែកច្បាប់ និងផលប៉ះពាល់លើកម្មសិទ្ធិបញ្ញាដូចខាងក្រោម ៈ

១-ផលវិបាកផ្នែកច្បាប់

*ក-ផលវិបាកអាក្រក់ :*

បើសិនជាយើងកែលម្អច្បាប់ និងបទបញ្ញត្តិទាំងឡាយដែលទាក់ទងនឹងការធ្វើអាជីវកម្មទាន់ពេលកម្ពុជា អាចនឹងអូសបន្លាយពេលវេលាទទួលផលប្រយោជន៍ ព្រោះយើងបានសន្យាឱ្យមានច្បាប់ បង្កើតតុលាការពាណិជ្ជកម្មត្រឹមដើម ឆ្នាំ ២០០៦។

*ខ-ផលវិបាកល្អ :*

វិស័យវប្បធម៌ យើងមានច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលជាថាមពលជំរុញ ការលើកទឹកចិត្ត ការបង្កើតផលិតផលវប្បធម៌ក្នុងគោលដៅអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ សម្រាប់អប់រំ និងផ្ទេរវប្បធម៌ខ្មែរដល់ខ្មែរជំនាន់ថ្មី។

ផលិតផលវប្បធម៌ជាតិមានច្រើននៅលើទីផ្សារ ជាការផ្សព្វផ្សាយអត្តសញ្ញាណជាតិ ផ្ទុយទៅវិញបើមានផលិតផលវប្បធម៌បរទេសច្រើននៅលើទីផ្សារជាតិ នាំឱ្យកូនខ្មែរទទួលយកវប្បធម៌ពី ខាងក្រៅច្រើនជាងការទទួលវប្បធម៌ខ្មែរ។ តែជាប្រការល្អបំផុតបើយើងទទួលយកវប្បធម៌ពីខាងក្រៅផ្នែកបច្ចេកទេសវិទ្យាទំនើប។ យើងមានច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ជាកត្តាសំខាន់រួមចំណែកពង្រឹងនីតិរដ្ឋខាងវិស័យវប្បធម៌។

២-ផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា :

*ក-ផលអវិជ្ជមាន*

ក្រោយពេលសង្គ្រាមខ្មែរយើងមានឥរិយាបថផ្ទុយពីដូនតា មិនសូវគោរពច្បាប់ រំលោភបំពានលួចចម្លងកម្មសិទ្ធិបញ្ញាដទៃធ្វើអាជីវកម្ម បង្កឱ្យមានការរាំងខ្ទប់ការតែងពិពន្ធបង្កើតផលិតផលថ្មីខាងវប្បធម៌ និងការធ្វើវិនិយោគជាកត្តានាំឱ្យមានការរីកចំរើនយឺត និងប៉ះពាល់ដល់ការពង្រឹងនីតិរដ្ឋ។ បើនៅមានបន្តបាតុភូតមិនគោរពច្បាប់នៅក្នុងសម័យដែលកម្ពុជាជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក នោះកម្ពុជាមិនត្រឹមតែ

គ្មានផលិតផលវប្បធម៌ សម្រាប់ប្រកួតប្រជែងជាអន្តរជាតិប៉ុណ្ណោះទេ ថែមទាំងរក្សាការពារវប្បធម៌ជាតិខ្លួនមិនបានទៀតផង។

### *ខ-ផលវិជ្ជមាន*

កម្ពុជាជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក នាំឱ្យខ្មែរកាន់តែច្រើនឡើងផ្លាស់ប្តូរឥរិយាបថពីការមិនគោរពច្បាប់ ទៅជាការគោរពច្បាប់វិញ។ ការគោរពច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលនាំឱ្យច្បាប់នេះបំពេញបានតួនាទីបីសំខាន់ៗ :

- ❖ តួនាទីវប្បធម៌
  - បង្កើនចំនួនអ្នកនិពន្ធដែលជាអ្នកបង្កើតចំណេះដឹងសម្រាប់បណ្តុះកូនខ្មែរដើម្បីកសាងប្រទេសជាតិឱ្យមានការីកចម្រើន
  - បង្កើនផលិតផលវប្បធម៌សម្រាប់បំពេញសេចក្តីត្រូវការ ក្នុងស្រុកជាបណ្តើរៗ
  - ពង្រឹងនិន្នាការស្នេហាវប្បធម៌ជាតិឡើងវិញ
  - ថែរក្សាអត្តសញ្ញាណជាតិបាន
- ❖ តួនាទីសេដ្ឋកិច្ច
  - ទាក់ទាញជំនឿទុកចិត្តការធ្វើនិវិយោគខាងវិស័យវប្បធម៌។ បច្ចុប្បន្ននេះ កម្ពុជាមានផលិតកម្មភាពយន្ត វិដេរចំនួន ៦៥ កំពុងដំណើរការផលិតភាពយន្ត និងវីដេរអូ។
  - មានផលិតកម្មកាន់តែច្រើនឡើងបានគោរពច្បាប់។
  - មានរោងភាពយន្តច្រើនបញ្ចាំងខ្សែភាពយន្តខ្មែរ។
- ❖ តួនាទីសង្គម
  - បង្កើតការងាររួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការងារក្នុងផលិតកម្មភាពយន្តវិដេរអូ ក្នុងរោងភាយន្ត ជាសិល្បករ ។ល។

### *គ-ក្តីរំពឹងចំពោះអនាគតកាល*

សមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោក ពេលនេះកម្ពុជាមិនបានទទួលផលពីការធ្វើពាណិជ្ជកម្មពិភពលោកទេ ព្រោះយើងគ្មានទំនិញគ្រប់គ្រាន់សម្រាប់ប្រកួតប្រជែង តែសមាជិកភាពនៃអង្គការនេះជំរុញឱ្យកម្ពុជាកែទម្រង់ច្បាប់ និងនាំខ្មែរឱ្យចេះគោរពច្បាប់ បង្កការលើកទឹកចិត្តបង្កើតផលិតផលមានគុណភាព ទាក់ទាញការធ្វើវិនិយោគទុនតែប៉ុណ្ណោះ។ សព្វថ្ងៃនេះពិនិត្យលើការគោរពច្បាប់មានការកើនឡើង ជាសេចក្តីសង្ឃឹមពេលអនាគតដ៏ខ្លីកម្ពុជានឹងឈ្នះខ្លួនឯង ហើយឈានទៅប្រកួតប្រជែងជាមួយអន្តរជាតិ។

# កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់ពលកម្មកម្ពុជា

**ឯកឧត្តម អ៊ុំ មាន**

អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

តាងនាមថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុង ចំពោះថ្នាក់ដឹកនាំ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព និងអ្នកចាត់ចែងកម្មវិធី ដែលបានផ្តល់កិត្តិយសឱ្យខ្ញុំបានចូលរួមជាវាគ្មិនក្នុងសន្និសីទជាតិដ៏មានសារៈសំខាន់នេះ ។

ទាក់ទងនឹងបទ ស្តីពី "ផលប៉ះពាល់ចំពោះពលកម្ម ពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា" ដោយមានវាគ្មិនជាច្រើន ដែលត្រូវបានអញ្ជើញឱ្យមកបកស្រាយដែរ ។ ហេតុនេះ ខ្ញុំសូមលើកឡើងនូវការកត់សំគាល់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទៅលើបញ្ហាមួយចំនួនដែលពាក់ព័ន្ធប៉ុណ្ណោះ ។

ក្នុងអំឡុងឆ្នាំ ២០០៥ មានកង្វល់ជាច្រើនពាក់ព័ន្ធនឹងសមាជិកភាពរបស់កម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក WTO និងការបញ្ចប់កូតានាំចេញផលិតផលកាត់ដេរសម្លៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក នាឆ្នាំ២០០៥ ។ មតិជាតិ និងអន្តរជាតិខ្លះសន្និដ្ឋានថា នៅឆ្នាំ២០០៥ នេះ អាចនឹងមានការធ្លាក់ចុះលើវិស័យកាត់ដេរនេះដោយសារកម្ពុជា ត្រូវប្រឈមមុខជាមួយនឹងការប្រកួតប្រជែងដ៏ស្រួចស្រាលពីប្រទេសមួយចំនួន

និង ជាពិសេសប្រទេសចិនដែលមានប្រៀបយ៉ាងធំធេង (វត្ថុធាតុដើមធនធានមនុស្ស គមនាគមន៍ និងសេវានានា ។ល។) ធ្វើឱ្យកម្ពុជាពុំសូវមានការបញ្ជាទិញរោងចក្រ ភាគច្រើនអាចបិទទ្វារ កម្មករត្រូវបាត់បង់ការងារយ៉ាងគំហុក និងការអាចកើនមាន វិបត្តិសង្គម ។ល។

I-ក្នុងទស្សនៈនេះ រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី២ នៃរដ្ឋសភា មានការគិតទុកជាមុន និងបានដំណើរការអនុវត្តន៍វិធានការមួយចំនួនរួមមាន :

- ការអភិវឌ្ឍន៍វិស័យទេសចរណ៍ កសិកម្ម កសិ-ឧស្សាហកម្ម គមនាគមន៍ បង្កើតតំបន់សេដ្ឋកិច្ចឱ្យបានច្រើន ។ល។ សម្រាប់ដោះស្រាយ និងបញ្ចៀសផលវិបាកដែលអាចកើតមាន។
- ក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ក្នុងឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងទ្វេភាគី ជាមួយសហរដ្ឋអាមេរិកលើការនាំចេញសម្លៀកបំពាក់ ដោយភ្ជាប់ទៅនឹងការធ្វើឱ្យកាន់តែប្រសើរឡើង នូវលក្ខណៈទូទៅនៃការងារ ព្រមទាំងបានដំណើរការ គម្រោងឃ្លាំមើលល័ក្ខខ័ណ្ឌការងាររបស់អង្គការពលកម្មអន្តរជាតិ ILO Monotoring Project on Labor Condition ចាប់ពីពេលនោះមក។ បច្ចុប្បន្ននេះ ទោះបីកូតាត្រូវបានបញ្ចប់ក៏ដោយ រាជរដ្ឋាភិបាលកម្ពុជានៅតែគាំទ្រគម្រោងឃ្លាំមើលល័ក្ខខ័ណ្ឌការងារ ដែលបានប្តូរឈ្មោះជា ***គម្រោង រោងចក្រកាន់តែប្រសើរនៅកម្ពុជា***។ ទន្ទឹមនឹងនេះ គម្រោងដោះស្រាយវិវាទការងារនៅកម្ពុជាបានជួយធ្វើឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង ក្នុងខែធ្នូ ឆ្នាំ២០០២។ រយៈពេល ៣ ឆ្នាំមកនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលដោះស្រាយវិវាទការងាររួមដែលកើតក្នុងទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករនិយោជិត និងនិយោជក នោះទទួល

លទ្ធផលគួរជាទីកត់សំគាល់ ទោះបីមានករណីខ្លះពុំទាន់យល់ព្រមពីភាគីវិវាទខ្លះក៏ដោយ ។ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា បានរួមចំណែកយ៉ាងច្រើនដល់ការវិវត្តន៍របស់វិស័យកាត់ដេរនៅកម្ពុជា។ សហរដ្ឋអាមេរិកបាលផ្តល់ជំនួយបន្ថែមសម្រាប់បន្តដំណើរការរបស់អង្គការពលកម្មអន្តរជាតិលើគម្រោងទាំង ២ នេះ រយៈពេល ៣ ឆ្នាំទៀត ២០០៥-២០០៨។ ដោយឡែកគណៈកម្មការប្រឹក្សាការងារ ដែលមានសមាសភាពពីភាគី រដ្ឋាភិបាល ភាគីនិយោជក និងភាគីកម្មករនិយោជិត ដូចមានចែងក្នុងជំពូកទី ១៥ នៃច្បាប់ស្តីពីការងារ ក៏បានរួមចំណែករបស់យ៉ាងសកម្មតាមបេសកកម្មរបស់ខ្លួនអំពី ការសិក្សាស្រាវជ្រាវរាល់បញ្ហាទាក់ទងនឹងការងារ មុខរបរនៃកម្មកនិយោជិត ប្រាក់ ឈ្នួល ការអប់រំវិជ្ជាជីវៈ ចលនាកម្លាំងពលកម្មក្នុងប្រទេស អន្តោប្រវេសន៍ ការរៀបចំឱ្យកាន់តែប្រសើរឡើងនូវលក្ខខ័ណ្ឌខាងសម្ភារៈ និងស្មារតីនៃកម្មករ និយោជិត បញ្ហាអនាម័យ និងសន្តិសុខការងារ ។

ជាលទ្ធផល កាលពីខែតុលា ឆ្នាំ ២០០៥ កន្លងទៅថ្មី១នេះ អង្គការពលកម្មអន្តរជាតិ នៅទីក្រុង ហ្សឺណែវ ក្នុងរបាយការណ៍របស់ខ្លួន នាកិច្ចប្រជុំវេទិកាត្រីភាគី ស្តីពី "ការលើកកម្ពស់សកលភាវូបនីយកម្ម ដោយស្មើភាពក្នុងវិស័យវាយនភណ្ឌ និងសម្លៀកបំពាក់ក្នុងពេលក្រោយការបញ្ចប់កិច្ចព្រមព្រៀងពហុសរសៃអំបោះ" Promoting fair globalization in textile and clothing in a post-MFA environment បានវាយតម្លៃអំពីកម្ពុជាយើងថា :

- លក្ខខ័ណ្ឌទូទៅនៃការងារនៅកម្ពុជា ល្អគួរឱ្យទុកចិត្តបានដែលជាប្រៀបខ្លាំង និងជាកិត្តិសព្ទ ធ្វើឱ្យអ្នកប្រើប្រាស់ទំនិញកម្ពុជានៅបន្តគាំទ្រ អ្នកបញ្ជាទិញនៅតែបន្តបញ្ជាទិញទៀត

- កម្ពុជាបានត្រៀមរៀបចំខ្លួនបានល្អ ជាអាទិ៍ មុនពេលបញ្ចប់កូតា កម្ពុជាគាំទ្រគម្រោងឃ្លាំមើលល័ក្ខខ័ណ្ឌការងារ និងក្នុងពេលបញ្ចប់កូតា កម្ពុជាបន្តគាំទ្រគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។

II-ដោយមានការខិតខំប្រឹងប្រែងទាំងអស់នេះ ទើបចុងឆ្នាំ២០០៥នេះ យើងពិនិត្យឃើញថា :

១- ទោះបីសភាពការណ៍ពិភពលោកបានជួបប្រទះបញ្ហាជាច្រើន ជាអាទិ៍ ការកើនឡើងថ្លៃប្រេងឥន្ធនៈ ការកើតគ្រោះធម្មជាតិ បញ្ហាភេរវកម្ម ។ល។ ដែលជះឥទ្ធិពលខ្លះៗចំពោះនិន្នាការវិវត្តន៍របស់សេដ្ឋកិច្ចកម្ពុជាដែរនោះ ប៉ុន្តែកម្ពុជាយើងនៅតែទទួលនូវអំណោយផលជាច្រើនក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ ជាក់ស្តែង វិស័យកាត់ដេរសម្លៀកបំពាក់ត្រឹមខែកញ្ញានេះ មានរោងចក្រចំនួនតែ ២៣ ដែលបានបិទទ្វារក្នុងនោះមានកម្មករសរុបចំនួន ១៦,៩០០នាក់ (ស្រីចំនួន ១១,៩៥០នាក់) ដែលបាត់បង់ការងារ ផ្ទុយទៅវិញត្រឹម ខែឧសភា មានរោងចក្រចំនួន ៣៦ ដែលបានបើកថ្មី។ រោងចក្រដែលបិទទ្វារ ភាគច្រើនជារោងចក្រតូចៗ ដែលទទួលវត្ថុធាតុដើមពីរោងចក្រធំៗ មកធ្វើរោងចក្រចំនួនបិទទ្វារបណ្តាលមក ពីសម្ពាធនៃការប្រកួតប្រជែង និងកង្វះខាតការគ្រប់គ្រងល្អ និងវិបត្តិទុន។ រោងចក្រដែលបើកថ្មីបាន និងកំពុងដំណើរការពង្រីកចង្វាក់ផលិតកម្មរបស់ខ្លួនជាបណ្តើរៗ ចំនួនកម្មករក៏បានកើនឡើងជាបន្តបន្ទាប់ ដោយស្រូបយកកម្មករចាស់ៗ ដែលបាត់ការងារពីរោងចក្របានដែលបិទទ្វារ និងជ្រើសរើសកម្មករចូលថ្មីថែមទៀត។

២- គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា របស់អង្គការពលកម្មអន្តរជាតិ ILO បានវាយតម្លៃថា វិស័យកាត់ដេរសម្លៀកបំពាក់ពុំមានការថយចុះទេ គិតត្រឹម ៤ ខែ

ដើមឆ្នាំ ២០០៥ នេះ ការនាំចេញទំនិញកាត់ដេរទៅកាន់សហរដ្ឋអាមេរិកបានកើន ១១ % គិតជាទឹកប្រាក់កើនឡើងជាង ១៧ % បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នា។ ទិន្នន័យរបស់ក្រសួងពាណិជ្ជកម្មកម្ពុជាក៏បានឱ្យដឹងដែរថា ក្នុងអំឡុង ១១ ខែ ឆ្នាំ ២០០៥នេះ តម្លៃរួមនៃការងារនាំទំនិញកាត់ដេរចេញទៅកាន់ប្រទេសនានាកើនឡើង ៥,៣៦ % ដោយឡែកទៅកាន់សហរដ្ឋអាមេរិក បានកើនឡើងជាង ១៧ % ការប្រើប្រាស់កម្លាំងពលកម្មក្នុងវិស័យនេះកើនឡើងជិត ៤ % បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នា នាឆ្នាំ ២០០៤។

៣- កាលពី ខែ មេសា ឆ្នាំ ២០០៥ នេះ មូលនិធិរូបិយវត្ថុអន្តរជាតិ IMF បានផ្លាស់ការព្យាករណ៍របស់ខ្លួនលើកកំណើនសេដ្ឋកិច្ចកម្ពុជាពី ២,៣ % ទៅ៦ % ដោយផ្អែកទៅលើភាពខ្លាំងនៃវិស័យកាត់ដេរ។ ក្រោយមកទៀត អង្គការនេះក៏បានកែប្រែការព្យាករណ៍របស់ខ្លួន រហូតដល់ ១៣.១ %។

៤- ក្រៅពីនេះវិស័យផ្សេងៗ ទៀតក៏មានការរីកចំរើនជាបន្តបន្ទាប់ដែរ ដែលជាកត្តាអាចផ្តល់ការងារធ្វើជូនប្រជាពលរដ្ឋយើងរាប់សែននាក់ ជាក់ស្តែងក្នុងវិស័យទេសចរណ៍ យើងមានសណ្ឋាគារចំនួនជាង ៣០០ ដែលមានចំនួនជាង ១៤០០០ បន្ទប់ ផ្ទះសំណាក់ចំនួនជាង ៦០០ ដែលមានចំនួនជាង ៧៦០០ បន្ទប់ ក្នុងនោះកម្លាំងពលកម្មបម្រើឱ្យវិស័យនេះ ទាំងមូលមានចំនួនប្រមាណ ២០ ម៉ឺននាក់។ ។ល។

៥- ទន្ទឹមនឹងទីផ្សារការងារក្នុងប្រទេស ដែលបានផ្តល់ការងារជូនប្រជាពលរដ្ឋបានយ៉ាងច្រើនបង្គួរដែរនោះ យើងក៏ខិតខំសម្លឹងទៅទីផ្សារក្រៅប្រទេសដទៃទៀត។ កន្លងមកកម្ពុជាយើងមានទំនាក់ទំនងជាមួយ ប្រទេសម៉ាឡេស៊ី សាធារណរដ្ឋកូរ៉េ ក្នុងការបញ្ជូនពលករយើងទៅធ្វើការនៅទីនោះ ដើម្បីបានប្រាក់ឈ្នួលខ្ពស់ និងបានជំនាញថែមទៀតដែលសរុបមានចំនួនជាង ៧,០០០នាក់ (ស្រីជាង ៤,០០០នាក់)។

បច្ចុប្បន្ននេះ យើងកំពុងរៀបចំលិខិតបែបបទស្របច្បាប់ ជូនពលករខ្មែរចំនួនប្រមាណ ១៨ ម៉ឺននាក់ ដែលកំពុងរស់នៅ និងធ្វើការនៅក្នុងប្រទេសថៃឡង់ដ៍។

III-ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសក្រីក្រ ដែលខ្សឿនឧស្សាហកម្មទន់ខ្សោយ កសិកម្ម បែបប្រពៃណី កម្លាំងពលកម្មដែលកើនឡើងប្រមាណ ១៧,៦% នោះភាគច្រើនពុំមានជំនាញ ឬមានកម្រិតវប្បធម៌ទាប។ ក្រៅពីការស្រូបយកពីវិស័យសេដ្ឋកិច្ចសេវាកម្ម ដូចជម្រាបខាងលើកម្លាំងពលកម្មសេសសល់ភាគច្រើន ត្រូវវិលត្រឡប់ទៅធ្វើការងារស្រែចំការរបស់គាត់វិញ។ ដូច្នេះ បញ្ហាអត់ការងារធ្វើពុំសូវជះឥទ្ធិពលធ្ងន់ធ្ងរដល់សង្គមជាតិ ដូចជាបណ្តាប្រទេសជឿនលឿនឡើយ។

ទោះបីយ៉ាងនេះក៏ដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានទទួលបេសកកម្មពីរាជរដ្ឋាភិបាលឱ្យអនុវត្តតួនាទី និងភារកិច្ចតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិនេះ ជាពិសេសយុទ្ធសាស្ត្រចតុកោណ ដែលបានចែងក្នុងមុំទី៣ នៃចតុកោណទី៣ គឺ "ការបង្កើតការងារ និងការធានាល័ក្ខខ័ណ្ឌការងារល្អប្រសើរជូនកម្មករនិយោជិត" នឹងត្រូវខិតខំបំពេញភារកិច្ចសំខាន់ៗ មួយចំនួនដូចតទៅ :

១- រួមចំណែកក្នុងការពង្រឹងស្ថិរភាពវិស័យឧស្សាហកម្មកាត់ដេរ និងការបង្កលក្ខណៈដល់ការពង្រីកវិនិយោគនានា តាមរយៈកិច្ចការ ៣ យ៉ាង គឺ :

ក-ការបន្តពង្រឹង និងពង្រីកជំនឿរបស់អ្នកបញ្ជាទិញ និងអ្នកប្រើប្រាស់ចំពោះកិត្តិសព្ទល្អរបស់ទំនិញកាត់ដេរកម្ពុជាដោយ ការជំរុញគ្រប់ភាគីពាក់ព័ន្ធឱ្យគោរពច្បាប់ ស្តីអំពី ការងារ និងអនុសញ្ញានានារបស់អង្គការអន្តរជាតិ ជាពិសេសការបន្តគាំទ្រ និងលើកទឹកចិត្តដល់ដំណើរការយន្តការតាមឃ្លាំមើលល័ក្ខខ័ណ្ឌការងារ និងដោះស្រាយវិវាទការងារដែលកំពុងវិវត្តល្អ។

ខ-ការបន្តពង្រឹង និងពង្រីកជំនឿរបស់អ្នកវិនិយោគដោយ ការដោះស្រាយវិវាទការងារឈរលើមូលដ្ឋានច្បាប់ និងប្រកបដោយសន្តិវិធី ការការពារសិទ្ធិកម្មករនិយោជិតត្រូវដើរទន្ទឹមគ្នានឹងការពារសិទ្ធិអ្នកវិនិយោគ តាមពាក្យស្លោកដ៏ខ្ពង់ខ្ពស់របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីមួយឃ្លាថា "កម្មករនិយោជិត និងថៅកែរោងចក្រត្រូវចាត់ទុករោងចក្រជាឆ្នាំងបាយរួមរបស់ខ្លួន"

គ-ការបន្តសហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំនីតិវិធីចាំបាច់មួយចំនួនដើម្បីបង្ការជាមុន និងសម្រាលការលំបាករបស់រដ្ឋ កម្មករនិយោជិត និងនិយោជកពេលរោងចក្រដួលរលំ ឬបិទទ្វារជាយថាហេតុ។

២- អភិវឌ្ឍមុខរបរនិងពង្រីកការងារធ្វើសំរាប់ប្រជាពលរដ្ឋតាមរយៈកិច្ចការ២យ៉ាងគឺ :

ក-ការយកចិត្តទុកដាក់អភិវឌ្ឍន៍ប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធានាជាបណ្តើរៗ នូវគុណភាព និងបរិមាណពលករជំនាញ ដែលអាចឆ្លើយតបចំពោះតម្រូវការទីផ្សារក្នុង និងក្រៅប្រទេស ឬយកមុខជំនាញទៅប្រកបរបរទទួលទានតាមសហគមន៍ផ្ទាល់។ សូមគូសបញ្ជាក់ជូនអង្គប្រជុំជ្រាបថា ក្រៅពីគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកជន គ្រប់កម្រិត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលគ្រប់គ្រងដោយក្រសួងផ្ទាល់ចំនួន ៣៩ នៅទូទាំងប្រទេស ក្នុងនោះវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ជាមជ្ឈមណ្ឌលថ្មី និងធំជាងគេមានកម្រិតអន្តរជាតិ និងជាផ្លែផ្កានៃទំនាក់ទំនងមិត្តភាពកម្ពុជា-កូរ៉េ។

ខ-ការជំរុញកំណើនបរិមាណនៃការបញ្ជូនពលករយើងទៅប្រទេស ដែលធ្លាប់ទទួលពលករយើងស្រាប់ ដូចជា សាធារណរដ្ឋកូរ៉េ ប្រទេសម៉ាឡេស៊ី ប្រទេសថៃឡង់ដ៏។ ទន្ទឹមនេះ ក្រសួងនឹងយកចិត្តទុកដាក់ពង្រីកទំនាក់ទំនងស្វែងរកទីផ្សារការងារនៅបណ្តាប្រទេសផ្សេងៗទៀត ក្នុងនោះជំរុញការបញ្ជូនពលករខ្មែរទៅ

បណ្តុះបណ្តាល និងធ្វើការនៅប្រទេសជប៉ុន ធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត ប្រទេសកាតា ប្រទេសប្រ៊ូណេ ។ល។

ឈរលើមូលដ្ឋានសភាពការណ៍ លទ្ធផល និងការប្តេជ្ញាចិត្តខាងលើនេះ យើងនៅតែមានសុទិដ្ឋិនិយមចំពោះការវិវត្តន៍រីកចម្រើនរបស់កម្ពុជា ទោះបីយើងត្រូវឆ្លងកាត់ការសាកល្បងដ៏លំបាកស្មុគស្មាញខ្លះក៏ដោយ។

# កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក "ផលប៉ះពាល់លើកសិកម្ម និងឧស្សាហកម្មកាត់ដេរកម្ពុជា"

**លោក សោម អូន**

ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា (CLUF)

## I-សេចក្ដីផ្ដើម :

បន្ទាប់ពីមានការបង្រួបបង្រួមជាតិ និងឆ្លងកាត់ការបោះឆ្នោតសកលជាបន្តបន្ទាប់ ចាប់តាំងពី ឆ្នាំ ១៩៩៣ តាមទំរង់លទ្ធិប្រជាធិបតេយ្យ ប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាព ស្ថិរភាពសង្គម ទទួលបាននូវអាសនៈនៅអង្គការសហប្រជាជាតិ ចូលជាសមាជិកអាស៊ាន ជាពិសេស បានទទួលនូវប្រព័ន្ធភាពអនុគ្រោះ (GSP) ពីសហរដ្ឋអាមេរិក។ ប្រទេសកម្ពុជា បានយកលក្ខខ័ណ្ឌការងារដាក់ភ្ជាប់ជាមួយរង្វាន់ Quota សម្រាប់នាំចេញ និងបានបើកទូលាយដល់អង្គការនានា មានដូចជាអង្គការពលកម្មអន្តរជាតិ (ILO) ផ្នែក ILO/WEP អប់រំចលនាសហជីព, ILO/ Monitoring ឃ្លាំឃ្មើលលក្ខខ័ណ្ឌការងារ (វាយតម្លៃតាមរោងចក្រ/សហគ្រាស និងតំណាងក្រសួងការងារសហរដ្ឋអាមេរិក បានចុះមកវាយតម្លៃអំពីលក្ខខ័ណ្ឌការងារ នេះជារៀងរាល់ ៦ខែម្ដង។ របាយការណ៍វាយតម្លៃតែងតែបានបង្ហាញអំពីភាពល្អប្រសើរនៃលក្ខខ័ណ្ឌការងារ ហើយទទួលបាននូវរង្វាន់ Quota បន្ថែមជារៀងរាល់ឆ្នាំ (មុនឆ្នាំ ២០០៥)។

កត្តាទាំងនេះ ជាចំណុចអាទិភាពសម្រាប់ទាក់ទាញអ្នកវិនិយោគទុនជាតិ និងអន្តរជាតិ និងអ្នកបញ្ជាទិញ (Buyers) មកបណ្ដាក់ទុននៅប្រទេសកម្ពុជា កើតរោងចក្រ/សហគ្រាសចំនួន ៣៩៧ ហើយបានស្រូបយកកម្លាំងពលកម្មប្រមាណម៣0ម៉ឺន នាក់ (ផ្នែកវាយនភ័ណ្ឌកាត់ដេរសម្លៀកបំពាក់ ៣៨២ និងស្បែកជើង១៥)។ កម្មករទាំង នោះ ៩0%ជាស្ត្រី ដែលបានធ្វើចំណាកស្រុកពីស្រែចម្ការមានជីវភាពក្រីក្រ និងពុំសូវមានចំណេះដឹង និងជំនាញច្បាស់លាស់។ ទោះបីប្រាក់ឈ្នួលមិនទាន់មានកម្រិតស្ដង់ដារ ក៏ដោយ ក៏បានកាត់បន្ថយនូវភាពក្រីក្ររបស់ពួកគេបានមួយកម្រិត។ ប្រទេសកម្ពុជាត្រូវបានបញ្ចប់ភាពអនុគ្រោះពន្ធ (GSP) នៅបំណាច់ ឆ្នាំ ២00៤ ហើយបានធ្វើឱ្យវិស័យវាយនភ័ណ្ឌកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើងមានការប្រែប្រួលគួរឱ្យបារម្ភ។

## II- **ការប្រឈមមុខ ការចូលអង្គការពាណិជ្ជកម្មពិភពលោក** (WTO)

### ១-ប្រព័ន្ធច្បាប់ :

ប្រទេសកម្ពុជា មានការប្រឈមមុខជាច្រើន នៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ មានការសន្យាជាច្រើនក្នុងការកំណែទម្រង់ច្បាប់ និងការបង្កើតច្បាប់ថ្មី រួមទាំងការអនុវត្តន៍ច្បាប់ ជាពិសេសត្រូវធ្វើកំណែទម្រង់បន្ថែមទៀត អំពីប្រព័ន្ធតុលាការ។ កម្ពុជាត្រូវការច្បាប់ថ្មីបន្ថែមទៀត វាជាបញ្ហាពិបាកមួយដែលពុំទាន់មានបទពិសោធន៍គ្រប់គ្រាន់ តម្រូវឱ្យមានការជួយពីជំនាញការបរទេសដើម្បីធ្វើសមាហរណកម្ម ច្បាប់ឱ្យស្របទៅនឹងគោលការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក។

### ២-វិស័យកសិកម្ម :

កសិកម្មជាវិស័យអាទិភាពសម្រាប់ប្រទេសកម្ពុជា។ ប្រជាពលរដ្ឋ ៨0% ជាកសិករ។ ប៉ុន្តែការងារកសិកម្មរបស់ប្រទេសកម្ពុជា នៅតែជាលក្ខណៈអភិរក្សនិយម និងបុរាណ ពុំទាន់មានបច្ចេកវិជ្ជាទំនើប និងពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីឈានទៅរកការប្រកួតប្រជែង ជាមួយបណ្តាប្រទេសដែលមានការរីកចម្រើនខ្លាំងក្លានៅក្នុងតំបន់បានទេ។ កន្លងមកក៏ដូចបច្ចុប្បន្ន ការនាំចេញផលិតផលកសិកម្ម ស្ថិតនៅក្នុងកម្រិតតិចតួចនៅឡើយ។

៣-វិស័យកាត់ដេរ :

បន្ទាប់ពីបញ្ចប់ប្រព័ន្ធអនុគ្រោះ (GSP) ពីសហរដ្ឋអាមេរិក និងស្របពេលប្រទេសកម្ពុជា ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) កម្ពុជាទទួលរងនូវផលប៉ះពាល់ដល់និរន្តរភាពការងាររបស់ពលករខ្មែរ និងជាពិសេសវិស័យកាត់ដេរនៅកម្ពុជាត្រូវធ្វើការប្រកួតប្រជែង ទៅលើជំនាញការងារ និងគុណភាពផលិត។

សហរដ្ឋអាមេរិក គឺជាទីផ្សារដ៏ធំបំផុតសម្រាប់ការនាំចេញ នៃផលិតផលកាត់ដេរកម្ពុជា។ ការបញ្ចប់ប្រព័ន្ធភាពអនុគ្រោះ (GSP) ពីសហរដ្ឋអាមេរិក បើគិតពីខែមករា ដល់ខែមិថុនា ឆ្នាំ ២00៥ បានធ្វើឱ្យរោងចក្រ សហគ្រាសបិទទ្វារជាស្ថាពរចំនួន ២0 រោងចក្រ នឹងបាត់បង់ការងារ កម្មករប្រមាណ ២,២0៧ នាក់ និងមានរោងចក្រព្យួរការងារកម្មករចំនួន ៤៨ រោងចក្រ មានកម្មករចំនួន ២,៨៩៤៤ នាក់។ ជាមួយនេះដែរមានរោងចក្រកើតថ្មីចំនួន ២៩ រោងចក្រ តែទទួលកម្មករធ្វើការបានតែចំនួន ៥៤៩៧ នាក់ ប៉ុណ្ណោះ។

ក-អំពីជំនាញការងារ និងគុណភាពផលិត

ទោះបីប្រទេសកម្ពុជាមានកម្លាំងពលកម្មយ៉ាងច្រើនក៏ដោយ ប៉ុន្តែកម្រិតបច្ចេកទេសជំនាញនៅពុំទាន់មានគ្រប់គ្រាន់ ដែលអាចប្រើប្រាស់ម៉ាស៊ីនមានល្បឿនលឿន នៅក្នុងវិស័យឧស្សាហកម្មបានឡើយ។ កម្ពុជាត្រូវខិតខំប្រឹងប្រែងបណ្ដុះបណ្ដាលបុគ្គលិក នូវជំនាញគ្រប់ផ្នែក ដែលអាចសម្រួលឱ្យកម្មករឈានទៅធ្វើការក្នុងឧស្សាហកម្មផ្សេងៗទៀតបាន។ កម្លាំងពលកម្មដែលមានជំនាញច្រើនមុខ និងមានលទ្ធភាពស្វែងរកស្ថិរភាពចំណូល និងសុខភាព។ ស្ថិរភាព និងលើកកំពស់ផ្នែកស្មារតីបែបនេះ និងជួយដល់ការបង្កើនផលិតភាព និងការប្រកួតប្រជែង។

ការប៉ះពាល់លើការងារ គឺមិនមានហេតុផលច្បាស់លាស់ ដែលត្រូវរក្សាគំនិតសុទិដ្ឋិនិយមខ្លាំងក្លានោះទេ។ ដោយមានការចាប់ផ្តើមបច្ចេកវិជ្ជាថ្មី និងការវិនិយោគច្រើនមកក្នុងទីផ្សារកម្ពុជានោះ និងពិតជាមានការប៉ះពាល់ដល់សមត្ថភាពផលិតកម្មនៃផលិតករក្នុងស្រុកជាមិនខាន។ ទន្ទឹមនឹងនេះ អាចកាត់បន្ថយនូវសហគ្រាសរបស់រដ្ឋ ហើយត្រូវដណ្តើមដោយសហគ្រាសឯកជន និងបរទេស។

ថាមពល និងជំនាញផលិតរបស់កម្មករកម្ពុជា មិនទាន់មានលក្ខណៈរឹងមាំ និងមានកម្រិតជាស្តង់ដារនៅឡើយ ដែលជាមូលហេតុធ្វើឱ្យប៉ះពាល់ដល់ការប្រកួតប្រជែងគុណភាពជាមួយផលិតផលបរទេស។ ទៅថ្ងៃមុខប្រទេសកម្ពុជា ត្រូវមានមជ្ឈមណ្ឌលថ្នាក់ជាតិ សម្រាប់ធ្វើការបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ ដល់ប្រជាពលរដ្ឋខ្មែរឱ្យមានកម្រិតជាស្តង់ដារ ដើម្បីឈានទៅរកការប្រកួតប្រជែងជាមួយបណ្តាប្រទេស និងពិភពលោក។

ខ-តម្លៃទីផ្សារនៃផលិតភាព

យើងដឹងហើយថា វិស័យវាយណភណ្ឌកាត់ដេរ សំលៀកបំពាក់ និងស្បែកជើងរបស់ប្រទេសកម្ពុជា គឺជាវិស័យតែមួយគត់ដែលមានសមត្ថភាពនាំចេញផលិតផលប្រកួត

ប្រជែងនៅលើទីផ្សារពិភពលោក។ ប៉ុន្តែអ្វីដែលជាបញ្ហាប្រឈមមុខ នោះគឺបញ្ហាតម្លៃនៃផលិតផលសម្រាប់នាំចេញមានតម្លៃខ្ពស់ជាងបណ្តាប្រទេសមួយចំនួន ដូចជាប្រទេស : ចិន, ឥណ្ឌា ,,,,,,,ជាដើម។

មូលហេតុចម្បង ដែលផលិតផលកាត់ដេររបស់កម្ពុជា មានតម្លៃខ្ពស់ជាងគេនោះគឺ ដោយសារប្រទេសកម្ពុជាមិនទាន់មានវត្ថុធាតុដើមខ្លួនឯង ហើយត្រូវនាំចូលពីបរទេសស្ទើរទាំងស្រុង។ មួយផ្នែកទៀត ដោយសារប្រទេសកម្ពុជា មានការិយាល័យធិបតេយ្យ និងមានបញ្ហាពុករលួយនៅក្នុងវិស័យកាត់ដេរនេះ ដែលបច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងតែធ្វើកំណែទម្រង់យ៉ាងខ្លាំងក្លាយ និងបង្កើតវេទិកាវិស័យឯកជនរៀងរាល់ ៦ ខែម្តង រវាងប្រមុខរាជរដ្ឋាភិបាល និងតំណាងនិយោជក។ ចំណែកឯហេដ្ឋារចនាសម្ព័ន្ធជាតិ ក៏នៅមិនទាន់មានលក្ខណៈប្រកួតប្រជែងនៅឡើយ ដូចជា : ផ្លូវគមនាគមន៍ ការដឹងជញ្ជូន ទឹក ភ្លើង មានតម្លៃខ្ពស់ ដែលមិនទាន់បានទាញអ្នកវិនិយោគទុនឱ្យបានខ្លាំងក្លា នោះទេ។

សរុបមកកត្តាខាងលើនេះ ជាបរិបទដ៏សំខាន់ក្នុងប្រកួតប្រជែង ផ្នែកតម្លៃផលិតភាពនៅលើទីផ្សារពិភពលោក ដែលត្រូវធ្វើកំណែទម្រង់សម្រាប់ទៅអនាគត។

## III- សេចក្តីសន្និដ្ឋាន

និយាយជារួម ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ជាជម្រើសដ៏ត្រឹមត្រូវរបស់ប្រទេសកម្ពុជា។ កម្ពុជាត្រូវតែស្វះស្វែងធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួនឱ្យស្រមជាមួយពិភពលោក តាមរយៈធ្វើសមាហរណកម្មសេដ្ឋកិច្ច។ សម្រាប់រយៈពេលខ្លីកម្ពុជាត្រូវជួបប្រទះនូវការប្រកួតប្រជែងជាមួយប្រទេសដែលមានការអភិវឌ្ឍន៍។ កម្ពុជាត្រូវទទួលនូវការហូរនូវទំនិញគ្រប់ប្រភេទពីបណ្តាប្រទេសនានា។

សម្រាប់រយៈពេលវែងកម្ពុជា នឹងទទួលបាននូវឱកាសល្អប្រសើរនៅក្នុងទីផ្សារពាណិជ្ជកម្ម និងជំនួញនៅពេលដែលប្រទេសកម្ពុជា បើកគោលនយោបាយសេរី វានឹងមានការទាក់ទាញនៃការនាំចូលពីខាងក្រៅ។ ផលិតផលក្នុងស្រុកត្រូវតែតម្រូវតាមទីផ្សារ និងការបង្កើនសមត្ថភាព និងគុណភាពផលិតកម្ម។ ដូច្នេះ ផលិតផលទាំងនោះនឹងមានសមត្ថភាពឈានទៅធ្វើការប្រកួតប្រជែងជាមួយផលិតផលបរទេសបាន។

និយាយដោយឡែកការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក គឺជាការសង្គ្រោះដ៏មានប្រសិទ្ធិភាពបំផុត ចំពោះវិស័យវាយនភណ្ឌកាត់ដេរ បន្ទាប់ពីត្រូវបានបញ្ចប់ភាពអនុគ្រោះពន្ធ (GSP) ដែលប្រទេសកម្ពុជាអាចនាំទំនិញរបស់ខ្លួនទៅលើទីផ្សារជាច្រើននៃប្រទេសដែលជាសមាជិក WTO ។

# ផលវិបាកផ្នែកច្បាប់ និងផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា

**លោក សុក សំអឿន**

សាស្ត្រាចារ្យច្បាប់ មេធាវី និងជានាយកអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

នៅពេលដែលប្រទេសកម្ពុជានៅជាចក្រភពខ្មែរក្នុងសម័យមហានគរ កម្ពុជាសម្បូរទៅដោយសម្បត្តិ វប្បធម៌ អក្សរសាស្ត្រ ស្ថាបត្យកម្ម ក្បាច់ចម្លាក់សិល្បៈ។ ព្រះនាងឥន្ទ្រទេវី ត្រូវបានគេទទួលស្គាល់ថា ជាអ្នកពូកែខាងអក្សរសាស្ត្រ។ ប្រទេសជិតខាងគេមករៀនពីខ្មែរ។ ក៏ប៉ុន្តែ គួរសោកស្តាយអ្វីទាំងនោះត្រូវបានបំផ្លាញ និងឆក់ប្លន់ដោយសង្គ្រាមពីប្រទេសជិតខាង។ រឹតតែគួរឱ្យស្តាយទៅទៀតនោះ របបកម្ពុជាប្រជាធិបតេយ្យបានបំផ្លាញវប្បធម៌ជាតិ បំផ្លាញឯកសារ វប្បធម៌ អក្សរសាស្ត្រ និងមរតកទាំងនោះ ស្ទើរតែទាំងស្រុកក្នុងរបបវាលពិឃាត។ នៅពេលនោះ អ្នកដែលខ្មែរក្រហមរកឃើញមានសៀវភៅជាភាសាខ្មែរក្តី ជាភាសាបរទេសក្តី ត្រូវចាត់ទុកជាអ្នកចេះដឹងជាពួកមូលធន ហើយយកទៅសម្លាប់ចោល។ នាសម័យនោះ អ្នកដែលមានសល់លាក់ទុកសៀវភៅ ត្រូវបង្ខំចិត្តប្រើជាក្រដាសមូរក្រដាសមូរបារីទៅវិញ។

ក្រោយរបបវាលពិឃាត កម្ពុជាមានការខ្វះខាតឯកសារយ៉ាងខ្លាំង។ ក្រោយឆ្នាំ ១៩៩៣ គេចាប់ឃើញមានការបោះពុម្ពសៀវភៅចាស់ៗ ឡើងវិញ និងមានសៀវភៅនិពន្ធថ្មីៗ ប្រសូតកាន់តែច្រើនវិញ។ ប៉ុន្តែ ដោយសារទម្លាប់ឱ្យតម្លៃទៅលើការអានត្រូវបានចុះថយនោះ គេមិនសូវឃើញមានការឱ្យតម្លៃទៅលើស្នាដៃនិពន្ធប៉ុន្មានទេ។ ថែមពី

នោះទៅទៀត គេឃើញមានការលួចបោះពុម្ពចម្លង និងថតចម្លងស្នាដៃរបស់គេស្អេក-ស្កាសយ៉ាងអនាធិបតេយ្យ ដែលធ្វើឱ្យអ្នកដែលអាចមានស្នាដៃនិពន្ធសៀវភៅផ្សេងៗ មានការធ្លាក់ទឹកចិត្តកាន់តែខ្លាំង និងមិនមានទឹកចិត្តរក្សាមរតកចំណេះវិជ្ជាខ្លួនទៅក្នុងសៀវភៅទេ។

ដោយឃើញបែបនេះ រាជរដ្ឋាភិបាលបានប្រឹងប្រែងបង្កើត និងអនុម័តច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៅថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០០៣។ ច្បាប់នេះមានគោលបំណងការពារស្នាដៃ សិទ្ធិរបស់អ្នកនិពន្ធ ផលិតករទាំងឡាយ និងដើម្បីជាការលើកទឹកចិត្តឱ្យកាន់តែមានការចូលរួម និងធ្វើឱ្យមានការរីកចម្រើនលើវិស័យនេះ។ ប៉ុន្តែមកទល់នឹងពេលនេះ តើការចំលងស្នាដៃរបស់គេនៅតែមានដែរឬទេ? បើមានតើមានមនុស្សប៉ុន្មាននាក់ហើយ ដែលត្រូវមានទោសដោយសារច្បាប់នេះ?

ពិតមែនតែការដោះស្រាយបញ្ហា ការធ្វើច្បាប់នោះគឺជាចំណុចជាអាទិភាពមួយ ហើយការគ្រាន់តែមានច្បាប់វាមិនគ្រប់គ្រាន់នោះទេ វាត្រូវការឱ្យមានការអនុវត្តន៍ច្បាប់នោះឱ្យមានប្រសិទ្ធិភាពថែមទៀត។ ប្រសិនបើមិនមានការអនុវត្តន៍ច្បាប់ណាមួយនោះទេ គេត្រូវពិនិត្យមើលថាតើមកពីហេតុអ្វី? តើមកពីច្បាប់ខ្លួនឯងនៅមានការខ្វះខាតដែលធ្វើឱ្យអ្នកអនុវត្តន៍មិនអាចអនុវត្តបាន? តើមកពីខ្វះយន្តការអនុវត្តន៍ដែលមានប្រសិទ្ធិភាព? ឬ តើមកពីអ្នកអនុវត្តន៍ខ្វះសមត្ថភាព?

និយាយរួម ភាពអប្រសិទ្ធិភាពក្នុងការអនុវត្តន៍អាចពីកត្តាច្រើនយ៉ាងដែលកត្តាសំខាន់ គឺមានបីដែលបានរៀបរាប់មកខាងលើ។ មានច្បាប់ល្អ វាហាក់បីដូចជាផ្ទះរបស់អ្នកដែលមានម៉ាស៊ីនត្រជាក់ល្អ មានទូទឹកកល្អ និងសម្ភារៈអេឡិចត្រូនិចល្អដូច្នោះដែរ។ របស់ល្អៗ ទាំងនោះនឹងទៅជាឥតប្រយោជន៍ ឬទៅជាខូចទៅវិញ ប្រសិនបើជាងតខ្សែមិនប្រយ័ត្ន ឬមិនល្អ។ ពោលគឺយើងត្រូវការប្រព័ន្ធអគ្គិសនីល្អ។ នៅក្នុងបញ្ហាច្បាប់ ច្បាប់

ស្តីពីនីតិវិធី គឺជាប្រព័ន្ធដែលអាចធ្វើច្បាប់អាចនឹងអនុវត្តន៍ ដោយមានប្រសិទ្ធិភាពបាន។ បច្ចុប្បន្ននេះ យើងមានតែច្បាប់ ស្តីពី នីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជាឆ្នាំ ១៩៩៣ យើងមាននីតិវិធីខ្លះចែងនៅក្នុងច្បាប់អ៊ុនតាក់ដែរ តែច្បាប់នោះមិនត្រូវបានតុលាការយកចិត្តទុកដាក់នោះទេ។ យើងមិនទាន់មានច្បាប់ ស្តីពី នីតិវិធីរដ្ឋប្បវេណីនោះទេ ពោលគឺយើងយកផ្នែកខ្លះពីច្បាប់ព្រហ្មទណ្ឌមកប្រើ ដែលពេលខ្លះនាំឱ្យមានការរិះគន់ពីប្រជាពលរដ្ឋ។ ដោយឃើញថាមានការខ្វះខាត និងមានការរិះគន់យ៉ាងច្រើនបែបនេះ ហើយបានជារាជរដ្ឋាភិបាលប្រឹងប្រែងធ្វើច្បាប់ទាំងពីរនេះ គឺនីតិវិធីព្រហ្មទណ្ឌ និងនីតិវិធីរដ្ឋប្បវេណីដោយឱ្យជំនាញការបារាំងជួយខាងនីតិវិធីព្រហ្មទណ្ឌ ហើយជំនាញការជប៉ុនជួយខាងនីតិវិធីរដ្ឋប្បវេណី។ ជាធម្មតាបើជនជាតិណាគេជួយព្រៀងហើយនោះ ប្រាកដជាច្បាប់នោះលំអៀងទៅប្រព័ន្ធច្បាប់របស់អ្នកព្រៀងហើយ។ ហើយប្រសិនបើ ប្រព័ន្ធទាំងពីរព្រហ្មទណ្ឌ និងរដ្ឋប្បវេណី វាផ្ទុយគ្នា ឬមានបដិភាពនឹងគ្នានោះ នោះក៏ជាបញ្ហាដែរ។ ដោយសារតែហេតុយ៉ាងដូច្នេះហើយ បានយើងជាអ្នកច្បាប់ និងជាអ្នកអនុវត្តន៍ផ្ទាល់បានជូនយោបល់ថា :

- សូមឱ្យអ្នកជំនាញបរទេសចូលមកជួយព្រៀងច្បាប់ខ្មែរ ដោយផ្អែកទៅលើកត្តាសង្គម និងស្ថានភាពជាក់ស្តែងនៅស្រុកខ្មែរ មិនត្រូវចម្លងច្បាប់របស់ខ្លួនទាំងស្រុងមកឱ្យខ្មែរអនុវត្តន៍នោះទេ ។
- សូមឱ្យអ្នកច្បាប់ទាំងពីរ សិក្សា និងពិភាក្សាគ្នាដោះស្រាយ ប្រសិនបើមានចំណុចណាមានទំនាស់នឹងគ្នា។

ទោះជាមានច្បាប់នីតិវិធីល្អហើយក៏ដោយ កាលបើមិនមានការប្រគល់តួនាទីច្បាស់លាស់ដល់ស្ថាប័នណាជាអ្នកអនុវត្តន៍នោះទេ និងមិនមានការផ្សព្វផ្សាយដល់មន្ត្រីអនុវត្តន៍ច្បាប់នោះទេ ច្បាប់នោះក៏មិនអាចអនុវត្តន៍បានដែរ ។

ភាពអប្រសិទ្ធិភាព នៃការអនុវត្តន៍ច្បាប់នៅមានកត្តាជាច្រើនទៀត ដូចជាអំណាចចាប់ខ្លួន ភាពច្របូកច្របល់នៃអំណាចស៊ើបអង្កេតរបស់នរគបាល នគរបាលយុត្តិធមិ ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត កង្វះនៃច្បាប់ភស្តុតាង ។ ឧទាហរណ៍ ក្នុងរឿងព្រហ្មទណ្ឌ ប្រសិនបើមិនមែនជាបទល្មើសជាក់ស្តែងទេ នគរបាលច្រើនតែរង់ចាំទាល់តែមានបណ្តឹងពីជនរងគ្រោះ ។ ទម្លាប់នេះអាចទឹងធ្វើច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា មិនអាចនឹងអនុវត្តន៍បានដែរ ។

សរុបសេចក្តីទៅ យល់ថាកាលបើមានច្បាប់កម្មសិទ្ធិបញ្ញាហើយ គឺជាបំពេញលក្ខខ័ណ្ឌរបស់អង្គការពាណិជ្ជកម្មពិភពលោក ហើយនោះជាការមិនត្រឹមត្រូវនោះទេ ។ វាគ្រាន់តែជាកត្តាមួយប៉ុណ្ណោះ ។ គឺត្រូវការឱ្យមានការអនុវត្តន៍ឱ្យមានប្រសិទ្ធិភាពទៀតផង ។ ដូច្នេះ ជាទស្សនៈខ្ញុំផ្ទាល់ ច្បាប់ ស្តីពី នីតិវិធីទាំងពីរគឺព្រហ្មទណ្ឌ និងរដ្ឋប្បវេណីសំខាន់ណាស់ ។ ហើយដើម្បីឱ្យច្បាប់ទាំងពីរនេះមានប្រសិទ្ធភាពច្បាប់ ស្តីពី ការចាត់តាំងតុលាការក៏ជាការសំខាន់ដែរ ព្រោះបើតាមសេចក្តីព្រៀងច្បាប់ទាំងពីរនេះប្រព័ន្ធតុលាការបច្ចុប្បន្នត្រូវតែផ្លាស់ប្តូរ ។ ក្នុងចំណោមច្បាប់ទាំងពីរនេះ បើច្បាប់ណាអនុម័តច្បាប់ដែលអនុម័តក្រោយត្រូវកែឱ្យសមស្របទៅនឹងច្បាប់មុន ។ ដោយហេតុយ៉ាងនេះយើងឃើញថា នៅពេលដែលដឹងថាច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី ដែលព្រៀងដោយអ្នកជំនាញច្បាប់ជប៉ុនត្រូវបានបញ្ជូនទៅរដ្ឋសភា ហើយនោះភាគីបារាំងបានទាមទារឱ្យពិនិត្យប្រៀបធៀបច្បាប់ទាំងពីរជាមុនសិន ។

តែទោះជាយ៉ាងណាក៏ដោយ យើងនៅតែសង្ឃឹមថា តាមរយៈរបបលទ្ធិប្រជាធិបតេយ្យ កម្ពុជានឹងមានការរីកចម្រើន ព្រមគ្នាលើវិស័យគោរពសិទ្ធិមនុស្ស និងសេដ្ឋកិច្ច។

# ផ្នែកទី ២
# សុន្ទរកថា ក្នុងកិច្ចប្រជុំគ្មមូល

# តើមានផលវិបាកខាងច្បាប់ និងគោលនយោបាយអ្វីខ្លះ ដល់សមាជិកភាពរបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក?

**លោក តាន់ យុវរដ្ឋ**

**អនុប្រធានការិយាល័យសេវាកម្ម**

**នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម**

## សារគារ

កម្ពុជាបានដាក់ពាក្យចូលអង្គការនេះនៅឆ្នាំ ១៩៩៤ និងត្រូវបានអនុញ្ញាតជាផ្លូវការ ឱ្យចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០០៣ ក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រី អង្គការពាណិជ្ជកម្មពិភពលោកលើកទី ៥ ប្រព្រឹត្តឡើងនៅក្រុងកាន់គូនប្រទេសម៉ិកស៊ិក។ កាលបរិច្ឆេទចុងក្រោយសម្រាប់ដំណឹងទៅអង្គការពាណិជ្ជកម្មពិភពលោកអំពីការឱ្យសច្ចាប័នរបស់រដ្ឋសភាគឺ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៤។ ប៉ុន្តែ ដោយមានការជាប់គាំងខាងនយោបាយ កាលបរិច្ឆេទនេះត្រូវបានបន្តរហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤។ ចុងក្រោយបញ្ចប់នេះត្រូវបានរដ្ឋសភាផ្តល់សច្ចាប័ន នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ និង ដោយព្រឹទ្ធសភានៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០៤។ សម្តេចប្រមុខរដ្ឋស្តីទី បានចុះហត្ថលេខាលើព្រះរាជក្រមនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៤ និងឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានចុះហត្ថលេខាលើលិខិតទុព្វករណ៍នៅ

ថ្ងៃដូចគ្នានេះដែរ ។ ហើយបញ្ជូនទៅហ្សឺណែវ និងបានទទួលដោយអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤។ មួយខែក្រោយមកកម្ពុជាបានក្លាយជាសមាជិកពេញសិទ្ធិទី ១៤៨ របស់អង្គការពាណិជ្ជកម្មពិភពលោក ។

ក្រោយពីព្រះរាជាណាចក្រកម្ពុជា បានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកជាផ្លូវការ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ មក កម្ពុជាត្រូវបំពេញនូវកាតព្វកិច្ចជាច្រើនរបស់អង្គការពាណិជ្ជកម្មពិភពលោក ក្នុងនោះក៏មានល័ក្ខខ័ណ្ឌនៃការកសាងច្បាប់ និងគោលនយោបាយនានា ដើម្បីគាំទ្រដល់សេរីភាវូបនីយកម្មពាណិជ្ជកម្មនៅកម្ពុជាផងដែរ ។

- **ច្បាប់ចំនួនប្រមាណ ៤០ ដែលត្រូវកសាងថ្មី ឬ ធ្វើវិសោធនកម្ម**
- **ធនធានមនុស្សដែលត្រូវបំពេញការងារនេះ**

កិច្ចព្រមព្រៀង WTO មានចំនួនជាង២០ កិច្ចព្រមព្រៀង ហើយមានលក្ខណៈស្មុគស្មាញ ។ ដូច្នេះ ទាមទារឱ្យមានការរៀបចំធនធានមនុស្សដែលមានសមត្ថភាព និងប្រសិទ្ធិភាពការងារដើម្បីទទួលខុសត្រូវលើកិច្ចព្រមព្រៀងនីមួយៗ មនុស្សម្នាក់មិនអាចទទួលខុសត្រូវលើកិច្ចព្រមព្រៀងច្រើនបានទេ (ផ្ទុយទៅវិញនៅប្រទេសមួយចំនួនមនុស្ស ៣-៤ នាក់ ទទួលបន្ទុកលើកិច្ចព្រមព្រៀង) បើនិយាយទាំងលើមូលដ្ឋានចំណេះឯកទេសប្រតិបត្តិទាំងលើការយល់ដឹងអំពី "ខ" នានា និងអត្ថន័យនៃកិច្ចព្រមព្រៀងទាំងនោះ ។ (កិច្ចព្រមព្រៀងពុំមានចំណងផ្សារភ្ជាប់គ្នាល្អ ពាក្យពេចន៍ឃ្លាប្រយោគខ្លះមានន័យ មិនច្បាស់លាស់ ពាំត្រណោត ដោយហេតុថា វាត្រូវបានគេ ច្របាច់បញ្ចូលគ្នាពីប្រភពជាច្រើនខុសគ្នា និងធ្វើឡើងក្នុងសំពាធពេលវេលា អ្នកច្បាប់ខ្លះ និយាយថា មកពីពុំបានឆ្លងកាត់អ្នកច្បាប់ពិនិត្យកែសម្រួលជាមុនសិន ទើបមានបញ្ហានៃការបកស្រាយរហូតមកដល់សព្វថ្ងៃនេះ ។)

## ១-ការងារសម្របសម្រួលរវាងអន្តរក្រសួង

នៅមានភាពមិនចុះសំរុងគ្នា ដោយសារកង្វះធនធានជំនាញនៅតាមស្ថាប័ននីមួយៗ និងពេលខ្លះបណ្តាលមកពីជំនាញការ ដែលអញ្ជើញមកធ្វើច្បាប់ពុំមានការយល់ដឹងអំពីកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកឱ្យបានស៊ីជម្រៅ។ ដូច្នេះត្រូវពិគ្រោះជាមួយក្រសួងជំនាញដែលមានការយល់ដឹងច្បាប់និងបញ្ញត្តិ WTO ដើម្បីជួយពិនិត្យលើភាពស្របគ្នាជាមួយច្បាប់និងបញ្ញត្តិ WTO ទាំងនោះ ដែលអាចជាការចំណេញពេលវេលា និងនីតិវិធីមុននឹងបញ្ចូលទៅពិភាក្សាគណៈរដ្ឋមន្ត្រី។

## ២-ពេលវេលាដែលត្រូវធ្វើច្បាប់

ច្បាប់នីមួយៗត្រូវការពេលវេលាសមស្របដើម្បីកសាង និងឆ្លុះបញ្ចាំងពីតម្រូវការពិតប្រាកដខាងសេដ្ឋកិច្ច និងសង្គមកិច្ច ដោយត្រូវមានការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយវិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត ។ល។ ប៉ុន្តែ ពេលវេលាដែលត្រូវបំពេញតាមការសន្យារបស់កម្ពុជាក្នុងអង្គការ WTO ក្នុងការកសាងច្បាប់មានរយៈពេលខ្លី។

នីតិវិធីដែលត្រូវឆ្លងច្បាប់វែង តាមពិតវាពុំមែនជាការអាក្រក់ទេ ដែលនិយាយយ៉ាងដូច្នេះ ព្រោះថាច្បាប់នីមួយៗ ទាមទារនូវការពិគ្រោះយោបល់ច្រើន មុននឹងបញ្ជូនទៅកាន់រដ្ឋសភា និងចុងក្រោយទៅកាន់ព្រឹទ្ធសភា ដើម្បីធ្វើការអនុម័តតាមនីតិវិធី។ ច្បាប់ និងបទបញ្ញត្តិចាស់ទាំងឡាយណាដែលផ្ទុយពីគោលការណ៍ និងច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោកនឹងត្រូវធ្វើវិសោធនកម្ម។

ច្បាប់ដែលត្រូវកសាងថ្មី ត្រូវតែគោរពតាមបទបញ្ញត្តិ និងគោលការណ៍នានានៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ជាពិសេសគោលការណ៍ធំៗ ដែលត្រូវតែពិចារណានៅពេលកសាងច្បាប់នីមួយៗមាន :

**ក-គោលការណ៍តម្លាភាព :** ធានាឱ្យមានការផ្សព្វផ្សាយច្បាប់ និងបទបញ្ញត្តិជាសាធារណៈ។ កម្ពុជាសន្យានៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកថា រាល់ច្បាប់ និងបទបញ្ញត្តិនានាត្រូវធ្វើការចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការរយៈពេល១ខែ មុននឹងច្បាប់នោះចាប់ផ្ដើមមានប្រសិទ្ធិភាពអនុវត្ត។

**ខ-គោលការណ៍មិនរើសអើង :** មានគោលការណ៍មិនរើសអើងចម្បង ២ នៅក្នុងច្បាប់ អ.ព.ព. : កាតព្វកិច្ចអនុវត្តប្រព្រឹត្តិកម្ម MFN និងកាតព្វកិច្ចប្រព្រឹត្តិកម្មជាតិ។

ក្នុងន័យសាមញ្ញកាតព្វកិច្ចប្រព្រឹត្តិកម្ម MFN ជាការហាមឃាត់ប្រទេសមួយមិនឱ្យធ្វើការរើសអើងប្រឆាំងនឹងប្រទេសផងគ្នាឯទៀត។ ឧទាហរណ៍-នៅក្នុងប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោកមួយមានផលិតផលដូចគ្នា ឬស្រដៀងគ្នានាំចូលមកពីប្រទេសពីរ ក្នុងករណីនេះប្រទេសម្ចាស់ផ្ទះត្រូវយកពន្ធ ដូចគ្នាលើទំនិញមកពីប្រទេសទាំងពីរ ហើយប្រសិនបើមានការផ្ដល់ល័ក្ខខ័ណ្ឌអនុគ្រោះដល់ទំនិញរបស់ប្រទេសមួយប្រទេសមួយទៀត ត្រូវតែទទួលបានល័ក្ខខ័ណ្ឌនោះដូចគ្នា។

បទបញ្ញត្តិគន្លឹះនៃ GATT ១៩៩៤ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ នោះគឺមាត្រា ១ ស្ដីពី កាតព្វកិច្ច MFN និងបទបញ្ញត្តិគន្លឹះនៅក្នុង GATS គឺមាត្រា ២ ស្ដីពី MFN។

គោលបំណងចម្បង MFN នៃមាត្រា ១ នៃ GATT 1994 គឺ : ដើម្បីធានាឱ្យមាន *ការលាភនុវត្តភាពស្មើគ្នា* ទាំងការនាំចូល ទាំងការនាំចេញទៅកាន់ប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់។

*មានសំណួរបីដែលត្រូវឆ្លើយ ដើម្បីកំណត់ថា មានការរំលោភលើកាតព្វកិច្ច MFN នៃមាត្រាI:1 ឬអត់ :*

*វិធានការនោះផ្តល់នូវប្រយោជន៍ "ពាណិជ្ជកម្ម" នៃប្រភេទដែលមានចែងក្នុងមាត្រា I:1 ឬអត់ផលិតផលនោះជាផលិតផលដែលមានលក្ខណៈ "ដូចគ្នា" ឬអត់ និងផលប្រយោជន៍នោះត្រូវបានផ្តល់ "ជាបន្ទាន់ និងគ្មានល័ក្ខខ័ណ្ឌ" ដល់ផលិតផលទាំងអស់ដែលដូចគ្នា ឬអត់ ក្នុងករណីនៃប្រព្រឹត្តិកម្ម MFN នៅក្រោម GATT 1994 គោលបំណងចម្បងរបស់ប្រព្រឹត្តិកម្ម MFN នៃមាត្រា ២:១ នៃ GATS គឺ : ដើម្បីធានានូវសមភាពសម្រាប់ការផ្តល់សេវាកម្ម និងអ្នកផ្តល់សេវាកម្មទាំងអស់នៃប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។*

*មានសំណួរបីដែលត្រូវឆ្លើយ ដើម្បីកំណត់ថា តើវិធានការនោះរំលោភលើកាតព្វកិច្ចប្រព្រឹត្តិកម្ម MFN នៅក្នុងមាត្រា ២:១ ឬយ៉ាងណា? :*
*(១)-វិធានការនោះជះឥទ្ធិពលទៅលើពាណិជ្ជកម្មសេវាកម្មឬអត់, (២)-សេវាកម្ម ឬអ្នកផ្តល់សេវាដែលពាក់ព័ន្ធនោះជាសេវាកម្ម ឬអ្នកផ្តល់សេវាដែលមានលក្ខណៈដូចគ្នា ឬអត់ និង (៣)-តើមានប្រព្រឹត្តិកម្មអនុគ្រោះតិចជាងចំពោះសេវាកម្ម ឬអ្នកផ្តល់សេវាកម្មរបស់ប្រទេសជាសមាជិកឬទេ?*

ចំណែកឯ កាតព្វកិច្ចប្រព្រឹត្តិកម្មជាតិហាមឃាត់ប្រទេសមួយមិនឱ្យធ្វើការរើសអើងប្រឆាំងនឹងផលិតផលរបស់ប្រទេសមួយទៀត នៅក្នុងទីផ្សារក្នុងស្រុក។ ឧទាហរណ៍ ផលិតផលសំណើ្លកសៀងរបស់ប្រទេស "ក" អាចនាំចូលមកលក់ក្នុងប្រទេស "ខ" ដោយ

ចំហ ក៏ប៉ុន្តែ ត្រូវបានគេកាត់បន្ថយភាពប្រកួតប្រជែងរបស់វា តាមរយៈការអនុវត្តន៍ការយកពន្ធផ្សេងៗ ដែលធ្វើឱ្យទំនិញនោះបន្ថែមតម្លៃរបស់ខ្លួន ប៉ុន្តែមិនមានការយកពន្ធបែបនេះលើផលិតផលដូចគ្នា ដែលផលិតនៅក្នុងស្រុកទេ។

គោលការណ៍ប្រព្រឹត្តិកម្មជាតិនេះ គឺដើម្បីធានាឱ្យមានសមភាពរវាងផលិតផល និងសេវាដែលផលិតក្នុងស្រុក និង ផលិតផលនិងសេវារបស់បរទេស។

គោលការណ៍ប្រព្រឹត្តិកម្មជាតិមានចែងនៅក្នុង "ខ" នានានៃកិច្ចព្រមព្រៀងសំខាន់បីរបស់ WTO គឺ កិច្ចព្រមព្រៀងពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មទំនិញ, ពាណិជ្ជកម្មសេវាកម្ម, និងកម្មសិទ្ធិបញ្ញា : (i) GATT: មាត្រា ៣; (ii) GATS: មាត្រា ១៧; (iii) TRIPS: មាត្រា ៣។

គោលការណ៍ប្រព្រឹត្តិកម្មជាតិនេះ ក៏ឃើញមាននៅក្នុងកិច្ចព្រមព្រៀងផ្សេងៗទៀត ដែលបង្កើតជាឧបសម្ព័ន្ធ I A នៃកិច្ចព្រមព្រៀង WTO ដូចជា កិច្ចព្រមព្រៀងស្តីពី *របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម* និងកិច្ចព្រមព្រៀង ស្តីពី *វិធានការអនាម័យ* ជាដើម។ គោលការណ៍នេះ ក៏ជាមូលដ្ឋាននៃកិច្ចព្រមព្រៀងពហុភាគីស្ម័គ្រចិត្ត ស្តីពីលទ្ធកម្មសាធារណៈផងដែរ។

*គោលបំណងចម្បងនៃកាតព្វកិច្ចប្រព្រឹត្តិកម្មជាតិនៃមាត្រា ៣ នៃ* GATT 1994 *គឺដើម្បីចៀសវាងការការពារ និយមក្នុងការប្រើប្រាស់នូវពន្ធខាងក្នុង និង វិធានការច្បាប់ដទៃទៀត។ ដូចដែលមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៣:១ គោលបំណងនៃមាត្រា ៣ គឺដើម្បីធានាវិធានការខាងក្នុង "មិនត្រូវបានអនុវត្តចំពោះផលិតផលក្នុងស្រុក និងនាំចូលដើម្បីជួយការពារផលិតកម្មក្នុងស្រុកឡើយ"។ ចុងបញ្ចប់មាត្រានេះតម្រូវឱ្យប្រទេសសមាជិក* WTO *ផ្តល់នូវសមាសភាពសម្រាប់ល័ក្ខខ័ណ្ឌប្រកួតប្រជែង*

សម្រាប់ផលិតផលនាំចូលធៀបនឹងផលិតផលក្នុងស្រុក ។ លក្ខខណ្ឌសម្រេចនៃពន្ធក្នុងស្រុក ជាមួយនឹងកាតព្វកិច្ចប្រព្រឹត្តិកម្មជាតិនៃមាត្រា ៣:២ ប្រយោគទីមួយនៃ GATT 1994 តម្រូវឱ្យមានការពិនិត្យមើលថាតើ :

៣- វិធានការនោះគឺជា "ពន្ធក្នុងស្រុក" ឬទេ

៤- ផលិតផលនាំចូល និងផលិតផលក្នុងស្រុកគឺ "ដូចគ្នា" និង

៥- ផលិតផលនាំចូលមិនត្រូវបានយកពន្ធលើសផលិតផលក្នុងស្រុកទេ

មាត្រា ៣:២ ប្រយោគទី ២ ក៏ពាក់ព័ន្ធនឹងប្រព្រឹត្តិកម្មជាតិ នៃពន្ធខាងក្នុងដែរ ប៉ុន្តែ សម្លឹងមើលដល់ "ប្រភេទផលិតផលទូលាយជាងមុន" ជាងក្នុងមាត្រា ៣:២ ប្រយោគទី១ ។ វាមិនអនុវត្តតែចំពោះ " ផលិតផលដូចគ្នា" ទេ ប៉ុន្តែចំពោះ "ផលិតផលប្រកួតប្រជែងគ្នាដោយផ្ទាល់ ឬអាចជំនួសគ្នាបាន" ផងដែរ ។ មាត្រា ៣:២ ប្រយោគទី២ មានចែងពីលក្ខខណ្ឌសម្រេចផ្សេងពីនេះ ដែលតម្រូវឱ្យមានការពិនិត្យមើលថាតើ :

៦- វិធានការនោះជា "ពន្ធក្នុងស្រុក"

៧- ផលិតផលនាំចូល និងក្នុងស្រុកមានការប្រកួតប្រជែងគ្នាដោយផ្ទាល់ ឬអាចជំនួសគ្នាបាន

៨- ផលិតផលទាំងនេះពុំត្រូវបានអនុវត្តក្នុងគោលបំណងការពារផលិតកម្មក្នុងស្រុក

កាតព្វកិច្ចប្រព្រឹត្តកម្មជាតិនៃមាត្រា ៣ មិនត្រឹមតែនិយាយអំពីពន្ធខាងក្នុងប៉ុណ្ណោះទេ ប៉ុន្តែអំពីបទបញ្ញត្តិក្នុងស្រុកផងដែរ ។ ប្រព្រឹត្តិកម្មជាតិ ចំពោះបទបញ្ញត្តិខាងក្នុងត្រូវបានចែងនៅក្នុងមាត្រា ៣:៤ ។ ដើម្បីកំណត់ថា តើវិធានការ

មួយស្របគ្នាជាមួយកាតព្វកិច្ចប្រព្រឹត្តិកម្មនៃមាត្រា ៣:៤ ឬអត់ គេត្រូវពិនិត្យមើលលើលក្ខខណ្ឌបីថាតើ :

៩- វិធានការនោះគឺជាច្បាប់ បទបញ្ញត្តិ ឬលក្ខខណ្ឌតម្រូវដែលមានចែងក្នុងមាត្រា ៣:៤ ឬទេ

១០- ផលិតផលនាំចូល និងផលិតផលក្នុងស្រុកជាផលិតផល "ដូចគ្នា"

១១- ផលិតផលនាំចូលត្រូវបានផ្ដល់ប្រព្រឹត្តិកម្មអនុគ្រោះតិចជាង ឬអត់

កាតព្វកិច្ចប្រព្រឹត្តិកម្មជាតិចំពោះវិធានការដែលជះឥទ្ធិពលដល់ពាណិជ្ជ-កម្ម សេវាកម្មមានចែងក្នុងមាត្រា ១២ នៃ GATS ។ ប្រព្រឹត្តិកម្មជាតិនៅក្រោមមាត្រា១២ មានភាពខុសគ្នាពីប្រព្រឹត្តិកម្មជាតិនៅក្រោមមាត្រា ៣ នៃ GATT 1994 ។ សម្រាប់ពាណិជ្ជកម្មទំនិញប្រព្រឹត្តិកម្មជាតិ ត្រូវអនុវត្តលើពាណិជ្ជកម្មទាំងអស់ ។ ចំណែកឯប្រព្រឹត្តិកម្មជាតិសម្រាប់សេវាកម្ម អនុវត្តតែចំពោះសមាជិក អ.ព.ព ណាដែលបានធ្វើការសន្យាដោយខ្លួនឯងក្នុងការផ្ដល់នូវ "ប្រព្រឹត្តិកម្មជាតិ" ដល់សេវាកម្មតាមវិស័យណាមួយតែប៉ុណ្ណោះ ។

ជារឿយៗ ការសន្យាប្រព្រឹត្តិកម្មជាតិទាំងនោះ ជាកម្មវត្ថុនៃការដាក់លក្ខខណ្ឌ និងការកំហិតផ្សេងៗ លើទំហំនៃការសន្យានោះ ។ នៅពេលដែលសមាជិកបានធ្វើការសន្យាតាមវិស័យនីមួយៗក្នុងការផ្ដល់ "ប្រព្រឹត្តិកម្មជាតិ" វាត្រូវបំពេញកាតព្វកិច្ច "ប្រព្រឹត្តិកម្មជាតិ" នៃមាត្រា ១៧ នៃGATS ។

ដើម្បីធ្វើការកំណត់ថា តើវិធានការនោះស្របជាមួយកាតព្វកិច្ចជាតិក្នុងមាត្រា ១៧ ឬអត់ គេមានលក្ខខណ្ឌបីដើម្បីធ្វើការកំណត់ ថាតើ :

- វិធានការនោះជះឥទ្ធិពលទៅលើពាណិជ្ជកម្មសេវាកម្មឬទេ

- *សេវាកម្មឬអ្នកផ្គត់ផ្គង់សេវាកម្មបរទេស និងក្នុងស្រុកមានល័ក្ខខ័ណ្ឌ "ដូចគ្នា" ឬទេ និងសេវាកម្ម ឬអ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបានផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះតិចជាងឬទេ ។*

*កាតព្វកិច្ចមិនរើសអើងនៃមាត្រា ១:១, ៣:២ ប្រយោគទី១ និង មាត្រា ៣:៤ នៃមាត្រា ២:១ និងមាត្រា ១៧:១ នៃ GATS អនុវត្តតែទៅលើផលិតផលសេវាកម្ម ឬសេវាករដែលមានលក្ខណៈ "ដូចគ្នា" ប៉ុណ្ណោះ ។ ដូចដែលចៅក្រមសាលាឧទ្ធរណ៍ បានធ្វើកំណត់សំគាល់លើអត្ថសញ្ញាណនៃពាក្យផលិតផល "ដូចគ្នា" មានលក្ខណៈដូចគ្នាទៅនឹងអាក់ក័រដេអុង ដែលទំហំរបស់វាអាចប្រែប្រួលអាស្រ័យលើបញ្ញត្តិ ដែលពាក្យនោះត្រូវបានគេបកស្រាយ ។*

ដូច្នេះ យើងឃើញថាមានសំពាធច្រើន ទាំងធនធានមនុស្ស ហិរញ្ញវត្ថុ និងពេលវេលា ក៏ដូចជាការសម្របសម្រួលក្នុងការកសាងច្បាប់នីមួយៗ កុំថាឡើយប្រទេសកម្ពុជា សូម្បីតែនៅប្រទេសជឿនលឿន នៅលោកខាងលិចដែលមានធនធានច្រើន ក៏ត្រូវចំណាយពេលវេលាយូរបង្គួរដែរ ដើម្បីកសាងច្បាប់និងបទបញ្ញត្តិនីមួយៗ ។ ប៉ុន្តែ បើយើងមិនធ្វើពលិកម្មទេ ប្រទេសយើងនឹងនៅតែពុំមានច្បាប់ទំនើបស្របតាមស្តង់ដារអន្តរជាតិ ដើម្បីជាមូលដ្ឋានសម្រាប់ធានា និងទាក់ទាញវិនិយោគិន និងធុរជនមកបណ្តាក់ទុន និងធ្វើពាណិជ្ជកម្ម និងផ្តល់សេវានៅកម្ពុជាឡើយ ។ **ខ្ញុំនៅចាំបានប្រសាសន៍របស់អ្នកចរចាពាណិជ្ជកម្មម្នាក់ដែលមានប្រសាសន៍ថា ប្រសិនបើកម្ពុជាខិតខំជំរុញការកសាង និងកែទម្រង់ច្បាប់ ទោះបីជាមានការយឺតយ៉ាវ ក៏ប្រទេសសមាជិកដទៃទៀតនឹងមានសមានចិត្តជួយគាំទ្រ និងមានការយោគយល់លើកលែងតែកម្ពុជាមិនធ្វើអ្វីសោះ ។**

ចំណែកខាងគោលនយោបាយពាណិជ្ជកម្មវិញ យើងត្រូវតែមានការប្រុងប្រយ័ត្នជាងមុនដោយហេតុថា យើងជាសមាជិក អ.ព.ព យើងត្រូវអនុវត្តគោលការណ៍ MFN

ប្រសិនបើយើងផ្តល់ការអនុគ្រោះអ្វីមួយ យើងត្រូវពិចារណាឱ្យបានម៉ត់ចត់អំពីលទ្ធភាពដែលអាចផ្តល់ផលចំណេញដល់សមាជិកផ្សេងទៀត ដែលអាចជាគូរប្រជែងដ៏ស្រួចស្រាលជាមួយយើង។ គោលនយោបាយជាច្រើននឹងត្រូវពិនិត្យសើរើឡើងវិញ ដើម្បីឱ្យស្របតាមយុគសម័យថ្មី និងសមស្របតាមការអភិវឌ្ឍន៍នៃសភាពការណ៍ពាណិជ្ជកម្ម ដែលប្រែប្រួលជានិច្ចនៅក្នុងយុគសម័យសាកលភាវូបនីយកម្មនេះ។

## សេចក្តីសន្និដ្ឋាន

ទោះបីជាយើងមានការឡើយបាត់ក្នុងការធ្វើច្បាប់ក៏ដោយ ក៏ការខិតខំរបស់យើងនឹងមិនឥតប្រយោជន៍ឡើយ : យើងមានច្រកចូលទីផ្សារចំនួន ១៤៧ ប្រទេស : កាលណាយើងមានផលិតផល (ហើយបំពេញបានតាមល័ក្ខខ័ណ្ឌតម្រូវនានារបស់ប្រទេសនាំចូល) គឺយើងមានទីផ្សារដែលបើកទ្វាររួចជាស្រេច ដោយប្រទេសទាំងនោះគ្មានលេសមិនសមរម្យណាមួយ ដើម្បីរាំងផលិតផលយើងមិនឱ្យចូលទីផ្សារបាននោះទេ ដូច្នេះនឹងបង្កើនផលិតភាព និងកាលានុវត្តភាពសម្រាប់ផលិតផលកម្ពុជា ក្នុងការជ្រៀតចូលទីផ្សារពិភពលោក។

ក្នុងករណីប្រទេសណាមួយអនុវត្តគោលការណ៍រើសអើង និងរឹតត្បឹតលើផលិតផលនាំចេញពីកម្ពុជា ប្រទេសនោះអាចប្រឈមមុខនឹងការតវ៉ា ហើយប្រសិនបើដោះស្រាយក្នុងលក្ខណៈទ្វេភាគីគឺមិនបានទេ ចុងក្រោយនឹងត្រូវបញ្ជូនទៅកាន់ :

យន្តការដោះស្រាយជម្លោះ WTO ជាយន្តការស្មើរភាពដែលប្រទេសតូចធ្លាប់ឈ្នះប្រទេសធំ។ នៅពេលដែលយើងមានច្បាប់នានា ដែលចាំបាច់សម្រាប់ទ្រទ្រង់បរិស្ថានវិនិយោគ និងធុរកិច្ចដែលស្របនឹងច្បាប់ និងល័ក្ខខ័ណ្ឌនានារបស់កិច្ចព្រមព្រៀង WTO

នៅកម្ពុជារួចហើយ ជំនឿទុកចិត្តរបស់វិនិយោគិន និងធុរជនបរទេសក្នុងស្រុកនឹងមានការកើនឡើង ដោយហេតុថា គេមានលទ្ធភាពច្រើនក្នុងព្យាករណ៍ និងធ្វើផែនការធុរកិច្ចរបស់គេ ដោយគេអាចប៉ាន់ស្មានពីចំណាយសម្រាប់ការបង់ពន្ធ ប្រសិនបើកម្ពុជាអនុវត្តនូវវិធីសាស្ត្រវាយតម្លៃពន្ធគយ តាមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។ ដូច្នោះ នឹងកាត់បន្ថយនូវការចំណាយក្រៅផ្លូវការ និងជាការបង្កើតភាពប្រកួតប្រជែង ហើយនឹងទាក់ទាញលើកទឹកចិត្តឱ្យមានវិនិយោគនិងធុរកិច្ចថ្មីនៅកម្ពុជា។ ការកែសម្រួលច្បាប់និងបទបញ្ញត្តិនានាថ្មីត្បិតតែមានភាពស្មុគស្មាញ និងជួបប្រទះនឹងការលំបាកជាច្រើន ប៉ុន្តែ វានឹងផ្តល់អត្ថប្រយោជន៍ដល់ប្រទេស និងប្រជារាស្ត្ររបស់យើងជាក់ស្តែង ដូចជាការកសាងច្បាប់ថ្មី ស្តីពី អនាម័យនិងជួយបង្កើនគុណភាពផលិតផលស្បៀងអាហាររបស់កម្ពុជា ទាំងសម្រាប់ការនាំចេញ ទាំងសម្រាប់ការប្រើប្រាស់ក្នុងស្រុក ដូច្នេះនឹងកាត់បន្ថយនូវការភ័យខ្លាច អំពីការជ្រៀតចូលមកក្នុងស្រុក នូវជំងឺនានា ដែលកើតចេញពីម្ហូបអាហារ ដូចជាកើតចេញពីពពួកប៉េស្តិ៍ ការប្រើសារធាតុគីមីក្នុងម្ហូបអាហារ អាហារខូចគុណភាព និងអាហារមានជាតិពុល។ ក្នុងនោះនៅក្រោមកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក ការត្រួតពិនិត្យព្រំដែនដើម្បីធ្វើចត្តាឡីស័ក គឺត្រូវផ្អែកលើមូលដ្ឋានហានិភ័យ ដូច្នេះនឹងមិនមានន័យថាច្បាប់ថ្មី នឹងបង្កជាការរឹតត្បឹតដល់ពាណិជ្ជកម្មឡើយ។ ម្យ៉ាងទៀត ការអនុម័តយកមកប្រើប្រាស់នូវបទដ្ឋានអន្តរជាតិ ក៏នឹងជួយឱ្យមានការទទួលស្គាល់នូវគុណភាពផលិតផលកម្ពុជា ជាអន្តរជាតិ ដែលជាផ្នែកមួយនៃការធានាភាពជោគជ័យផងដែរ។

# អង្គការពាណិជ្ជកម្មពិភពលោក និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា

## លោក សុក សំអឿន

**មេធាវី និងជានាយកអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា**

ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា គឺជារឿងថ្មី និងជារឿងដែលកម្ពុជាត្រូវតែត្រៀមខ្លួន ដើម្បីទប់ទល់ក្នុងទម្លាប់បរិយាកាស និងវប្បធម៌ថ្មី។ អ្វីក៏ដោយវាតែងតែមានផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានមិនលែងឡើយ។ នៅពេលដែលយើងមិនទាន់សម្រេចចិត្ត យើងអាចលើកយកផលប៉ះពាល់ទាំងនោះ ដើម្បីជាមូលដ្ឋានសម្រាប់សម្រេចចិត្តថា តើយើងត្រូវសម្រេចចិត្តចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនេះឬក៏អត់? ប៉ុន្តែ កាលបើយើងបានសម្រេចចិត្តថានឹងធ្វើអ្វីឬថា ចូលជាសមាជិកអង្គការពាណិជ្ជកម្មនោះទៅ ហើយផលប៉ះពាល់ទាំងនោះលែងជាមូលដ្ឋានទៀតសម្រាប់សម្រេចទៀតហើយ តែវាក្លាយទៅជាមូលដ្ឋានសម្រាប់យើងត្រៀមខ្លួន ទប់ទល់នឹងផលជាវិជ្ជមានទាំងឡាយ និងព្យាយាមកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានទាំងនោះ។

ចំពោះផលប៉ះពាល់សេដ្ឋកិច្ចក្នុងរយៈពេលប៉ុន្មានឆ្នាំ ដំបូងកម្ពុជាប្រហែលជាត្រូវរងការសម្រុកចូលនៃមុខទំនិញ និងក្រុមហ៊ុនបរទេសជាច្រើនប្រាកដណាស់ ហើយកម្ពុជាក៏ប្រឈមទៅនឹងការប្រកួតប្រជែងជាមួយបរទេសដែរ។

ការប្រកួតប្រជែងទាំងនោះរួមមាន :

*ការប្រកួតផលិតផល* : ផលិតករនៅក្នុងស្រុកអាចនឹងត្រូវងាយប្រឈមទៅនឹងផលិតផលបរទេសទាំងតម្លៃ និងគុណភាព។ ដោយសារយើងជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក យើងនឹងពិបាកយកពន្ធផលិតផលបរទេសខ្ពស់ណាស់ ដូច្នេះផលិតផលបរទេសអាចថោក ហើយមានគុណភាពជាងផលិតផលក្នុងស្រុក។ ដូច្នេះ ដើម្បីឱ្យផលិតផលក្នុងស្រុករស់នៅបាននោះត្រូវតែបន្ថយពន្ធ ឬមិនយកពន្ធផលិតផលក្នុងស្រុកមួយរយៈ ហើយរដ្ឋត្រូវជួយពង្រឹងសមត្ថភាព ផលិតករក្នុងស្រុក និងពង្រឹងគុណភាពផលិតផលក្នុងស្រុក។

*ការប្រកួតទីផ្សារពលករ* : កុំថាឡើយដល់ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក សូម្បីតែបច្ចុប្បន្ននេះ ក៏ប្រជាពលរដ្ឋកម្ពុជាត្រូវប្រឈមទៅនឹងធនធានមនុស្សបរទេសដែរ។ សព្វថ្ងៃនេះ មានជនបរទេសដែលស្ម័គ្របម្រើការងារនៅតាមអង្គការសកលវិទ្យាល័យ និងមានរហូតដល់ក្រសួងស្ថាប័នរដ្ឋទៅទៀត ដោយទាមទារបៀវត្សរ៍មិនជាខ្ពស់ជាងពលរដ្ឋខ្មែរនោះទេ។ ដូច្នេះ ប្រសិនបើរដ្ឋមិនកំហិត និងត្រួតពិនិត្យតឹងតែងនោះទេ ប្រជាពលរដ្ឋខ្មែរនឹងមិនងាយរកការធ្វើនោះបានឡើយ ហើយតាមក្រុមហ៊ុន និងស្ថាប័នធំៗ អាចនឹងសម្បូរទៅដោយជនបរទេស ឬជនជាតិខ្មែរដើមកំណើតបរទេស។ ពោលគឺសេដ្ឋកិច្ចស្រុកខ្មែរ អាចនឹងត្រូវដឹកនាំដោយជនបរទេសទៅវិញ។ ក្នុងន័យនេះ ច្បាប់សញ្ជាតិ ច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារត្រូវពិនិត្យជាថ្មី និងត្រូវតែអនុវត្តន៍ឱ្យបានម៉ឺងម៉ាត់។

***ឧស្សាហកម្ម និងវត្ថុធាតុដើម*** : បញ្ហាឧស្សាហកម្ម កម្ពុជានៅមានការខ្វះខាតឬក៏អាចថា គ្មានតែម្តងក៏បាន ដូច្នេះ រឿងប្រកួតប្រជែងផ្នែកឧស្សាហកម្មនោះគឺមិនសូវជាមាននោះទេ ។ ក៏ប៉ុន្តែ ខ្ញុំមានកង្វល់ដូចតទៅ :

កម្ពុជានៅតែគ្មានការរីកចម្រើនផ្នែកឧស្សាហកម្មដដែល ។ កន្លងមក នេះឃើញមានរោងចក្រលក់ទៅឱ្យជនបរទេស តែបែរជាមិនដំណើការទៅវិញ ដូចជាគ្រាន់តែទិញដើម្បីបិទ ដើម្បីបើកឱ្យផលិតផល ប្រទេសជិតខាងដណ្តើមទីផ្សារនៅប្រទេសកម្ពុជាទៅវិញ ។ ដោយការដឹកវត្ថុធាតុដើមចេញទៅក្រៅប្រទេសវាងាយពេកនោះ នោះនឹងអាចមានបញ្ហាបី គឺកម្ពុជានៅតែគ្មានការរីកចម្រើនផ្នែកឧស្សាហកម្មដដែលពលករកម្ពុជានៅតែខ្វះការងារធ្វើដដែល និងវត្ថុធាតុដើមកម្ពុជាងាយនឹងរលាយនាពេលអនាគត ។

ដូច្នេះ ដើម្បីទប់ទល់នឹងបញ្ហានេះ ការនាំចេញនូវវត្ថុធាតុដើមសុទ្ធៗ ត្រូវតែហាមឃាត់ឬរឹតបន្តឹង ។ ប្រសិនបើច្បាប់កំណត់ថា ត្រូវហាមឃាត់ការនាំចេញនូវវត្ថុធាតុដើមសុទ្ធ យើងអាចបង្ខំឱ្យក្រុមហ៊ុនបរទេសត្រូវតែបង្កើតរោងចក្រនៅកម្ពុជា ដើម្បីផលិតរបស់នាំចេញ ឬយ៉ាងហោចណាស់ឱ្យពាណិជ្ជករ កម្ពុជាអាចនឹងបែកគំនិតអភិវឌ្ឍន៍ឧស្សាហកម្ម ។ ហើយកាលបើមានរោងចក្រកើតឡើងច្រើន ហើយពេលនោះកម្ពុជាក៏នឹងអាចសម្បូរការងារដល់ប្រជាពលរដ្ឋដែរ ។

***ហេដ្ឋារចនាសម្ព័ន្ធ*** : ចំណុចខ្សោយដែលធ្វើឱ្យឧស្សាហកម្មកម្ពុជាមិនអាចនឹងរីកចម្រើនទៅបាននោះ គឺការខ្វះនូវហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ផ្លូវ ដែក និងអគ្គិសនី ។ ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធទាំងនោះនៅខ្វះខាត ថ្លៃដឹក ជញ្ជូននឹងមានតម្លៃខ្ពស់ ដែលនាំឱ្យតម្លៃផលិតផលនៅក្នុងស្រុកអាចនឹងឡើងខ្ពស់ ដូច្នេះ ដើម្បីជួយទ្រទ្រង់ផលិតផលក្នុងស្រុកឱ្យបាននោះ គឺត្រូវពង្រឹងហេដ្ឋារចនាសម្ព័ន្ធទាំងនោះឱ្យបាន ។

***អំពើពុករលួយ*** : អំពើពុករលួយក៏ជាកត្តាដែលនាំមានថយចុះនូវវិនិយោគទុនបរទេស និងនាំឱ្យផលិតផលក្នុងស្រុកឡើងថ្លៃ ឬរាំងស្ទះមិនអាចនឹងមានការរីកចម្រើនដែរ។

ទោះបីជាបើកចំហយ៉ាងនេះមែន ថ្វីត្បិតតែការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក តម្រូវឱ្យកម្ពុជាត្រូវមានច្បាប់ជាមូលដ្ឋានមួយចំនួនធំក៏ដោយ ក៏មិនសង្ឃឹមថា អ្នកវិនិយោគទុនបរទេស ក្រោយពេលដែលគេឃើញថា កម្ពុជាមានច្បាប់គ្រប់គ្រាន់ហើយ ហើយបោលសម្រុកចូលកម្ពុជានោះក៏ទេដែរ កត្តាមួយទៀតដែលសំខាន់នោះគឺថា តើប្រសិនបើគេមានជម្លោះណាមួយ គេនឹងទទួលបាននូវយុត្តិធម៌ដែរឬទេ? តើគេទទួលបាននូវការពារនោះដែរឬទេ? និយាយឱ្យខ្លី ទោះបីជាមានច្បាប់ច្រើនយ៉ាងណាក៏ដោយ ប្រសិនបើតុលាការ និងនគរបាលនៅពុករលួយនៅតែខ្វះសមត្ថភាពច្បាប់ទាំងនោះគ្រាន់តែជាក្រដាសតែប៉ុណ្ណោះ។ ដូច្នេះ រដ្ឋាភិបាលត្រូវតែកែទម្រង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថាប័នតុលាការ និងកងកម្លាំងនគរបាល។

# កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់កសិកម្មកម្ពុជា

លោក ទួត សារារុធ

## ១-សេចក្តីផ្តើម

ក្រោយរយៈពេលជិត១០ ឆ្នាំ គឺចាប់ពីពេលដែលប្រទេសកម្ពុជាបានដាក់ពាក្យសុំចូលជាសមាជិក កាលពី ខែធ្នូ ឆ្នាំ ១៩៩៤ ទើបតែរយៈពេល ៣០ ថ្ងៃ ក្រោយពីរដ្ឋាភិបាលកម្ពុជា បានជូនដំណឹងទៅអង្គការពាណិជ្ជកម្មពិភពលោកនេះ អង្គការក៏បានអនុញ្ញាតឱ្យប្រទេសកម្ពុជា ចូលជាសមាជិកពេលសិទ្ធិទី ១៤៨ នៅថ្ងៃទី ១៣ តុលា ២០០៤។

## ២-ស្ថានភាពទូទៅនៃប្រទេសកម្ពុជា

- ចំនួនប្រជាជន ១៤ លាននាក់
- លផិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ ២៨១,៣៨ ដុល្លារក្នុងមួយឆ្នាំ
- ប្រជាជនដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ ៣៥,៩%
- ប្រជាពលរដ្ឋកម្ពុជាជាង ៨០% នៅជនបទ
- ប្រជាពលរដ្ឋ ៧០% ពឹងផ្អែកលើកសិកម្មសម្រាប់ចិញ្ចឹមជីវិត (៨៩%ជានារី)
- ភាគរយផលិតផលក្នុងស្រុកសរុបតាមវិស័យ

- កសិកម្ម ៣៨ %
- ឧស្សាហកម្ម ២៣.៥ %
- សេវាកម្ម ៣៥ %
- ភាគរយការងារតាមវិស័យ
- កសិកម្ម ៧៤ %
- ឧស្សាហកម្ម ៨ %
- សេវាកម្ម ១៨ %
- ភាគរយនៃថវិកាជាតិសម្រាប់កសិកម្ម និងការអភិវឌ្ឍន៍ជនបទ ឆ្នាំ ២០០២៤ %
- ប្រជាជនដែលពេញកម្លាំងសម្រាប់ការងារ ៤៥ %
- ប្រជាជនដែលមានអាយុក្រោម ២០ ឆ្នាំ មាន ៥៤.៦ %
- ប្រជាជនដែលអាចចេះអាន និងសរសេរបាន ៣៧ %
- ប្រជាជនដែលចេះអាន និងសរសេរខ្លះមាន ២៧ %

## ៣-កសិកម្មកម្ពុជា

កសិកម្មដើរតួនាទីយ៉ាងសំខាន់សម្រាប់ការងារកាត់បន្ថយភាពក្រីក្រ និងបង្កើនសមត្ថភាពសម្រាប់ការអភិវឌ្ឍន៍មនុស្ស ។ ក្នុងវិស័យកសិកម្មដំណាំ និងជលផលជាអនុវិស័យដែលសំខាន់ជាងគេ ដែលមាន ៤៥ % និង ៣៥ % នៃផលិតផលក្នុងស្រុកសរុបនៃវិស័យកសិកម្ម ។ ដីដាំដំណាំមាន ២.៦ លានហិចតា ក្នុងនោះដំណាំស្រូវមាន ៩០ % នៃផ្ទៃដីដាំដំណាំទាំងអស់ ។ ដំណាំនាំចេញមានស្រូវ (៥ ម៉ឺនតោន នៅឆ្នាំ ២០០១) ហើយនៅឆ្នាំ ២០០៥ តម្លៃទីផ្សារសម្រាប់ស្រូវមានតម្លៃខ្ពស់ជាង ដើមឆ្នាំ ២០០៤។ កៅស៊ូជាដំណាំនាំចេញមួយដ៏សំខាន់ដែរសម្រាប់កម្ពុជាយើង ដំណាំនេះកំពុងតែចាប់ដាំឡើង

វិញ លើសពីនេះទៅទៀត ចំការកៅស៊ូក៏កំពុងដំណើរការ ទៅជាឯកជនភាវូបនីយកម្មផងដែរ។ ការចិញ្ចឹមសត្វរួមចំណែកលើផលិតផលក្នុងស្រុកសរុប ១៤% ទៅ ១៥% នៃផលិតផលកសិកម្ម។ ជលផលមានចំណែកក្នុងការនាំចេញដែរ ក៏ប៉ុន្តែ ការដែលព្រួយបារម្ភនោះគឺ ផលិតផលត្រីធម្មជាតិមានការធ្លាក់ចុះ។ ការរួមវិភាគទានលើផលិតផលក្នុងស្រុកសរុបមានការថយចុះ គឺអនុវិស័យព្រៃឈើ។ ផលិតផលកសិកម្មជាទំនិញចម្បងមួយដែលគេរំពឹងថានឹងអាចនាំចេញបាន ប៉ុន្តែពេលនេះមិនអាចធ្វើទៅរួចដោយគុណភាពរបស់យើងនៅមានកម្រិត។ ការគាំទ្រកសិកម្ម និងការផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជានៅតែមានកម្រិតខ្សោយនៅឡើយ ឬពុំទាន់បង្កើតបាន។

## ៤-អង្គការពាណិជ្ជកម្មពិភពលោក (WTO)

**៤-១-អ្វីទៅជា** WTO? WTO គឺជាប្រព័ន្ធដែលផ្អែកលើគោលការណ៍ច្បាប់ជាធំផ្អែកលើកិច្ចព្រមព្រៀង និងវិន័យដែលផ្អែកលើវិធានការច្បាប់ពាណិជ្ជកម្មសមាជិកនាពេលបច្ចុប្បន្នគឺ ១៤៨ ប្រទេស។

**៤-២-តើគេបង្កើតអង្គការពាណិជ្ជកម្មពិភពលោកក្នុងគោលបំណងអ្វី?** លើកតម្កើងជីវភាពរស់នៅរបស់ប្រទេសជាសមាជិក ពង្រីកការធ្វើពាណិជ្ជកម្មខាងទំនិញ និងពាណិជ្ជកម្មខាងសេវាកម្ម ឱ្យស្របតាមគោលដៅនៃការទ្រទ្រង់និរន្តរភាពសម្រាប់ការអភិវឌ្ឍន៍ ការពារ និងថែរក្សាបរិស្ថាន តម្លាភាព និងភាពអាចទស្សន៍ទាយបានជាវេទិកាសម្រាប់ចរចាពាណិជ្ជកម្ម ជាវេទិកាសម្រាប់យន្តការដោះស្រាយជម្លោះខាងពាណិជ្ជកម្ម។

**៤-៣-តើ** WTO **មានមុខងារអ្វីខ្លះ?** ជាកន្លែងសម្របសម្រួលលើកិច្ចការប្រតិបត្តិកិច្ចការរដ្ឋបាល និងធ្វើឱ្យកិច្ចព្រមព្រៀង WTO នានាអាចដំណើរការជាប្រក្រតីបានជាវេទិកាចរចាលើប្រធានបទ គ្របខ័ណ្ឌ WTO ជាវេទិកាចរចាសម្រាប់

កិច្ចព្រមព្រៀងផ្សេងៗ វិធានច្បាប់ផ្សេងៗ វិន័យនានាសម្រាប់អនាគត ជាកន្លែងសម្រាប់គ្រប់គ្រងយន្តការដោះស្រាយជម្លោះ ជាកន្លែងសម្រាប់គ្រប់គ្រងយន្តការត្រួតមើលការកែសម្រួលខាងគោលនយោបាយពាណិជ្ជកម្ម ។

**៤-៣-កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក :** ប្រទេសកម្ពុជាបានក្លាយជាសមាជិកពេញសិទ្ធិរបស់ WTO ទី ១៤៨ នៅថ្ងៃទី ១៣ តុលា ២០០៤។

ប្រទេសកម្ពុជាជាប្រទេសមានការអភិវឌ្ឍន៍យឺតទី២ ដែលបានចូលជាសមាជិកពេញសិទ្ធិរបស់ WTO ។ បន្ទាប់ពីប្រទេសបង់ក្លាដេស ដែលបានចូលជាសមាជិកអង្គការនេះ នៅថ្ងៃ ២៣ មេសា ២០០៤។ ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមវេលាមានការអភិវឌ្ឍន៍យឺតទាំង ៣ នៃអង្គការ WTO ។

## ៥-ផលប៉ះពាល់ដល់កសិកម្មកម្ពុជា (Impact on Cambodia Agriculture)

### ៥-១-ផលប៉ះពាល់ជាវិជ្ជមាន (Positive impact)

ការចូលជាសមាជិក WTOនេះ ត្រូវបានមន្ត្រីរាជរដ្ឋាភិបាលពន្យល់ថា ប្រទេសកម្ពុជានឹងមានទីផ្សារយ៉ាងធំលើឆាកអន្តរជាតិ ដែលអាចនឹងប្រមូលអ្នកវិនិយោគទុនបរទេសឱ្យចូលមករកស៊ីកាន់តែច្រើនឡើង។ ក៏ប៉ុន្តែ ពុំទាន់មានការសិក្សាណាមួយបានបង្ហាញច្បាស់ថា តើការចូលជាសមាជិក WTO របស់កម្ពុជាបានទទួលផលចំណេញឬខាតយ៉ាងណាពិតប្រាកដនោះទេ។

ការចូលជាសមាជិក WTO នៃប្រទេសកម្ពុជាចាំបាច់ត្រូវមានច្បាប់ ៤០ បន្ថែមទៀត ដើម្បីតម្រូវតាមសន្យារបស់ប្រទេសជាមួយ WTO នេះ ក្នុងនោះមានច្បាប់មួយចំនួនឆ្លើយតបទៅនឹងវិស័យកសិកម្ម ដូចជា ច្បាប់គ្រប់គ្រងធញ្ញជាតិ ច្បាប់ការពាររុក្ខជាតិថ្មីជាដើម។

ក្នុងរយៈពេល ៥ ឆ្នាំខាងមុខនេះ ប្រទេសកម្ពុជាត្រូវអនុមត័នូវច្បាប់សំខាន់ៗមួយចំនួន ដើម្បីបំពេញការសន្យាដែលបានធ្វើនៅក្នុងកិច្ចព្រមព្រៀង ចូលជាសមាជិក WTO ។ កម្ពុជានឹងធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនក្នុងប្រព័ន្ធ WTO ។

**៥-២-ផលប៉ះពាល់អវិជ្ជមាន :**

ផលិតផលកសិកម្មអាចលក់បានតែក្នុងខេត្ត មិនអាចនាំចេញបានមិនអាចប្រកួតទីផ្សារក្រៅប្រទេស ។

*<u>មូលហេតុ</u>* : មិនត្រូវតាមស្តង់ដារអន្តរជាតិ និងការគ្រប់គ្រងសម្រួលបែបបទពាណិជ្ជកម្មនៅកម្ពុជាមានភាពសាំញ៉ាំ ដែលបណ្តាលឱ្យថ្លៃដើមឡើងខ្ពស់ជាងផលិតផលនាំចូលពីបរទេស ។

*<u>ផលិតផលរំពឹងទុកអាច</u>* : រដ្ឋាភិបាលនឹងសម្រួលបែបបទឱ្យលក់ និងកសិករបញ្ឈប់ការផលិតនោះនឹងមានការហូរចូលកាន់តែច្រើន ហើយប្រជាជនកាន់តែក្រ : លក់ដី លក់កម្លាំងពលកម្មទៅក្រៅប្រទេស ។ នៅក្នុងអង្គសិក្ខាសាលា ស្តីពី "ផលប៉ះពាល់នៃសមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក មកលើកសិករកម្ពុជា" ២៣-២៤ ធ្នូ ២០០៤ ដែលរៀបចំដោយអង្គការស្តារកម្ពុជាបានបង្ហាញថា : ថ្លៃចំណាយខ្ពស់សម្រាប់ការផ្គត់ផ្គង់ផលិតភាពកសិកម្ម ខ្វះថវិកានៅចុងរដូវប្រមូលផលរបស់កសិករ (ផ្ទៃដីដាំដំណាំតិច) ឈ្មួញកណ្តាលមួយចំនួនប្រមូលទិញកសិផលក្នុងតម្លៃថោក អាចនាំចេញទៅលក់ក្រៅប្រទេសបាន ប៉ុន្តែលក់ឱ្យកសិករវិញក្នុងតម្លៃខ្ពស់ ផលិតផលនៅកម្ពុជាពិបាករកចំណោញផងតើអាចប្រកួតទីផ្សារបានដែរឬទេ?

## ៦_សំណូមពរ

- រដ្ឋាភិបាលគួរកំណត់ស្តង់ដារពូជនាំចេញដល់ប្រជាកសិករ ដើម្បីឱ្យផលិតផលនាំចេញតាមតម្រូវការទីផ្សារអន្តរជាតិ។
- រដ្ឋាភិបាលគួរពិចារណាលើការនិយាយរបស់ស្ថានទូតអាមេរិក ដែលបានលើកឡើងថា : សមាជិកភាពនៃអង្គការ WTO គឺជាយាន្តមួយសម្រាប់កាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព។ ក៏ប៉ុន្តែ វាក៏តម្រូវឱ្យមានការដើរដោយឆន្ទៈនយោបាយនិរន្តរភាព និងការប្តេជ្ញាចិត្តដើម្បីជំរុញការអនុវត្តន៍ច្បាប់ផ្សេងៗ និងកាតព្វកិច្ចមួយចំនួនដែលទាក់ទងដល់អង្គការពាណិជ្ជកម្មពិភពលោក។
- រាជរដ្ឋាភិបាលជួយពង្រឹងប្រសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ ការផ្ទេរបច្ចេកទេសកសិកម្ម ធារាសាស្ត្រដល់កសិករ និងសម្រួលរាល់នយោបាយពាណិជ្ជកម្មឱ្យកាន់តែល្អឡើង។

## ៧_សេចក្តីសន្និដ្ឋាន

ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់ប្រទេសកម្ពុជា ពិតជាធ្វើឱ្យមតិជាតិអន្តរជាតិ និងជាពិសេស ប្រជាជននៅជនបទមានការចាប់អារម្មណ៍ និងបានសម្តែងឡើងនូវមតិជាច្រើន ក្នុងការជួយជំរុញការអភិវឌ្ឍន៍ជាតិ ឱ្យកាន់តែមានភាពខ្លាំងក្លាឡើង។

# កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់កសិកម្មកម្ពុជា

**លោកស្រី ប្រុក វ៉ាន់នី**

**អ្នកឯកទេស**

**យេនឌ័រនិងសង្គមនៃកម្មវិធីអភិវឌ្ឍន៍ផ្នែកកសិកម្ម ប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

## សារតារ និងការបង្ហាញ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលមានការអភិវឌ្ឍតិចតួច ហើយប្រទេសនេះបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅខែកញ្ញា ឆ្នាំ២០០៣។ ទើបតែមួយទសវត្សរ៍ប៉ុណ្ណោះ តាំងពីកម្ពុជាបានរស់រានមានជីវិតឡើងវិញនាឆ្នាំ១៩៩៣ បន្ទាប់ពីស្ថិតនៅក្នុងភាពឯកោ សង្គ្រាមរ៉ាំរ៉ៃ និងការសម្លាប់រង្គាលអស់បីទសវត្សរ៍។ នេះគឺជាសមិទ្ធផលមួយដ៏ចម្បងបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា។ កម្ពុជាបានក្លាយទៅជាសមាជិកភាពពេញសិទ្ធិ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) នៅក្នុង ឆ្នាំ១៩៩៩។

តាំងពីឆ្នាំ ១៩៩៣ មក កម្ពុជាជាប្រទេសដែលមានប្រវត្តិសាស្ត្រទំនើបបានបញ្ចូលរបៀបនៃការគ្រប់គ្រងសេដ្ឋកិច្ចទីផ្សារ នាំមុខដ៏មានប្រសិទ្ធិភាពទៅក្នុងអភិបាលកិច្ចដែលមានលក្ខណៈសេដ្ឋកិច្ច។ រចនាសម្ព័ន្ធនៃអត្រាពន្ធគយជាទូទៅ គឺទាបហើយថេរ

ព្រមទាំងមានឧបសគ្គផ្នែកពន្ធតិចតួចបំផុតទៀតផង។ ច្បាប់វិនិយោគនៅកម្ពុជាគឺ ស្ថិតនៅក្នុងចំណោមក្របខ័ណ្ឌច្បាប់វិនិយោគ សេរីជាងគេនៅក្នុងតំបន់ ដែលមិនខុសផ្លែកគ្នារវាងការវិនិយោគក្រៅស្រុក និងក្នុងស្រុកទេ លើកលែងតែក្នុងករណីម្ចាស់កម្មសិទ្ធិដីធ្លី ដែលបម្រុងទុកជារបស់ជនជាតិកម្ពុជា។ រាល់ការរក្សាទុកបញ្ហានិយតករ ត្រូវតែបំពេញតួនាទីជាមួយផ្នែកកសិកម្មជារបស់រដ្ឋ ដែលក្នុងករណីខ្លះកំពុងដំណើរការឯកជនីយកម្ម។

ក្នុងនាមជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ហើយឥឡូវនេះ ក៏ជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ទៀតនោះ ប្រទេសកម្ពុជាបានសម្រេចចិត្តគោរពតាមច្បាប់ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកជាលក្ខណៈសាកល នោះគឺកិច្ចព្រមព្រៀងកសិកម្ម មាត្រាកំណែទម្រង់ (បច្ចុប្បន្ននេះស្ថិតនៅក្រោមការត្រួតពិនិត្យមើលឡើងវិញ និងការចរចា) ផ្នែកពិធីសារអាស៊ាន និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ព្រមទាំងគម្រោងអនុគ្រោះពន្ធគយរួម (CEPT)។

កម្ពុជាពេញចិត្តនឹងជោគជ័យមួយចំនួន ក្នុងការប្រកួតប្រជែងផ្នែកសុវត្ថិភាពអាហារ និងកសិកម្ម។ នៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ កម្ពុជាបានទទួលនូវផលិតផលស្រូវគ្រប់គ្រាន់សម្រាប់ខ្លួនឯង ជាក់ស្តែង កម្ពុជាបានក្លាយទៅជាអ្នកនាំចេញស្រូវតិចតួចខ្លះ ទៅកាន់ប្រទេសជិតខាងរបស់ខ្លួន ជាពិសេសក្នុងអំឡុងពេលក្រោយពីរដូវច្រូតកាត់។ អតិផរណាក្នុងប្រទេសកម្ពុជា បង្ហាញដោយសន្ទស្សន៍តម្លៃប្រើប្រាស់ (CPI) ពី-១ (ដកមួយ) ទៅ៣% រយៈកាលប្រាំឆ្នាំកន្លងមក អាស្រ័យដោយតម្លៃអាហារថេរឬក៏ធ្លាក់ចុះ។ លើសពីនេះទៅទៀត ការធ្វើអង្កេតលើផ្នែកសុខភាពថ្មីៗនេះបង្ហាញនូវភាពល្អប្រសើរ ក្នុងស្ថានភាពអាហាររូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋ ជាពិសេសក្នុងចំណោមកុមារ។

ទោះជាយ៉ាងណាក៏ដោយ សុវត្ថិភាពអាហារ និងកំណើនសរុបក្នុងពេលអនាគតនៃផ្នែកកសិកម្មរបស់កម្ពុជាត្រូវពឹងផ្អែក ទៅលើការប្រកួតប្រជែងរយៈពេលយូររបស់ជាតិ នៅក្នុងបទបញ្ញត្តិរបស់អាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ព្រមទាំងបង្ហាញភិនភាគ និងអភិវឌ្ឍកាលានុវត្តភាព ដែលផ្តល់ដោយសេរីភាវូបនីយកម្មនៃពាណិជ្ជកម្ម។ នេះគឺសំខាន់ណាស់សំរាប់ផ្នែកកសិកម្ម និងជនបទកម្ពុជា ដែលផ្នែកនេះផ្តល់ឱ្យយើងយ៉ាងច្រើនដល់ទៅ ២/៣ នៃការងារ និងបង្កើនផលិតផល ក្នុងស្រុកបាន ៣២ %។ ក្រៅពីនេះ ដូចការធ្វើនិទស្សន៍នៅក្នុងបទពិសោធន៍អភិវឌ្ឍន៍ជាអន្តរជាតិបានបង្ហាញថា ការរីកចម្រើនលើវិស័យកសិកម្ម និងជនបទនឹងជះឥទ្ធិពលយ៉ាងសំខាន់ទៅលើប្រាក់ចំណូល ក្រៅពីវិស័យកសិកម្ម និងការងារតាមរយៈការផ្សារភ្ជាប់ និងភាពរស់រវើកជាមួយផ្នែកសេដ្ឋកិច្ចដទៃទៀត។ ការលូតលាស់ទៅមុខនាពេលថ្មីៗនេះ លើផ្នែកកម្មន្តសាលនៅកម្ពុជាភាគច្រើន អាស្រ័យដោយការកើនឡើងយ៉ាងឆាប់រហ័សនូវផ្នែកនាំចេញឧស្សាហកម្មកាត់ដេរ និងវាយនភណ្ឌដែលកំណើនបែបនេះ អាចរស់រានបានតាមរយៈគុណភាពល្អ និងតម្លៃប្រកួតប្រជែង។ ជាលទ្ធផលតម្លៃប្រកួតប្រជែងជាសំខាន់ទទួលរងឥទ្ធពលពីកម្រៃប្រាក់ឈ្នួល និងតម្លៃម្ហូបអាហារ។

កម្ពុជាស្ថិតនៅកណ្តាលរវាងប្រទេសថៃ និងប្រទេសវៀតណាម ដែលប្រទេសទាំងពីរ នាបីទសវត្សរ៍ចុងក្រោយនេះ បានបង្ហាញនូវការប្រកួតប្រជែងផ្នែកកសិកម្មដ៏លេចធ្លោ។ ប្រទេសចិនក៏បានបង្ហាញខ្លួននៅក្នុងតំបន់ផងដែរ។ កម្ពុជាត្រូវតែរៀនយកគំរូពីការវិភាគពិសោធន៍នៃប្រទេសជិតខាងខ្លួន ហើយគួរតែប្រជែងជាមួយជោគជ័យរបស់ប្រទេសជិតខាង និងចៀសវាងរាល់កំហុសផ្សេងៗ។

សរុបសេចក្តីមក សមត្ថភាពរបស់ជាតិអាចចាត់ចែង និងដឹកនាំក្នុងរយៈពេលយូរគឺដើម្បីស្ថាបនា និងការពារការប្រកួតប្រជែងផ្នែកកសិកម្មជាតិ និងទាញយក

ប្រយោជន៍ពីឱកាស ដែលផ្តល់ដោយអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងសមាជិកអាស៊ាននៅក្រៅប្រទេស ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងធ្វើការវិភាគ និងប៉ាន់ស្មានដ៏ទូលំទូលាយ អំពីការប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ចំពោះទំនិញសំខាន់ៗដែលផលិតដោយកម្ពុជា។ ការវាយតម្លៃបែបនេះ គួរតែគ្របដណ្តប់លើផលិតភាព តម្លៃផលិតកម្ម និងទីផ្សាររួមទាំងស្ថាប័នគោលនយោបាយ និងបទបញ្ញត្តិដែលមានឥទ្ធិពល ហើយអាចកំណត់តម្លៃនិងផលិតភាព។ ដំណើរការវិភាគនឹងជួយធ្វើឱ្យមានភាពជាក់លាក់ ជួយសម្រួលការពិភាក្សា ស្តីពី បញ្ហាផ្សេងៗ និងការលំបាក ជាពិសេសប្រសិនបើដំណើរការវិភាគបានធ្វើឡើង ដោយលក្ខណៈតម្លាភាព និងមានការចូលរួម។

ការកសាងមត្ថភាពវិភាគលើដំណើរការ ស្តីពី គម្រោងជំនួយផ្នែកបច្ចេកទេស គឺពិតជាសំខាន់សម្រាប់កម្ពុជា ដើម្បីបង្កើនភាពល្អប្រសើរនៃការងារសេដ្ឋកិច្ចទីផ្សារ និងរបៀបគ្រប់គ្រងប្រព័ន្ធតម្លៃ។ ទាំងនេះគឺសំខាន់ណាស់ ដោយហេតុថាប្រទេសកម្ពុជាធ្លាប់បានស្ថិតនៅឯកោ និងមានប្រវត្តិសាស្ត្រនៃការអនុវត្តន៍ផែនការមជ្ឈឹម។ បើយើងក្រឡេកមើលទៅអនាគតកាលមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសមត្ថភាពវិភាគគោលនយោបាយតាមផ្នែកត្រូវតែរៀបចំឡើងវិញ និងធ្វើឱ្យជ្រួតជ្រាបដល់សមាហរណកម្មអន្តរជាតិ និងក្នុងតំបន់ និងដៃគូប្រកួតប្រជែងដែលទាញយកប្រយោជន៍ពីដៃគូ ឬអ្នកប្រកួតប្រជែងផ្នែកពាណិជ្ជកម្មរបស់ខ្លួនក្នុងគោលបំណង ដើម្បីទ្រទ្រង់នូវសុវត្ថិភាពអាហារ ការប្រកួតប្រជែងផ្នែកកសិកម្ម ការលូតលាស់ និងការអភិវឌ្ឍន៍ជាតិ។

## <u>ការប្រឈមមុខ និងដំណោះស្រាយ</u>

### ២.១-ជួយគាំពារ និងកែលម្អទំនិញផ្នែកកសិកម្មរបស់កសិករតូចតាច

កសិកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា និងជាវិស័យទី ១ នៃការផ្តល់ការដោះស្រាយ ៨០% នៃកម្លាំងពលកម្មស្ថិតនៅក្នុងវិស័យកសិកម្ម ហើយភាគច្រើនពួកគេគឺជាកសិករតូចតាចហើយក្រីក្រ ។ ហេតុដូច្នេះហើយ ការយកចិត្តទុកដាក់ដ៏វិសេសមួយត្រូវផ្តល់ដល់ពួកគេ ចំពោះផលប៉ះពាល់នៃការចូលជាសមាជិក WTO លើផ្នែកកសិកម្ម ពិសេសចំពោះកសិករតូចតាច ។ បើគ្មានការសម្រាលនូវឥទ្ធិពលនេះទេ វាប្រាកដជាកើតមានគ្រោះថ្នាក់នៃវិបត្តិសង្គម ។

ដើម្បីគាំពារ និងធានាចំពោះប្រាក់ចំណូលរបស់កសិករ ជាការចាំបាច់គឺត្រូវ :

- អនុវត្តគោលនយោបាយតម្លៃមួយក្រោមការកម្រិតរបស់ WTO (*Amber Box*) ជាមួយនឹងលទ្ធភាពពីរយ៉ាង ។
- **ទីមួយ** គឺត្រូវផ្តល់ពតិមាន ពីការប្រើប្រាស់កន្លែងរក្សាទុកនូវសុវត្ថិភាព ស្បៀងបម្រុង ជាឧបករណ៏សម្របសម្រួលតម្លៃស្រូវ ។ កាលបើពតិមានត្រូវបានរាយការណ៏ ហើយប្រទេសកម្ពុជាអាចប្រើប្រាស់កម្រិតដូចៗគ្នាជារៀងរាល់ឆ្នាំ
- **ទីពីរ** គឺបទបញ្ញត្តិ “de minimis” គេអាចផ្តល់ការគាំទ្រតម្លៃចំពោះស្រូវ អង្ករ ប្រសិនបើតម្លៃនៃការគាំទ្រ នោះវាតិចជាង ១០ % តម្លៃសរុបនៃការផលិតស្រូវ [តម្លៃនៃការគាំទ្រ = (តម្លៃក្នុងស្រុក-តម្លៃពិភពលោក) x បរិមាណ] ។
- ដើម្បីឈានចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ប្រទេសកម្ពុជាត្រូវភ្ជាប់តារាងពន្ធគយរបស់ខ្លួន លើផលិតផលកសិកម្មក្នុងកម្រិតផ្សេងៗ គ្នា។ ចំពោះស្រូវដែលជាគ្រាប់ធញ្ញជាតិ យុទ្ធសាស្ត្ររបស់ខ្មែរតារាងពន្ធគយ គឺអាចឈានដល់ ៤០ % ហើយកម្រិតនោះវាគ្រប់គ្រាន់ ដើម្បីគាំពារផលិតកម្មក្នុងស្រុក និងកសិករ និងដើម្បីបញ្ចៀសការហូរចូលនៃការនាំស្រូវថោកៗ ចូល

- ការស្ទង់មតិលើភាពខុសផ្លែកគ្នារវាងតម្លៃក្នុងស្រុក និងតម្លៃអន្តរជាតិ គឺមានសារៈសំខាន់ណាស់ ។
- ក្នុងករណីដែលមានការកើនឡើងយ៉ាងលឿននូវបរិមាណ នៃការនាំចូលប្រទេសកម្ពុជា អាចនឹងត្រូវងាកទៅយកបទបញ្ញត្តិនៃការការពារ ជាពិសេសដោយបន្ថែមពន្ធ ៣០% ទៅលើពន្ធគយសម្រាប់រយៈពេលមួយមានកំណត់ ( មិនលើសពីមួយឆ្នាំ)
- ដើម្បីចៀសវាងកុំឱ្យការប្រកួតប្រជែង នៃផលិតផលនាំចូលរបស់កម្ពុជាថយចុះ ជាការចាំបាច់គឺត្រូវឱ្យមានការ គាំទ្រមួយចំពោះការបង្កើនផលិតភាព។ ការធ្វើបែបនេះទាមទារឱ្យគុណភាពនៃធាតុចូល ( គ្រាប់ពូជ ជី ថ្នាំសម្លាប់សត្វ ចង្រៃ) កាន់តែប្រសើរឡើង ការបណ្ដុះបណ្ដាលកសិករ និងគាំទ្រអង្គការកសិករ ដើម្បីធ្វើឱ្យអំណាច ទីផ្សាររបស់ពួកគេកាន់តែល្អប្រសើរ នៅចំពោះមុខពាណិជ្ជករ។ ការងារនេះអាចប្រព្រឹត្តទៅបានក្រោមក្របខ័ណ្ឌនៃអង្គការ WTO ពីព្រោះវិធានការទាំងនេះ ត្រូវបានចាត់បញ្ចូលក្នុងប្រអប់បៃតង (Green box) ។

## ២,២-ការលានុវត្តភាពនៃការនាំចេញ

- ការក្លាយជាសមាជិកអង្គការ WTO ប្រទេសកម្ពុជាមានកាលានុវត្តភាពនៃការនាំចេញជាច្រើន។ ប្រសិនបើប្រទេសអភិវឌ្ឍន៍មួយចំនួនផ្តល់ច្រកចូលទៅក្នុងទីផ្សាររបស់ខ្លួនបានល្អ ហើយដោយមកពីស្ថានភាពរបស់ប្រទេសកម្ពុជា ជាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ច្រកចូលទីផ្សារនោះនឹងត្រូវបានអនុវត្ត ហើយសមាជិកអង្គការ WTO ទាំងអស់នឹងអនុវត្ត ចំពោះប្រទេសកម្ពុជានូវប្រព្រឹត្តិកម្មជាប្រទេសទទួលការអនុគ្រោះបំផុត (Most Favored Nation) ។

- ក៏ប៉ុន្តែ ដើម្បីអាចឱ្យមានការនាំផលិតផលកសិកម្មចេញទៅប្រទេសឯទៀតៗ និងជាពិសេសនោះ ទៅប្រទេសអភិវឌ្ឍន៍ (ប្រទេសអ្នកមាន) យើងត្រូវតែឆ្លើយតបទៅតាមលក្ខណៈវិនិច្ឆ័យនៃភូតគាមអនាម័យ (SPS) គឺជាការចាំបាច់។ រឿងនេះតម្រូវឱ្យមានការវិនិយោគលើការទុកដាក់ក្នុងឃ្លាំង ការប្រើម៉ាស៊ីនត្រជាក់ និងបន្ទប់ពិសោធន៍ ការអនុវត្តន៍ប្រព័ន្ធអធិការកិច្ចដោយខ្លួនឯង ការអនុវត្តន៍ការត្រួតពិនិត្យជាសាធារណៈ ការបណ្ដុះបណ្ដាល តាំងពីកសិកររហូតដល់អ្នកនាំចេញ។ ការបិទផ្លាកលើផលិតផល គឺជាឧបករណ៍សម្រាប់បង្កើនតម្លៃបន្ថែម និងការការពារការបញ្ជាក់ភូមិសាស្ត្រ ដែលគាំពារដោយក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក។ ការធ្វើបែបនេះអាចផ្ដល់នូវកាលានុវត្តភាពដ៏ល្អៗដែរ។

## ២,៣-ការរៀបចំភស្តុភាក្នុងប្រទេស

បញ្ហានៅក្នុងប្រទេសកម្ពុជា គឺជាការលាក់លៀមតម្លៃការរត់ពន្ធ កង្វះការត្រួតពិនិត្យ និងភាពផ្ដាច់មុខ ខុសច្បាប់ ដែលជាហេតុធ្វើឱ្យវិនិយោគិនបាក់ទឹកចិត្ត និងបន្ថយលទ្ធភាព ក្នុងការទាញយកផលប្រយោជន៍ពេញលេញ ពីការចូលជាសមាជិកអង្គការ WTO។ ការរត់ពន្ធធ្វើឱ្យគ្មានប្រសិទ្ធិភាពដល់ការគ្រប់គ្រងពាណិជ្ជកម្ម និងការអនុវត្តន៍អ្វីៗឱ្យបានតាមស្តង់ដារ។

ការចូលជាសមាជិកអង្គការ WTO ផ្ដល់កាលានុវត្តភាពឱ្យកម្ពុជាបង្កើតក្របខ័ណ្ឌច្បាប់មួយ។ ដើម្បីគោរពក្របខ័ណ្ឌ WTO ច្បាប់ចំនួន ៤៦ ត្រូវតែអនុម័ត ឬកែតម្រូវនៅក្នុងឆ្នាំក្រោយៗនេះ។ ក្រោយការអនុម័ត រដ្ឋាភិបាលត្រូវតែអនុវត្ត និងធានាប្រសិទ្ធិ ភាពតាមរយៈការធ្វើប្រព័ន្ធតុលាការសាជាថ្មីឡើងវិញ។

## ២,៤-ទីផ្សារ

- ផលិតករជាច្រើនប្រឈមមុខ ជាមួយការលំបាកយ៉ាងច្រើន ក្នុងការលក់ផលិតផលរបស់ខ្លួន។ ហេដ្ឋារចនាសម្ព័ន្ធ មិនអំណោយផលដល់ការដឹកជញ្ជូន ការសាងសង់ឃ្លាំងស្តុកទំនិញ និងទីសត្វឃាត។ ឧស្សាហកម្មកែច្នៃមានភាព អន់ថយណាស់ សហគ្រាសឯកជន និងកសិករប្រឈមនឹងការខ្វះពត៌មានទីផ្សារ។ ចំពោះការចូលជាសមាជិកអង្គការ WTO ត្រូវនាំមកនូវការអនុវត្តន៍អ្វីៗ តាមស្តង់ដា។ ដើម្បីឆក់យកឱ្យបាននូវកាលានុវត្តភាពនៃការនាំចេញ និងការប្រឈមជាមួយការប្រកួតប្រជែងថ្មី នៃផលិតផលនាំចូលល័ក្ខខ័ណ្ឌនៃការស្វែងយល់ពីទីផ្សារ ត្រូវតែជំរុញឱ្យបានប្រសើរឡើង។
- ការវិនិយោគជាសាធារណៈ ជាសេចក្តីត្រូវការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហើយក្នុងករណីខ្លះ គេនឹងអាចអំពាវនាវរកការវិនិយោគឯកជន។ ប្រព័ន្ធផ្តល់ពត៌មាន អំពីទីផ្សារមួយត្រូវតែបង្កើតឡើង នៅក្នុងជំហានដំបូងមួយដោយសហគ្រាសសាធារណៈ ជាមួយនឹងការរួមចំណែកផ្នែកហិរញ្ញវត្ថុ នៃអ្នកប្រើប្រាស់ដើម្បីឈានទៅយកពត៌មាន។ ការអនុវត្តនូវស្តង់ដារនៃគុណភាពតម្រូវឱ្យមានការហ្វឹក-ហ្វឺន ព្រមជាមួយនឹងបណ្តាញផ្គត់ផ្គង់ ការធ្វើវិនិយោគ (ជាសាធារណៈឬជាឯកជន) នៅបន្ទប់ម៉ាស៊ីនត្រជាក់ មន្ទីរពិសោធន៏ ត្រួតពិនិត្យការបង្កើតក្រុមមន្ត្រីរាជការដ៏មានប្រសិទ្ធិភាពមួយក្រុម។
- ដើម្បីថែរក្សាកសិ-ឧស្សាហកម្មថ្មី ក្នុងបំណងរក្សាទុកតម្លៃបន្ថែម គេអាចអនុវត្តនូវបទបញ្ញត្តិគាំពារ ក្រោមក្បួនច្បាប់ទូទៅរបស់កិច្ចព្រមព្រៀង ស្តីពី តារាងពន្ធគយ និងពាណិជ្ជកម្ម (GATT) ដើម្បីថែរក្សាឧស្សាហកម្មទើបតែកើតថ្មី។

## សេចក្តីសន្និដ្ឋាន

១- អង្គការពាណិជ្ជកម្មពិភពលោកផ្តល់នូវក្របខ័ណ្ឌ សម្រាប់គោលនយោបាយពាណិជ្ជ-កម្មនៅក្នុងន័យទូលាយ។ ជាការពិតណាស់អង្គការ WTO បង្ហាញនូវឧបសគ្គ ប៉ុន្តែផ្តល់នូវលទ្ធភាព ដើម្បីអភិវឌ្ឍពាណិជ្ជកម្មកសិកម្ម។ កម្ពុជាបច្ចុប្បន្នបានក្លាយទៅជាសមាជិកអង្គការ WTO ដូច្នេះ យើងត្រូវតែអនុវត្តទាំងការប្តេជ្ញាចិត្តរបស់ខ្លួន។

២- ដើម្បីទាញយកឱកាស និងបន្ថយនូវភាពប្រថុយប្រថាន រដ្ឋាភិបាលកម្ពុជាមានតួនាទីជាចម្បងមានក្នុងការអនុវត្តន៍។ ក្នុងភាពសកម្មដោយគាំទ្រផ្នែកកសិកម្ម ដើម្បីទប់ទល់នឹងការប្រឈម ជាមធ្យោបាយតែមួយដើម្បីទាញយកផលប្រយោជន៍ទាំងស្រុងពីស្ថានភាពថ្មីនេះ ដោយសារតែការចូលជាសមាជិកអង្គការ WTO កសិកម្មកម្ពុជាត្រូវតែប្រឈមនឹងបញ្ហាជាច្រើន។

៣- បើយោងទៅតាមបទបញ្ញត្តិអង្គការ WTO ការអនុវត្តន៍អាចធ្វើទៅបានលុះត្រាតែបទបញ្ញត្តិអង្គការ WTO និងបទបញ្ញត្តិជាតិមានការកែប្រែដើម្បីឱ្យស៊ីសង្វាក់គ្នា។

៤- ក្នុងចំណោមច្បាប់ទាំងអស់ ការអនុវត្តន៍ SPS និងរបាំងបច្ចេកទេសលើការធ្វើពាណិជ្ជកម្ម (TBT) ទាមទារនូវជំនួយផ្នែកបច្ចេកវិទ្យា និងការកសាងសមត្ថភាព។

៥- អង្គការ WTO គឺស្ថិតនៅក្នុងដំណើរការចរចាជាអចិន្ត្រៃយ៍ កម្ពុជាត្រូវតែរៀបចំជំហររបស់ខ្លួននៅក្នុងដំណើរការនេះ។ ការងារនេះទាមទារឱ្យកម្ពុជា បញ្ជាក់ការកែលម្អក្នុងក្របខ័ណ្ឌអង្គការ WTO ដើម្បីគាំពារកសិកម្មកម្ពុជា និងជំរុញការអភិវឌ្ឍរបស់ខ្លួន ដើម្បីផ្តល់ពត៌មានទៅដល់ស្ថាប័នដទៃទៀត និងដើម្បីស្ថាបនាសម្ព័ន្ធភាព។

# ឯកសារយោង

១- ប៉ែនីឌិក មើមីឡាំង (២០០៤) "កសិកម្មកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក"

២- ទស្សនៈនៃការប្រកួតប្រជែងកសិកម្ម នៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងអង្គការពាណិជ្ជកម្មពិភពលោក (ខែកក្កដា ឆ្នាំ ២០០៤)

៣- កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ស្តីពី កសិកម្ម

៤- កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ស្តីពី ភូតគាមអនាម័យ (SPS)

# កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់ពលកម្មកម្ពុជា

**ឯកឧត្តម អ៊ុំ មាន**

**អនុរដ្ឋលេខាធិការ និងជាតំណាងឯកឧត្តមរដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ជាបឋម សូមអនុញ្ញាតឱ្យខ្លួនខ្ញុំ តាងនាមឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមសម្តែងនូវក្តីសោមនស្សរីករាយ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំនៃ *វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព* ដែលបានរៀបចំកម្មវិធីដ៏មានសារៈសំខាន់នេះ ព្រមទាំងបានផ្តល់កិត្តិយសឱ្យខ្ញុំបានចូលរួម និងថ្លែងបទអន្តរាគមន៍ក្នុងវេទិកានេះទៀតផង។

ដូចឯកឧត្តម លោកជំទាវ លោកស្រី អស់លោក សមាជិក សមាជិកានៃអង្គវេទិកាបានជ្រាបហើយថា រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ២ នៃរដ្ឋសភាបានអនុវត្តសម្រេច និងប្រកបដោយជោគជ័យជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រត្រីកោណ ធ្វើឱ្យគ្រប់វិស័យនៃសេដ្ឋកិច្ច សង្គមកិច្ចបានរីកចម្រើនគួរជាទីកត់សំគាល់ ជាក់ស្តែងវិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងបានរីកចម្រើនពីចំនួនប្រមាណ ៤០ រោងចក្រ មកដល់ពេលនេះមានចំនួនជាង ៣០០ រោងចក្រ កម្មកររីកចម្រើនពីចំនួនប្រមាណ ៣ ម៉ឺននាក់មកដល់ចំនួនជាង ២ សែននាក់។ ទំនិញនាំចេញនៃវិស័យនេះបាន

កើនពីប្រមាណ ៨០ ម៉ឺនដុល្លារអាមេរិកមក ១,៩០០ លានដុល្លារអាមេរិក នៅឆ្នាំ ២០០៤ កន្លងទៅនេះ។ ទិន្នន័យខាងលើនេះសរបញ្ជាក់ អំពីសារៈសំខាន់របស់វិស័យ ឧស្សាហកម្មកាត់ដេរ ក្នុងការរួមចំណែកបង្កើនចំណូលដល់ថវិកាជាតិ និងការបង្កើត ការងារធ្វើជូន ប្រជាពលរដ្ឋកម្ពុជា នេះគឺជាចំណែកមួយនៃការអនុវត្តន៍គោលនយោបាយ ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រទេសជាតិយើង។ ក្រៅពីនេះ វិស័យទេសចរណ៍ គមនាគមន៍ កសិកម្ម ។ល។ ក៏បានស្រូបយកកម្លាំងពលកម្ម ទាំងដោយផ្ទាល់ ទាំងដោយ ប្រយោលរាប់សែននាក់ផ្សេងទៀត។

ក្នុងដំណាក់កាល ដែលទីផ្សារការងារក្នុងប្រទេសស្រូបយកមិនអស់កម្លាំង ពលកម្មដែលមានកំណើនប្រមាណ ១៧,៦ % ជារៀងរាល់ឆ្នាំនោះ ទីផ្សារការងារក្រៅ ប្រទេសក៏ជាទិសដៅមួយដែរ ក្នុងការដោះស្រាយការងារជូនយុវជន និងពលករទាំង ពីរភេទ ដើម្បីលើកកម្ពស់ជីវភាពផង និងទទួលបាននូវការបណ្តុះបណ្តាល ឬបង្កើន ជំនាញវិជ្ជាជីវៈទៅតាមបច្ចេកវិទ្យាទំនើបផង។ កន្លងមក កម្ពុជាមានកិច្ចព្រមព្រៀងជា មួយប្រទេសមួយចំនួននៅក្នុងតំបន់ ក្នុងការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅក្រៅ ប្រទេស ក្នុងនោះយើងបានបញ្ជូនទៅប្រទេសម៉ាឡេស៊ី ចំនួនជិត ២,៥០០ នាក់ និងទៅ សាធារណរដ្ឋកូរ៉េបានជាង ១,៦០០ នាក់ រួចហើយ។ ពលករកម្ពុជាចំនួន ១៨ ម៉ឺននាក់ ដែលកំពុងរស់នៅ និងធ្វើការនៅក្នុងព្រះរាជាណាចក្រថៃឡង់ កំពុងទទួលការរៀបចំ ឯកសារបែបបទ ដើម្បីក្លាយទៅជាពលករស្របច្បាប់ ដែលបងប្អូននឹងទទួលនូវសិទ្ធិ ប្រយោជន៍ ដូចពលករជាតិថៃដែរ។ យើងនឹងខិតខំពង្រីកទំនាក់ទំនងជាមួយប្រទេស ផ្សេងទៀត ដើម្បីស្រូបយកកម្លាំងពលកម្មរបស់យើងថែមទៀត។

## អង្គការពាណិជ្ជកម្មពិភពលោក និងផលប៉ះពាល់ចំពោះពលកម្មកម្ពុជា

ព្រឹត្តិការណ៍មួយនេះ ដែលធ្វើឱ្យយើងទាំងអស់គ្នាសប្បាយរីករាយ និងមានមោទនភាពយ៉ាងខ្លាំង នោះគឺប្រទេសកម្ពុជាបានក្លាយជាប្រទេសទី ១ ក្នុងចំណោមប្រទេសក្រីក្រក្នុងការចូលជាសមាជិក ទី ១៤៧ នៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) កាលពីខែកញ្ញា ឆ្នាំ ២០០៣ កន្លងទៅនេះ។ ចាប់ពីឆ្នាំ ២០០៥ តទៅនេះ ការផ្តល់កូតាសម្រាប់នាំទំនិញទៅទីផ្សារសហរដ្ឋអាមេរិកត្រូវបានបញ្ចប់។

ក្នុងស្ថានភាពនេះ កម្ពុជាយើងមានផលវិបាក ២ យ៉ាង គឺផលវិបាកជាវិជ្ជមាន គឺទំនិញរបស់កម្ពុជាយើង នឹងត្រូវនាំទៅលក់ដោយសេរីនៅទីផ្សារនានាក្នុងពិភពលោក ដោយគ្មានកំណត់កូតាឡើយ។ រីឯផលវិបាកជាអវិជ្ជមាននោះគឺទំនិញរបស់កម្ពុជាយើង ពិសេសក្នុងវិស័យកាត់ដេរត្រូវចូលរួមប្រកួតប្រជែងអំពីទីផ្សារ ជាមួយបណ្តាប្រទេសដែលផលិតមុខទំនិញ ដូចយើងនេះដែរ។ តាមការសន្និដ្ឋានរបស់អ្នកជំនាញការសេដ្ឋកិច្ចអន្តរជាតិ ទៅអនាគតអាចមានប្រមាណជាង ១០ ប្រទេសប៉ុណ្ណោះ ដែលនឹងចូលរួមនៅក្នុងការប្រកួតប្រជែងក្នុងវិស័យកាត់ដេរ ក្នុងនោះមានប្រទេសធំៗ មួយចំនួននៅក្នុងតំបន់យើង ដូចជា ប្រទេសចិន ប្រទេសឥណ្ឌូនេស៊ី ប្រទេសថៃឡង់ដ៍ ប្រទេសវៀតណាម ប្រទេសបង់ក្លាដេស និងបណ្តាប្រទេសមួយចំនួន នៅក្នុងទ្វីបអាមេរិកឡាទីន និងទ្វីបអាហ្វ្រិកផងដែរ។ អ្នកជំនាញការសេដ្ឋកិច្ចអន្តរជាតិបានវាយតម្លៃថា កម្ពុជាជាប្រទេសមួយ ដែលអាចចូលរួមក្នុងការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិបាននឹងគេដែរ ក៏ប៉ុន្តែកម្ពុជាត្រូវខិតខំប្រឹងប្រែងអនុវត្តឱ្យបានល្អនូវប្រការ និងល័ក្ខខ័ណ្ឌជាគន្លឹះមួយចំនួន គឺ :

- ការអនុវត្តន៍ល័ក្ខខ័ណ្ឌការងារពិគ្រប់ភាគីពាក់ព័ន្ធឱ្យបានល្អ
- ការបង្កើនគុណភាពផលិតផល
- ការដោះស្រាយបញ្ហាថ្លៃទំនិញ

- ការដោះស្រាយបញ្ហារយៈពេលបញ្ជូនផលិតផលទៅដល់ទីផ្សារ ។

កន្លងមក ប្រទេសកម្ពុជាយើងបានទទួលចំណាត់ថ្នាក់លំដាប់ទី ១ អំពីការអនុវត្តន៏ល័ក្ខខ័ណ្ឌការងារ ដែលក្នុងនោះប្រទេសជិតខាង ដូចជា ប្រទេសថៃឡង់ដ៏ បានទទួលលំដាប់ទី ៤ រីឯប្រទេសចិន ប្រទេសវៀតណាម និងប្រទេសបង់ក្លាដេសស្ថិតក្នុងលំដាប់ទី៨។ ប្រការនេះ គឺជាសក្តានុពលភាពដ៏វិសេសរបស់កម្ពុជាយើង ដែលគ្រប់ភាគីពាក់ព័ន្ធត្រូវតែចូលរួមគ្នា បន្តអនុវត្តឱ្យកាន់តែប្រសើរថែមទៀត ។

យោងតាមតារាងស្ថិតិ រោងចក្រកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងដែលក្រសួងមានជាផ្លូវការត្រឹមខែឧសភា ឆ្នាំ២០០៥ នេះបានបញ្ជាក់ ឱ្យយើងកត់សំគាល់ថា មានរោងចក្រចំនួន ១៦ ត្រូវបិទទ្វារជាស្ថាពរ ដែលមានកម្មករនិយោជិតរួមចំនួន ១៤,០៧៩ នាក់ ក្នុងនោះមានកម្មការិនីចំនួន ៩,៤៨៩ នាក់ និងរោងចក្រចំនួន ៤៨ ត្រូវព្យួរមួយរយៈដែលមានកម្មករនិយោជិករួមចំនួន ២៨,៩៤៤ នាក់ ក្នុងនោះមានកម្មការិនីចំនួន ៣៨,៧០៨ នាក់។ មូលហេតុ នៃការបិទ និងព្យួររោងចក្រខាងលើនេះគឺរោងចក្រមួយចំនួនមានខ្នាតតូច និងជារោងចក្រទទួលដេរបន្តពីរោងចក្រធំៗ។ រោងចក្រជួបប្រទះការលំបាកអំពីការរកទីផ្សារ ទន្ទឹមនឹងនោះ មានបញ្ហាវិវាទក្នុងរោងចក្រញឹកញាប់ពេកដែលបង្កភាពរអាក់រអួលក្នុងការបញ្ជូនទំនិញ។ ផ្ទុយទៅវិញ មានរោងចក្រថ្មីចំនួន ៣៦ បានដំណើរការ ហើយដែលបានស្រូបយកពលករចូលធ្វើការចំនួន ៦,៩៣១ នាក់ ក្នុងនោះមានកម្មការិនីចំនួន ៦,០០៥ នាក់។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាសេនាធិការមួយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៣នៃរដ្ឋសភា មានទស្សនវិស័យ គោលនយោបាយរបស់ខ្លួនគឺអនុវត្ត និងសហការអនុវត្តជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ***នូវកម្មវិធី***

*នយោបាយ* និង*យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា* ដែលជាត្រីវិស័យដើម្បីសម្រេចភារកិច្ចដោយជោគជ័យ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យល់ឃើញថា ក្រសួង និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងភាគីនិយោជក និងកម្មករនិយោជិតទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តតាមអនុសាសន៍របស់ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលសម្តេចបានថ្លែងតាមសារលិខិត ក្នុងឱកាសទិវាពលកម្មអន្តរជាតិ *១ ឧសភា ២០០៥* កន្លងទៅថ្មីៗនេះ ។ អត្ថន័យជាសារវ័ន្តនៃអនុសាសន៍ នោះគឺការជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ជាពិសេសលើឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ក្នុងទិសដៅ *"ខិតខំរក្សានិរន្តរភាព និងការអភិវឌ្ឍន៍ឧស្សាហកម្មកាត់ដេរ ដើម្បីការប្រកួតប្រជែង និងការបង្កើតការងារជូនពលរដ្ឋកម្ពុជា"*។

ដើម្បីសម្រេចបានគោលបំណងដ៏ពិសិដ្ឋខាងលើនេះ ភាគីពាក់ព័ន្ធនានាត្រូវអនុវត្តដោយយកចិត្តទុកដាក់នូវការងារមួយចំនួន ដូចខាងក្រោមនេះ :

១- ក្រុមហ៊ុនកាត់ដេរត្រូវខិតខំលើកកម្ពស់បច្ចេកទេស តាមរយៈការប្រើប្រាស់សម្ភារៈ និងបរិក្ខាផលិតកម្មទំនើប និងការហ្វឹកហ្វឺនកម្មករនិយោជិត ជាបន្តបន្ទាប់ដើម្បីលើកកម្ពស់ថែមទៀតនូវផលិតភាព និងគុណភាពទំនិញកាត់ដេរកម្ពុជាឱ្យស្របទៅតាមល័ក្ខខ័ណ្ឌ និងតម្រូវការរបស់ទីផ្សារ ។

២- បន្តគោលនយោបាយលើកទឹកចិត្តដល់អ្នកវិនិយោគ តាមច្បាប់ស្តីពីការវិនិយោគទុន ព្រមទាំងបង្កើតកម្មវិធីអប់រំផ្សព្វផ្សាយសង្គមជាតិទាំងមូល អំពី សារៈសំខាន់នៃការវិនិយោគដើម្បីបង្កើតរោងចក្រសហគ្រាស បង្កើតការងារធ្វើជូនប្រជាពលរដ្ឋឱ្យច្រើនថែមទៀត ។ ការលើកទឹកចិត្តការវិនិយោគទុន ត្រូវដើរស្របគ្នានឹងការជំរុញឱ្យអ្នកវិនិយោគត្រូវគោរពច្បាប់ស្តីពីការងារ និងសិទ្ធិរបស់កុមារ ។ ទន្ទឹមនឹងនោះ

ត្រូវការពារសិទ្ធិស្របច្បាប់របស់គ្រប់ ភាគីពាក់ព័ន្ធផងដែរ ជាពិសេសចៀសវាងឱ្យបានដាច់ខាតការប្រើប្រាស់អំពើហិង្សា ក្នុងសកម្មភាពស្វែងរកដំណោះស្រាយ និងក្នុងដំណើរការផ្សះផ្សាវិវាទ។ បើគ្មានវិនិយោគ ឬមានការវិនិយោគហើយ ប៉ុន្តែត្រូវដួលរលំទៅវិញនោះ ពុំមែនមានតែភាគីនិយោជកប៉ុណ្ណោះទេ ដែលត្រូវខាតបង់ ប៉ុន្តែ ជីវភាពកម្មករនិយោជិតក៏ត្រូវរងផលប៉ះពាល់ដែរ។ ត្រូវយើងចងចាំថា យើងកំពុងដើរ លើមាគ៌ានៃការប្រកួតប្រជែងទីផ្សារ ដើម្បីលក់ទំនិញរបស់កម្ពុជាយើង ហេតុនេះ យើងទាំងអស់គ្នាត្រូវប្តេជ្ញាចិត្តខិតខំប្រឹងប្រែង ដើម្បីទិសដៅរួមដូចពោលខាងលើ។

៣- បន្តលើកតម្កើងកេរ្តិ៍ឈ្មោះ និងកិត្តិសព្ទដ៏ល្អរបស់ទំនិញកម្ពុជា ដែលទីផ្សារអន្តរជាតិ ជាពិសេស ទីផ្សារអាមេរិក និងសហគមន៍អឺរ៉ុបបានទទួលស្គាល់ថា នៅកម្ពុជាមិនមានការងារដោយបង្ខំ មិនមានការរើសអើង មិនមានការប្រើប្រាស់ពលកម្មកុមារ និងបានអនុវត្តត្រឹមត្រូវតាមបទដ្ឋានអន្តរជាតិខាងការងារ។ ក្នុងន័យនេះ យើងត្រូវខិតខំពង្រឹង និងពង្រីកស្នារតីនៃលទ្ធផលរបស់គម្រោងឃ្លាំមើលល័ក្ខខ័ណ្ឌការងារនៅកម្ពុជា។ អង្គការអន្តរជាតិខាងការងារដែលយើងចាត់ទុកថា ជាការត្រួសត្រាយផ្លូវដ៏មានសារៈសំខាន់សម្រាប់ការអនុវត្តន៏ច្បាប់ ស្តីពី ការងារ ការរក្សាទំនាក់ទំនងល្អរវាងកម្មករនិយោជិត និងនិយោជក ទាំងរយៈពេលចំពោះមុខ និងទៅអនាគតយូរអង្វែង។

៤- ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការក្នុងការបន្តថែរក្សាទីផ្សារធំៗ ដែលធ្លាប់ផ្តល់ភាពអនុគ្រោះសម្រាប់នាំទំនិញចេញរបស់កម្ពុជា មានជាអាទិ៍ ទីផ្សារសហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ជប៉ុន កាណាដា ។ល។ ទន្ទឹមនឹងនេះ ត្រូវខិតខំបង្កលក្ខណៈឱ្យសេវាដឹកជញ្ជូន និងសេវាកម្មផ្សេងៗ ដែលពាក់ព័ន្ធបានចុះថោក ដើម្បី

បន្ថយថ្លៃដើមទំនិញ ព្រមទាំងកាត់បន្ថយរយៈពេលនាំចេញទំនិញ ដែលទាំងអស់នេះក៏ជាកត្តាមូលដ្ឋាន បង្កភាពងាយស្រួលក្នុងការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិផងដែរ ។

៥- បន្តពង្រឹង និងពង្រីកភាពជាដៃគូជាមួយផ្នែកឯកជន តាមរយៈការពង្រឹងក្រុមការងារចម្រុះ ដែលមានស្រាប់ជាយន្តការពិគ្រោះយោបល់ ។ កិច្ចប្រជុំវេទិការវាងរាជរដ្ឋាភិបាល និងឯកជន គឺជាឱកាសដែលភាគីពាក់ព័ន្ធអំពីវិនិយោគ និងធុរៈកម្មពិនិត្យ និងដោះស្រាយបញ្ហាបានដោយផ្ទាល់ និងឆាប់រហ័ស ។

៦- ក្នុងអាណត្តិកន្លងមកនេះ អតីតក្រសួងសង្គមកិច្ចការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានខិតខំដោះស្រាយដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតវិស័យកាត់ដេរពី ៤០ ទៅ ៤៥ ដុល្លារអាមេរិក ហើយនិងមានប្រាក់រង្វាន់មួយចំនួនថែមទៀត ។ ក្នុងស្ថានភាពសេដ្ឋកិច្ចអំណោយផល មានន័យថានៅពេលដែលបញ្ហាការិយាល័យធិបតេយ្យត្រូវបានកែទម្រង់ ការប្រកួតប្រជែងរបស់យើងនៅលើទីផ្សារអន្តរជាតិទទួលបានជោគជ័យ ក្រសួងនឹងពិចារណាជំរុញការតម្លើងប្រាក់ឈ្នួលជូនកម្មករថែមទៀត តាមរយៈការចរចាសមូហភាពដែលគ្រប់ភាគីអាចទទួលយកបាន ហើយនិងធានាបានថា អ្នកវិនិយោគរក្សានិរន្តរភាព ឬបន្តការសាងសង់រោងចក្រនៅកម្ពុជាថែមទៀត ដែលធ្វើឱ្យកម្មករនិយោជិករាប់សែននាក់របស់យើងនៅមានការងារបន្ត ឬប្រជាពលរដ្ឋកម្ពុជាយើងអាចមានការងារបន្ថែមទៀត ។

៧- ក្នុងគោលបំណងការពារ និងបង្កើតមុខរបរជូនកម្មករ និយោជិក ក៏ដូចជាប្រជាពលរដ្ឋកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា មានគម្រោងបង្កើតតំបន់ឧស្សាហកម្មកែច្នៃសម្រាប់នាំចេញ គម្រោងអភិវឌ្ឍន៍ផ្នែកកសិឧស្សាហកម្ម គម្រោងអភិវឌ្ឍន៍

ទេសចរណ៍ ឧស្សាហកម្មធុនតូច និងមធ្យម ដែលត្រូវការប្រើប្រាស់កម្លាំងពលកម្មរាប់សែននាក់ ដើម្បីស្រូបយកកម្លាំងពលកម្មសេសសល់ក្នុង ករណីវិស័យកាត់ដេរជួបការលំបាក ។

*ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក សមាជិក សមាជិកា នៃអង្គប្រជុំជាទីគោរព និងជាទីរាប់អាន*

ការលើកគោលនយោបាយ ឬទិសដៅភារកិច្ចសម្រាប់ការអនុវត្តន៍ គឺជាការលំបាកមួយហើយ ពីព្រោះទាមទារនូវការវាយតម្លៃការអនុវត្តន៍ និងលទ្ធផលកន្លងមកឱ្យបានត្រឹមត្រូវសម្រាប់ធ្វើជាមូលដ្ឋាននៃទស្សនវិស័យ ។ ប៉ុន្តែ អ្វីដែលលំបាកជាងនេះទៅទៀត គឺការចេះអនុវត្តន៍ឱ្យសម្រេចគោលនយោបាយ ឬទិសដៅនោះ ។ ដូច្នេះទាមទារឱ្យយើងទាំងអស់គ្នាដែលជាដៃគូ និងភាគីពាក់ព័ន្ធក្នុងសង្គមស្វែងយល់ និងចូលរួមប្រកបដោយសុឆន្ទៈ មិនមើលបំណាំ និងយ៉ាងសកម្មបំផុត ។ ការរួបរួមគ្នា ការរក្សាសាមគ្គីភាព ការចេះថែរក្សាភាពសុខដុមរមនារវាងភាគីពាក់ព័ន្ធ ការខិតខំប្រឹងប្រែងជម្នះគ្រប់ ឧបសគ្គដោយស្មារតីស្រឡាញ់ជាតិមាតុភូមិ និងកិត្តិយសប្រទេសជាតិ ប្រាកដជានឹងអាចឱ្យយើងទទួលបានជោគជ័យ ក្នុងការប្រកួតប្រជែងទីផ្សារអន្តរជាតិពិតជាមិនខាន ។

ក្នុងន័យនេះ តាងនាមឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងខ្លួនខ្ញុំផ្ទាល់ សូមអំពាវនាវចំពោះអង្គការវិជ្ជាជីវៈ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិទាំងអស់ សូមបន្តចូលរួមឱ្យកាន់តែសកម្មថែមទៀត អំពីការងារអប់រំ និងផ្សព្វផ្សាយនូវខ្លឹមសារច្បាប់ ស្តីពីការងារ លិខិតបទដ្ឋាន និងគោលការណ៍នានារបស់អង្គការពលកម្មអន្តរជាតិជូននិយោជក និងបងប្អូនកម្មករ និយោជិកឱ្យបានជ្រួតជ្រាប

និងរួមគ្នាអនុវត្តឱ្យបានល្អប្រសើរ ដើម្បីសម្រេចតាមគោលបំណងដ៏ពិសិដ្ឋ របស់យើងទាំងអស់គ្នា គឺ ***មានវិនិយោគមានការងារធ្វើមានល័ក្ខខ័ណ្ឌការងារល្អ មានភាពយោគ-យល់គ្នា មានភាពសុខដុមរមនា មានជោគជ័យក្នុងការប្រកួតប្រជែង មានជីវភាពធូរធា មានសេដ្ឋកិច្ចជាតិរីកចម្រើនមានប្រទេសជាតិរុងរឿង*** ។

ជាទីបញ្ចប់ និងសារជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើយ៉ាងស្មោះស្ម័គ្រ ចំពោះការចាត់ចែងរៀបចំការប្រជុំវេទិកានាពេលនេះ ដែលបានដំណើរការប្រកបដោយបរិយាកាសសាមគ្គីភាព ភារតភាព និងសប្បាយរីករាយ ។

សូមជូនពរ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក សមាជិក សមាជិកាអង្គប្រជុំទាំងអស់ ប្រកបដោយពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លាងឃ្លាតឡើយ ។

# តើមានផលប៉ះពាល់យ៉ាងណាចំពោះសមាជិក WTO របស់កម្ពុជានៅលើឧស្សាហកម្មកាត់ដេរ

**លោក យា ប៊ុនណា**

**អនុប្រធាននាយកដ្ឋាន កិច្ចការឧស្សាហកម្ម និងជាប្រធានអង្គភាពផលិតភាពអាស៊ី**

**នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល**

ក្រោយពេលខិតខំប្រឹងប្រែងអស់រយៈពេលជិត ៩ ឆ្នាំ ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO នៅថ្ងៃទី១៣ តុលា ២០០៤ ក្រោមការផ្តល់សច្ចាប័នពីរដ្ឋសភា និងមានការអនុម័តយល់ព្រមរបស់ព្រឹទ្ធសភាជាតិកម្ពុជា។ ក្នុងនាមជាសមាជិក WTO កម្ពុជានឹងមានឱកាសលើវិស័យពាណិជ្ជកម្មជាមួយបណ្តាប្រទេសជាច្រើន ដោយឈរលើគោលការណ៍ច្បាប់ និងវិធានការនានាប្រកបដោយតម្លាភាព។

ជាមួយនឹងលទ្ធផលនៃការខិតខំប្រឹងប្រែងរហូតបានក្លាយជាសមាជិក WTO នេះ មានមតិជាច្រើនបានវែកញែកអំពីផលប៉ះពាល់ ក៏ដូចជា លទ្ធភាពដែលកម្ពុជាអាចទទួលបាននូវប្រយោជន៍ ពីសមាជិកភាពនៃអង្គការនេះ។ ហើយនៅក្នុងវេទិកាដែលវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បានរៀបចំឡើងនៅពេលនេះ ក៏នឹងពិភាក្សាអំពីផលប៉ះពាល់នៃសមាជិកភាពកម្ពុជាក្នុង WTO ទៅលើឧស្សាហកម្មកាត់ដេរ ដែលបច្ចុប្បន្នជាឧស្សាហកម្មឈានមុខ ក្នុងការផ្តល់ការងារធ្វើដល់ពលករខ្មែររហូតដល់

២៩៥,៨៧៦ នាក់។ ដូច្នេះវាសនាឧស្សាហកម្មកាត់ដេររបស់កម្ពុជា នៅពេលអនាគតមានសារៈសំខាន់ល្មមឱ្យមានការចាប់អារម្មណ៍ ដើម្បីរកវិធានការការពារកុំឱ្យផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសេដ្ឋកិច្ច សង្គមកម្ពុជា ក្នុងករណីមានសភាពការណ៍អាក្រក់កើតឡើង។

ក្រោយខែមករា ឆ្នាំ ២០០៥ បន្ទាប់ពីកិច្ចព្រមព្រៀងវាយនភណ្ឌត្រូវបានបញ្ចប់ បណ្តាប្រទេសដែលទទួលបានផលប្រយោជន៍ ពីការផ្តល់កូតាសម្លៀកបំពាក់នាំចូលទៅក្នុងសហរដ្ឋអាមេរិក។ កម្ពុជាមានការព្រួយបារម្ភអំពីការដែលមិនអាចប្រកួតប្រជែងជាមួយប្រទេសធំ ដូចជា ចិនដែលកំពុងមានលទ្ធភាពផលិតនូវសម្លៀកបំពាក់ប្រកបដោយចំណាយផលិតកម្មដ៏ទាប។ ហើយមកដល់ពេលនេះ មានរយៈពេល ៦ខែ ហើយគេនៅពុំទាន់ឃើញមានអ្វីធ្ងន់ធ្ងរកើតមានដល់ឧស្សាហកម្មកម្ពុជាឡើយ។

យោងតាមតួលេខ ពីសមាគមផលិតករកាត់ដេរកម្ពុជា មកដល់ពេលនេះចំនួនរោងចក្រនៅកម្ពុជាបានបិទអស់ចំនួន ១១ រោងចក្រ ប៉ុន្តែរោងចក្រកាត់ដេរដែលសុំបើកថ្មីមានចំនួន២៣ ហើយរោងចក្រដែលកំពុងដំណើរការផលិតកម្មមាន២៤០ (សូមពិនិត្យមើលតារាងជូនភ្ជាប់)។

ក្នុងចំណោមរោងចក្រដែលបើកថ្មីទាំង ២៣ នេះភាគច្រើនជារោងចក្រមកពីប្រទេសចិន (១៥រោងចក្រ) និងបន្ទាប់ពីចិនគឺប្រទេសកូរ៉េ (៥រោងចក្រ)។ ដូច្នេះផលិតករផ្នែកសម្លៀកបំពាក់របស់ចិន ប្រហែលជាមានយុទ្ធសាស្ត្របង្កើនការវិនិយោគផ្នែកនេះមកកម្ពុជា តាមសេចក្តីតម្រូវរបស់អតិថិជនដែលបញ្ជាទិញ ជាពិសេសពីទីផ្សារសហរដ្ឋអាមេរិក ដែលរដ្ឋាភិបាលអាមេរិកបានដាក់នូវវិធានការដាក់ស្តែងមួយទប់ស្កាត់ទំនិញផ្នែកសម្លៀកបំពាក់ដែលហូរគំហុកមកពីប្រទេសចិន។ ឧស្សាហកម្មកាត់ដេរនៅកម្ពុជាហាក់ដូចជាមានវាសនាផ្សារភ្ជាប់យ៉ាងសំខាន់ ជាមួយល័ក្ខខណ្ឌអភិវឌ្ឍក្នុងវិស័យ

កាត់ដេររបស់អង្គការពាណិជ្ជកម្មពិភពលោក ជាពិសេសគឺប្រតិកម្មរបស់សមាជិកដ៏សំខានមួយនៃអង្គការនេះ នោះគឺសហរដ្ឋអាមេរិក។

**សង្ខេបចលនានៃចំនួនរោងចក្រកាត់ដេរនៅកម្ពុជាពីឆ្នាំ ១៩៩៦ -២០០៥**

| ល.រ | ឆ្នាំ | រោងចក្របង្កើតថ្មី | រោងចក្របិទទ្វា | រោងចក្រដែលកំពុងដំណើរការ |
|---|---|---|---|---|
| 1 | 1996 | 48 | 0 | 48 |
| 2 | 1997 | 28 | 0 | 76 |
| 3 | 1998 | 63 | 1 | 138 |
| 4 | 1999 | 47 | 1 | 184 |
| 5 | 2000 | 34 | 23 | 195 |
| 6 | 2001 | 13 | 19 | 189 |
| 7 | 2002 | 12 | 7 | 194 |
| 8 | 2003 | 20 | 7 | 207 |
| 9 | 2004 | 30 | 9 | 228 |
| 10 | 2005 | 23 | 11 | 240 |
| 96 - May 05 | | **318** | **78** | **240** |

ចំនួនកម្មករសរុប ២៥៥,៨៧៦ នាក់

ចំនួនកម្មករស្រី ២៣៣,៣១២ នាក់

ចំនួនកម្មករប្រុស២២,៥៦៤ នាក់

តើកម្ពុជាគួរតែរង់ចាំមើល និងផ្ញើវាសនាទៅលើការអភិវឌ្ឍន៍ នៃអង្គការពាណិជ្ជកម្មពិភពលោក និងប្រតិកម្មរបស់សហរដ្ឋអាមេរិក ឬយ៉ាងណា?

ដោយប្រមើលមើលអំពីការបង្កើនផលិតភាពនៅកម្ពុជា ឃើញថាអាចជាសកម្មភាពមួយរួមចំណែក ក្នុងការរួមកម្លាំងដោះស្រាយបញ្ហាប្រឈម ដែលកម្ពុជានឹងត្រូវជួបប្រទះក្រោយពីការចូលជាសមាជិកនៃអង្គការ WTO។ ចាប់ពីឆ្នាំ ២០០៣ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានខិតខំប្រឹងប្រែងសុំចូល ជាសមាជិកអង្គការផលិតភាពអាស៊ី (Asian Productivity Organization, APO) ដែលជាអង្គការ

មួយត្រូវបានគេទទួលស្គាល់ថា ជាស្ថាប័នដែលមានឯកទេស និងបទពិសោធន៍គ្រប់គ្រាន់លើការជំរុញ និងលើកកម្ពស់ផលិតភាពនៅអាស៊ី ហើយដែលថ្មីៗនេះ អង្គការនេះមានគម្រោងពង្រីកសកម្មភាពរបស់ខ្លួនទៅក្រៅទ្វីបអាស៊ីថែមទៀត (ទិសដៅចំពោះមុខគឺឆ្ពោះទៅទ្វីបអាហ្វ្រិក)។ ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានខិតខំបំពេញសំណុំបែបបទ និងសេចក្ដីតម្រូវរបស់អង្គការផលិតភាពអាស៊ីនេះ រហូតដល់បានទទួលការអនុម័តពីកិច្ចប្រជុំគណៈគ្រប់គ្រងអង្គការ ផលិតភាពអាស៊ីលើកទី ៤៦ ឱ្យកម្ពុជាបានចូលជាសមាជិកទី ២០ នៅថ្ងៃទី ១៧ ឧសភា ២០០៤។

ការចូលជាសមាជិកនៃអង្គការនេះ គឺសំដៅចូលរួមចលនាលើកកម្ពស់ផលិត-ភាព ដែលនឹងជួយដល់ការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងដល់ឧស្សាហកម្មកាត់ដេរកម្ពុជា ក៏ដូចជាឧស្សាហកម្មនានា ជាពិសេសគឺឧស្សាហកម្ម និងសិប្បកម្មធុនតូច និងមធ្យម ព្រមទាំងលើកកម្ពស់ផលិតភាពដល់វិស័យកសិកម្ម ពាណិជ្ជកម្ម ដែលរួមចំណែកបង្កើនមុខផលិតផលនាំចេញ សំដៅទាញយកប្រយោជន៍ឱ្យបានច្រើនជាអតិបរិមា ពីការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា។

អង្គការផលិតភាពអាស៊ីមានទីស្នាក់ការកណ្ដាលទីក្រុងតូក្យូដើម្បីបម្រើការងារឱ្យសមាជិកទាំង២០។ ចលនាលើកកម្ពស់ផលិតភាពនៃអង្គការផលិតភាពអាស៊ី បាននឹងកំពុងផ្ដោតទៅមុខព្រួញសំខាន់៧ប្រាំគឺ :

**ពង្រឹងសហគ្រាសធុនតូច និងមធ្យម** (Strengthening of Small and Medium Enterprises): គឺជួយដល់សហគ្រាសធុនតូច និងមធ្យមឱ្យមានលទ្ធភាពប្រកួតប្រជែងនៅលើទីផ្សារជាតិ និងអន្តរជាតិ តាមរយៈការលើកកម្ពស់សហគ្រិនភាព ការគ្រប់គ្រង និងជំនាញបច្ចេកទេស។

**កម្មវិធីអភិវឌ្ឍន៍សហគមន៍** (Integrated Community Development): គឺជួយប្រទេសជាសមាជិកទាំងអស់ ឱ្យសម្រេចបាននូវតុល្យភាពអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីកាត់បន្ថយភាពក្រីក្រ បង្កើនការងារធ្វើអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម លើកកម្ពស់សហគ្រិនភាព និងលើកស្ទួយផ្នែកនៃសង្គមដែលខ្វះលទ្ធភាព រួមទាំងផ្នែកស្ត្រីផងដែរ ។

**ផលិតភាពបៃតង** (Green Productivity): គឺជួយគាំទ្រដល់ប្រទេសជាសមាជិកឱ្យការពារបាននូវការបំពុលបរិស្ថាន តាមរយៈការលើកកម្ពស់ផលិតភាព និងពង្រឹងសមត្ថភាពអង្គភាពផលិតភាពជាតិ ដើម្បីអនុវត្តកម្មវិធីផលិតភាពបៃតង ។

**ការគ្រប់គ្រងពុទ្ធិ** (Knowledge Management):ការគ្រប់គ្រងពុទ្ធិ គឺការស្វែងរកការគ្រប់គ្រង ហើយអនុវត្តពុទ្ធិដើម្បីធ្វើឱ្យប្រសើរឡើង នូវសមត្ថភាពការងាររបស់បុគ្គលម្នាក់ៗ ក្នុងការប្រកួតប្រជែងនៅផ្ទៃក្នុងសហគ្រាស និងនៅក្នុងការអភិវឌ្ឍន៍ជាតិ ។ ការគ្រប់គ្រងពុទ្ធិអាចអនុវត្តបានទាំងនៅ ក្នុងបច្ចេកវិជ្ជាជាន់ខ្ពស់ ក្នុងឧស្សាហកម្ម និងកសិកម្មផងដែរ ។ កម្មវិធីនេះ គឺជួយប្រទេសជាសមាជិកឱ្យរៀបចំបាននូវអន្តរកាលនៃមូលដ្ឋានពុទ្ធិសេដ្ឋកិច្ច (Knowledge-based Economies) ។

**អភិវឌ្ឍអង្គការផលិតភាពជាតិ** (Development on National Productivity Organization NPOs) ក្នុងមុខព្រួញអភិវឌ្ឍអង្គការផលិតភាពជាតិ ដែលហៅកាត់ថា DON នេះគឺអង្គការផលិតភាពអាស៊ីមានគោលដៅពង្រឹងអង្គការផលិតភាពជាតិ ដោយកសាងសមត្ថភាពផ្តល់សេវាកម្ម និងជំរុញចលនាផលិតភាពដើម្បីទាក់ទាញចំណាប់អារម្មណ៍អ្នកធ្វើគោលនយោបាយ និងថ្នាក់ដឹកនាំឱ្យរួមចំណែកបង្កើតជាចលនាផលិតភាពជាតិទាំងមូល ។

ពិនិត្យទៅលើមុខព្រួញសំខាន់ៗទាំងប្រាំ នៃអង្គការផលិតភាពអាស៊ីបានឆ្លុះបញ្ចាំងសកម្មភាពអង្គការនេះ ដែលបានផ្សារភ្ជាប់ទៅនឹងនិន្នាការវិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចនិងសង្គមនៅក្នុងដំណាក់កាលបច្ចុប្បន្ន ហើយភាគច្រើន គឺសមស្របទៅនឹងសភាពការណ៍សេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា កម្ពុជា និងឡាវផងដែរ។ នៅក្នុងឱកាសនៃកិច្ចប្រជុំកំពូលរបស់អង្គការផលិតភាពអាស៊ីលើកទី ៤៧ ក្នុងខែមិថុនា ឆ្នាំ២០០៥ នេះ ប្រទេសជប៉ុនតាមរយៈក្រសួងការបរទេស និងក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម ជប៉ុនបានបង្ហាញនូវជំហរ និងការប្តេជ្ញាចិត្តយ៉ាងចំហរបស់ខ្លួនក្នុងការជួយជាពិសេសដល់សមាជិកអង្គការ ផលិតភាពអាស៊ីដែលជាប្រទេសកំពុងអភិវឌ្ឍ ដូចជា កម្ពុជា និងឡាវ ដើម្បីកាត់បន្ថយនូវគំលាតនៃកម្រិតអភិវឌ្ឍន៍ ពិសេសគឺគំលាតនៅក្នុងសមាជិកអាស៊ាន។ កម្ពុជានឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើន ពីការចូលជាសមាជិកភាព ក្នុងអង្គការផលិតភាពអាស៊ីនេះ។

ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក៏បានយកចិត្តទុកដាក់ទៅលើផលិតកម្មនៃឧស្សាហកម្មធុនតូច និងមធ្យម តាមរយៈការអនុគណៈកម្មាធិការឧស្សាហកម្មធុនតូច និងមធ្យម ដែលបាននឹងកំពុងដោះស្រាយឧបសគ្គនានា លើយន្តការអន្តរក្រសួងជាមួយតំណាងផ្នែកឯកជន និងសហគមន៍អន្តរជាតិ ស្របតាមភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលក៏បានរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ ក៏ដូចជាបានបង្កើតច្បាប់នានាមានជាអាទិ៍ ច្បាប់ស្តីពីអគ្គិសនី ច្បាប់ស្តីពីការគ្រប់គ្រងធនធានរ៉ែ ច្បាប់ស្តីពីការប្រកាសនីយប័ត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ។ល។ ហើយកំពុងរៀបចំសេចក្តីព្រាងច្បាប់មួយចំនួនដូចជា ច្បាប់គ្រប់គ្រងរោងចក្រ ចងក្រងគោលនយោបាយឧស្សាហកម្មធនតូចនិងមធ្យម ច្បាប់ស្តង់ដារឧស្សាហកម្មកម្ពុជា ច្បាប់ស្តីពីមាត្រសាស្ត្រ

។ល។ ច្បាប់ទាំងអស់នេះ ក៏ជាមូលដ្ឋានគ្រឹះក្នុងការចូលរួមចំណែកលើកកម្ពស់ទាក់ទាញវិនិយោគពីបរទេស និងក្នុងស្រុក ដើម្បីបង្កើនផលិតកម្មសម្រាប់មុខផលិតផលផ្សេងៗទៀត ដែលផ្តល់ឱកាសដោយសមាជិកភាពរបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក សំដៅបង្កើតឱ្យមានការងារធ្វើក្រៅពីវិស័យកាត់ដេរ។

នៅក្នុងដំណាក់កាល ដែលកម្ពុជាកំពុងមានការព្រួយបារម្ភ អំពីវាសនានៃវិស័យផលិតកម្មកាត់ដេរ ការចូលជាសមាជិករបស់កម្ពុជា ទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ក៏នឹងអាចផ្តល់នូវឱកាសល្អសម្រាប់កម្ពុជាផងដែរ ប្រសិនបើកម្ពុជាអាចបង្កើតបរិស្ថានអាជីវកម្មមួយល្អសម្រាប់វិស័យឯកជន ដើម្បីទាក់ទាញការវិនិយោគពីបរទេស និងសម្រាប់អ្នកវិនិយោគក្នុងស្រុក។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលត្រូវខិតខំបង្កើនលទ្ធភាពឱ្យមានភាពជាដៃគូរវាងវិស័យឯកជន និងរដ្ឋបាលសាធារណៈកាន់តែប្រសើរឡើង តាមរយៈការផ្តល់លទ្ធភាពឱ្យវិស័យឯកជន បានទទួលនូវពុទ្ធិថ្មីៗ ទាំងផ្នែកគ្រប់គ្រង និងបច្ចេកវិជ្ជាជាដើមដោយបង្កលទ្ធភាព ទទួលការបណ្តុះបណ្តាលទាំងនៅក្នុងស្រុក និងក្រៅស្រុក។ ការផ្តល់លទ្ធភាពឱ្យអ្នកវិនិយោគក្នុងស្រុក ជាពិសេសគឺសម្រាប់សហគ្រាសធុនតូច និងមធ្យមងាយរកខ្ចីបាននូវទុនវិនិយោគ ដោយពង្រឹងប្រព័ន្ធច្បាប់ដែលអាចផ្តល់ការការពារដល់ប្រភពឱ្យខ្ចីប្រាក់ ក៏ជាសកម្មភាពមួយដ៏ប្រសើរផងដែរ។

ជារួម កម្ពុជានៅមានមធ្យោបាយច្រើនទៀត ដែលត្រូវអនុវត្តដើម្បីឈានទៅរកជោគជ័យ ពីការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ការរួបរួមគ្នា និងប្រឹងប្រែងប្រកបដោយសុទិដ្ឋិនិយមទូទាំងកម្ពុជាជាកត្តាសំខាន់បំផុត។

# កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : តើមានផលប៉ះពាល់អ្វីខ្លះទៅលើកម្មវិធីកាត់បន្ថយភាពក្រីក្រ?

**លោកស្រី ហ្វូត រតនៈ**

**នាយិកា អង្គការវេទិកាទូទៅនៃកម្ពុជា**

ថ្ងៃនេះខ្ញុំមានសេចក្តីរីករាយ ដែលបានមកចូលរួមធ្វើចំណាប់អារម្មណ៍ ក្នុងអង្គវេទិកាលើកទី៦ ស្តីពី "**កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក តើមានផលប៉ះពាល់អ្វីខ្លះទៅលើកម្មវិធីកាត់បន្ថយភាពក្រីក្រ ?**" ។

ព្រឹត្តិការណ៍មួយដែលធ្វើឱ្យយើងទាំងអស់គ្នាសប្បាយរីករាយ និងមានមោទនភាពយ៉ាងខ្លាំងនោះគឺ ប្រទេសកម្ពុជាយើងបានក្លាយទៅជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក នាខែកញ្ញា ឆ្នាំ ២០០៣ នាកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោក នៅទីក្រុងកានគុននៃប្រទេសម៉ិចស៊ិកូកន្លងទៅនេះ។ កម្ពុជាបានធ្វើការចរចាអំពី លក្ខខណ្ឌនៃការចូលជាសមាជិក ជាមួយសមាជិកអង្គការពាណិជ្ជកម្មពិភពលោកដទៃទៀតអស់រយៈពេលជិត ៩ ឆ្នាំ។ តាមរយៈការចូលរួមក្នុងអង្គការ WTO ប្រទេសកម្ពុជាទទួលបាននូវទំនាក់ទំនងបែបកិច្ចសន្យា ដែលអាចអនុវត្តបានជាមួយស្ទើរតែគ្រប់ប្រទេសទាំងអស់ដែលមានការពាក់ព័ន្ធ ជាពិសេសក្នុងវិស័យពាណិជ្ជកម្ម។ កិច្ចសន្យាអង្គការ WTO គឺជាកញ្ចប់នៃការសន្យា និងវិធានការដែលបើកឱ្យមានច្រកចូល

ទៅកាន់ទីផ្សារនានាបាន។ គេអនុវត្តកិច្ចសន្យានេះ តាមរយៈប្រព័ន្ធដោះស្រាយវិវាទដែលមានសមត្ថកិច្ចលើផ្នែកច្បាប់ និងពាណិជ្ជកម្មជាសារវន្ត។

ប្រព័ន្ធច្បាប់របស់អង្គការ WTO មានលក្ខណៈស្មុគស្មាញខ្លាំងណាស់។ ប្រព័ន្ធនេះមានកិច្ចព្រមព្រៀងជិត ២០ រួមជាមួយនឹងសេចក្ដីសម្រេច និងមានអនុស្សារណៈជាច្រើនបន្ថែមទៀត។ ក៏ប៉ុន្តែគោលការណ៍នៃប្រព័ន្ធនេះ មានលក្ខណៈសាមញ្ញណាស់។ គោលការណ៍ទាំងនោះរួមមាន ការមិនរើសអើងចំពោះសមាជិក ច្បាប់ និងបញ្ញត្តិពាណិជ្ជកម្មមានតម្លាភាព មានប្រព្រឹត្តកម្ម ពិសេសចំពោះបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ការមិនប្រើប្រាស់ប្រព័ន្ធពន្ធគយសម្រាប់ការពារទីផ្សារក្នុងស្រុក និងការធ្វើសេរីភាវូបនីយកម្មទីផ្សារជាជំហានៗ។

សមាជិកភាពរបស់អង្គការ WTO មិនធានាអំពីជោគជ័យនៅក្នុងពាណិជ្ជកម្មពិភពលោកឡើយ។ ផ្ទុយទៅវិញអង្គការ WTO ផ្ដល់នូវក្របខ័ណ្ឌមួយសម្រាប់កំណែទម្រង់សេដ្ឋកិច្ច និងកំណែទម្រង់ដទៃទៀត ដែលជួយប្រទេសកម្ពុជាឱ្យមានលក្ខណៈប្រកួតប្រជែងនៅក្នុងទីផ្សារបរទេស ហើយទន្ទឹមពេលជាមួយគ្នានោះ សមាជិកភាពក៏ផ្ដល់បរិយាកាសដែលទាក់ទាញវិនិយោគផងដែរ។ លុះក្រោយមកនឹងមានឱកាសទីផ្សារថ្មីៗសម្រាប់ក្រុមហ៊ុន ដែលមានលក្ខណៈសហគ្រិនភាព និងប្រកួតប្រជែង។ ក៏ប៉ុន្តែជោគជ័យនៃការនាំចេញនឹងកើនឡើង លុះត្រាតែមានភាពជាដៃគូដែលប្រកបដោយផ្លែផ្ការវាងរដ្ឋាភិបាល និងវិស័យឯកជនតែប៉ុណ្ណោះ។

## អង្គវេទិកាជាទីមេត្រី !

បញ្ហាចម្បងដែលត្រូវពិចារណា ចំពោះស្ថានភាពក្រីក្រនៅកម្ពុជានាពេលបច្ចុប្បន្ននេះគឺ : ផលិតផលជាតិសរុប (GDP), ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ,

ការអប់រំសុខភាព ភាពគ្មានការងារធ្វើវិសមភាពយេនឌ័រ ភាពលោភលន់ និងអំពើពុករលួយ និងការគ្រប់គ្រងប្រកបដោយខ្វះតម្លាភាព។

តម្រូវការក្នុងស្រុករបស់កម្ពុជាមិនទាន់គ្រប់គ្រាន់ល្មម អាចជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្របានឡើយ ពោលគឺកម្ពុជាចាំបាច់ត្រូវធ្វើពាណិជ្ជកម្មដើម្បីកាត់បន្ថយភាពក្រីក្រ។ ប្រទេសនេះបានបើកចំហសេដ្ឋកិច្ច តាមរយៈការធ្វើសមាហរណកម្មក្នុងប្រព័ន្ធពាណិជ្ជកម្មតំបន់ និងពិភពលោក។ ឥឡូវនេះ កម្ពុជាត្រូវតែពង្រីកសេដ្ឋកិច្ចរបស់ខ្លួនឱ្យសម្បូរបែប ដោយជ្រើសរើសយកវិស័យដែលមានអត្ថប្រយោជន៍ប្រកួតប្រជែងនៅក្នុងប្រព័ន្ធពាណិជ្ជកម្មនេះ។

ក្នុងស្ថានភាពនេះ កម្ពុជាយើងមានផលវិបាក ២ យ៉ាងគឺ : ផលវិបាកជាវិជ្ជមានគឺ ទំនិញរបស់កម្ពុជានឹងត្រូវនាំទៅលក់ដោយសេរីនៅទីផ្សារនានានៅក្នុងពិភពលោក ដោយគ្មានការកំណត់កូតាឡើយ រីឯផលវិបាកជាអវិជ្ជមាននោះគឺ ទំនិញរបស់កម្ពុជាយើង ជាពិសេសក្នុងវិស័យកាត់ដេរត្រូវចូលរួមប្រកួតប្រជែងអំពីទីផ្សារ ជាមួយបណ្តាប្រទេសដែលផលិតមុខទំនិញដូចយើងនេះដែរ។

ក្រោយខែ មករា ឆ្នាំ ២០០៥ នេះ គឺបន្ទាប់ពីកិច្ចព្រមព្រៀងវាយនភណ្ឌត្រូវបានបញ្ចប់ បណ្តាប្រទេសដែលមានប្រយោជន៍ពីការផ្តល់កូតា សម្លៀកបំពាក់នាំចូលទៅក្នុងសហរដ្ឋអាមេរិក ដូចជាកម្ពុជាមានការព្រួយបារម្ភ អំពីការដែលមិនអាចប្រកួតប្រជែងជាមួយប្រទេសធំ (ចិន) ដែលកំពុងមានលទ្ធភាពផលិតនូវសម្លៀកបំពាក់ប្រកបដោយចំណាយផលិតកម្មដ៏ទាប។ មកដល់ពេលនេះមានរយៈពេល ៦ ខែហើយគេនៅពុំទាន់ឃើញ មានអ្វីធ្ងន់ធ្ងរកើតមានដល់ឧស្សាហកម្មកាត់ដេរកម្ពុជាឡើយ។ យោងតាមតួលេខ ពីសមាគមផលិតករកាត់ដេរកម្ពុជា មកដល់ពេលនេះចំនួនរោងចក្រនៅកម្ពុជាបានបិទអស់ចំនួន ១១ រោងចក្រ តែរោងចក្រកាត់ដេរដែលសុំបើកថ្មីមានចំនួន

២៣ ហើយរោងចក្រដែលកំពុងដំណើរការផលិតកម្មមាន ២៤០។ ក្នុងចំណោមរោងចក្រដែលបើកថ្មីទាំង ២៣ នេះ មានភាគច្រើនជារោងចក្រមកពីប្រទេសចិន (១៥រោងចក្រ) និងបន្ទាប់ពីចិនគឺប្រទេសកូរ៉េ (៥រោងចក្រ)។

ដូច្នេះ ផលិតករផ្នែកសម្លៀកបំពាក់របស់ចិនប្រហែលជាមានយុទ្ធសាស្ត្របង្កើនការវិនិយោគផ្នែកនេះមកកម្ពុជា តាមសេចក្ដីតម្រូវរបស់អតិថិជនដែលបញ្ជាទិញ ជាពិសេសពីទីផ្សារសហរដ្ឋអាមេរិក ដែលរដ្ឋាភិបាលអាមេរិកបានដាក់នូវវិធានការជាក់ស្ដែងមួយ ទប់ស្កាត់ទំនិញផ្នែកសម្លៀកបំពាក់ ដែលហូរគំហុកមកពីប្រទេសចិន។ ឧស្សាហកម្មកាត់ដេរនៅកម្ពុជា ហាក់ដូចជាមានវាសនាផ្សារភ្ជាប់យ៉ាងសំខាន់ជាមួយល័ក្ខខ័ណ្ឌអភិវឌ្ឍក្នុងវិស័យកាត់ដេររបស់អង្គការ WTO ជាពិសេសគឺប្រតិកម្មរបស់សមាជិកដ៏សំខាន់មួយនៃអង្គការនោះគឺសហរដ្ឋអាមេរិក។

តាមការសន្និដ្ឋានរបស់អ្នកជំនាញការសេដ្ឋកិច្ចអន្តរជាតិ ទៅអនាគតអាចនៅមានប្រមាណជាង១០ ប្រទេសប៉ុណ្ណោះ ដែលនឹងចូលរួមក្នុងការប្រកួតប្រជែងក្នុងវិស័យកាត់ដេរ ក្នុងនោះមានប្រទេសធំៗមួយចំនួននៅក្នុងតំបន់យើង ដូចជាប្រទេសចិន ឥណ្ឌូណេស៊ី ថៃឡង់ដ៏ វៀតណាម បង់ក្លាដេស និងបណ្ដាប្រទេសមួយចំនួននៅក្នុងទ្វីបអាមេរិកឡាទីន និងទ្វីបអាហ្វ្រិកផងដែរ។ *អ្នកជំនាញការសេដ្ឋកិច្ចអន្តរជាតិបានវាយតម្លៃថា កម្ពុជាជាប្រទេសមួយដែលអាចចូលរួមក្នុងការប្រកួតប្រជែង ក្នុងទីផ្សារអន្តរជាតិបាននឹងគេដែរ ក៏ប៉ុន្តែ កម្ពុជាត្រូវខិតខំប្រឹងប្រែងអនុវត្តឱ្យបានល្អនូវប្រការ និងល័ក្ខខណ្ឌ័ជាគន្លឹះមួយចំនួនគឺ :*

១- ការអនុវត្តនីល័ក្ខខ័ណ្ឌការងារពីគ្រប់ភាគីពាក់ព័ន្ធឱ្យបានល្អ

២- ការបង្កើនគុណភាពផលិតផល

៣- ការដោះស្រាយបញ្ហាថ្លៃទំនិញ និង

៤- ការដោះស្រាយបញ្ហាបញ្ជូនផលិតផលទៅដល់ទីផ្សារទាន់ពេលវេលា។

ផលប៉ះពាល់របស់សមាជិកភាពនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក មកលើអាជីវកម្មកម្ពុជារួមមាន :

- ច្បាប់ និងបទបញ្ញត្តិទាំងឡាយ ដែលទាក់ទងនឹងអាជីវកម្ម បានប្រសើរជាងមុននិងអនុម័តច្បាប់តុលាការពាណិជ្ជកម្ម និងច្បាប់ពាណិជ្ជម្មដទៃទៀត។ កាលណាច្បាប់ថ្មី បានល្អប្រសើរជាងមុនសម្រាប់គ្រប់គ្រងអាជីវកម្ម ហើយត្រូវបានអនុវត្តតាមគោលការណ៏ច្បាប់ នោះវានឹងមានការទាក់ទាញ ការវិនិយោគទុនច្រើនជាងមុន។
- កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងពាណិជ្ជកម្មដទៃទៀត ផ្តល់ឱកាសឱ្យអាជីវកម្មរបស់កម្ពុជា អាចចូលទីផ្សារបរទេសបានដោយមានការអនុគ្រោះ (ត្រី និងផលិតផលធ្វើពីត្រី ពន្ធនាំចូលគឺ 0% សម្រាប់ទីផ្សារសហរដ្ឋអាមេរិក និងកាណាដា)។
- អង្គការពាណិជ្ជកម្មពិភពលោកផ្តល់ជម្រើស ឱ្យប្រទេសជាសមាជិកទប់ទល់ជាមួយនឹងការប្រកួតប្រជែងនៅក្នុងទីផ្សាររបស់ខ្លួន (វិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ស្តីពី ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងវិធានការការពារ)។

នៅក្នុងដំណាក់កាល ដែលកម្ពុជាកំពុងមានការព្រួយបារម្ភ អំពីវាសនានៃវិស័យផលិតកម្មកាត់ដេរ ការចូលជាសមាជិករបស់កម្ពុជា ទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ក៏នឹងអាចផ្តល់នូវឱកាសល្អសម្រាប់កម្ពុជាផងដែរ ប្រសិនបើកម្ពុជាអាចបង្កើនបរិស្ថានអាជីវកម្មមួយល្អសម្រាប់វិស័យឯកជន ដើម្បីទាក់ទាញការវិនិយោគពីបរទេស

និងសម្រាប់អ្នកវិនិយោគក្នុងស្រុក។ ទទ្ទឹមនឹងនេះ រាជរដ្ឋាភិបាលត្រូវខិតខំប្រឹងប្រែង បង្កើនលទ្ធភាពឱ្យមានភាពជាដៃគូរវាងវិស័យឯកជន និងរដ្ឋបាលសាធារណៈកាន់តែប្រសើរឡើង តាមរយៈការផ្តល់លទ្ធភាពឱ្យវិស័យឯកជនបានទទួលនូវពុទ្ធិថ្មីៗ ទាំងផ្នែកគ្រប់គ្រង និងបច្ចេកវិទ្យាជាដើម ដោយបង្កលទ្ធភាពទទួលការបណ្តុះបណ្តាលទាំងនៅក្នុងស្រុក និងក្រៅស្រុក។ ការផ្តល់លទ្ធភាពឱ្យអ្នកវិនិយោគក្នុងស្រុក ជាពិសេសគឺសម្រាប់សហគ្រាសធុនតូច និងមធ្យមងាយរកខ្ចីបាននូវទុនវិនិយោគ ដោយពង្រឹងប្រព័ន្ធច្បាប់ដែលអាចផ្តល់ការការពារដល់ប្រភពឱ្យខ្ចីប្រាក់ ក៏ជាសកម្មភាពមួយដ៏ប្រសើរផងដែរ។

ទាំងអស់នេះ គឺជាកត្តារួមចំណែកផ្តល់លទ្ធភាពឱ្យអាជីវកម្មក្នុងស្រុកមាន ការអភិវឌ្ឍ និងអាចឈានចូលប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ប្រកបដោយភាពស្មើមុខស្មើមាត់ ហើយថែមទាំងផ្តល់នូវការងារធ្វើដល់ប្រជាពលរដ្ឋក្នុងស្រុកផងដែរ ដែលកត្តាទាំងនេះនឹងរួមចំណែកដល់ការបន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ប៉ុន្តែ ផ្ទុយទៅវិញ បើអាជីវកម្មក្នុងស្រុក ពុំអាចមានលទ្ធភាពប្រកួតប្រជែងនឹងគេបាននោះ ផលប៉ះពាល់ និងផលវិបាកនឹងកើតមានឡើងច្រើនសម្រាប់អាជីវកម្មក្នុងស្រុក ហើយប្រជាពលរដ្ឋក៏បាត់បង់ការងារធ្វើផងដែរ។ បញ្ហាទាំងនេះអាចបណ្តាលឱ្យអាជីវកម្ម ត្រូវបានបិទទ្វារ ឬក៏ឈប់ដំណើរការអាជីវកម្មតែម្តង។

***<u>ចំណុចគួរចងចាំ</u>***

១- សមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោក មិនធានាពីជោគជ័យទេ តែវាផ្តល់ក្របខ័ណ្ឌសម្រាប់កែទម្រង់ ដើម្បីជួយក្រុមហ៊ុនកម្ពុជាឱ្យទទួលបាននូវលក្ខណៈសម្បត្តិដើម្បីប្រកួតប្រជែង។

២- ពេលនេះកម្ពុជាស្ថិតក្នុងប្រព័ន្ធពាណិជ្ជកម្មមួយផ្អែកលើច្បាប់ និងវិធានការត្រឹមត្រូវ។

៣- ការនេះផ្តល់នូវការការពារយ៉ាងច្រើន ចំពោះការអនុវត្តន៍មិនយុត្តិធម៌ក្នុងទីផ្សារនាំចេញ ។

៤- ត្រូវតែចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចចរចាពាណិជ្ជកម្មបច្ចុប្បន្ន និងអនាគត ដែលបង្កើតនូវវិធានការថ្មីៗ ហើយរដ្ឋាភិបាលត្រូវការសួរយោបល់ពីសំណាក់អាជីវករ ។

៥- សមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក គឺសម្រាប់ប្រទេសកម្ពុជាទាញយកអត្ថប្រយោជន៍ពីឱកាសថ្មីនេះ ។

ជារួមកម្ពុជានៅមានមធ្យោបាយច្រើនទៀតដែលត្រូវអនុវត្ត ដើម្បីឈានទៅរកជោគជ័យពីការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ការរួបរួម និងប្រឹងប្រែងប្រកបដោយសុទិដ្ឋិនិយមទូទាំងកម្ពុជា ជាកត្តាសំខាន់បំផុតដើម្បីឈានទៅរកការកាត់បន្ថយភាពក្រីក្រ និងធ្វើការអភិវឌ្ឍប្រទេសឱ្យមានភាពរីកចម្រើន និងមានភាពស្មើមុខស្មើមាត់ ដូចជាបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោកផងដែរ ។

### *ឯកសារពិគ្រោះ*

១- អ៊ុំ មាន : បទអន្តរាគមន៍ក្នុងវេទិកាស្តីពី "**កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោកផលប៉ះពាល់ដល់ពលកម្មកម្ពុជា**" ដែលរៀបចំឡើងដោយវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥ ។

២- យា ប៊ុនណា : បទអន្តរាគមក្នុងវេទិកាស្តីពី "**កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក**" ដែលរៀបចំឡើង ដោយវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និង សន្តិភាព នាថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥ ។

៣- កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ "**កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក សៀវភៅមគ្គុទេសក៍សម្រាប់អាជីវកម្ម**"។

៤- ទស្សនាវដ្តីវិភាគសេដ្ឋកិច្ច ច្បាប់ចេញផ្សាយឆ្នាំទី ១ លេខ ៦ តុលា-ធ្នូ ឆ្នាំ ២០០៤ ទំព័រ ៩-១២ "**កម្ពុជានៅក្នុងសេដ្ឋកិច្ចពិភពលោក : កូនបក្សីនៅក្នុងព្រៃដ៏ធំ**"។

៥- វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព : របាយការណ៍ ស្តីអំពី "**កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក ផលប៉ះពាល់ដល់កសិកម្មកម្ពុជា**" ថ្ងៃច័ន្ទ ទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥។

៦- សមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា : **ស្ថានភាពសិទ្ធិមនុស្ស ២០០៣** ភ្នំពេញ ២០០៤។

# កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ការប្រើប្រាស់ WTO ជាឧបករណ៍ជំរុញកំណែទម្រង់

**លោក ហៀវ វ៉ាស្នា**

**នាយកគ្រប់គ្រង មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម**

## សកលូបនីយកម្ម និងអង្គការពាណិជ្ជកម្មពិភពលោក (The Globalization and WTO

សព្វថ្ងៃនេះ សកលូបនីយកម្ម (ការធ្វើឱ្យទៅជាសកល- globalization) គឺជាប្រធានបទពេញនិយមបំផុតសម្រាប់ការពិភាក្សា និងការធ្វើវិភាគ។ ប្រធានបទនេះបានក្លាយទៅជាក្ដីកង្វល់ដ៏ចម្បងនៃអ្នករិះគិត (thinker) អំពីការអភិវឌ្ឍ និងអ្នកដែលពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍន៍នៅក្នុងរដ្ឋាភិបាលនានា រួមទាំងរាជរដ្ឋាភិបាលកម្ពុជាដែលទើបតែចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) ផងដែរ។ តាមការពិតទៅដំណើរការនេះ គួរតែជាក្ដីកង្វល់នៃប្រជាពលរដ្ឋទូទៅ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ ដោយសារដំណើរការនេះអាចនឹងមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅ (deep impacts) ដល់ជីវភាពរស់នៅនៃអ្នកទាំងនោះ។

គេតែងឮសម្លេងដ៏កងរំពងនៃអ្នកគាំទ្រសកលូបនីយកម្ម ដែលអះអាងថាដំណើរការនេះមានសក្ដានុពលឥតព្រំដែន (infinite potencial) សម្រាប់ការអភិវឌ្ឍ និងសុខុមាលភាពនៃមនុស្សជាតិ។ អ្នកទាំងនោះនិយាយថា ទោះជាក្នុងករណីណាក៏ដោយ

សកលូបនីយកម្មនេះ គឺជាដំណើរការដែលមិនអាចចៀសវាងបាន និងមិនអាចវិលត្រឡប់ថយក្រោយវិញបាន។ ហេតុដូច្នេះ គេគួរតែខិតខំធ្វើដំណើរការនេះឱ្យបានល្អប្រសើរបំផុត។

ក៏ប៉ុន្តែ ចំពោះពួកប្រឆាំងដែលមានសម្លេងខ្លាំងដូចគ្នា ដែលបានបញ្ចេញទស្សនៈបញ្ជាក់ថា សកលូបនីយកម្មគឺជាបិសាចដ៏កំណាច ដែលចេញមកកៀរគរប្រទេសក្រីក្រនានាឱ្យវិលត្រឡប់ទៅក្នុងសម័យអាណានិគមខ្លួនវិញ ហើយអ្នកក្រីក្រក្នុងបណ្តាប្រទេសទាំងនោះ ក៏ងើបឡើងប្រឆាំងនឹងបញ្ហាក្រីក្រនេះផងដែរ។ ភាគីទាំងសងខាងតែងផ្តល់សេចក្តីរឹងប៉ឹងខ្លាំងក្លា ដើម្បីគាំទ្រការអះអាងរៀងៗខ្លួន។

តាមបទពិសោធន៍សកលូបនីយកម្មរមែងមានផលវិបាកមិនល្អ ទៅលើផ្នែកអ្នកក្រ និងអ្នកខ្សត់ខ្សោយនៃសង្គម និងទៅលើសហគ្រាសពាណិជ្ជកម្មតូចតាច។ ដោយហេតុនេះ ការយល់ដឹងឱ្យច្បាស់លាស់អំពីចរិតលក្ខណៈ បញ្ហាជំពាក់ពិន និងផលវិបាកនៃដំណើរការនេះគឺជាការចាំបាច់ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍នានា ដែលភាពក្រីក្រកាន់តែកើនឡើងគ្មានអ្វីទប់ទល់ និងដែលសកម្មភាពពាណិជ្ជកម្មមានកំណត់ ស្ទើរតែទាំងស្រុងនៅត្រឹមខ្នាតតូចតាចជាលក្ខណៈគ្រួសារ។ ដំណើរការនេះគួរតែទាក់ទងនឹងប្រជាពលរដ្ឋដែលត្រូវដឹងថា តើសកលូបនីយកម្មមានឥទ្ធិពលដូចម្តេចខ្លះ ចំពោះដំណើរការអភិវឌ្ឍ? និង ថាតើសកលូបនីយកម្មនេះ មានផលប៉ះពាល់ដូចម្តេចខ្លះ ទៅលើភាពក្រីក្រ?

## ១- លក្ខណៈពិសេសសំខាន់ៗ នៃសកលូបនីយកម្ម Main Features

សកលូបនីយកម្មមានន័យយ៉ាងទូលំទូលាយថា កិច្ចប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែនប្រទេសដោយសេរីពេញលេញ ដោយគ្មានការទប់ទល់ណាមួយពីរដ្ឋាភិបាលនៃប្រទេសនានា។ កិច្ចប្រតិបត្តិការសេដ្ឋកិច្ចបែបនេះ និយាយរួមមានពីរប្រភេទគឺ (១)- ការហូរចូលនៃទំនិញ និងសេវាពីប្រទេសមួយទៅក្នុងប្រទេសមួយទៀត និង (២)-

ការហូរចូលនៃមូលធនពីប្រទេសមួយទៅក្នុងប្រទេសមួយទៀត។ លទ្ធភាពនៃការរួមផ្សំសកម្មភាពទាំងពីរប្រភេទនេះ អាចបង្ហាញជាឧទាហរណ៍ នៃកិច្ចប្រតិបត្តិការសេដ្ឋកិច្ចមួយប្រភេទទៀត ដូចជាផលិតកម្មទំនិញ និងសេវា។

ការហូរនៃទំនិញឆ្លងកាត់ព្រំដែន សំដៅយកការនាំចេញ និងការនាំចូលទំនិញផ្សេងៗ។ ឧទាហរណ៍ ការហូរសេវាឆ្លងកាត់ព្រំដែនបានដល់កិច្ចការធនាគារ ការធានារ៉ាប់រងទូរគមនាគមន៍ និងសេវាផ្សេងៗស្រដៀងគ្នានេះ ដែលប្រទេសមួយផ្តល់ទៅឱ្យប្រទេសមួយទៀត ការហូរនៃមូលធនរមែងកើតមានឡើង ដោយការបង្កើត ឬការទទួលបានរោងចក្រ ឬដោយការដាក់ទុនតម្កល់ ឬផ្សារភាគហ៊ុន (Share market) ក្នុងប្រទេសមួយទៀត។ ឧទាហរណ៍មួយទៀតនៃផលិតកម្មទំនិញជាសកល គឺរោងចក្រមួយដែលគេកសាងឡើង នៅក្នុងប្រទេសមួយតាមរយៈមូលធនដែលគេវិនិយោគពីប្រទេសមួយទៀត និងការប្រើប្រាស់វត្ថុធាតុតម្រូវការ ពីប្រទេសដទៃនៅក្នុងដំណើរការផលិតកម្ម ឬការតម្រង់ទិសដៅផលិតកម្មទៅលើអ្នកប្រើប្រាស់ក្នុងប្រទេសផ្សេងទៀត។ ជាការជាក់ស្តែងប្រភេទផ្សេងៗ នៃសកម្មភាពសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន ដូចបានពោលពីខាងដើមនោះ គេមិនអាចចាត់ទុកថាជាទឹកជ្រាបចូលមិនបានឡើយ។ ដោយហេតុថាក្នុងករណីភាគច្រើនបំផុតសកម្មភាពទាំងនោះ គឺជារបាយលាយបញ្ចូលគ្នានៃសារធាតុទាំងនេះ។

## ២- **<u>អាហរ័ណកម្ម និងនីហរ័ណកម្មទំនិញ</u>** Import and Export of Goods

ឥឡូវនេះ យើងគួរពិនិត្យមើលថា តើកិច្ចប្រតិបត្តិការសេដ្ឋកិច្ចឆ្លងដែនសំដៅយកអ្វីខ្លះ? ការហូរទំនិញ គឺការនាំទំនិញចូល និងការនាំទំនិញចេញមានន័យថា ប្រទេសមួយមិនគួរដាក់កំណត់ការរឹតបន្តឹង ឬបទបញ្ញានៅតាមព្រំដែនខ្លួនចំពោះទំនិញចេញ ឬ

ចូលឡើយ ហើយដោយហេតុនេះផលិតផលណាក៏ដោយអាចត្រូវបាននាំចូល ឬនាំចេញក្នុងបរិមាណប៉ុនណាក៏បាន។ នេះមានន័យថា រដ្ឋាភិបាលមិនគួរដាក់កំណត់បរិមាណនៃផលិតផលនាំចូលណាមួយឡើយ ហើយជាការល្អ រដ្ឋាភិបាលក៏មិនគួរដាក់កម្រិតពន្ធគយលើទំនិញនាំចូលផងដែរ។

ផលិតផលតម្លៃ និងបរិមាណទំនិញនាំចេញ និងទំនិញនាំចូលគួរអាស្រ័យទាំងស្រុងទៅលើការវិនិច្ឆ័យរបស់អ្នកនាំទំនិញចេញ និងអ្នកនាំទំនិញចូល ដែលជាអ្នកប្រកបមុខរបរនេះ។ សេចក្តីសន្និដ្ឋានដែលមិនទាន់ច្បាស់លាស់នោះ គឺថាពួកពាណិជ្ជករនឹងចូលទៅក្នុងទំនាក់ទំនងការងារនេះ តែនៅពេលណាដែលគេគិតឃើញថា ទំនាក់ទំនងនេះអាចសម្រេចផលខាងសេដ្ឋកិច្ចបានប៉ុណ្ណោះ។ ឧទាហរណ៍ នៅពេលដែលគេប៉ាន់ប្រមាណឃើញថា អ្នកប្រើប្រាស់ត្រៀមខ្លួននឹងនាំទំនិញទាំងនោះ ហើយអ្នកផលិតក៏ត្រៀមខ្លួននឹងផលិតនិងលក់ទំនិញនោះដែរ។

## ៣- <u>ពាណិជ្ជកម្មសេវាកម្ម</u> Trade in Services

ការហូរចេញ-ចូលនៃសេវាឆ្លងកាត់ព្រំដែនដោយសេរី ដោយគ្មានការរឹតត្បិតនឹងមានន័យថា ធនាគារនៃប្រទេសមួយអាចនឹងធ្វើប្រតិបត្តិការយ៉ាងពេញលេញក្នុងប្រទេសមួយទៀត។ ធនាគារទាំងនោះអាចនឹងបើកសាខានៅកន្លែងណាក៏បាន និងធ្វើប្រតិបត្តិ ការកិច្ចការធនាគារផ្សេងៗដោយគ្មានការត្រួតត្រាពីរដ្ឋាភិបាល។ ដូច្នេះ គេអាចនឹងផ្ទេរប្តូរប្រាក់តម្កល់ និងផ្តល់ប្រាក់កម្ចីដោយគ្មានការត្រួតពិនិត្យ ឬសេចក្តីណែនាំពីរដ្ឋាភិបាលឡើយ។ ចំពោះសេវាកម្មដទៃទៀត ដូចជាការធានារ៉ាប់រងគមនាគមន៍ សំណង់ ការពិគ្រោះយោបល់ ។ល។ ក៏មានស្ថានភាពស្រដៀងគ្នានេះដែរ។

**៤- ការហូរចេញ-ចូលនៃប្រាក់មូលធន** Flow of Capital

ចលនាចេញចូល នៃប្រាក់មូលធនឆ្លងកាត់ព្រំដែន ដោយគ្មានការរារាំងទាំងស្រុង មានន័យថា ក្រុមហ៊ុនបរទេសអាចនាំប្រាក់មូលធនចូលសម្រាប់សកម្មភាពអ្វីមួយនៅពេលណាក៏បាន និងនាំយកប្រាក់មូលធនទាំងនោះចេញទៅវិញ នៅពេលណាក៏បានដែរ។ នេះមានន័យថា ក្រុមហ៊ុនបរទេសមួយអាចធ្វើវិនិយោគទុន ក្នុងការកសាងរោងចក្រមួយ ឬតម្កល់ប្រាក់ក្នុងធនាគារបានដោយសេរី។ ក្រុមហ៊ុននេះអាចដកប្រាក់កម្រៃ ឬប្រាក់ចំណេញជារូបិយប័ណ្ណបរទេស ហើយអាចលក់ភាគហ៊ុន ដកប្រាក់តម្កល់ និងយកប្រាក់ជា រូបិយប័ណ្ណបរទេសទៅវិញនៅពេលណាក៏បានផងដែរ។

ការជ្រើសរើសផលិតផល និងទីតាំងភូមិសាស្ត្រសម្រាប់រោងចក្រ ដែលនឹងត្រូវកសាងឡើងនឹងត្រូវទុកឱ្យអ្នកវិនិយោគទុនបរទេសជាអ្នកសម្រេចទាំងស្រុង។ លើសពីនេះទៀត អ្នកវិនិយោគទុនបរទេស ដែលកសាងរោងចក្រនឹងមានសេរីភាពពេញទីក្នុងការយកវត្ថុធាតុពីណាមកបញ្ចូលក្នុងរោងចក្រ ហើយនឹងយកផលិតផលទៅលក់ឯណាគឺថា សម្ភារៈបញ្ចូលរួមទាំងវត្ថុធាតុដើមផង នឹងត្រូវនាំចូលពីក្រៅ ឬអាចរកបានក្នុងស្រុក ថាតើផលិតផលរោងចក្រនឹងត្រូវនាំចេញទៅក្រៅប្រទេសឬលក់តាមទីផ្សារក្នុងប្រទេស?

**៥- សំយោគមូលដ្ឋាន** Underlying Assumption

សេចក្តីសន្និដ្ឋានជាមូលដ្ឋានគឺថា អ្នកប្រតិបត្តិការខាងសេដ្ឋកិច្ច ដូចជាម្ចាស់ផលិតកម្ម អ្នកជំនួញ អ្នកផ្គត់ផ្គង់សេវាធនាគារ ។ល។ រមែងធ្វើការប្រកបដោយប្រសិទ្ធិភាពខ្ពស់ ហើយកិច្ចប្រតិបត្តិការដោយគ្មានឧបសគ្គរារាំង របស់អ្នកទាំងនោះនឹងនាំអត្ថប្រយោជន៍មកឱ្យសង្គម ជាមួយនឹងអ្នកទាំងនោះ ដែលទាញយកផលប្រយោជន៍អំពីកិច្ចប្រតិបត្តិការខ្លួន។

មានសេចក្តីសន្និដ្ឋានទៅទៀតថា អន្តរាគមន៍ណាមួយពីរដ្ឋាភិបាល រមែងកាត់បន្ថយប្រសិទ្ធិភាពអ្នកទាំងនោះ ដោយហេតុនេះ ក៏ជាការកាត់បន្ថយអត្ថប្រយោជន៍សង្គមដែរ។ នៅពេលប្រកួតប្រជែងគ្នាដោយចំហក្នុងចំណោមគ្នាឯង គេសន្មតថា ក្រុមហ៊ុនទាំងឡាយធ្វើការកែលម្អកិច្ចប្រតិបត្តិការខ្លួនជាបន្តបន្ទាប់។ ភាពអន់ខ្សោយរបស់ក្រុមហ៊ុនណាមួយនឹងត្រូវផ្តន្ទាទោស ដោយការប្រកួតប្រជែងជាចំហ ក្នុងន័យថា អ្នកទន់ខ្សោយនឹងត្រូវដកយកចេញដោយរក្សាទុកអ្នកខ្លាំង។ ការអះអាង និងការយល់បែបនេះសន្មតទុកជាមុនថា កិច្ចប្រតិបត្តិការដោយសេរីនៃទីផ្សារនឹងមានអត្ថប្រយោជន៍ដល់សង្គម និងប្រជាពលរដ្ឋ។

ការសន្មតមួយទៀតថា អន្តរាគមន៍រដ្ឋាភិបាលរមែងកាត់បន្ថយការប្រកួតប្រ-ជែងគ្នាដោយសេរី ហើយដោយហេតុនេះ ក៏ជាការកាត់បន្ថយប្រសិទ្ធិភាពនៃប្រតិបត្តិការសេដ្ឋកិច្ចផងដែរ។ គេអះអាងថា រដ្ឋាភិបាលប្រតិបត្តិដោយហេតុផលនយោបាយ ហើយអន្តរាគមន៍រដ្ឋាភិបាលនឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់ដំណើរការសេដ្ឋកិច្ច។

ការអះអាងទាំងនេះដាក់ទម្ងន់សារៈសំខាន់ជាច្រើន ទៅលើគតិបណ្ឌិតនៃកិច្ច-ការពាណិជ្ជកម្មឯកជន។ គេសន្និដ្ឋានថា ទីផ្សារជាអ្នកកំណត់កិច្ចប្រតិបត្តិការសេដ្ឋកិច្ចដែលគេចូលចិត្តតាមមធ្យោបាយប្រកបដោយប្រសិទ្ធិភាព និងល្អប្រសើរបំផុត។ ការយល់ឃើញបែបនេះអាចជាគំនិតល្អបំផុតជាប្រយោជន៍ដល់ពាណិជ្ជកម្មឯកជន ប៉ុន្តែមិនប្រាកដថា ជាគំនិតល្អបំផុតសម្រាប់ប្រជាពលរដ្ឋផងទេ ជាពិសេសសម្រាប់ស្រទាប់ <u>**អ្នកក្រីក្រ និងអ្នកខ្សត់ខ្សោយ**</u> នៃសង្គម។

ក្នុងទម្រង់ដ៏ល្អបំផុតនោះ ពាណិជ្ជកម្មឯកជនប្រព្រឹត្តទៅ ដើម្បីឱ្យបានផលចំណេញដែលគេអាចយល់បានយ៉ាងច្បាស់ ហើយក្នុងករណីខ្លះក៏គួរជាទីប្រាថ្នាផងដែរ។ ទុនវិនិយោគដែលធ្វើដោយពាណិជ្ជកម្មឯកជន ត្រូវតែរកឱ្យបានប្រាក់ចំណូលល្មមគ្រប់

គ្រាន់ដើម្បីទូទាត់ថ្លៃវិនិយោគ ហើយក៏ដើម្បីឱ្យបានចម្រើនលូតលាស់ដោយទៀតទាត់ផងដែរ បើមិនដូច្នោះទេ កិច្ចការនេះមិនអាចចាត់ទុកថា ជាពាណិជ្ជកម្មប្រកបដោយចីរភាពឡើយ ហើយអាចនឹងដួលរលំក្នុងពេលដ៏ខ្លី ។

## ៦- <u>**សេចក្តីសន្និដ្ឋាន**</u> Conclusion

ការមានពាណិជ្ជកម្មរឹងមាំត្រឹមត្រូវក្នុងសង្គម គឺជាកត្តាមានសារៈសំខាន់បំផុត ពីព្រោះកត្តានេះនឹងជួយបង្កើនការងារ និងសេដ្ឋកិច្ចទាំងមូល ។ ក៏ប៉ុន្តែគេមិនអាចរំពឹងលើពាណិជ្ជកម្មឱ្យជួយគាំពារពួកអ្នកក្រីក្រ អ្នកទន់ខ្សោយក្នុងសង្គម និងឱ្យមានគោលដៅឆ្ពោះទៅរកផ្នែកសង្គមធំទូលាយបានឡើយ ។ ជាមួយគ្នានេះដែរ គេក៏មិនអាចរំពឹងលើពាណិជ្ជកម្មនេះ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសទាំងមូលបានដែរ ព្រោះបច្ចុប្បន្នយើងនៅមានកង្វះខាតច្រើន ។

ពាណិជ្ជកម្មឯកជនតែងតែប្រព្រឹត្តទៅ នៅក្នុងបរិដ្ឋាននៃការប្រកួតប្រជែងគ្នាជាមូលដ្ឋាន ដែលក្នុងនោះអ្នកខ្លាំងត្រូវតែឈ្នះ ចំណែកឯអ្នកខ្សោយត្រូវតែចាញ់ ។ ដូច្នេះគេត្រូវតែមានធនធានគ្រប់គ្រាន់ដើម្បីធ្វើពាណិជ្ជកម្មផងដែរ ។ ធនធាននោះអាចមានរូបភាពជាប្រាក់កាស ឬរូបភាពជារូបវ័ន្ត ដូចជា ដីធ្លី ឬផ្ទះសម្បែង ឬក៏អាចមានរូប-ភាពជាកេតនភណ្ឌខាងបញ្ញាស្មារតី ឬរូបវ័ន្ត (mental of physical attribute) ដូចជា មុខជំនាញខាងវិជ្ជាជីវៈឬគ្រាន់តែជាកម្លាំង ដើម្បីធ្វើការងារខាងផ្លូវកាយដែលមិនចាំបាច់មានមុខជំនាញ ។ ក្នុងស្ថានភាពនេះ អ្នកដែលមានទ្រព្យសម្បត្តិ និងមុខជំនាញខ្ពស់ជាងគេនឹងត្រូវឈ្នះ ចំណែកឯអ្នកឯទៀត ដែលគ្មានទ្រព្យសម្បត្តិនឹងត្រូវទុកឱ្យនៅខាងក្រោយគេ ហើយនឹងគ្មានកន្លែងរកស៊ីទៀតឡើយ ។ ម្យ៉ាងទៀតទីផ្សារក៏មានចំណុចខ្វះខាតខ្លួនខ្លួះដែរ ហើយការបរាជ័យនៃប្រព័ន្ធទីផ្សារក៏មានលទ្ធភាពអាចនឹងកើតឡើង

បានខ្លាំងក្លាណាស់ដែរ នៅក្នុងកាលៈទេសៈជាច្រើន។ ក្នុងករណីនេះប្រសិទ្ធិភាពដ៏ប្រសើរបំផុតនឹងមិនបានសម្រេចផលឡើយ ហើយអាស្រ័យហេតុនេះ ផលប្រយោជន៍ដែលគេរំពឹងថានឹងបានមកដល់សង្គមនោះក៏នឹងមិនបានកើតឡើងដែរ។

ទាំងអស់នេះ ទាមទារឱ្យរដ្ឋាភិបាលបំពេញមុខនាទីក្នុងកាលៈទេសៈជាចាំបាច់ និងក្នុងវិស័យមួយចំនួន។ សុខុមាលភាពប្រជាពលរដ្ឋ គឺជាការទទួលខុសត្រូវរបស់រដ្ឋាភិ-បាលយ៉ាងពិតប្រាកដ។ ពាណិជ្ជកម្មឯកជន ជាពិសេសក្រុមហ៊ុនពាណិជ្ជកម្មបរទេសមិនអាចទទួលបន្ទុកនេះបានទេ ថ្វីបើក្រុមហ៊ុនទាំងនោះមានបញ្ហាសង្គមមួយចំនួននៅក្នុងសកម្មភាពខ្លួនក៏ដោយ។ ការគាំពារអ្នកខ្សត់ខ្សោយ និងអ្នកដែលគ្មានទ្រព្យសម្បត្តិ ឬមានទ្រព្យសម្បត្តិស្តួចស្តើង គឺជាទិដ្ឋភាពដ៏សំខាន់នៃការងាររដ្ឋាភិបាល។

ក្នុងការសម្រេចគោលបំណងនេះ រដ្ឋាភិបាលត្រូវតែបំពេញមុខនាទីដ៏សកម្មមួយដែលអាចរារាំងការស្វែងរកកម្រៃ ដោយសេរីនៃក្រុមហ៊ុនឯកជន។ម្យ៉ាងទៀត មានការងារ និងសកម្មភាពប្រភេទខ្លះ ដែលមិនហុចផលកម្រៃទាន់ហាន់ ជាក់ស្តែង ឬផលកម្រៃតិចតួច និងយឺតយ៉ាវ ដូចជាវិធានការសុខាភិបាលសាធារណៈ សាលាបឋមសិក្សា ផ្លូវលំតាមភូមិជាដើម។ ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមើលមិនឃើញការងារទាំងនោះថា ជាទីចាប់អារម្មណ៍គ្រប់គ្រាន់ទេ ហើយរដ្ឋាភិបាលត្រូវតែរ៉ាប់រងការទទួលខុសត្រូវទាំងនោះ។ ជាមួយនេះដែរ រដ្ឋាភិបាលត្រូវតែធានារារាំងក្រុមហ៊ុនមិនឱ្យដេកដួលទៅក្នុងសកម្មភាពនានា ដែលមានលក្ខណៈជាការកេងយកប្រយោជន៍ ឬក៏មានគ្រោះថ្នាក់ដល់សង្គម និងប្រជាពលរដ្ឋទូទៅ។

បន្ទាប់ពីចំណុចទាំងអស់នេះ ការលើកស្ទួយផលប្រយោជន៍សាធារណៈ ការអនុវត្តន៍ឱ្យមានប្រសិទ្ធិភាពនៃអភិបាលកិច្ចល្អ ការបំបាត់អំពើពុករលួយទាំងផ្នែកបុគ្គល និង

ទាំងផ្នែកនយោបាយ ការរៀបចំប្រព័ន្ធសេដ្ឋកិច្ចតាមបែបបច្ចេកវិទ្យា ការពង្រឹងប្រព័ន្ធច្បាប់ និងការហ៊ានទទួលខុសត្រូវជាក់លាក់ គឺជាកាតព្វកិច្ចធំបំផុតរបស់រដ្ឋាភិបាល ។

បើពិនិត្យមើលសេចក្តីសន្និដ្ឋាននេះដោយត្រួសៗ អ្នកគាំទ្រដំណើរការសកលូបនីយកម្មអាចនឹងទាមទារឱ្យរដ្ឋាភិបាលកម្រិតតួនាទីខ្លួននៅត្រឹមតែ លើវិស័យជាប្រពៃណីសំខាន់ៗ ដូចជា ការថែរក្សាច្បាប់ និងសណ្តាប់ធ្នាប់ ។ល។ ទោះបីយ៉ាងណាក៏ដោយ គេមិនយល់ព្រមឱ្យរដ្ឋាភិបាលអនុវត្តការងារណា ដែលជ្រៀតជ្រែកទៅក្នុងកិច្ចប្រតិបត្តិការក្រុមហ៊ុនឯកជន និងការស្វែងរកផលចំណេញឡើយ ។

## ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាប្រឈមនឹងការប្រកួតប្រជែង

ការកត់សម្គាល់នូវការប្រកួតប្រជែងជាច្រើន ដែលប្រទេសកម្ពុជាត្រូវប្រឈមជាមួយ ដើម្បីឱ្យសហគ្រាសកសិកម្មអាចទទួលផលចំណេញពីការចូលជាសមាជិកនៃអង្គការ WTO នេះ ។

### ១- អភិបាលកិច្ចល្អ

សព្វថ្ងៃនេះបញ្ហាចម្បង ដែលប្រទេសកម្ពុជាត្រូវប្រឈមជាមួយអាចត្រូវប្រមូលផ្តុំក្រោមទស្សនៈនៃអភិបាលកិច្ចដ៏ល្អ និងភាពខ្លាំងនៃរដ្ឋាភិបាល ។ ការលាក់លៀមតម្លៃរត់ពន្ធ ខ្វះការត្រួតពិនិត្យ និងភាពផ្តាច់មុខខុសច្បាប់ ធ្វើឱ្យវិនិយោគិនបាក់ទឹកចិត្ត និងបន្ថយលទ្ធភាព ក្នុងការទាញយកផលប្រយោជន៍ពេញលេញពី ការចូលជាសមាជិក WTO ។ កសិកររំពឹងតែទៅលើពាណិជ្ជករ ដោយគ្មានអ្វីជាជំនួយបន្ទាន់ឡើយ ។ សេចក្តី

សម្រេចដោយបំពារបំពាន និងអំពើពុករលួយជាការគំរាមចំពោះវិនិយោគិន។ ការរត់ពន្ធធ្វើឱ្យគ្មានប្រសិទ្ធិភាពដល់ការគ្រប់គ្រងពាណិជ្ជកម្ម និងការអនុវត្តអ្វីៗឱ្យបានតាមស្តង់ដា។

ការចូលជាសមាជិក WTO ផ្តល់កាលានុវត្តភាពឱ្យកម្ពុជាបង្កើតក្របខណ្ឌច្បាប់មួយ។ ដើម្បីគោរពក្របខ័ណ្ឌ WTO ច្បាប់ចំនួន ៤៦ ត្រូវបានអនុម័ត ឬកែតម្រូវនៅក្នុងឆ្នាំក្រោយៗនេះ។ ក្រោយការអនុម័ត រដ្ឋាភិបាលនឹងត្រូវអនុវត្ត និងធានារ៉ាប់រងដល់ធរមានបញ្ញត្តិនៃច្បាប់ទាំងនេះ តាមរយៈការធ្វើប្រព័ន្ធតុលាការសាជាថ្មីឡើងវិញ។

## ២- ការស្វែងយល់ពីទីផ្សារ

ពួកផលិតករប្រឈមមុខជាមួយការលំបាកយ៉ាងច្រើន ក្នុងការកំណត់តម្លៃលក់ផលិតផលរបស់ខ្លួន។ ហេដ្ឋារចនាសម្ព័ន្ធមិនអំណោយផលដល់ការដឹកនាំ ការរក្សាទុកក្នុងឃ្លាំង ការសម្លាប់។ ឧស្សាហកម្មកែច្នៃមានភាពអន់ថយណាស់ សហគ្រាសឯកជន និងកសិករប្រឈមនឹងការខ្វះពត៌មានពីទីផ្សារ។ នៅទីបញ្ចប់ ការចូលជាសមាជិក WTO ត្រូវនាំមកនូវការអនុវត្តន៏អ្វីៗតាមស្តង់ដារ ដើម្បីឆក់យកឱ្យបាននូវកាលានុវត្តភាពនៃការនាំចេញ និងការប្រឈមជាមួយការប្រជែងថ្មី នៃផលិតផលនាំចូលល័ក្ខខ័ណ្ឌនៃការស្វែងយល់ពីទីផ្សារត្រូវតែឱ្យបានប្រសើរឡើង។

ការវិនិយោគជាសាធារណៈ ជាសេចក្តីត្រូវការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហើយក្នុងករណីខ្លះ គេនឹងអាចអំពាវនាវរកការវិនិយោគឯកជនជាមួយនឹងប្រព័ន្ធថ្លៃឈ្នួល។ ប្រព័ន្ធផ្តល់ពត៌មានអំពីទីផ្សារមួយ ត្រូវតែបង្កើតឱ្យមានឡើងនៅក្នុងជំហានដំបូងមួយ ដោយសហគ្រាសសាធារណៈជាមួយនឹងការរួមចំណែក ផ្នែកហិរញ្ញវត្ថុនៃអ្នកប្រើប្រាស់ ដើម្បីឈានទៅយកពត៌មាន។ ការអនុវត្តនូវស្តង់ដារនៃគុណភាពតម្រូវឱ្យមានការហ្វឹកហ្វឺន ព្រមជាមួយនឹងការផ្គត់ផ្គង់ជាបន្តគ្នាទាំងអស់ ការធ្វើវិនិយោគ (ជាសាធា

រណៈ ឬជាឯកជន) នៅបន្ទប់មាស៊ីនត្រជាក់ មន្ទីរពិសោធន៍ត្រួតពិនិត្យ ការបង្កើតក្រុមរាជការដ៏សក្តិសិទ្ធិមួយក្រុម ។

ដើម្បីថែរក្សាកសិ-ឧស្សាហកម្មថ្មី ក្នុងបំណងរក្សាទុកតម្លៃបន្ថែម គេអាចអនុវត្តនូវបទប្បញ្ញត្តិគាំពារ ក្រោមក្បួនច្បាប់ទូទៅរបស់ GATT ដើម្បីថែរក្សាឧស្សាហកម្មទើបកើតថ្មី ។

**៣- ជួយគាំពារកសិករដែលមានធនធានតូចតាច**

កសិកម្មមានតួនាទីចម្បងក្នុងសេដ្ឋកិច្ចខ្មែរ និងក្នុងនាមជាវិស័យទី ១ នៃការប្រើប្រាស់ ។ ៨០ % នៃកម្លាំងពលកម្មស្ថិតនៅក្នុងវិស័យកសិកម្ម ហើយភាគច្រើនគឺជាកសិករតូចតាចក្រីក្រ ។ ហេតុដូច្នេះ គេត្រូវផ្តល់ការយកចិត្តទុកដាក់ដ៏វិសេសមួយចំពោះលទ្ធភាពនៃការចូលជាសមាជិក WTO លើផ្នែកកសិកម្ម ជាមួយនឹងការប្រមូលផ្តុំទៅលើកសិករតូចតាច ។ បើគ្មានការសម្រាលនូវឥទ្ធិពលនេះទេ វាពិតជាកើតមានគ្រោះថ្នាក់នៃវិបត្តិសង្គម ។

ដើម្បីគាំពារ និងធានារ៉ាប់រងប្រាក់ចំណូលរបស់កសិករជាការចាំបាច់ គឺត្រូវអនុវត្តគោលការណ៍តម្លៃមួយក្រោមការកម្រិតរបស់ WTO *(ប្រអប់លឿងទុំ)* ជាមួយនឹងលទ្ធភាពពីរយ៉ាង ។ លទ្ធភាព**ទីមួយ** គឺត្រូវផ្តល់ពតិមានពីការប្រើប្រាស់កន្លែងរក្សាទុកនូវស្បៀងបម្រុងជាឧបករណ៍សម្របសម្រួលតម្លៃស្រូវ ។ កាលបើពតិមានត្រូវបានរាយ-ការណ៍ហើយ ប្រទេសកម្ពុជាអាចប្រើប្រាស់កម្រិតដូច១ គ្នាជារៀងរាល់ឆ្នាំ ។ លទ្ធភាព**ទីពីរ** គឺបទបញ្ញត្តិ “de minimis” គេអាចផ្តល់ការគាំទ្រតម្លៃចំពោះស្រូវអង្ករ ប្រសិនបើតម្លៃនៃការគាំទ្រនោះវាតិចជាង ១០% នៃតម្លៃសរុបនៃការផលិតស្រូវ ។

ដើម្បីឈានចូលទៅ WTO ប្រទេសកម្ពុជាត្រូវភ្ជាប់តារាងតម្លៃរបស់ខ្លួន លើផលិតផលកសិកម្មក្នុងកម្រិតផ្សេងៗគ្នា។ ចំពោះស្រូវជាគ្រាប់ធញ្ញជាតិយុទ្ធសាស្ត្ររបស់ខ្មែរ តារាងតម្លៃគឺអាចឈានដល់ ៤០ % តើកម្រិតនោះវាគ្រប់គ្រាន់ ដើម្បីគាំពារផលិតកម្មក្នុងស្រុក និងកសិករ និងបញ្ចៀសតម្លៃថោកនៃការនាំស្រូវចូលឬទេ? ការស្ទង់មតិលើភាពខុសគ្នារវាងតម្លៃក្នុងស្រុក និងតម្លៃអន្តរជាតិ មានសារៈសំខាន់ណាស់ចំពោះការប្រើប្រាស់ឧបករណ៍គាំពារ (ប្រសិនបើចាំបាច់) ដែលកិច្ចព្រមព្រៀងស្តីពី កសិកម្មរបស់អង្គការ WTO បានយល់ព្រមឱ្យប្រើប្រាស់។ ក្នុងករណីដែលមានការកើនឡើងយ៉ាងលឿននូវបរិមាណនៃការនាំចូលប្រទេសកម្ពុជា អាចនឹងត្រូវងាកទៅយកបទបញ្ញត្តិនៃការការពា ជាពិសេសបន្ថែមពន្ធ ៣០ % ទៅនឹងតារាងតម្លៃសម្រាប់រយៈពេលមួយ ដែលមានកំណត់ (មិនលើសពីមួយឆ្នាំ)។

ដើម្បីចៀសវាងកុំឱ្យការប្រកួតប្រជែង នៃផលិតផលរបស់កម្ពុជាថយចុះ នៅចំពោះមុខផលិតផលនាំចូលជាការចាំបាច់ គឺត្រូវឱ្យមានការគាំទ្រមួយ ចំពោះការបង្កើនគុណភាពនៃផលិតភាព។ ការណ៍នេះមានន័យថា ធ្វើឱ្យគុណភាពនៃដើមទុន (ពូជ ជី ថ្នាំសម្លាប់សត្វល្អិត) កាន់តែប្រសើរឡើងជំរុញឱ្យមានការហ្វឹកហ្វឺនកសិករ និងគាំទ្រអង្គការកសិករ ដើម្បីធ្វើឱ្យលទ្ធភាពទីផ្សាររបស់ពួកគេកាន់តែល្អប្រសើរ នៅចំពោះមុខពាណិជ្ជករ។ ការងារនេះអាចធ្វើបានក្រោមក្របខ័ណ្ឌនៃអង្គការ WTO ពីព្រោះវិធានការទាំងនេះត្រូវបានចាត់បញ្ចូលក្នុងប្រអប់បៃតង។

## ៤- ការប្រើកាលានុវត្តភាពនៃការនាំចេញ

តាមការចូលជាសមាជិក WTO ប្រទេសកម្ពុជាត្រូវប្រឈមនឹងកាលានុវត្តភាពនៃការនាំចេញជាច្រើន។ ប្រសិនបើប្រទេសអភិវឌ្ឍន៍ខ្លះ រកទីផ្សាររបស់ខ្លួនបានល្អ

ហើយដោយមកពីលក្ខន្តិកៈជា LDC របស់ប្រទេសកម្ពុជា ការរកបានទីផ្សារនោះនឹងត្រូវពង្រឹងថែមទៀត ហើយសមាជិក WTO ទាំងអស់នឹងអនុវត្តចំពោះប្រទេសកម្ពុជា នូវប្រព្រឹត្តិកម្មជាប្រទេសអនុគ្រោះបំផុត (Most Favored Nation)។

ប៉ុន្តែ ដើម្បីអាចឱ្យមានការនាំផលិតផលកសិកម្មចេញទៅប្រទេសឯទៀតៗ និងជាពិសេសទៅទៀតប្រទេសអភិវឌ្ឍន៍ (ប្រទេសអ្នកមាន) ការប្រកួតជាមួយលក្ខណៈវិនិច្ឆ័យនៃការ SPS គឺជាការចាំបាច់។ រឿងនេះតម្រូវឱ្យមានការវិនិយោគ លើការទុកដាក់ក្នុងឃ្លាំង ការប្រើម៉ាស៊ីនត្រជាក់ និងបន្ទប់ពិសោធន៍ ការអនុវត្តប្រព័ន្ធអធិការកិច្ចដោយខ្លួនឯង ការអនុវត្តការត្រួតពិនិត្យជាសាធារណៈ ការហ្វឹកហ្វឺនតាំងពីកសិកររហូតដល់អ្នកនាំចេញ។

ការបិទផ្លាកលើផលិតផល គឺជាឧបករណ៍សម្រាប់បង្កើនតម្លៃបន្ថែម ជាការប្រជែងតាមរបៀបនេះជាមួយនឹងទីផ្សារ នៅក្នុងប្រទេសអភិវឌ្ឍន៍ មានដូចជាផលិតផលមានជីវិត។ ការបង្កើតឡើងនូវសន្ទស្សន៍ភូមិសាស្ត្រ ដែលគាំពារដោយក្របខ័ណ្ឌនៃអង្គការ WTO ក៏អាចផ្តល់នូវកាលានុវត្តភាពដ៏ល្អៗដែរ។

# ផ្នែកទី ៣

# របាយការណ៍សង្ខេបនៃវេទិកាសាធារណៈ

# របាយការណ៍សង្ខេបនៃវេទិកា ទី ១

## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក ទស្សនៈរួម

**សេចក្តីផ្តើម** :

ក្រោយពីមានការបោះឆ្នោតថ្នាក់ជាតិដំបូងបំផុត ក្នុងឆ្នាំ ១៩៩៣ មក ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាហូរហែ និងទៀងទាត់រហូតមក។ ដំណើរការបោះឆ្នោតនេះបានមកនូវសន្តិភាព និងស្ថិរភាពនៃនយោបាយសេដ្ឋកិច្ចក្នុងអំឡុងពេលសតវត្សក្រោយនេះ។

រយៈកាលនេះប្រទេសកម្ពុជា ក៏បានបើកចំហទ្វារសារជាថ្មី សម្រាប់ឱកាសពាណិជ្ជកម្មថ្នាក់ដំបូង និងពាណិជ្ជកម្មអន្តរជាតិ និងបានក្លាយជាសមាជិកអាស៊ាន (ASEAN) និងអង្គការពាណិជ្ជកម្មពិភពលោក (WTO)។

វេទិកាលើកទី១ ឆ្នាំ ២០០៥ ស្តីអំពី *"ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក WTO ទស្សនៈរួម"* បានប្រព្រឹត្តទៅ កាលពីថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០០៥ ក្រោមអធិបតីភាពរបស់ឯកឧត្តម អ៊ឹង ហួត ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា និងជាអនុប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ដោយមានការចូលរួមពីគណៈវាគ្មិនកិត្តិយសពីររូប និងអ្នកសម្របសម្រួលមួយរូប។ សម្របសម្រួល គម្រោងកម្មវិធីនេះត្រូវធ្វើឡើងដោយ លោកបណ្ឌិត **ចាប សុថារិទ្ធ**

នាយកប្រតិបត្តិការនៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព។ វាគ្មិនទី១ : លោក **ចាន់ សេរី** នាយក នាយកដ្ឋានធនធានមនុស្សនៃធនាគារ អេស៊ីលីដា ភី អិល ស៊ី (ACLEDA Bank. PLC), វាគ្មិនទី២ : លោក តឹករ៉េត សំរេច ជំនួយការឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

ក្នុងឱកាសនោះ លោកបណ្ឌិត បានបញ្ជាក់ថា វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បានរៀបចំសន្និសីទថ្នាក់ជាតិម្តងរួចទៅហើយ កាលពីឆ្នាំ ២០០៣ ស្តីពី ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក។ អង្គការពាណិជ្ជកម្មពិភពលោក គឺជាបញ្ហាសំខាន់ដែលរាជរដ្ឋាភិបាលសម្រេចចិត្តចូលជាសមាជិក។ នៅក្នុងឆ្នាំ ២០០៥ វិទ្យាស្ថានបានធ្វើកិច្ចពិភាក្សាតុមូលចំនួន ១០ លើក និងសន្និសីទថ្នាក់ជាតិមួយលើកថែមទៀត ដើម្បីពិភាក្សាវែកញែករកផលចំណេញដែលប្រទេសកម្ពុជាបានចូលជាសមាជិកនៃអង្គការនេះ។ ជាមួយនោះដែរ លោក បណ្ឌិត ក៏បានលើកពីយុទ្ធសាស្ត្រត្រីកោណរបស់រាជរដ្ឋាភិបាលដែលមានចំណុចសំខាន់បីគឺ :

- ធ្វើឱ្យមានស្ថិរភាពនយោបាយ និងសន្តិភាពនូវពេញផ្ទៃប្រទេស
- រក្សាកំណើនសេដ្ឋកិច្ច
- ការកាត់បន្ថយភាពក្រីក្រ។

ក្នុងចំណោមចំណុចទាំងបីខាងលើចំណុច ទី ១ និង ចំណុច ទី ២ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើឱ្យសម្រេចជាស្ថាបពរ តែចំណុចទី ៣ មិនទាន់សម្រេចនៅឡើយនេះបើតាមប្រសាសន៍របស់លោក បណ្ឌិត ចាប សុថារិទ្ធ។

## II- ទស្សនៈរួមនៃវាគ្មិនកិត្តិយស :

(១) -**លោក ចាន់ សេរី** នាយក នាយកដ្ឋានធនធានមនុស្សនៃធនាគារអេស៊ីលីដា ភីអិលស៊ី បានបង្ហាញនូវទស្សនវិស័យរបស់លោក ស្តីពី "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក" (WTO) ដែលជាសំខាន់ទៅលើការកសាងធនធានមនុស្ស ។

*ក- គោលបំណង :*

កម្ពុជាចូលជាសមាជិកភាព WTO ដើម្បីចូលរួមកសាងធនធានមនុស្សឱ្យសម្រេចនូវឧត្តមប្រយោជន៍ជាតិ ។

*ខ-កត្តាធនធានមនុស្ស*

អ្វីៗទាំងអស់ ក្នុងលោកសម្រេចបានអំពីមនុស្ស ។ ដូច្នេះ ចាំបាច់ត្រូវរៀបចំអភិវឌ្ឍន៍នូវធនធានមនុស្សឱ្យបាន ដំបូងមុនគេបង្អស់ ។

*គ-ការអភិវឌ្ឍធនធានមនុស្ស*

ជ្រើសរើសមនុស្សឱ្យបានល្អ (មនុស្សល្អ គឺ : មនុស្សមានអត្តចរិតល្អ, មានចំណេះដឹង និងជំនាញស្របតាមតួនាទី) ពោលគឺ :

- យល់ដឹង និងបដិបត្តិល្អតាមច្បាប់ជាតិ និងអន្តរជាតិ
- យល់ដឹង និងអនុវត្តល្អតាមគោលការណ៍ និងនីតិវិធីរបស់ការងារក្នុងតួនាទី
- ចំណេះដឹងការងារក្នុងតួនាទី អប់រំបណ្តុះវប្បធម៌ការងារល្អ ដូចជាការបដិបត្តិដោយគោរព ដើម្បីឱ្យមាននូវសុចរិតភាពឆន្ទៈនយោបាយ ។
- ធ្វើឱ្យបានសម្រេចផល ទាំងបរិមាណ និងគុណភាពតាមផែនការជាគោលដៅកំណត់ ។

- យល់ដឹងអំពីសិទ្ធិការងាររបស់ខ្លួន និងអ្នកដទៃ ទាំងបរិស្ថានរស់នៅ និងបរិស្ថានសង្គម ( មិនសាងនូវអំពើបាប ខំប្រឹងសាងកុសល និងធ្វើចិត្តឱ្យស្អាតផូរផង់) ។
- ដោយគិតគូរតាំងពីការក្សាការពារឱ្យមាននូវសុខភាពល្អ (បង្កើតកម្លាំងកាយ និងកម្លាំងចិត្ត កម្លាំង បញ្ញាស្មារតី) ។
- ការឧបត្ថម្ភដល់ជីវភាពធ្វើឱ្យមានការចូលរួមពីគ្រប់លំដាប់ថ្នាក់( មតិយោបល់)
- រួមបង្កើតគោលការណ៍ នីតិវិធី និងរួមអនុវត្ត ។
- រួមត្រួតពិនិត្យកែលម្អ ដើម្បីអភិវឌ្ឍការងារទាន់សម័យ ។
- សិក្សាបន្តពីគ្នា និងគ្នា ដើម្បីអភិវឌ្ឍន៍ចំណេះដឹងជានិច្ចធ្វើអ្វី១ ត្រូវចេះគិតដល់ផលចំណេញ ដើម្បីឧត្តមប្រយោជន៍ជាតិ ( ក្រុមហ៊ុនស្ថាប័ន) ។
- ត្រូវគិតដល់ភពផែនដី ( បរិស្ថានសង្គម) ។

ទាំងអស់ខាងលើនេះ ត្រូវហ្វឹកហាត់ជារឿយ១ ឱ្យទៀងទាត់ ។ល។ ។

*ឃ-ជំហានឆ្ពោះទៅរកការសម្រេចបំណង*

ធនធានមនុស្សដែលអនុវត្តការងារក្នុងតួនាទី បានសម្រេចលទ្ធផលតាមបំណង លុះត្រាតែអនុវត្តតាមជំហាន ដូចខាងក្រោម :

**ឆន្ទះ** ត្រូវមានការស្រឡាញ់ពេញចិត្ត នូវការងារក្នុងតួនាទីរបស់ខ្លួន ។

**វិរិយះ** ត្រូវមានសេចក្ដីព្យាយាមធ្វើការងាររបស់ខ្លួន ឱ្យសម្រេចប្រកបដោយគុណភាពល្អមិនបោះបង់ចោល ។

**ចិត្តះ** ប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ ចៀសឱ្យផុតនូវអគតិធម៌ និងលះបង់នូវអកុសល ( លោភៈ ទោសៈ និងមោហៈ)

**វិមំសាៈ** មើលស្នាដៃរបស់ខ្លួនដែលបានធ្វើហើយ ដើម្បីកែលម្អបំពេញកង្វះខាត ( អភិវឌ្ឍលទ្ធផលឱ្យកាន់តែមានគុណភាព)

ជាសង្ខេប **លោក ចាន់ សោរី** បានវាយតម្លៃធនធានមនុស្សជាកត្តាចំបង បំផុតក្នុងការធ្វើឱ្យសម្រេចបំណងប្រទេសកម្ពុជា និងការទាញផលប្រយោជន៍ពីអង្គការពាណិជ្ជកម្មពិភពលោក។ នេះជាទស្សនៈតំណាងឱ្យផ្នែកឯកជន ។

(២)- លោក **តឹករ៉េត សំរេច** ជំនួយការផ្ទាល់របស់ឯកឧត្តម **សុខ អាន** បានលើកឡើងថា បើនិយាយពីអង្គការពាណិជ្ជកម្មពិភពលោក ចាំបាច់ត្រូវនិយាយអំពីនិន្នាការសេដ្ឋកិច្ចថ្មីរបស់ប្រទេសកម្ពុជា។ ការកែទម្រង់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ពីសេដ្ឋកិច្ចផែនការប្រមូលផ្តុំមកសេដ្ឋកិច្ចទីផ្សារសេរី កើតឡើងនៅឆ្នាំ ១៩៩៣ ក្រោយពីមានការបោះឆ្នោតជាសកល។ ទន្ទឹមនឹងនោះ ការដាក់ពាក្យសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក្រុមការងារត្រួតពិនិត្យការសុំចូលរបស់កម្ពុជា ត្រូវបានបង្កើតនៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ១៩៩៤។ លោក បានបញ្ជាក់បន្ថែម ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការចូលជាសមាជិក WTO ដែលភ្ជាប់ជាមួយនូវល័ក្ខខ័ណ្ឌជាច្រើនដូចជា ការកែទម្រង់ច្បាប់ និងបង្កើតច្បាប់ ការបង្កើតនូវតុលាការពាណិជ្ជកម្មជាដើម។ ចំណែកឯដៃគូពាណិជ្ជកម្មសំខាន់ៗ ដែលកម្ពុជាធ្វើការចរចាទ្វេភាគី រួមមានប្រទេសអាមេរិក, សហគមន៍អឺរ៉ុប, ជប៉ុន, ឥណ្ឌា, កូរ៉េ, កាណាដា, អូស្រ្តាលី និងចិនតៃវ៉ាន់។ ការកកើតអង្គការWTO គឺនៅថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៩៥ ដែលមានសមាជិក ១៤៨ ប្រទេស ហើយប្រទេសដែលចូលចុងក្រោយគេគឺ កម្ពុជា, នេប៉ាល់ និងប្រទេសដែលកំពុងសុំចូលជាសមាជិកមានចំនួន ២៥។ លេខាធិការដ្ឋានអង្គការ WTO មានទីតាំងនៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស ដែលមានអគ្គនាយកគឺ លោក Supachai Panitchpakdi ចាប់ពីថ្ងៃ ទី១០ ខែកញ្ញា ២០០២ ដល់ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៥។ អង្គការ WTO មានថវិកាប្រហែល ១៥០ លានដុល្លាអាមេរិក ហើយ

សមាជិកនីមួយៗ ត្រូវបង់ប្រាក់ទៅតាមតម្លៃនៃការធ្វើពាណិជ្ជកម្ម។ អង្គការ WTO មិនមែនជាភ្នាក់ងារផ្តល់ជំនួយការអភិវឌ្ឍន៍ទេ អង្គការនេះជាយន្តការសម្របសម្រួលពាណិជ្ជកម្ម ដែលមានទំនាក់ទំនង ពិសេសជាមួយមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ។

*មុខនាទីសំខាន់ៗ របស់*WTO :

- អនុវត្តសន្ធិសញ្ញាពាណិជ្ជកម្មពហុភាគី
- ជាវេទិកាសម្រាប់ការចរចា
- ជាវេទិកាដោះស្រាយជម្លោះរវាងសមាជិក
- ជាអ្នកត្រួតពិនិត្យ ការអនុវត្តន៍គោលនយោបាយពាណិជ្ជកម្ម នៃប្រទេសជាសមាជិក
- ធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ។

*យុត្តាធិការរបស់*WTO

សន្ធិសញ្ញាពាណិជ្ជកម្មនេះ មានកិច្ចព្រមព្រៀងទាំងអស់ចំនួន ២៧ ដែលត្រូវអនុវត្តដោយសមាជិកទាំង ១៤៨ ទៅតាមការសន្យារបស់ខ្លួន ទៅតាមកិច្ចព្រមព្រៀងលើការធ្វើពាណិជ្ជកម្មទំនិញ និងកិច្ចព្រមព្រៀងលើការធ្វើពាណិជ្ជកម្ម សេវាកម្ម រួមនឹងកិច្ចព្រមព្រៀងលើពាណិជ្ជកម្មទាក់ទង និងកម្មសិទ្ធិបញ្ញា។ ក្រៅពីនេះ លោកសំរេច ក៏បានលើកផងដែរ ពីរចនាសម្ព័ន្ធរបស់អង្គការ WTO ដែលរួមមាន :

- សន្និសីទថ្នាក់រដ្ឋមន្ត្រី (Ministerial Conference)
- អគ្គក្រុមប្រឹក្សា (General Council) ដែលរួមមានការដោះស្រាយជម្លោះ យន្តការត្រួតពិនិត្យនយោបាយពាណិជ្ជកម្ម។

- ក្រុមប្រឹក្សា (Council) ដែលក្នុងនោះមានពាណិជ្ជកម្មទំនិញ, ពាណិជ្ជកម្មលើវិស័យសេវាកម្ម និងពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ។
- កិច្ចសន្យានានានឹងកិច្ចសន្យាលម្អិតផ្សេងៗ រួមមានក្រោមកិច្ចព្រមព្រៀងនីមួយៗ ការខាតបង់ថវិកា តុល្យាភាពជញ្ជីងទូទាត់, ពាណិជ្ជកម្ម និងការអនុវត្តន៍ ។

*សេចក្តីសម្រេចរបស់* (Decision maleing) របស់ WTO

- កុងសង់ស៊ុស
- ការបោះឆ្នោត
- សិទ្ធិនៃការលើកលែងមិនអនុវត្តកាតព្វកិច្ច
- ការសុំដកខ្លួនថយពីសមាជិកភាព

លោកបានបន្ថែមទៀតថា អង្គការ WTO មិនដូចទៅនឹងអង្គការសហប្រជាជាតិទេ តែទាក់ទងផ្ទាល់ជាមួយផ្នែកមួយចំនួនរបស់អង្គការសហប្រជាជាតិ ។

*ឥទ្ធិពលរបស់អង្គការពាណិជ្ជកម្មពិភពលោក* :

- ឥទ្ធិពលលើនយោបាយសេដ្ឋកិច្ច
- ឥទ្ធិពលលើវិស័យឯកជន
- ឥទ្ធិពលលើសង្គម
- ការវាយតម្លៃផលប៉ះពាល់លើសេដ្ឋកិច្ច
- នាទីរបស់វិស័យឯកជន
- នាទីរបស់សកលវិទ្យាល័យ

នៅចុងបញ្ចប់ លោកបានបញ្ជាក់បន្ថែមទៀតថា ក្នុងអំឡុងពេលបីឆ្នាំខាងមុខនេះ គឺ ឆ្នាំ ២០០៥, ២០០៦, ២០០៧, កម្ពុជាត្រូវធ្វើច្បាប់ឱ្យបានចំនួន ៤៧ ច្បាប់ ដែលពាក់ពន្ធជាសំខាន់ជាមួយអង្គការពាណិជ្ជកម្មពិភពលោក ។

## III- មតិនៃអង្គពិភាក្សា :

ក្នុងការបើកកិច្ចពិភាក្សា ឯកឧត្តម **អ៊ឹង ហួត** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាអនុប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បានសង្កាត់ធ្ងន់ថា ដើម្បីទទួលបានចំណេញពីអង្គការ WTO យើងត្រូវរៀនភាសាបរទេស ។ ជាពិសេសភាសាអង់គ្លេស ។ ចំណែក បណ្ឌិត **ចាប សុថារិទ្ធ** វិញ លោកបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើគុណសម្បត្តិ និងគុណវិបត្តិនៃការចូលជាសមាជិក WTO របស់ប្រទេសកម្ពុជា :

**គុណសម្បត្តិ :**

- ប្រទេសកម្ពុជាចាប់យកទីផ្សារធំទូលាយដែលមាន ១៤៨ ប្រទេសជា ឱកាសឱ្យប្រទេសកម្ពុជា បានកសាងសមត្ថភាពរបស់អ្នកជំនាញ លើប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ នឹងជំរុញឱ្យមានអភិបាលកិច្ចល្អ ដោយត្រូវបង្កើតច្បាប់បន្ថែម និងប្រសិទ្ធិភាពនៃការអនុវត្តន៍ច្បាប់ ។
- បង្កើនការទាក់ទាញវិនិយោគ ។

**គុណវិបត្តិ :**

- ការកែទម្រង់ធ្វើឱ្យមានការប៉ះពាល់ដល់ការបង់ថ្លៃជាប្រចាំ ដូចជា ការចូលជាសមាជិកអាស៊ានដែរ
- អាចបាត់ភាពទន់ភ្លន់ក្នុងការរៀបចំគោលនយោបាយ

ក្រៅពីនេះ មតិនៃអង្គពិភាក្សា ភាគច្រើនបានចាប់អារម្មណ៍ទៅលើការបង្កើតច្បាប់ និងការអនុវត្តន៍ច្បាប់ ដោយសាររយៈពេលខ្លី គឺរយៈបីឆ្នាំ ត្រូវបង្កើតច្បាប់ឱ្យបាន ៤៧ ច្បាប់។ តែក្ដីកង្វល់នេះអង្គពិភាក្សាបានរកដំណោះស្រាយ ដោយបានបញ្ជាក់ថា ច្បាប់មួយចំនួន បានបង្កើតរួចហើយត្រូវសម្រួលតែប៉ុណ្ណោះ ដូច្នេះ យើងមិនត្រូវបារម្ភពេកទេ។ ចំណែកបញ្ហាអនុវត្តច្បាប់ត្រូវតែមានលក្ខណៈសកលពីព្រោះប្រទេស ១៤៧ ជាអ្នកឃ្លាំមើល។ ពិសេសជាងនេះទៅទៀត អង្គពិភាក្សាបានរកឃើញថា ត្រូវតែជំរុញឱ្យប្រជាជនប្រើប្រាស់ផលិតផលក្នុងស្រុក។ ដើម្បីទប់ស្កាត់ការហូរចូលទំនិញពីប្រទេសថៃឡង់ដ៍ វៀតណាម ឯការផ្សព្វផ្សាយអង្គពិភាក្សាទាំងមូលបានឯកភាពគ្នា និងត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីប្រជាជនខ្មែរចូលរួមឱ្យមានក្រុមកម្លាំងសង្គមស៊ីវិលរួបរួមធ្វើសេចក្ដីសម្រេចលើការបង្កើតច្បាប់។ ចំណែកឯកង្វល់របស់និស្សិតក្នុងការស្វែងរកការងារធ្វើនោះអង្គពិភាក្សាបានយល់ថា ត្រូវគិតពីសីលធម៌ វិជ្ជាជីវៈ សមត្ថភាព ជំនាញ ចំណេះដឹងធ្វើសីលធម៌សង្គម និងធ្វើយ៉ាងណាឱ្យដើរទាន់បច្ចេកវិទ្យាទំនើប។

## IV- **សេចក្តីសន្និដ្ឋាន** :

ជារួមកិច្ចពិភាក្សាតុមូលលើកទី១ បានបញ្ចប់នៅម៉ោង១២ ថ្ងៃត្រង់ ប្រកបដោយលទ្ធផលគួរជាទីគាប់ចិត្ត។ ប្រជាជាតិខ្មែរទាំងមូលត្រូវតែទទួលបាននូវចំណេះដឹងពី WTO និងប្រឹងប្រែងបង្កលក្ខណៈអំណោយផលដើម្បីទាក់ទាញ និងជំរុញពាណិជ្ជកម្ម និងមានវិនិយោគឱ្យកាន់តែច្រើន ពិសេសកំណែទម្រង់ច្បាប់ជាច្រើន ជាអាទិ៍ ច្បាប់ស្តីពីក្រុមពាណិជ្ជកម្ម, ច្បាប់ស្តីពី ពីកិច្ចសន្យា, ច្បាប់កម្មសិទ្ធិបញ្ញា, ច្បាប់ក្ស័យធន, ច្បាប់ដីធ្លី, និងច្បាប់រួមបញ្ចូល និងការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព និងសីលធម៌ថែមទៀត។

# របាយការណ៍សង្ខេបនៃវេទិកា ទី ២

## ថាតើមានផលលំបាកខាងច្បាប់ និងគោលនយោបាយអ្វីខ្លះ ដល់សមាជិកភាពរបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក?

## I-សេចក្តីផ្តើម

ដើម្បីអនុវត្តកិច្ចព្រមព្រៀងនានា របស់អង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាត្រូវបង្កើនល្បឿនក្នុងការតាក់តែង និងអនុម័តច្បាប់គោលនានាឱ្យបានគ្រប់គ្រាន់។ ច្បាប់នោះទៀតសោតត្រូវគោរពទៅតាមស្តង់ដារអន្តរជាតិ។ សមាជិកភាពរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោកអាចមានផលវិបាកខាងច្បាប់ និងគោលនយោបាយនានានៅកម្ពុជា។ អាស្រ័យហេតុនេះ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាពបានរៀបចំវេទិកាលើកទី២ ស្តីអំពី ថាតើមានផលលំបាកខាងច្បាប់ និងគោលនយោបាយអ្វីខ្លះ ដល់សមាជិកភាពរបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក?

## II-ទស្សនៈរួមនៃគណៈវាគ្មិនកិត្តិយស

លោកបណ្ឌិត **ចាប សុថារិទ្ធ** នាយកប្រតិបត្តិនៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បានអញ្ជើញគណៈវាគ្មិនកិត្តិយសពីររូប (ក)-លោក **តាន់ យុទរដ្ឋ** អនុប្រធានការិយាល័យ សេវាកម្ម នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ

ក្រសួងពាណិជ្ជកម្ម, (ខ)-លោកមេធាវី **សុក សំអឿន** នាយកក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។

(ក)-លោក តាន់ យុវរដ្ឋ បានបញ្ជាក់បន្ថែមថា ការបរិច្ឆេទចូលរបស់ប្រទេសកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក គឺនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០០៤ ជាសមាជិក ទី ១៤៧។ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៤ រដ្ឋសភាបានឱ្យសច្ចាប័ន។

ក្រោយពីព្រះរាជាណាចក្រកម្ពុជា បានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកជាផ្លូវការ នៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៤ មក កម្ពុជាត្រូវបំពេញនូវកាតព្វកិច្ចជាច្រើនសម្រាប់ស្ថាប័ននេះ ក្នុងនោះក៏មានល័ក្ខខ័ណ្ឌនៃការកសាងច្បាប់ និងគោរពនយោបាយនានា ដើម្បីគាំទ្រដល់សេរីភាវូបនីយកម្មពាណិជ្ជកម្មនៅប្រទេសកម្ពុជាផងដែរ។

លោកបានលើកឡើងពីផលលំបាកខាងវិស័យច្បាប់របស់កម្ពុជា រួមមាន :

- ច្បាប់ចំនួនប្រមាណ ៤០ ត្រូវកសាងថ្មី ឬធ្វើវិសោធនកម្ម
- ច្បាប់នីមួយៗ ត្រូវប្រើរយៈពេល ២ ខែ និងអាចឈានទៅដល់១ឆ្នាំ
- ធនធានមនុស្សដែលត្រូវបំពេញការងារលើកកិច្ចព្រមព្រៀង
- អង្គការពាណិជ្ជកម្មពិភពលោក មានចំនួនជាង ២០ កិច្ចព្រមព្រៀង ហើយមានលក្ខណៈស្មុគស្មាញពិបាកយល់។ ដូច្នេះ ទាមទារឱ្យមានការរៀបចំធនធានមនុស្សដែលមានសមត្ថភាពការងារ ដើម្បីសិក្សាស្រាវជ្រាវឱ្យយល់ច្បាស់លើកិច្ចព្រមព្រៀងនីមួយៗ ។
- ការងារសម្របសម្រួលអន្តរក្រសួង មិនបានស៊ីចង្វាក់គ្នា ដោយខ្វះធនធានជំនាញតាមស្ថាប័ននីមួយៗ។ ដូច្នេះ ត្រូវពិគ្រោះជាមួយក្រសួងជំនាញដែលមានការយល់ដឹងពីច្បាប់ និងបទបញ្ញត្តិអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីជួយ

ពិនិត្យពីភាពស្របគ្នា ជាមួយច្បាប់បទបញ្ញត្តិអង្គការពាណិជ្ជកម្មពិភពលោក ទាំងអស់នោះ ដែលអាចជាការចំណេញពេលវេលា និងនីតិវិធីមុននឹងបញ្ជូនទៅពិភាក្សានៅគណៈរដ្ឋមន្ត្រី។

- ពេលវេលាសមស្របដើម្បីកសាង និងឆ្លុះបញ្ចាំងពីតម្រូវការពិតប្រាកដខាងសេដ្ឋកិច្ច និងសង្គមកិច្ច គឺត្រូវមានការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយវិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត។

លោកក៏បានបញ្ជាក់បន្ថែមទៀតថា ច្បាប់ ឬបទបញ្ញត្តិ ចាស់ទាំងឡាយណាដែលផ្ទុយពីគោលការណ៍ច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោកនឹងត្រូវធ្វើវិសោធនកម្ម។ ចំណែកឯច្បាប់ត្រូវកសាងថ្មីវិញ ត្រូវតែគោរពទៅតាមបទ-បញ្ញត្តិគោលការណ៍នានានៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ជាពិសេសគោលការណ៍ធំៗ ដែលត្រូវពិចារណានៅពេលកសាងច្បាប់នីមួយៗ។

*គោលការណ៍ទាំងនោះរួមមាន :*

ក-គោលការណ៍តម្លាភាពដោយធានាឱ្យមានការផ្សព្វផ្សាយច្បាប់ និងបទបញ្ញត្តិជាសាធារណៈ ក្នុងនោះកម្ពុជា បានសន្យានៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកថា រាល់ច្បាប់បទញ្ញត្តិនានា ត្រូវធ្វើការចុះផ្សាយក្នុងព្រឹត្តិប័ត្រជាផ្លូវការ រយៈពេល ១ខែ មុននឹងច្បាប់នោះចាប់ផ្តើមមានប្រសិទ្ធិភាពអនុវត្ត។

ខ-គោលការណ៍មិនរើសអើងចម្បងពីរ ក្នុងច្បាប់អង្គការពាណិជ្ជកម្មពិភពលោក :

- **កាតព្វកិច្ចប្រព្រឹត្តិកម្ម** MFN ជាការហាមឃាត់ប្រទេសមួយមិនឱ្យរើសអើងប្រឆាំង និងប្រទេសផងគ្នាឯទៀត។ ឧទាហរណ៍ នៅក្នុងប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោកមួយមានផលិតផលដូច ឬ ស្រដៀង

គ្នា ដែលនាំចូលមកពីប្រទេសពីរ,,,,,,ក្នុងករណីនេះ ប្រទេសម្ចាស់ផ្ទះ ត្រូវយកពន្ធដូចគ្នាលើទំនិញមកពីប្រទេសទាំងពីរ ហើយប្រសិនបើមានការផ្តល់ល័ក្ខខ័ណ្ឌអនុគ្រោះដល់ទំនិញរបស់ប្រទេសមួយ ជាមួយប្រទេសមួយទៀត ត្រូវតែទទួលបានល័ក្ខខ័ណ្ឌនោះដូចគ្នាដែរ ។

- **កាតព្វកិច្ចប្រព្រឹត្តិកម្មជាតិ**

កាតព្វកិច្ចប្រព្រឹត្តិកម្មជាតិ ជាកាតព្វកិច្ចដែលហាមឃាត់ប្រទេសមួយមិនឱ្យធ្វើការរើសអើងប្រឆាំង នឹង ផលិតផលរបស់ប្រទេសមួយទៀត នៅក្នុងទីផ្សារក្នុងស្រុក ។ ឧទាហរណ៍ផលិតផលសណ្តែកសៀងរបស់ប្រទេស "ក" អាចនាំចូលមកកាន់ប្រទេស "ខ" ដោយចំហ ក៏ប៉ុន្តែត្រូវបានគេកាត់បន្ថយភាពប្រកួតប្រជែងរបស់វា តាមរយៈការអនុវត្តន៍ទារយកពន្ធផ្សេងៗ ដែលធ្វើឱ្យទំនិញនេះបន្ថែមតម្លៃរបស់ខ្លួន ប៉ុន្តែមិនមានការយកពន្ធបែបនេះ លើផលិតផលដូចគ្នា ដែលផលិតនៅក្នុងស្រុកទេ ។ គោលការណ៍ប្រព្រឹត្តិកម្មជាតិនេះ គឺដើម្បីធានាឱ្យមានសមភាពរវាងផលិតផល,សេវា ដែលផលិតផលនៅក្នុងស្រុក និងផលិតករ សេវារបស់បរទេស ។

គោលការណ៍ប្រព្រឹត្តិកម្មជាតិចែងនៅក្នុង "ខ" នានា នៃកិច្ចព្រមព្រៀងសំខាន់បីរបស់អង្គការពាណិជ្ជកម្ម គឺកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម និងកម្មសិទ្ធិបញ្ញា (i) GATT: មាត្រា. ៣ (ii) GATS: មាត្រា ១៧, (iii) TRIPS មាត្រា ៣ ។

ដូច្នេះ យើងឃើញថាមានសំពាធច្រើន ទាំងធនធានមនុស្ស ហិរញ្ញវត្ថុ និងពេលវេលា ក៏ដូចជា ការសម្របសម្រួលក្នុងការកសាងច្បាប់នីមួយៗ ។ កុំថាឡើយសម្រាប់ប្រទេសកម្ពុជា សូម្បីតែប្រទេសជឿនលឿននៅលោកខាងលិច ដែលមានធនធានច្រើន ក៏ត្រូវចំណាយពេលវេលាយូរបង្គួរដែរ ដើម្បីកសាងច្បាប់បទបញ្ញត្តិ

ទីមួយៗ។ លោក យុវរដ្ឋ បានបន្ថែមទៀតថា បើយើងមិនធ្វើពលីកម្មទេ ប្រទេសយើងនឹងនៅតែពុំទាន់មានច្បាប់ទំនើបស្របតាមស្តង់ដារអន្តរជាតិ ដើម្បីជាមូលដ្ឋានសម្រាប់ធានា និងទាក់ទាញវិនិយោគ និងធុរជន មកបណ្តាក់ទុន និងធ្វើពាណិជ្ជកម្ម និងផ្តល់សេវានៅកម្ពុជាឡើយ។ លោកបានបញ្ជាក់ថា លោកចាំបានទូវប្រសាសន៍របស់អ្នកចរចាពាណិជ្ជកម្ម ដែលបានលើកឡើងថា ប្រសិនបើកម្ពុជាខិតខំជំរុញការកសាង និងកែទម្រង់ច្បាប់ ទោះបីមានការយឺតយ៉ាវក្តី ក៏ប្រទេសសមាជិកដទៃទៀតនឹងមានចិត្តជួយគាំទ្រ និងមានការយោគយល់វៀរលែងតែយើងមិនធ្វើអ្វីសោះ។

លោក យុវរដ្ឋ ក៏បានបញ្ជាក់ផងដែរថា យើងត្រូវតែមានការប្រុងប្រយ័ត្នជាងមុន ព្រោះយើងជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក យើងត្រូវអនុវត្តគោលការណ៍ MFN ប្រសិនបើយើងផ្តល់អនុគ្រោះអ្វីមួយ យើងពិចារណាឱ្យបានម៉ត់ចត់ អំពីលទ្ធភាពដែលអាចផ្តល់ផលចំណេញដល់សមាជិកផ្សេងៗ ទៀត ដែលអាចជាគូប្រជែងដ៏ស្រួចស្រាលជាមួយយើង។

(ខ)-លោក សុក សំអឿន បានលើកឡើងថា ប្រទេសកម្ពុជាបានសម្រេចចិត្តចូល ជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករួចទៅហើយ ដូច្នេះ យើងត្រូវត្រៀមខ្លួនទប់ទល់នឹងផលជាអវិជ្ជមានទាំងឡាយ និងព្យាយាមកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានទាំងនោះ។ ចំពោះផលប៉ះពាល់សេដ្ឋកិច្ច ក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូងកម្ពុជា ប្រហែលជាត្រូវរងការសម្រុកចូលនៃមុខទំនិញ និងក្រុមហ៊ុនបរទេសជាច្រើនជាប្រាកដណាស់ ហើយកម្ពុជាក៏ប្រឈមទៅនឹងការប្រកួតប្រជែងជាមួយនឹងបរទេសដែរ ដូចជា : ការប្រកួតប្រជែងផលិតផល ការប្រកួតប្រជែងទីផ្សារពលករ ការប្រកួតប្រជែងឧស្សាហកម្ម និងវត្ថុធាតុដើម។

លោកបានសង្កត់ធ្ងន់ថា កម្ពុជានៅតែគ្មានការរីកចម្រើនផ្នែកឧស្សាហកម្មដដែល។ កន្លងមកឃើញមានរោងចក្រខ្លះលក់ទៅឱ្យជនបរទេស តែបែរជាមិនដំណើរការទៅវិញ ដូចជាគ្រាន់តែទិញដើម្បីបិទ ដើម្បីបើកឱ្យផលិតផលប្រទេសជិតខាងដំណើរការនៅទីផ្សារនៅកម្ពុជាទៅវិញ។ លោកយល់ថា ដោយការដឹកវត្ថុធាតុដើមចេញក្រៅប្រទេសវាងាយពេកនោះ នឹងអាចមានបញ្ហាបី គឺកម្ពុជានៅតែគ្មានការរីកចម្រើនផ្នែកឧស្សាហកម្មដដែល។ ពលករកម្ពុជានៅតែខ្វះការងារធ្វើដដែល និងវត្ថុធាតុដើមកម្ពុជាងាយនឹងរលាយនាអនាគត។

ដូច្នេះ ដើម្បីទប់ទល់នឹងបញ្ហានេះ ការនាំចេញនូវវត្ថុធាតុដើមសុទ្ធៗ ត្រូវតែហាមឃាត់ឬរឹតបន្តឹង។ ប្រសិនបើច្បាប់កំណត់ថា ត្រូវហាមឃាត់ការនាំចេញនូវវត្ថុធាតុដើមសុទ្ធ យើងអាចបង្ខំឱ្យក្រុមហ៊ុនបរទេសត្រូវបង្កើតរោងចក្រនៅកម្ពុជា ដើម្បីផលិតរបស់នាំចេញ ឬយ៉ាងហោចឱ្យពាណិជ្ជករកម្ពុជាអាចនឹងបែកគំនិតអភិវឌ្ឍឧស្សាហកម្ម។ ហើយ កាលបើមានរោងចក្រកើតឡើងច្រើន ពេលនោះកម្ពុជាក៏នឹងអាចសម្បូរការងារដល់ប្រជាពលរដ្ឋកម្ពុជាដែរ។

លោកបានលើកឡើងពីចំណុចខ្សោយ ដែលធ្វើឱ្យឧស្សាហកម្មកម្ពុជាមិនអាចនឹងរីកចម្រើនទៅបាន នោះគឺការខ្វះនូវហេដ្ឋារចនាសម្ព័ន្ធ ដូចជា ថ្នល់ ផ្លូវដែក អគ្គិសនី និងទឹក។ ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធទាំងនេះនៅខ្វះខាតនោះ ថ្លៃដឹកជញ្ជូននឹងមានតម្លៃខ្ពស់ ដែលនាំឱ្យតម្លៃផលិតផលក្នុងស្រុកអាចនឹងឡើងខ្ពស់។ ដូច្នេះ ដើម្បីអាចជួយទ្រទ្រង់ផលិតផលក្នុងស្រុកឱ្យបាននោះ គឺត្រូវពង្រឹងហេដ្ឋារចនាសម្ព័ន្ធទាំងនោះឱ្យបាន។

ចំណុចខ្សោយមួយទៀតគឺ អំពើពុករលួយ ក៏ជាកត្តាដែលនាំឱ្យមានការថយចុះនូវវិនិយោគទុនបរទេស និងនាំឱ្យផលិតផលក្នុងស្រុកឡើងថ្លៃ ឬរាំងស្ទះមិនអាចនឹងមានការរីកចម្រើនដែរ។ ទោះបីជាបើកចំហយ៉ាងនេះ ថ្វីត្បិតតែការចូលជាសមាជិក

អង្គការពាណិជ្ជកម្មពិភពលោកតម្រូវឱ្យកម្ពុជា ត្រូវមានច្បាប់ជាមូលដ្ឋានមួយចំនួនធំក៏ដោយ ក៏មិនសង្ឃឹមថា អ្នកវិនិយោគទុនបរទេសក្រោយពេលដែលគេឃើញថា កម្ពុជាមានច្បាប់គ្រប់គ្រាន់ហើយ នោះពិតជាបោលសម្រុកចូលមកដាក់វិនិយោគជាមិនខាន។ កត្តាដែលសំខាន់នោះគឺ ថាតើប្រសិនបើគេមានជម្លោះណាមួយ គេនឹងទទួលបាននូវយុត្តិធម៌ដែរឬទេ? តើគេទទួលបាននូវការការពារនោះដែរឬទេ? និយាយឱ្យខ្លី ទោះបីជាមានច្បាប់ច្រើនយ៉ាងណាក៏ ដោយប្រសិនបើតុលាការ និងនគរបាលនៅពុករលួយនៅតែខ្វះសមត្ថភាព ច្បាប់ទាំងនោះគ្រាន់តែជាក្រដាស់តែប៉ុណ្ណោះ។ ដូច្នេះ រដ្ឋាភិបាលត្រូវកែទម្រង់ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថាប័នតុលាការ និងកងកម្លាំងនគរបាល។

## III-មតិរួមនៃអង្គពិភាក្សា

បណ្ឌិត ចាប សុថារិទ្ធ បានបង្ហើបថា ការចូលរបស់ប្រទេសកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក ត្រូវបង្កើតច្បាប់សម្រាប់អនុវត្ត ១៤៧ ប្រទេស។ ដូចជាច្បាប់ពាណិជ្ជកម្ម និងច្បាប់របាំងពន្ធគយជាដើម ដែលចាំបាច់ក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច ត្រូវការពេលវេលាពិគ្រោះយោបល់គ្នាឱ្យបានល្អិតល្អន់ ដើម្បីចៀសវាងការខាតបង់ម្ខាងៗ។

លោក ហាម សំណាង ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បានចាប់អារម្មណ៍ទៅលើតុលាការពាណិជ្ជកម្ម តើមានដំណើរដល់ណាហើយ? ព្រោះថា តុលាការពាណិជ្ជកម្មមានសារៈសំខាន់ណាស់សម្រាប់វិនិយោ-គិន។ តាមពិតពាក់ព័ន្ធនឹងតុលាការពាណិជ្ជកម្មនេះ អង្គពិភាក្សាបានយល់ព្រម គ្នាថា តុលាការពាណិជ្ជកម្មត្រូវតែដាច់ស្រឡះពីតុលាការផ្សេងៗទៀត និងប្រកបដោយចៅក្រមមានសមត្ថភាព។ ទៅអនាគតក្រសួងពាណិជ្ជកម្មត្រូវតែជ្រើសរើសអ្នកជំនាញផ្នែកច្បាប់

មកធ្វើការជាមួយ។ លោក សុក សំអឿន បានយល់ថា កន្លងមកការបង្កើតច្បាប់រដ្ឋាភិបាលមិនសូវផ្តល់ដំណឹងឱ្យស្ថាប័ន អង្គការក្រៅរដ្ឋាភិបាលចូលរួមទេ ព្រោះខ្លាចអង្គការក្រៅរដ្ឋាភិបាលយកមកធ្វើពាណិជ្ជកម្ម។ បញ្ហានេះ ធ្វើឱ្យច្បាប់បង្កើតចេញមកមិនសូវរលូនមានការពិបាកក្នុងការអនុវត្តន៍ ។

កិច្ចពិភាក្សាក៏បានលើកផលដែរ ពីនីតិវិធីនៃការរើសចៅក្រម និងមេធាវី។ មេធាវីត្រូវតែបញ្ចប់បរិញ្ញាប័ត្រ មិនថាលើផ្នែកណានោះទេ និងត្រូវបានឆ្លងកាត់សាលាបច្ចេកទេសច្បាប់ ៣ ឆ្នាំ ថែមទៀត ទើបអ្នកក្លាយជាមេធាវីពេញលេញ។ ចំណែកឯសមាសភាពចៅក្រមវិញត្រូវធ្លាប់ជាមេធាវី ដែលធ្លាប់ទទួលរឿងក្តីអស់រយៈពេល៥ឆ្នាំយ៉ាងតិច ទើបក្លាយជាចៅក្រមបាន។ លើសពីនេះទៀត អង្គពិភាក្សាបានសម្តែងកង្វល់ទៅលើការដោះស្រាយវិវាទពាណិជ្ជកម្ម តើស្ថាប័នណាជាអ្នកចេញមុខដោះស្រាយវិវាទរវាងប្រទេស និងប្រទេស ឬរវាងប្រទេស និងអង្គការពាណិជ្ជកម្មពិភពលោក?

បញ្ហាវិវាទពាណិជ្ជកម្ម គណៈវាគ្មិនបានពន្យល់ថា បើមានប្រទេសពីរមានវិវាទរឿងពាណិជ្ជកម្ម ដំបូងត្រូវរកដំណោះស្រាយដោយសន្តិវិធី របៀបចរចាជាទ្វេភាគី បើមិនទទួលជោគជ័យត្រូវប្តឹងទៅ WTO ដោយមានមេធាវីជំនាញមកពីអង្គការពាណិជ្ជកម្មពិភពលោកជាអ្នកជួយ។ ឆ្លើយតបនឹងសំណួរដែលថា តើប្រទេសកម្ពុជាមានការប្រកួតប្រជែង លើវិស័យពាណិជ្ជកម្មបានដល់កម្រិតណា? វាគ្មិនបានបកស្រាយថា ដើម្បីចូលរួមប្រកួតប្រជែង ប្រទេសយើងត្រូវមានផលិតផល ដូចជា ស្រូវ គ្រាប់ស្វាយចន្ទី និងម្រេចនៅកំពតជាដើម បូករួមនឹងកម្លាំងពលកម្មថោកនោះ យើងសង្ឃឹមថានឹងមានឱកាសច្រើន។ បញ្ហាស្រូវ ចំពោះប្រទេសនានាត្រូវគិតពីគុណភាព តែសម្រាប់ខ្មែរយើងត្រូវគិតពីបរិមាណ តើត្រូវធ្វើយ៉ាងណាដើម្បីផលិតស្រូវឱ្យបានច្រើន? រឿងសំខាន់មួយទៀត ដែលប្រទេសកម្ពុជាត្រូវគិតនោះ គឺភូមិមួយផលិតផលមួយ (one

village one product) ដើម្បីជំរុញការនាំចេញប្រកបដោយគុណភាព ។ ក្រៅពីនេះ អង្គពិភាក្សាក៏បានយកចិត្តទុកដាក់ទៅលើច្បាប់សំខាន់ៗ ដូចជា ច្បាប់កម្មសិទ្ធិបញ្ញា, ច្បាប់ធនាគារ, ច្បាប់ភូមិបាល, ច្បាប់គ្រប់គ្រងក្រុមហ៊ុន, ច្បាប់ក្ស័យធន និងត្រូវមានច្បាប់អាជ្ញាកណ្តាលមួយ (arbitration) ថែមទៀត ។

## IV-សេចក្តីសន្និដ្ឋាន :

ទោះបីជាមានការប្រឈមមុខជាច្រើន ក្នុងការធ្វើច្បាប់យ៉ាងណាក៏ដោយ ក៏អង្គពិភាក្សាបានរកឃើញនូវផលប្រយោជន៍ជាច្រើន ដូចជា : កម្ពុជានឹងមានច្រកចូលទីផ្សារចំនួន ១៤៧ ប្រទេស។ សម្រាប់ប្រទេសកម្ពុជា ប្រសិនបើយើងមានផលិតផលមានគុណភាពស្របតាមស្តង់ដារនៃ WTO នោះ គ្មានលេសមិនសមរម្យណាមួយ ដែលរាំង-ខ្ទប់ផលិតផលរបស់យើងមិនឱ្យចូលទៅប្រទេសទាំង ១៤៧ នោះទេ។ ដោយហេតុថាយើងមានយន្តការដោះស្រាយជម្លោះ WTO ជាយន្តការស្មើភាពគ្នា ដែលប្រទេសតូចធ្លាប់បានឈ្នះប្រទេសធំ ។

សំខាន់ជាងនោះទៅទៀត នៅពេលដែលយើងមានច្បាប់នានា ដែលចាំបាច់សម្រាប់ទ្រទ្រង់បរិស្ថានវិនិយោគ និងធុរកិច្ចដែលស្រប និងច្បាប់ល័ក្ខខ័ណ្ឌតម្រូវនានារបស់កិច្ចព្រមព្រៀង WTO នៅកម្ពុជារួចហើយ នោះជំនឿទុកចិត្តរបស់វិនិយោគ និងធុរជនបរទេស ក្នុងស្រុកនឹងមានការកើនឡើង ដោយហេតុថាគេមានលទ្ធភាពច្រើនក្នុងការព្យាករណ៍ និងធ្វើផែនការទុរកិច្ចរបស់គេ ដោយគេអាចប៉ាន់ស្មានបានពីចំណាយសម្រាប់ការបង់ពន្ធ ប្រសិនបើកម្ពុជាអនុវត្តនូវវិធីសាស្ត្រវាយតម្លៃពន្ធគយ ទៅតាមកិច្ចព្រមព្រៀង WTO ។ បញ្ហានេះនឹងកាត់បន្ថយនូវការចំណាយក្រៅផ្លូវការ បង្កើនភាព

ប្រកួតប្រជែងប្រកបដោយការទាក់ទាញ និងការលើកទឹកចិត្តឱ្យមានវិនិយោគធុរកិច្ចថ្មីនៅកម្ពុជា។

ពិសេសបំផុតនោះគឺការកែសម្រួលច្បាប់ បទបញ្ញត្តិនានា ថ្វីត្បិតតែមានភាពស្មុគស្មាញ និងជួបប្រទះការលំបាកជាច្រើនក៏ពិតមែន ប៉ុន្តែ វានឹងផ្តល់អត្ថប្រយោជន៍ដល់ប្រទេស និងប្រជារាស្ត្ររបស់យើងជាក់ជាមិនខាន។ ជាក់ស្តែងការកសាងច្បាប់ថ្មីស្តីអំពីអនាម័យ និងភូតគាមអនាម័យនឹងជួយឱ្យមានគុណភាព ផលិតផលស្បៀងអាហាររបស់កម្ពុជា ទាំងសម្រាប់ការនាំចេញ និងទាំងសម្រាប់ការប្រើប្រាស់ក្នុងស្រុក។ ច្បាប់ទាំងនោះ នឹងជួយកាត់បន្ថយនូវការភ័យខ្លាច អំពីការជ្រៀតចូលក្នុងស្រុកនូវជំងឺនានា ដែលកើតចេញពីម្ហូបអាហារ ដូចជា កើតចេញពីពពួកប៉េស្តិ៍ ដោយសារការប្រើសារធាតុគីមី ក្នុងម្ហូបអាហារដែលគ្មានគុណភាព និងអាហារមានជាតិពុលជាដើម។ ក្នុងករណីនេះ ក្រោមកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក ការត្រួតពិនិត្យព្រំដែន ដើម្បីចត្តាឡីស័ក គឺផ្អែកលើមូលដ្ឋានហានិភ័យ។ ដូច្នេះ នឹងមិនមានន័យថាច្បាប់ថ្មីនឹងបង្កជាការរឹតត្បិតដល់ពាណិជ្ជកម្មឡើយ។

ម្យ៉ាងទៀត ការអនុម័តយកមកប្រើប្រាស់នូវបទដ្ឋានអន្តរជាតិ ក៏នឹងជួយឱ្យមានការទទួលស្គាល់នូវគុណភាព ផលិតផលកម្ពុជាជាអន្តរជាតិ ដែលជាផ្នែកមួយនៃការធានាជោគជ័យលើទីផ្សារផងដែរសម្រាប់កម្ពុជា។

# របាយការណ៍សង្ខេបនៃវេទិកា ទី ៣

## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់កសិកម្មកម្ពុជា

## I-សេចក្តីផ្តើម :

ក្នុងនាមជាសមាជិកម្នាក់របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ប្រទេសកម្ពុជា ត្រូវឆក់យកឱកាសនាំចេញផលិតផលកសិកម្ម ឧស្សាហកម្ម និងជលផល ដើម្បីជាយានមួយសម្រាប់ចម្លង ការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធិភាព។ កត្តានេះ តម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជា មានមនសិការប្រកបដោយឆន្ទៈនយោបាយ មោះមុត និងមានការប្តេជ្ញាចិត្តច្បាស់លាស់ ដើម្បីជំរុញការអនុវត្តន៍ច្បាប់ បទដ្ឋាននានារួមផ្សំ និងកាតព្វកិច្ចមួយចំនួនដែលទាក់ទង ទៅដល់អង្គការពាណិជ្ជកម្មពិភពលោក។

## II- ទស្សនៈរួមនៃវាគ្មិនកិត្តិយស

១- លោក **ឡូត សារ៉ាវុធ** អនុប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធ WTO លោកបានបញ្ជាក់ថា ផលប៉ះពាល់មិនគ្រាន់តែមកលើវិស័យកសិកម្មប៉ុណ្ណោះទេ គឺវាប៉ះពាល់លើគ្រប់វិស័យ ដូចជា កម្មករ អង្គការសង្គមស៊ីវិល ផ្នែកឯកជន ក៏ដូចជា ស្ថាប័នរដ្ឋដទៃទៀតដែរ។ តែផ្នែកទាំងអស់នោះត្រូវតែចូលរួមប្រកួតប្រជែងយកឈ្នះ។ ការចូល WTO របស់ខ្មែរអាចប៉ះពាល់ដល់

អ្នករកស៊ីតូចតាច ដូចជាកសិករកម្មករជាដើម។ លោកបានលើកឡើងថា តើធ្វើយ៉ាងណា ដើម្បីឱ្យកសិករតូចតាចរកស៊ីបាន? រដ្ឋមានផែនការអ្វីខ្លះ ដើម្បីគាំទ្រដល់អ្នកទាំងនោះ? ហេតុអ្វីបានជាកម្ពុជាសម្រេចចិត្តចូល WTO? លោកបានបញ្ជាក់ថា ប្រទេសចិន ជាទីផ្សារមួយយ៉ាងធំ នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ប្រទេសវៀតណាមបានចុះកិច្ចព្រមព្រៀងទ្វេភាគីពាណិជ្ជកម្មជាមួយអាមេរិក។ ដូច្នេះ ការធ្វើពាណិជ្ជកម្មគ្មានមនោ-សញ្ចេតនាទេ គឺត្រូវពឹងផ្អែកទៅលើការពិនិត្យជញ្ជីងពាណិជ្ជកម្មទាំងសងខាង។ ចំណែកឯវិស័យកសិកម្ម ការនាំអង្ករចូលវាទាក់ទងទៅនឹងកំណើនប្រជាជន (ខ្មែរ១៤លាននាក់) កំណើនកម្លាំងពលកម្មនឹងត្រូវគិត ចាប់តាំងពីពេលផលិតរហូតដល់នាំចេញ ដូចជា បញ្ហាដឹកជញ្ជូន ការបង់ពន្ធ និងការយកពន្ធត្រូវតែគិតឱ្យបានច្បាស់លាស់ ធ្វើយ៉ាងណាសម្រួលដល់អ្នករកស៊ីលើផលិតផលកសិកម្មអាចរកផលកម្រៃបាន។

លោក សារ៉ាវុធ បានលើកឡើងផងដែរ អំពីការយកពន្ធខុសច្បាប់ទៅលើអ្នកជំនួញផ្នែកស្រូវអង្ករអ្នកទាំងនោះ ដោយលើកឡើងថា គេយកលុយពីឈ្មួញ មិនមែនយកលុយពីកសិករទេ តែទោះជាយ៉ាងណាក៏ដោយលោកបានបញ្ជាក់ថា បញ្ហានេះរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់។ លើសពីនេះទៅទៀតលោកបានបញ្ជាក់ថា រាជរដ្ឋាភិបាលបានសម្រេចចិត្តចូល WTO គឺមានការប្រសើរជាង GATT ទាំង ការដោះស្រាយទំនាស់ដោយសន្តិវិធីទាំងការរើសអើង។ លោកក៏បានបញ្ជាក់ផងដែរ ពីការចូលជាសមាជិក WTO តាមពិតប្រទេសកម្ពុជា ត្រូវចូលមុនប្រទេសនេប៉ាល់ ប៉ុន្តែដោយសារក្រោយពីការបោះឆ្នោត ២០០៣ ប្រទេសយើងមានបញ្ហានយោបាយ ធ្វើឱ្យយើងយឺតមួយឆ្នាំ ។

ក្រៅពីនេះ លោក សារ៉ាវុធ ក៏បានបញ្ជាក់ផងដែរ ពីអាជ្ញាបត្រនាំចេញ (Export License) និងល័ក្ខខ័ណ្ឌវិនិយោគ។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលខ្មែរបាន

ចេញគោលការណ៍ថា រាល់ការវិនិយោគទាំងឡាយណា ដែលមានតម្លៃក្រោម ២លាន ដុល្លារអាមេរិក គឺមិនបាច់សុំច្បាប់វិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ឡើយ ត្រូវទៅទាក់ទងជាមួយអាជ្ញាធរខេត្ត-ក្រុងតែម្តង នេះជាការសម្រួល និងលើក ទឹកចិត្តដល់អ្នកវិនិយោគទាំងឡាយ ដែលចង់វិនិយោគលើវិស័យកសិកម្មនៅគ្រប់ខេត្ត-ក្រុងនានា។

ការនាំចេញផលិតផលកសិកម្មត្រូវគិតដល់គុណភាព និងមានលក្ខណៈប្រមូលផ្តុំ ព្រមទាំងមានការគាំទ្រយកចិត្តទុកដាក់ពីរដ្ឋាភិបាល។ ជាងនេះទៅទៀត ដើម្បីលើក ទឹកចិត្តដល់អ្នកផលិតប្រទេសខ្លះ ដូចជា ប្រទេសជប៉ុន រដ្ឋាភិបាលបានប្រមូលទិញ ផលិតផលកសិកម្មពីប្រទេសរបស់គេក្នុងតម្លៃខ្ពស់ ហើយលក់ទៅឱ្យប្រជាពលរដ្ឋគេវិញ ក្នុងតម្លៃទាប។ ការធ្វើបែបនេះមានន័យថា រដ្ឋបំពេញខាត ឬរដ្ឋឧបត្ថម្ភធន។ ឧទាហរណ៍ រដ្ឋទិញស្រូវពីប្រជាជនក្នុងតម្លៃ 4US$ ក្នុងមួយកីឡូក្រាមពេលលក់ឱ្យប្រជាជនវិញ នៅត្រឹមតែ 2US$ ក្នុងមួយកីឡូក្រាម។ សំខាន់ជាងនេះទៅទៀត អ្នកចរចារបស់ កម្ពុជាក្នុងអង្គការ WTO បានខិតខំធ្វើយ៉ាងណាដើម្បីឱ្យខ្មែរយើងទាញផលចំណេញ ពីស្ថាប័ននេះ។ បើផលិតផលណាដែលយើងសំបូរ យើងត្រូវយកពន្ធនាំចូលខ្ពស់ដើម្បី ទប់ស្កាត់ការនាំចូលពីក្រៅ ហើយបើផលិតផលណាដែលនៅក្នុងស្រុកមិនសូវសំបូរ យើង ត្រូវយកពន្ធទាប ដើម្បីឱ្យគេនាំចូល ដូចជា ទំពាំងបាយជូ, ប៉ោម ជាដើម។

ពាក់ព័ន្ធនឹងឧស្សាហកម្មកាត់ដេរ លោកបានមានប្រសាសន៍ថា យើងមិនអាច ប៉ះពាល់ខ្លាំងក្លាទេ ទោះបីមាន ការបញ្ចប់កូតាក៏ដោយ ដោយហេតុថា មានរោងចក្រខ្លះ បិទទ្វារ តែមានរោងចក្រថ្មីកើតឡើង បូករួមនឹងកម្មករខ្មែរ មានបទពិសោធន៍ថែមទៀត នោះ ធ្វើឱ្យយើងមានលទ្ធភាពចូលរួមប្រកួតប្រជែងទៅក្នុងទីផ្សារពិភពលោកបាន។

២- លោកស្រី ប្រុក វ៉ាន់នី អ្នកឯកទេស យេនឌ័រ និងសង្គមនៃកម្មវិធីអភិវឌ្ឍន៍ផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក-ស្ថានភាពទូទៅនៃប្រទេសកម្ពុជា

លោកស្រី ប្រុក វ៉ាន់នី បានសម្តែងនូវកង្វល់ ពីការកើនឡើងនៃចំនួនប្រជាជនគឺរហូតដល់ ១៤ លាននាក់ ក្នុងនោះប្រជាពលរដ្ឋ ៧០ % រស់នៅជនបទ ដែលពឹងផ្អែកលើវិស័យកសិកម្មទាំងស្រុង និង ៣៥.៩ % រស់នៅក្រោមបន្ទាត់ភាពក្រីក្រនៅឡើយ។ អ្នកស្រីក៏បានមានប្រសាសន៍ផងដែរ ពីផលិតផលក្នុងស្រុកសម្រាប់មនុស្សម្នាក់ (GDP) ស្មើនឹង ២៨១ ដុល្លារ ក្នុងមួយឆ្នាំ។ ចំណែកឯថវិកាជាតិសម្រាប់វិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទនៅក្នុងឆ្នាំ ២០០២ គឺមានចំនួនតិចតួចប៉ុណ្ណោះ។ ក្រៅពីនេះលោកស្រីបានសង្កត់ធ្ងន់ទៅលើវិស័យកសិកម្មថា មានតួនាទីសំខាន់ណាស់ក្នុងការកាត់បន្ថយភាពក្រីក្រ និងបង្កើនសមត្ថភាពក្នុងការអភិវឌ្ឍ។ ជាក់ស្តែង នៅក្នុងឆ្នាំ ២០០៥ នេះ តម្លៃស្រូវនៅលើទីផ្សារមានតម្លៃខ្ពស់ជាងនៅឆ្នាំ ២០០៤។ ក្រៅពីស្រូវ លោកស្រីបានចាត់ទុកអាទិភាពក្នុងការនាំចេញនោះគឺ កៅស៊ូ ដែលយើងកំពុងដំណើរការទៅជាឯកជនភាវូបនីយកម្ម ចំណែកឯចំណាត់ថ្នាក់ទី ៣ នោះគឺជលផល ប៉ុន្តែ ការព្រួយបារម្ភនោះគឺ ទិន្នផលត្រីធម្មជាតិមានការថយចុះជាលំដាប់ ដោយសារតែការគ្រប់គ្រងការនេសាទមិនបានល្អ។

ខ-អង្គការពាណិជ្ជកម្មពិភពលោក

លោកស្រី បានឱ្យនិយមន័យអង្គការពាណិជ្ជកម្មពិភពលោក (WTO) ថាជាស្ថាប័នដែលផ្អែកលើគោលការណ៍ច្បាប់ លើកិច្ចព្រមព្រៀង និងវិធានច្បាប់ពាណិជ្ជកម្ម ដែលមានសមាជិក ១៤៨ ប្រទេស។ ការបង្កើត WTO ក្នុងគោលបំណងលើកតម្កើងជីវភាពរស់នៅរបស់ប្រជាជន នៅក្នុងគ្រប់បណ្តាប្រទេសជាសមាជិក និងដើម្បីពង្រីកការ

ធ្វើពាណិជ្ជកម្មទំនិញ សេវាកម្ម ឱ្យស្របទៅតាមគោលដៅនៃការទ្រទ្រង់និរន្តរភាព សម្រាប់ការអភិវឌ្ឍន៍ការការពារ និងថែរក្សាបរិស្ថានប្រកបដោយតម្លាភាព និងភាពអាចទស្សទាយបាន ជាកន្លែងចរចាពាណិជ្ជកម្ម និងជាវេទិកាសម្រាប់ដោះស្រាយជម្លោះខាងពាណិជ្ជកម្ម ។

គ-ផលប៉ះពាល់ដល់កសិកម្មកម្ពុជា

*ក-ផលប៉ះពាល់អវិជ្ជមាន :*

ផលិតផលកសិកម្មកម្ពុជាអាចលក់បានតែក្នុងខេត្ត-ក្រុង មិនអាចនាំចេញបានដោយសារខ្វះការប្រមូលផ្តុំ មិនអាចប្រកួតប្រជែងទីផ្សារក្រៅប្រទេសបាន ដោយសារគុណភាពមិនត្រូវតាមស្តង់ដារអន្តរជាតិ និងដោយសារការគ្រប់គ្រង ការសម្របសម្រួលបែបបទពាណិជ្ជកម្មនៅកម្ពុជា មានភាពសាំញ៉ាំដែលបណ្តាលឱ្យថ្លៃដើមឡើងខ្ពស់ជាងផលិតផលនាំចូលពីបរទេស ។

*ខ-ផលប៉ះពាល់វិជ្ជមាន :*

កម្ពុជានឹងមានទីផ្សារធំទូលាយរហូតដល់ទៅ ១៤៧ ប្រទេសអាចទាក់ទាញវិនិយោគទុនមករកស៊ីឱ្យកាន់តែច្រើនថែមទៀត ។ រដ្ឋាភិបាលក្នុង ការបង្កើតច្បាប់រាជរដ្ឋាភិបាលបានបង្កើតច្បាប់ថ្មី និងកែទម្រង់ច្បាប់រហូតដល់ទៅ ៤០ បន្ថែមទៀតដើម្បីបំពេញតម្រូវការ WTO ដែលធ្វើឱ្យកម្ពុជាក្លាយជានីតិរដ្ឋ ។

## III-ផលខ្លួនផលនៃកិច្ចពិភាក្សារួម :

លោកម្នាក់ដែលបានអញ្ជើញមកពីអាកាសចរណ៍ស៊ីវិល បានលើកសំណួរថា តើរាល់របាយការណ៍ដែលបាន ពិភាក្សាកន្លងមក បានផ្ញើទៅរដ្ឋាភិបាលដែរឬទេ? សំណួរនេះលោកនាយកប្រតិបត្តិ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បាន

ឆ្លើយថា រាល់របាយការណ៍នៃកិច្ចពិភាក្សា យើងតែងតែចងក្រងជាសៀវភៅ និងបោះពុម្ព ចែកចាយដោយឥតគិតថ្លៃ ទៅគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់។ មិនតែប៉ុណ្ណោះ នៅរាល់កិច្ចពិភាក្សាយើងតែងតែបានអញ្ជើញ អ្នកជំនាញគ្រប់ស្ថាប័នរដ្ឋដែលពាក់ព័ន្ធ ក៏ដូចជា NGOs ឱ្យមកធ្វើជាវាគ្មិនជារៀងរាល់កិច្ចប្រជុំថែមទៀតផង។ សំណួរមួយទៀតថា តើប្រទេសកម្ពុជាយើងមានផលិតផល និងទំនិញអ្វីខ្លះ សម្រាប់ការនាំចេញ? គណៈវាគ្មិនបានឆ្លើយថា យើងមានផលិតផលជាច្រើន ដូចជា ផលិតផលតម្បាញ និងសម្លៀកបំពាក់ស្រូវ សណ្តែកសៀង កៅស៊ូ គ្រាប់ស្វាយចាន់ទី ម្រេច បូករួមនឹងផលិតផលមួយចំនួនទៀត។

ចំណែកឯលោក ដែលបានអញ្ជើញមកពីអង្គការមួប់បៃតង បានលើកសំណួរថា គ្រប់ល្បែងទាំងអស់ អ្នកដែលចូលរួមលេងតែងមានឈ្នះចាញ់ តើល្បែងពាណិជ្ជកម្មដែលកម្ពុជាយើងលេងដូចល្បែងទូទៅដែរឬទេ? គណៈវាគ្មិនបានបកស្រាយថា បញ្ហានេះហើយ ដែលយើងខិតខំដើម្បីឱ្យបានចូលជាសមាជិក WTO គឺ ដើម្បីធ្វើយ៉ាងណាឱ្យប្រទេសជាសមាជិកទទួលផលចំណេញរៀងខ្លួន តាមរយៈការចរចា ការប្រកួតប្រជែងទំនិញជាដើម ថែមទាំងបានទុកឱកាសឱ្យអ្នកជំនួញខ្មែរអាចរកស៊ីបានទៀតផង ទាំងនេះគឺជាចំណុចសំខាន់ ដែលអ្នកចរចាយើងតែងតែគិត ដើម្បីយកឈ្នះខាងពាណិជ្ជកម្ម។

លោកម្នាក់ទៀត ដែលបានអញ្ជើញមកពីអង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា បានលើកសំណួរថា តើរដ្ឋាភិបាលបានគិតគូរអ្វីខ្លះ សម្រាប់ឱ្យប្រជាពលរដ្ឋស្តារវិស័យកសិកម្ម? គណៈវាគ្មិនបានឆ្លើយថា រាជរដ្ឋាភិបាលបានជំរុញផ្នែកពូជ ដូចជា គ្រាប់ពូជធញ្ញជាតិ និងពូជសត្វនឹងកំពុងបានស្តារប្រព័ន្ធធារាសាស្ត្រ ដើម្បីបំពេញតម្រូវការផ្នែកកសិកម្ម។ ចំណែក ឯឧត្តម ជាសមាជិកព្រឹទ្ធសភាបានមានប្រសាសន៍បន្ថែមថា សព្វថ្ងៃស្ថាប័ននីតិបញ្ញត្តិ បានកំពុងតែជំរុញវិស័យច្បាប់ដោយធ្វើការបង្កើតច្បាប់ និងកែទម្រង់

ច្បាប់ឱ្យបានគ្រប់គ្រាន់ ទៅតាមតម្រូវការអង្គការពាណិជ្ជកម្មពិភពលោក ដោយហេតុថា ច្បាប់ជាបញ្ហាសំខាន់ក្នុងការប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម។

ក្រៅពីនេះ អង្គពិភាក្សាក៏បានលើកសំណូមពរផងដែរ ដល់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ឱ្យធ្វើការបោះពុម្ពរាល់របាយការណ៍ ជាពិសេសរបាយការណ៍បូកសរុបពីផលលទ្ធផលនៃកិច្ចប្រជុំពិភាក្សាទាំង ១០ លើក ស្តីពី "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក" ជាកូនសៀវភៅតូចៗ ដើម្បីសម្រួលដល់ការផ្សព្វផ្សាយ។ លើសពីនេះទៅទៀត អង្គពិភាក្សាទាំងមូលមានការបារម្ភជាខ្លាំងពីការហូរចូលទំនិញខូច គុណភាពពីបណ្តាប្រទេសជិតខាង ជាពិសេសគឺម្ហូបអាហារ និងការប្រើប្រាស់ថ្នាំពុល ដែលគ្មានលក្ខណៈបច្ចេកទេសច្បាស់លាស់ ដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពប្រជាជន ដូច្នេះ យើងទាំងអស់គ្នាត្រូវរកមធ្យោបាយធ្វើយ៉ាងណា ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមា និងជំរុញឱ្យប្រជាពលរដ្ឋប្រើប្រាស់ថ្នាំពុលមានស្តង់ដារ និងជីធម្មជាតិឱ្យបានជាអនេកប្បការ។

## IV- សំណូមពរ និងអនុសាសន៍ :

ដើម្បីទាញយកផលចំណេញពីអង្គការពាណិជ្ជកម្មពិភពលោក រាជរដ្ឋាភិបាលត្រូវបង្កើនខ្ទង់ថវិកាជាតិបន្ថែមទៀត សម្រាប់វិស័យកសិកម្ម និងគួរកំណត់ស្តង់ដារពូជគ្រប់ប្រភេទ ដល់ប្រជាកសិករ ព្រមទាំងជួយពង្រឹងប្រសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ ការផ្ទេរបច្ចេកទេសកសិកម្ម ការស្តារប្រព័ន្ធធារាសាស្ត្រ និងជួយសម្រួលដល់នយោបាយពាណិជ្ជកម្ម ឱ្យបានប្រសើរថែមទៀត ដើម្បីទាក់ទាញវិនិយោគឱ្យមកបណ្តាក់ទុន នៅប្រទេសកម្ពុជាឱ្យបានច្រើន ជាពិសេសគឺប្រទេសជប៉ុន និងសហគមន៍អ៊ឺរ៉ុប។

សរុបសេចក្តីមក ដើម្បីសម្រេចបាននូវការប្រជែងឈ្នះក្នុងអង្គការពាណិជ្ជកម្មពិភពលោកប្រកបដោយប្រសិទ្ធិភាពនោះ លុះត្រាតែទាំងរាជរដ្ឋាភិបាល ទាំងកសិករ កម្មករ ជាពិសេសផ្នែកឯកជនត្រូវ ចូលរួមសម្របសម្រួល និងសហការផលិតផលកសិកម្ម ឧស្សាហកម្ម និងជលផលប្រកបដោយលក្ខណៈប្រមូលផ្តុំ ដើម្បីជំរុញការនាំចេញប្រកបដោយគុណភាព និរន្តរភាព និងប្រសិទ្ធិភាពខ្ពស់។

# របាយការណ៍សង្ខេបនៃវេទិកា ទី ៤

## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ចំពោះពលកម្មកម្ពុជា

## I-សេចក្តីផ្តើម

ជាបឋម ឯកឧត្តម **អ៊ឹង ហួត** អនុប្រធានក្រុមប្រឹក្សាភិបាល វ.ខ.ស.ស បានជម្រាបអង្គពិភាក្សាតុមូលថា ការជជែកគ្នាក្នុងថ្ងៃនេះមិនមែនក្នុងក្របខ័ណ្ឌរដ្ឋាភិបាលទេ គឺក្នុងក្របខ័ណ្ឌក្រៅរដ្ឋាភិបាល ប៉ុន្តែ យើងអាចផ្តល់ជាយោបល់ ជាគំនិតដល់រាជរដ្ឋាភិបាល តាមរយៈការបញ្ជូនរបាយការណ៍ទៅគ្រប់ស្ថាប័នពាក់ព័ន្ធដោយប្រយោល និងតាមរយៈការអញ្ជើញគណៈវាគ្មិនកិត្តិយស ដែលជាសមាជិករាជរដ្ឋាភិបាលដោយផ្ទាល់។ ជាក់ស្តែង ឯកឧត្តមបានបញ្ជាក់ថា ដូចជាថ្ងៃនេះជាដើម CICP បានអញ្ជើញ ឯកឧត្តម អ៊ុំ មាន អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាអ្នកប្រតិបត្តិច្បាប់ការងារ និងមានបទពិសោធន៍ជាច្រើនចាប់តាំងពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមិនទាន់កើតម្ល៉េះ។ ឯកឧត្តម អ៊ឹង ហួត បានបន្ថែមទៀតថា ឯកឧត្តមមានសេចក្តីរីករាយណាស់ ដែលកម្ពុជាបានចូលជាសមាជិក WTO ដែលជាសមាជិកពិសេសក្នុងនោះប្រទេសកម្ពុជា និងប្រទេសនេប៉ាល់ជាប្រទេសក្រីក្រ និងអន់ថយជាងគេក្នុងចំណោមប្រទេស ១៤៨ ដើម្បីធ្វើការដកពិសោធន៍ ថាតើប្រទេសទាំងនោះ ទៅរួចឬអត់ ទាំងវិស័យច្បាប់វិនិយោគ ច្បាប់ការងារ ទាំងការនាំចេញ ទាំងគុណភាពទំនិញ

និងសមត្ថភាពផលិត។ ហើយថាតើយើងត្រូវការជំនួយផ្នែកអ្វីខ្លះ ដើម្បីមានលទ្ធភាពប្រកួតប្រជែង លើទីផ្សារសេរីរបស់អង្គការពាណិជ្ជកម្មពិភពលោក?

## II-ទស្សនៈរួមរបស់គណៈវាគ្មិនកិត្តិយស

**វាគ្មិនទី ១** ឯកឧត្តម អ៊ុំ មាន **អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានមានទស្សនៈថា រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ២ នៃរដ្ឋសភាបានអនុវត្តនូវយុទ្ធសាស្ត្រត្រីកោណប្រកបដោយជោគជ័យ និងបានធ្វើឱ្យវិស័យសេដ្ឋកិច្ចសង្គមរីកចម្រើនជាក់ស្តែង ដូចជាវិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងបានរីកលូតលាស់យ៉ាងឆាប់រហ័ស។ ដំបូងមានតែ ៤០ រោងចក្រដែលប្រើកម្លាំងពលកម្មប្រមាណ ៣០,០០០ នាក់ ក្រោយមកកើនទៅដល់ ៣០០ រោងចក្រ និងប្រើកម្លាំងពលកម្មរហូតទៅដល់ពីរសែននាក់ ហើយទំនិញនាំចេញរបស់វិស័យកាត់ដេរបានកើនពី ៨០ ម៉ឺន ដល់ ១,៩០០ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៤ កត្តានេះបានរួមចំណែកបង្កើនចំណូលដល់ថវិកាជាតិថែមទៀត។

ឯកឧត្តមបានបញ្ជាក់ប្រាប់អង្គពិភាក្សាថា ទៅអនាគតប្រទេសដែលអាចចូលរួមប្រកួតប្រជែង ផ្នែកវិស័យកាត់ដេរបានមានតែប្រទេសចិន ឥណ្ឌូណេស៊ី ថៃឡង់ដ៍ វៀតណាម បង់ក្លាដេស ជាពិសេសប្រទេសមួយចំនួនទៀតក្នុងទ្វីបអាមេរិកឡាទីន និងទ្វីបអាហ្រិក។ ចំណែកឯប្រទេសកម្ពុជា ក៏អាចចូលរួមការប្រកួតប្រជែងផងដែរ ប្រសិនបើយើងខិតខំប្រឹងប្រែងអនុវត្តឱ្យបានល្អនូវប្រការបួន នោះគឺ :

- ការអនុវត្តន៏ល័ក្ខខ័ណ្ឌការងារពីគ្រប់ភាគីពាក់ព័ន្ធឱ្យត្រឹមត្រូវ
- ការដោះស្រាយបញ្ហាថ្លៃទំនិញ
- ការបង្កើនគុណភាពផលិតផល

- ការកំណត់ពេលវេលាឱ្យបានច្បាស់លាស់ ដើម្បីបញ្ជូនផលិតផលទៅដល់ ទីផ្សារ។

ក្រៅពីនេះ ឯកឧត្តមបានបញ្ជាក់បន្ថែមទៀតថា កន្លងមកប្រទេសកម្ពុជាបានទទួលចំណាត់ថ្នាក់លំដាប់លេខ ១ ស្តីពី ការអនុវត្តន៍ល័ក្ខខ័ណ្ឌការងារក្នុងតំបន់។ ទោះជាបច្ចុប្បន្នមានរោងចក្រ ១៦ ត្រូវបិទទ្វារដែលមានកម្មករចំនួន ១៤,០៧៩ នាក់ ខ្វះការងារ ប៉ុន្តែ មានរោងចក្រថ្មីចំនួន ៣៦ បានដំណើរការដែលបានស្រូបយកកម្លាំងពលកម្មចំនួន ៦,៩៣១ នាក់។

ឯកឧត្តមបានមានប្រសាសន៍បញ្ជាក់បន្ថែមថា ដើម្បីអនុវត្តឱ្យបានជោគជ័យនូវយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួង និងស្ថាប័នពាក់ព័ន្ធព្រមទាំងភាគីនិយោជក និងកម្មករ ត្រូវសហការគ្នាខិតខំថែរក្សានិរន្តរភាព និងការអភិវឌ្ឍន៍ឧស្សាហកម្មកាត់ដេរ ដើម្បីធ្វើការប្រកួតប្រជែង និងបង្កើតការងារដល់ប្រជារាស្រ្តកម្ពុជា។ ដើម្បីសម្រេចបាននូវយុទ្ធសាស្រ្តខាងលើក្រុមហ៊ុនកាត់ដេរ ត្រូវខំលើកកម្ពស់បច្ចេកទេស និងគុណភាពទំនិញ ព្រមទាំងអនុវត្តគោលនយោបាយលើកទឹកចិត្តដល់អ្នកវិនិយោគបូករួមនឹងកម្មវិធីអប់រំផ្សព្វផ្សាយ ពីសារៈសំខាន់នៃការវិនិយោគដល់អ្នកដែលពាក់ព័ន្ធ។ លើសពីនេះត្រូវរក្សាទីផ្សារសំខាន់ៗ ដូចជា អាមេរិក និងសហគមន៍អឺរ៉ុបជាដើម។ មិនតែប៉ុណ្ណោះ ឯកឧត្តមបានបញ្ជាក់បន្ថែមទៀតថា ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការថែរក្សាទីផ្សារ ដែលធ្លាប់ផ្តល់ភាពអនុគ្រោះធំៗមាន ជប៉ុន កាណាដា សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក។ លើសពីនេះទៅទៀត ត្រូវបន្តពង្រឹងភាពជាដៃគូជាមួយផ្នែកឯកជន តាមរយៈក្រុមការងារចម្រុះដែលមានស្រាប់ ជាយន្តការពិគ្រោះយោបល់ និងកិច្ចប្រជុំរវាងរដ្ឋាភិបាល និងវិស័យឯកជន ដែលជាឱកាសសម្រាប់អ្នកវិនិយោគ និងធុរៈកម្មពិនិត្យ និងដោះស្រាយបញ្ហាបានដោយផ្ទាល់ និងឆាប់រហ័ស។ កត្តាសំខាន់មួយទៀត គឺការផ្តល់ប្រាក់លើសម៉ោង និងប្រាក់ខែដល់កម្មករឱ្យបានសមរម្យ

និងត្រូវបង្កើតតំបន់ឧស្សាហកម្មកែច្នៃ សម្រាប់នាំចេញគម្រោងអភិវឌ្ឍផ្នែកឧស្សាហកម្ម ផ្នែកទេសចរណ៍ និងឧស្សាហកម្មធុនតូចនិងមធ្យមបន្ថែមទៀត ដើម្បីស្រូបយកពលកម្ម ឱ្យបានច្រើនជាងមុន។ បន្ថែមលើនេះទៅទៀត ឯកឧត្តម អ៊ុំ មាន បានបញ្ចប់ដោយ ភ្ជាប់ជាមួយពាក្យ *"មានវិនិយោគមានការងារធ្វើមានល័ក្ខខ័ណ្ឌការងារល្អ មានភាព យោគយល់គ្នា មានភាពសុខដុមរមនា មានជោគជ័យក្នុងការប្រកួតប្រជែង មានជីវភាព ធូរធារ មានសេដ្ឋកិច្ចរីកចម្រើន និងមានប្រទេសជាតិមួយដ៏ថ្កើនរុងរឿង"*។

**វាគ្មិនទី ២** លោក **សេខ ផល្លី** នាយកប្រតិបត្តិ **អង្គការការងារកម្ពុជា** យល់ ឃើញថា ដោយសារសេដ្ឋកិច្ចសង្គមមានការផ្លាស់ប្តូរពី សេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ច បែបទីផ្សារសេរី អង្គការរបស់លោកមានកម្មវិធីពីរ គឺបង្រៀនមនុស្សឱ្យយល់ពីសិទ្ធិ សហជីព និងបង្រៀនអំពីច្បាប់ការងារដែលមានការគាំទ្រពី UNDP ហើយថាតើ សហជីពសង្គមនិយមមានន័យដូចម្តេច? សហជីពសេរីមានន័យដូចម្តេច? មិនតែប៉ុណ្ណោះ លោក បានចូលរួមផ្តល់មតិ ក្នុងការតាក់តែងច្បាប់ការងារនៅឆ្នាំ ១៩៩៧ ផងដែរ។ ក្រៅពីនេះ អង្គការរបស់លោក មានសកម្មភាពផ្តោតទៅលើការអប់រំពីច្បាប់ការងារ ការអប់រំពីរបៀបតស៊ូមតិតាមផ្លូវច្បាប់ ដោយធ្វើយ៉ាងណាឱ្យក្រសួងសង្គមកិច្ចទទួល ស្គាល់ និងបានធ្វើការរៀបចំក្រុមសហជីពឯករាជ្យធំៗពីរ សហជីពតូចៗចំនួន ២០ និង បានបង្ហាត់បង្រៀនកម្មករ ស្តីពីច្បាប់ការងារ សិទ្ធិកម្មករបានជាង ២០,០០០ នាក់ ថែមទៀត ចាប់តាំងពី ILO មិនទាន់កើតមកម្ល៉េះ។ លើសពីនេះទៅទៀត លោក បានរកគ្រប់មធ្យោបាយ ដើម្បីឱ្យរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសង្គមកិច្ចទទួលស្គាល់ ពីសិទ្ធិកម្មករ និងគោរពច្បាប់ការងារ ដោយទៅធ្វើការចរចាដោយផ្ទាល់ជាមួយក្រសួង តែមិនបានលទ្ធផល ក៏ធ្វើការជាមួយស្ថានទូតអាមេរិក ដែលចុះកិច្ចព្រមព្រៀងពីស្តង់ដារ

ពលកម្មនៅតែមិនបានផល ទើបលោកទៅជួបសហជីពធំរបស់អាមេរិក នៅទីបំផុតទើបបានទទួលលទ្ធផល។ ពាក់ព័ន្ធរឿង WTO លោកបានមានប្រសាសន៍ថា វាជាការលឿនបន្តិចដោយសារតែយើងជាប្រទេសក្រីក្រ ខ្វះធនធានមនុស្ស យើងត្រូវការពេលវេលាដើម្បីរៀបចំខ្លួនឡើងវិញ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏យើងមានសុទិដ្ឋិនិយមច្រើនទៅលើការបង្កើត និងកែទម្រង់ច្បាប់ចំនួន ៤០ ទៅតាមស្តង់ដារ ក៏ដូចជាការចូលរួមកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលក្នុងខណៈនោះ លោកបានបន្ថែមថា វាក៏ជាឱកាសដើម្បីពង្រឹងតម្លាភាពផ្នែកពាណិជ្ជកម្មផងដែរ។ ពាក់ព័ន្ធនឹងតម្លាភាពពាណិជ្ជកម្មនេះទៀតសោត លោកក៏បានធ្វើការប្រៀបធៀបទៅ និងប្រទេសចិន ក្នុងនោះចិនមានបច្ចេកវិជ្ជាខ្ពស់ និងសំបូរធនធានមនុស្សសំបូរវត្ថុធាតុដើម និងមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ មិនតែប៉ុណ្ណោះមហាយក្សចិន ក៏បានទម្លាក់ពន្ធនាំចូលយ៉ាងទាប ដើម្បីជាថ្នូនឹងការនាំចេញទៅសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប។ ចំណែកឯប្រទេសខ្មែរ មានលក្ខណៈអំណោយផលមួយដែរគឺ កម្លាំងពលកម្មថោក ក៏ប៉ុន្តែ វត្ថុធាតុដើមត្រូវនាំចូលបច្ចេកវិជ្ជាមិនទាន់ទំនើបបូករួមទាំង ការខ្វះហេដ្ឋារចនាសម្ព័ន្ធ ទឹក ភ្លើង ផ្លូវ និងប្រេង ថ្លៃថែមទៀតនោះធ្វើឱ្យយើងមានការលំបាក ក្នុងការនាំចេញផលិតផលឱ្យមានលក្ខណៈគ្រប់គ្រាន់ និងប្រកួតប្រជែង។ លោកបានបន្ថែមថា តាមការវិភាគរបស់អ្នកសេដ្ឋកិច្ចបានបង្ហាញថាដើម្បីចៀសវាងផលប៉ះពាល់ ពីការផ្តាច់កូតា និងដើម្បីចូលរួមប្រកួតប្រជែងផ្នែកពាណិជ្ជកម្មប្រទេសនីមួយៗ ត្រូវ :

មានស្ថិរភាពផ្នែកម៉ាក្រូ និងត្រូវកាត់បន្ថយអំពើពុករលួយ ពង្រឹងការគ្រប់គ្រងរបស់ថៅកែ និងត្រូវលើកទឹកចិត្តដល់កម្មករឱ្យមានប្រាក់ខែសមរម្យ មិនត្រូវចំណាយលើ

វត្ថុធាតុដើមច្រើនពេកទេ (កាត់បន្ថយការនាំចូល) ធ្វើយ៉ាងណាឱ្យអ្នកទិញពេញចិត្ត (គ្មានការបង្ខំឱ្យធ្វើការគ្មានពលកម្មកុមារ) ជាចុងបញ្ចប់លោកបានផ្តល់នូវអនុសាសន៍ពីរៈ

១- ក្រសួងការបរទេសត្រូវសហការជួយទាក់ទាញវិនិយោគ ដោយហេតុថា ក្រសួងនេះមានទំនាក់ទំនងច្រើន ដើម្បីបន្ថែមលើក្រសួងពាណិជ្ជកម្ម។

២- ការបណ្តុះបណ្តាលធនធានមនុស្ស ត្រូវធ្វើការកែទម្រង់ពីការអប់រំ ដើម្បីរកការងារធ្វើទៅជាការអប់រំដើម្បីបង្កើតការងារ ក្រោយពីបញ្ចប់មហាវិទ្យាល័យអាចបង្កើតគម្រោងបាននិងបង្កើតការងារជូនប្រជារាស្ត្រ។

## III-**មតិពិភាក្សារួម :**

ទាក់ទងទៅនឹងសំណួររបស់លោក **លី សុភា** ចំពោះគម្រោងតាមដាន (monitoring project) ឯកឧត្តម **អ៊ុំ មាន** បានមានប្រសាសន៍ថា នេះជាចំណុចដែលសហរដ្ឋអាមេរិករៀបចំឡើង ដើម្បីគាំទ្រទំនិញដែលនាំចេញទៅសហរដ្ឋអាមេរិក។ ដើម្បីឱ្យទំនិញរបស់កម្ពុជា មានគុណភាពអាចប្រកួតប្រជែង នៅលើទីផ្សារអន្តរជាតិ សហរដ្ឋអាមេរិកបានសហការជាមួយអង្គការ ILO ដោយធ្វើការយកចិត្តទុកដាក់ទៅលើផលិតផលកាត់ដេរតែមួយមុខប៉ុណ្ណោះ។ ដូច្នេះ ការបង្កើត Monitoring project ដើម្បីគាំទ្រដល់កិត្តិសព្ទទំនិញ កម្ពុជា។ តាមពិតទៅ Monitoring project ត្រូវចប់នៅឆ្នាំ ២០០៤ តែដោយសារកម្ពុជាមានកិត្តិសព្ទល្អ សហរដ្ឋអាមេរិក និង ILO បានស្នើមករដ្ឋាភិបាលកម្ពុជា ឱ្យបន្តនូវគម្រោងនេះរយៈពេលពីរឆ្នាំទៀត គឺរហូតដល់ឆ្នាំ ២០០៥។

**ទាក់ទងនឹងសុវត្ថិភាពការងារក្នុងកន្លែងធ្វើការ** លោកបានបញ្ជាក់បន្ថែមថា នៅពេលដែលមានការផ្តល់ quota ពីសហរដ្ឋអាមេរិក ក្រុមហ៊ុនវិនិយោគជាច្រើនបាន មកធ្វើវិនិយោគនៅកម្ពុជា ហើយមានក្រុមហ៊ុនខ្លះរកបានកន្លែងល្អ និងខ្លះទៀតមិនសូវល្អ ដោយបានត្រឹមតែជួលផ្ទះតូចមួយតែប៉ុណ្ណោះ ដើម្បីដំណើរការផលិតកម្មក្នុងសភាពបន្ទាន់ ដូចនេះ បរិស្ថានការងារពិតជាមានលក្ខណៈមិនសូវល្អ។ ឯកឧត្តម អ៊ុំ មាន ក៏បានទទួល ស្គាល់ផងដែរថា ធនធានមនុស្សនៅក្នុងក្រសួងនៅមានកម្រិតនៅឡើយ ហើយក្រុម អធិការកិច្ចពុំមានអ្នកណាមួយមានសញ្ញាប័ត្របរិញ្ញា ដូចក្រុមអធិការកិច្ចនៅប្រទេស បារាំងទេ ដូច្នេះ យើងធ្វើបណ្តើររៀនបណ្តើរ។ ឯកឧត្តមក៏បានបន្ថែមទៀតថា ក្រសួង ការងារបានផ្តល់ដំណឹងទៅក្រសួងពាណិជ្ជកម្ម ក្នុងករណីណាដែលថៅកែរោងចក្រមិន ព្រមអនុវត្តតាមល័ក្ខខ័ណ្ឌការងាររបស់កម្មករ ដើម្បីឱ្យក្រសួងពាណិជ្ជកម្មចុះពិនិត្យហើយ បើសិននៅតែមិនព្រមកែប្រែល័ក្ខខ័ណ្ឌទេនោះ ក្រសួងនឹងផ្អាកផលិតកម្មរបស់រោងចក្រ មួយរយៈ។

ចំណុចទាក់ទងការបញ្ចេញមតិរបស់កម្មករ ឯកឧត្តម អ៊ុំ មាន បានលើកឡើង ថា : ការធ្វើកូដកម្មដើម្បីបញ្ចេញមតិ វាជាការត្រឹមត្រូវតែកូដកម្មត្រូវធ្វើក្នុងរោងចក្រ។ ការបញ្ចេញមតិ និងការទាមទារត្រូវធ្វើក្នុងបរិវេណរោងចក្រ តែបើកូដកម្មហែរចេញ ជាក្បួន នោះនឹងត្រូវទាមទារឱ្យសុំច្បាប់ក្នុងការធ្វើបាតុកម្ម។ ឯកឧត្តម បានបន្ថែមថា ការធ្វើកូដកម្ម បាតុកម្មទាមទាររបស់កម្មករ វាជាការត្រឹមត្រូវណាស់ តែអ្វីដែលជាភាព មិនប្រក្រតីនោះ គឺថាការធ្វើបាតុកម្មនេះច្រើនមានកម្លាំងពីខាងក្រៅ ដែលជំរុញឱ្យ បាតុកម្ម ក្លាយជាអំពើហិង្សា ដែលអាចឈានទៅដល់ការបំផ្លាញទ្រព្យសម្បត្តិរបស់ រោងចក្រ ឬដុតរោងចក្រ។ ជាការពិតណាស់រដ្ឋាភិបាល មានកាតព្វកិច្ចការពារទ្រព្យ សម្បត្តិរបស់អ្នកវិនិយោគដូចមានចែងក្នុងច្បាប់ ដូច្នេះ ដើម្បីកុំឱ្យបន្ទុកទាំងនេះធ្លាក់

ទៅក្នុងកណ្ដាប់ដៃរដ្ឋាភិបាលធ្ងន់ធ្ងរពេក រដ្ឋាភិបាលមានវិធានការទប់ស្កាត់ និងបង្ក្រាបបាតុកម្ម ដែលការទប់ស្កាត់នេះអាចឈានទៅដល់ការប្រើអំពើហិង្សារវាងបាតុករ និងសមត្ថកិច្ចក៏មាន។ ក្នុងការដោះស្រាយបញ្ហារវាងកម្មករ និងថៅកែរោងចក្រ ជាដំបូងកម្មករត្រូវសុំច្បាប់មកអាជ្ញាធរ ហើយការដោះស្រាយជំហានដំបូង គឺដោះស្រាយរវាងកម្មករ និងថៅកែរោងចក្រ ហើយបើករណីនេះ ដោះស្រាយមិនបានសម្រេចទេនោះ កម្មករ ឬតំណាងកម្មករត្រូវផ្ដល់ដំណឹងដល់ក្រសួងការងារដើម្បីធ្វើអន្តរាគមន៍ ហើយបើក្រសួងធ្វើអន្តរាគមន៍មិនបាន ត្រូវបញ្ជូនសំណុំរឿងទៅតុលាការជាដំណាក់កាលចុងក្រោយ។

មតិបន្ថែមរបស់លោក សេង ផល្លី ចំពោះ Monitoring project លោកបានរិះគន់ចំពោះ ILO ថា អនុវត្តការងារមិនបានម៉ត់ចត់ព្រោះមួយឆ្នាំ ILO ចុះត្រួតពិនិត្យតែម្ដងគឺវាមិនគ្រប់គ្រាន់ទេ ហើយម្យ៉ាងទៀត បុគ្គលិករបស់ ILO ក៏មានចំនួនតិច។ លើសពីនេះចំណុចមិនល្អមួយទៀតគឺ ILO មិនបានហ្វឹកហ្វឺនបុគ្គលិកខ្មែរឱ្យមានសកម្មភាពទៅលើ Monitoring project នេះជាបញ្ហាចម្បង ព្រោះនៅពេលដែល ILO អស់អាណត្តិ បុគ្គលិកខ្មែរនឹងមិនមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញការងារនេះទេ។

សំណួររបស់លោកម្នាក់ មកពីអង្គការសង្កេតការបោះឆ្នោតកម្ពុជា *"តើវិវាទរវាងកម្មករ និងនិយោជកមានការថយចុះប៉ុន្មានភាគរយ? ហើយតើចាប់ពីឆ្នាំណាមកដែលប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ ១ ពីល័ក្ខខ័ណ្ឌការងារ? និងបញ្ហាថៅកែចង់គេចវេសពីអតីតភាពរបស់កម្មករជាដើម"* ។

ឯកឧត្ដម អ៊ុំ មាន បានបកស្រាយថា ក្រោយពីមានវេទិការវាងរដ្ឋាភិបាល និងផ្នែកឯកជនមក គឺចាប់ផ្ដើម ពី ឆ្នាំ ២០០២ មក គេបានវាយតម្លៃលើបីចំណុចគឺ គ្មានការ

ធ្វើការងារដោយបង្ខំ គ្មានការរើសអើង និងគ្មានពលកម្មកុមារ ដែលធនាគារពិភពលោកបានសរសេរក្នុងរបាយការណ៍នៅឆ្នាំ ២០០៤ ដោយឱ្យចំណាត់ថ្នាក់ប្រទេសកម្ពុជាលេខ ១ ប្រទេសថៃលេខ ៤ ប្រទេសវៀតណាម និងប្រទេសចិនលេខ ៨ ដោយវាយតម្លៃទៅតាមចំណុចបីខាងលើ។ ចំណែកឯការគេចវេសរបស់ថៅកែកន្លងមកមាន ប៉ុន្តែភាគតិចបំផុតប្រហែលជា ១០% ប៉ុណ្ណោះ។ ក្នុងឱកាសនោះដែរ ឯកឧត្តម អ៊ឹង ហួត បានលើកសំណួរថា *តើយើងបានកែប្រែច្បាប់ការងារលើចំណុចណាខ្លះ ក្រោយពីខ្មែរបានចូលជាសមាជិក WTO?* សំណួរនេះ ឯកឧត្តម អ៊ុំ មាន បានបកស្រាយថា យើងបានតែច្បាប់ការងារលើចំណុចការពន្យាកិច្ចសន្យា ការងាររបស់ជនបរទេសដែលមកធ្វើការនៅកម្ពុជា ដែលពីមុនបន្តកិច្ចសន្យាមួយឆ្នាំម្តង មកពីរឆ្នាំម្តងស្របតាមស្តង់ដារ WTO។ ចំណែកឯសំណួររបស់ លោក ហម សំណាង នៅវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព *តើរាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធបានគិតដល់កម្មករខ្មែរដែលទៅធ្វើការនៅបរទេសដែរឬទេ?* ឯកឧត្តម អ៊ុំ មាន បានមានប្រសាសន៍ថា យើងបានគិតគួរច្បាស់លាស់ណាស់ គឺយើងមានក្រុមហ៊ុននាំពលករ និងតាមរយៈស្ថានទូតសម្រាប់ឱ្យកម្មករធ្វើទំនាក់ទំនង នៅពេលមានបញ្ហាកើតឡើង យើងដោះស្រាយទៅតាមច្បាប់ការងារ។ ចំពោះសំណួររបស់ លោក សំណាង ដដែល ដែលបានលើកពីការគិតទុកមុន ក្រោយពីរោងចក្របិទទ្វារ *ថាតើកម្មករទាំងអស់ត្រូវធ្វើអ្វីបន្តទៀត?* ឯកឧត្តម បានឆ្លើយថា រដ្ឋាភិបាលបានបង្កើត ***"តំបន់កែច្នៃកសិ-ឧស្សាហកម្ម"*** ដែលបច្ចុប្បន្នមានដំណើរការបណ្តើរៗ ហើយដូចជាការផលិតស្រាចេក ស្រាម្នាស់ និងស្រាទឹកត្នោតជាដើមទៅអនាគតដ៏ខ្លីនេះ យើងនឹងធ្វើការកែច្នៃផ្លែចេកជាកញ្ចប់ថែមទៀត។

លោកម្នាក់ ដែលបានអញ្ជើញមកពីក្រសួងពាណិជ្ជកម្មបានបញ្ជាក់បន្ថែមទៀតថា កម្ពុជាបានត្រៀមខ្លួនចូលជាសមាជិក WTO តាំងពីឆ្នាំ ១៩៩៤ មកម្ល៉េះ ក្រៅពីនេះ

លោកបានលើកសំណួរថា *"តើយើងមានវិធានការយ៉ាងណា ដើម្បីអភិវឌ្ឍតំបន់កសិ-ឧស្សាហកម្មនោះ?"*

ឯកឧត្តម អ៊ុំ មាន បានឆ្លើយថា យើងត្រូវប្រមូលផ្តុំទំនិញឱ្យបានច្រើន ត្រូវជំរុញការដឹកផលិតផលឱ្យបានឆាប់ និងត្រូវកែលម្អហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត។ ជាចុងបញ្ចប់ លោក សេង ផល្លី បានបន្ថែមថា ដើម្បីធ្វើការអភិវឌ្ឍនីប្រទេសត្រូវមានការបង្កើតថ្មី ក៏ដូចជា ការបង្កើតការងារត្រូវធ្វើយ៉ាងណា ឱ្យនិស្សិតដែលបញ្ចប់ពីសាលានោះ ចេះសរសេរគម្រោង ហើយនឹងសុំឱ្យម្ចាស់ជំនួយទុកខ្ទង់ចំណាយសម្រាប់គម្រោងទាំងនោះ។

ជាចុងក្រោយ ឯកឧត្តម អ៊ឹង ហួត បានលើក គំនិតថា រាជរដ្ឋាភិបាលមិនត្រូវគិតតែពីការទារពន្ធពេកទេ ដូចជា សាំង ត្រូវបញ្ចុះពន្ធ គឺត្រូវលក់ឱ្យប្រជាជនក្នុងតម្លៃដើម ដោយមិនបាច់គិតថ្លៃពន្ធនាំចូល ដើម្បីធ្វើឱ្យវិស័យដទៃទៀតរីកចម្រើន ព្រោះថាបើសាំងឡើងថ្លៃ អ្វីៗក៏ថ្លៃ ហើយនឹងធ្វើឱ្យប្រជាជនបាត់ ឱកាសក្នុងការរកចំណូល។

## IV-**សេចក្តីសន្និដ្ឋាន :**

ដើម្បីឱ្យផលិតផលកម្ពុជាមានសក្តានុពល ក្នុងការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ យើងត្រូវផ្តោតការ យកចិត្តទុកដាក់នៅលើការអនុវត្តល័ក្ខខ័ណ្ឌការងារឱ្យបានត្រឹមត្រូវការបន្ធូរបន្ថយពន្ធលើវត្ថុធាតុដើម ដូចជាសាំងជាដើម ការស្តារ និងការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជួយសម្រួលដល់ចរាចរទំនិញ និងកាត់បន្ថយថ្លៃដឹកជញ្ជូន។ ជាមួយគ្នានេះ ការផ្តល់សិទ្ធិសេរីភាពគ្រប់គ្រាន់ឱ្យទៅកម្មករក្នុងការទាមទារ និងតវ៉ាចំពោះការរំលោភ និងជិះជាន់របស់ថៅកែរោងចក្រជាកត្តាសំខាន់បំផុត

ដើម្បីធ្វើឱ្យប្រសើរឡើងចំពោះបរិដ្ឋានការងារ ។ តែការធ្វើបាតុកម្ម ត្រូវតែគិតគូដល់សណ្តាប់ធ្នាប់សង្គម និងការយោគយល់គ្នារវាងនិយោជក និងនយោជិត ។

លើសពីនេះទៅទៀត ការអភិវឌ្ឍន៍ធនធានមនុស្សជាកត្តាសំខាន់បំផុតដែលមិនអាចខ្វះបានដើម្បីដណ្តើមយកឧត្តមភាពប្រកួតប្រជែងនៅលើឆាកអន្តរជាតិ ។ ធនធានមនុស្សមិនត្រឹមតែជាកត្តាចម្បង សម្រាប់ការអភិវឌ្ឍន៍ និងលើកកំពស់សេដ្ឋកិច្ចប៉ុណ្ណោះទេ តែថែមទាំងជាកត្តាលីករដែលជំរុញការអភិវឌ្ឍន៍គ្រប់វិស័យ ដូចជាសង្គមកិច្ច បច្ចេកទេស និងប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ ។ ក្នុងការសហការរវាងរដ្ឋាភិបាល និងផ្នែកឯកជនជាកត្តាសំខាន់បំផុតមិនអាចខ្វះបាន ព្រោះផ្នែកឯកជនជាអ្នកចូលរួមយ៉ាងសកម្ម និងធ្វើការយ៉ាងជិតស្និតជាមួយកម្មករ ហើយផ្នែកឯកជននេះជាអ្នកផ្តល់នូវបច្ចេកទេសទាក់ទង និងការបង្កើតច្បាប់ការកែប្រែច្បាប់ និងជាអ្នកដែលផ្តល់ការហ្វឹកហ្វឺន ដើម្បីអភិវឌ្ឍធនធានមនុស្ស ព្រោះធនធានមនុស្សជាកត្តាសំខាន់បំផុតនៅក្នុង WTO នេះ ។

# របាយការណ៍សង្ខេបនៃវេទិកា ទី ៥

## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : តើមានផលប៉ះពាល់យ៉ាងណាចំពោះសមាជិក WTO របស់កម្ពុជាទៅលើឧស្សាហកម្មកាត់ដេរ?

## I-សេចក្តីផ្តើម

ជាកិច្ចចាប់ផ្តើម ឯកឧត្តម អ៊ុន នីង សមាជិកក្រុមប្រឹក្សាភិបាល វ.ខ.ស.ស និងជាអនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងពត៌មាននៃរដ្ឋសភាមានមតិស្វាគមន៍ និងណែនាំគណៈវាគ្មិននៃកិច្ចពិភាក្សា ចំពោះអង្គប្រជុំទាំងមូល។ ឯកឧត្តមបានលើកឡើងថា កិច្ចពិភាក្សាតុមូលនេះគឺដើម្បីសិក្សា និងលើកកម្ពស់ការយល់ដឹងរបស់សមាជិកភាពនៃកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក និងលើកស្ទួយតួនាទីនៃថ្នាក់ដឹកនាំ និងប្រជាជនកម្ពុជាទាំងមូលឱ្យយកចិត្តទុកដាក់ និងធ្វើការដើម្បីសម្រេចបានប្រយោជន៍ដ៏ធំធេងសម្រាប់កម្ពុជា។ យើងក៏នៅមិនទាន់ច្បាស់ថា ថ្នាក់ដឹកនាំនៃប្រទេសកម្ពុជាយល់ដឹង អំពីផលប៉ះពាល់នៃអង្គការ WTO មកលើកម្ពុជាក្នុងកំរិតណានោះឡើយ ថាតើបន្ទាប់ពីចូល WTO កម្ពុជាទទួលផលប៉ះពាល់លើវិស័យណាខ្លះ? តើវិស័យអប់រំ កសិកម្ម ឧស្សាហកម្មរបស់កម្ពុជាទៅជាដូចម្តេច? ដូចនេះហើយទើបវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បានយកប្រធានបទនេះមកពិភាក្សា និងផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងពី WTO មកលើវិស័យកាត់ដេរ ព្រោះនេះជាបញ្ហាសំខាន់ រសើបសម្រាប់កម្ពុជាដែលត្រូវតែយកចិត្តទុកដាក់។

## II-ទស្សនៈរបស់គណៈវាគ្មិនកិត្តិយស

**វាគ្មិនទី ១** លោក **យា ប៊ុនណា** អនុប្រធាននាយកដ្ឋាន កិច្ចការឧស្សាហកម្ម និងជាប្រធានអង្គភាពផលិតភាពអាស៊ី ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល បានលើកឡើងថា ការចូលជាសមាជិករបស់កម្ពុជាក្នុងអង្គការ WTO មានសារៈសំខាន់ផង និងផលប៉ះពាល់ផង ដែលយើងមិនអាចដឹងបាននៅថ្ងៃអនាគត។ កម្ពុជាបានខិតខំរៀបចំខ្លួនដើម្បីចូលជាសមាជិក WTO រយៈពេល ៩ ឆ្នាំហើយ ទីបំផុតយើងបានចូលជាសមាជិកនៅខែតុលា ២០០៤ ក្រោយពីការផ្តល់សច្ចាប័នរបស់រដ្ឋសភា និងការអនុម័ត យល់ព្រមពីព្រឹទ្ធសភា។ លោកបានបន្ថែមទៀតថា ការចូលជាសមាជិកនេះ កម្ពុជាមានឱកាសជាច្រើន ដើម្បីធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀត និងជាសមាជិកដោយឈរលើមូលដ្ឋានច្បាប់ និងតម្លាភាព។ លើសពីនេះទៅទៀតការឈ្វេងយល់ពីច្បាប់ និងវិធានការនានារបស់ WTO ជាប្រការសំខាន់បំផុត ដើម្បីយើងអាចទាញយកអត្ថប្រយោជន៍សម្រាប់ប្រទេសកម្ពុជាយើង។ ចាប់តាំងពីកម្ពុជាបានចូលជាសមាជិក WTO មានមតិជាច្រើនបានលើកឡើង និងរើកញែកផលចំណេញ និងផលប៉ះពាល់របស់កម្ពុជា ក្នុងអង្គការនេះ ជាពិសេសវិស័យកាត់ដេរ ដែលជាវិស័យឈានមុខសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងបង្កើតបាននូវការងារជាច្រើនសម្រាប់ប្រជាជនកម្ពុជា រហូតដល់ទៅ ២៩៥,៨៧៦ នាក់។ ដូច្នេះ វិស័យនេះយើងត្រូវតែចាប់អារម្មណ៍ដើម្បីរកវិធានការទប់ស្កាត់នូវផលប៉ះពាល់ធ្ងន់ធ្ងរទៅថ្ងៃអនាគត។ លោក យា ប៊ុនណា ក៏បានលើកឡើងផងដែរ នូវកិច្ចព្រមព្រៀងវាយនភណ្ឌ ដែលបានបញ្ចប់នៅខែមករា ឆ្នាំ ២០០៥ នេះ ដែលធ្វើឱ្យប្រទេសផ្សេងៗ នាំសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបដោយគ្មានកូតា។ ជាពិសេសប្រទេសកម្ពុជាមានការព្រួយបារម្ភ ព្រោះមិនអាចធ្វើការ

ប្រកួតប្រជែងជាមួយប្រទេសចិន ដែលជាប្រទេសមានឥទ្ធិពលក្នុងការផលិតសម្លៀកបំពាក់ដោយចំណាយនូវថ្លៃដើមទាប។ តែទោះជាយ៉ាងនេះក៏ដោយរហូតមកដល់ពេលនេះ យើងមិនទាន់ឃើញមានផលប៉ះពាល់ធ្ងន់ធ្ងរ មកលើវិស័យកាត់ដេររបស់ប្រទេសយើងទេ ជាក់ស្តែងយើងឃើញមានរោងចក្រចំនួន ១១ បានបិទទ្វារ តែយើងមានរោងចក្រចំនួន ២៣ បានបង្កើតឡើង ដូចនេះចំនួនបើកច្រើនជាងបិទ។ ចំនួនរោងចក្រកាត់ដេរសរុបនៅក្នុងប្រទេស កម្ពុជាបច្ចុប្បន្នគឺមានចំនួន ២៤០។ ក្នុងចំណោម ២៣ រោងចក្រដែលបានបង្កើតថ្មីៗនេះគឺមាន ១៥ រោងចក្រ មកពីចិន និង៥រោងចក្រមកពីកូរ៉េ។ លោក យ៉ា ប៊ុនណា បានធ្វើការវិភាគថា មូលហេតុដែលធ្វើឱ្យចិនវិនិយោគច្រើនថែមទៀតលើវិស័យកាត់ដេរក្នុងប្រទេសកម្ពុជានោះគឺ ដោយសារតែអាមេរិកនៅតែបន្តដាក់កម្រិតកូតានាំចូលសម្លៀកបំពាក់ពីប្រទេសចិន ដូច្នេះ ចិនត្រូវតែបង្វែរទិសវិនិយោគមកកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវតែដឹងថា កម្ពុជានឹងមានផលប៉ះពាល់យ៉ាងខ្លាំងក្លាក្នុងវិស័យកាត់ដេរនេះ នៅពេលដែលអាមេរិកលុបចោលនូវការដាក់កម្រិតកូតា សម្លៀកបំពាក់ចំពោះចិនទាំងស្រុង ព្រោះយោងតាមច្បាប់ WTO អាមេរិកមិនអាចដាក់កម្រិតរបៀបនេះរហូតបានទេ នៅក្នុងករណីបែបនេះមានសំណួរមួយដែលយើងត្រូវលើកឡើងគឺ *"តើវាសនាអនាគតនៃវិស័យកាត់ដេររបស់កម្ពុជា ត្រូវពឹងផ្អែកទាំងស្រុងទៅលើការដាក់កម្រិតកូតារបស់សហរដ្ឋអាមេរិក ចំពោះប្រទេសចិនឬយ៉ាងណា?"*

បើយើងក្រលេកមើលតម្លៃពលកម្មនៅស្រុកខ្មែរ យើងឃើញមានកម្រិតទាបមែនតែយើងក៏មានផលិតភាពទាបដែរ បើសិនជាធ្វើការប្រៀបធៀបជាមួយកម្លាំងពលកម្មនៅប្រទេសចិន ដោយសារតែកត្តាផលិតភាពរបស់គេខ្ពស់នោះ ធ្វើឱ្យកម្លាំងពលកម្មនៅស្រុកខ្មែរយើងថ្លៃជាង។ ដូច្នេះ ដើម្បីទប់ស្កាត់នូវផលប៉ះពាល់ខ្លាំងក្លាលើវិស័យនេះ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានខិតខំធ្វើយ៉ាងណា ដើម្បីបង្កើន

ផលិតភាពក្នុងគោលបំណងទប់ស្កាត់ផលប៉ះពាល់ធ្ងន់ធ្ងរទៅថ្ងៃអនាគត។ ដោយយល់ថា ការបង្កើនផលិតភាពជាកត្តាសំខាន់ ក្នុងការរួមចំណែកទប់ស្កាត់នូវបញ្ហាប្រឈមទើប ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានខិតខំប្រឹងប្រែងសុំចូលជាសមាជិកផលិតភាព អាស៊ី (Asia Productivity Organization) ដែលជាអង្គការមួយមានកម្លាំង និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីជំរុញនិងលើកកម្ពស់ផលិតភាពនៅអាស៊ី កម្ពុជាបានក្លាយ ជាសមាជិកពេញសិទ្ធិរបស់ APO នៅថ្ងៃទី២០ ឧសភា ២០០៤។ ថ្មីៗនេះ APO មាន គម្រោងពង្រីកសមាជិកភាពរបស់ខ្លួនក្រៅទ្វីបអាស៊ីទៀត គឺនៅទ្វីបអាហ្វ្រិក។ ការចូល ជាសមាជិកនៃអង្គការ APO របស់កម្ពុជា មិនត្រឹមតែអាចឱ្យកម្ពុជាបង្កើនផលិតភាព លើវិស័យកាត់ដេរទេ តែថែមទាំងក្នុងវិស័យសហគ្រាស ធុនតូច និងមធ្យមផងដែរ។ APO មានទីស្នាក់ការនៅទីក្រុង Tokyo និងមានប្រទេសចំនួន២០ ជាសមាជិកអង្គការ នេះមានគោលដៅ ៥ យ៉ាងគឺ : ពង្រឹងសហគ្រាសធុនតូច និងមធ្យមធ្វើកម្មវិធីអភិវឌ្ឍ សហគមន៍ បង្កើននូវផលិតភាពបៃតង គ្រប់គ្រងពុទ្ធិ អភិវឌ្ឍអង្គការផលិតភាពជាតិ ។

អង្គការផលិតភាពអាស៊ីនេះ តម្រូវឱ្យប្រទេសជាសមាជិកនីមួយៗ ត្រូវបង្កើត នូវអង្គការផលិតភាពជាតិមួយ (National Productivity Organization) សំរាប់ កម្ពុជាយើង។ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានបង្កើតនូវអង្គការផលិតភាពជាតិ បន្ទាប់មកទៀតរដ្ឋាភិបាល ក៏បានអនុញ្ញាតឱ្យយើងបង្កើតនូវក្រុមប្រឹក្សាផលិតភាពជាតិ មួយហៅថា (Cambodian Council Productivity Unit) ដើម្បីបង្កើននូវទំនាក់ ទំនងជាអន្តរក្រសួង។ លើសពីនេះទៅទៀត ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក៏បាន យកចិត្តទុកដាក់ផងដែរលើសហគ្រាសធុនតូច និងមធ្យម ដើម្បីដោះស្រាយបញ្ហានានា ដែលវិស័យនេះជួបប្រទះ។ ក្រសួងក៏បានរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងមូលដ្ឋានគ្រឹះ នានាសម្រាប់ធ្វើការអភិវឌ្ឍន៍ ដោយបានបង្កើតនូវច្បាប់ជាច្រើន ដូចជា ច្បាប់គ្រប់គ្រង

អគ្គិសនី ច្បាប់គ្រប់គ្រងធនធានរ៉ែ ។ល។ និងកំពុងរៀបចំច្បាប់គ្រប់គ្រងមួយចំនួនទៀត ដូចជា ច្បាប់គ្រប់គ្រងរោងចក្រ ច្បាប់ស្តង់ដារឧស្សាហកម្មកម្ពុជា និងចងក្រងគោលនយោបាយសហគ្រាសធុនតូច និងមធ្យម។ ច្បាប់ទាំងនេះចូលរួមចំណែកលើកកម្ពស់ និងទាក់ទាញ វិនិយោគពីបរទេស ក៏ដូចជា ក្នុងស្រុកសំដៅបង្កើតឱ្យមានការងារផ្សេងៗទៀត ក្រៅពីវិស័យកាត់ដេរ។ លោកក៏បានសង្កត់ធ្ងន់ថា នៅកម្ពុជាក្រៅពីផលិតភាពទាប គឺយើងនូវមានបញ្ហាការអនុវត្តន៍ច្បាប់មិនបានត្រឹមត្រូវ ដូច្នេះ ទើបអ្នកវិនិយោគគេមិនសូវមករកស៊ីនៅកម្ពុជា ជាពិសេសប្រព័ន្ធតុលាការស្រុកខ្មែរយើង មិនទាន់មានលក្ខណៈដែលអាចធ្វើឱ្យអ្នកវិនិយោគជឿទុកចិត្តបាន ប្រព័ន្ធធនាគារក៏នៅមានភាពទន់ខ្សោយ។

**វាគ្មិនទី ២** លោក **ជួន មុំថុល ប្រធានសហព័ន្ធសហជីពខ្មែរ** បានលើកឡើងថា ផលវិជ្ជមានរបស់ប្រទេសកម្ពុជាក្នុងអង្គការ WTO គឺកម្ពុជាអាចនាំទំនិញរបស់ខ្លួនទៅលក់ដោយសេរី ទៅឱ្យប្រទេសដែលជាសមាជិក WTO ជាពិសេស លើផលិតផលកាត់ដេរ ព្រោះយើងមិនមានការកម្រិតកូតាដូច MFN ឬ GSP ទេ គឺយើងអាចផលិត និងនាំទៅលក់ដោយបរិមាណគ្មានកំណត់ តែបញ្ហាធំគឺទំនិញត្រូវមានគុណភាព ដែលអាចប្រកួតប្រជែងលើទីផ្សារបាន។ លោកបានបន្ថែមទៀតថា កម្ពុជាជាប្រទេសទី ១ ដែលធ្វើកិច្ចព្រមព្រៀងទ្វេភាគី ជាមួយសហរដ្ឋអាមេរិក ហើយនិងមានភ្ជាប់ល័ក្ខខ័ណ្ឌការងារមកជាមួយ ពិសេសជាងនេះទៅទៀត កម្ពុជាជាប្រទេសតែមួយគត់ដែល មានអង្គការ ILO ជួយត្រួតពិនិត្យល័ក្ខខណ្ឌ័ការងាររបស់រោងចក្រកាត់ដេរ ដែលធ្វើឱ្យកិត្តិសព្ទរបស់កម្ពុជា ក្នុងវិស័យកាត់ដេរនេះមាន ភាពល្បីល្បាញលើទីផ្សារអន្តរជាតិ ដែលជាកត្តាមួយក្នុងការទាក់ទាញវិនិយោគ។

ចំពោះផលប៉ះពាល់អវិជ្ជមានវិញ លោកបានមានប្រសាសន៍ថា ចាប់ពីកម្ពុជាត្រូវបានផ្តាច់កូតា កម្ពុជាមានរោងចក្រជាច្រើនបានបិទទ្វារ ហើយលោក ជួន មុំថុល

បានបដិសេធនឹងចោលចំពោះរបាយការណ៍ថា ចាប់តាំងពីកម្ពុជាអស់កូតា គឺមានរោងចក្រ ១១ បិទ និង ២៣ បើកទ្វារ ដោយលោកសង្កត់ធ្ងន់ថា សមាគមកាត់ដេរដែលបានឱ្យទិន្នន័យ ទៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល គឺមិនមានលក្ខណៈប្រាកដប្រជា ព្រោះទិន្នន័យនេះបញ្ជាក់តែអ្នកជាសមាជិករបស់ខ្លួនតែប៉ុណ្ណោះ យើងឃើញថាជាង ៣០០ រោងចក្រ គឺមានរោងចក្រប្រហែលជាង ២០០ ដែលជាសមាជិករបស់សមាគមកាត់ដេរ ដូច្នេះអ្នកដែលមិនមែនជា សមាជិកសមាគមកាត់ដេរ មិនបានដាក់បញ្ចូលទេ។ លោកបានបន្ថែមទៀតថា ចាប់តាំងពីខែកញ្ញា ២០០៤ មក មានរោងចក្រ ៣៦ បានបិទទ្វារជាស្ថាពរ និងមាន ៤១ រោងចក្រ ទៀតបានព្យួរ។ ចាប់តាំងពីនោះគឺមានកម្មករចំនួនប្រហែល ៥០,០០០ នាក់ដែលបាត់បង់ការងារធ្វើ ហើយរោងចក្រដែលបានបិទទ្វារនេះគឺគេទៅវិនិយោគនៅប្រទេសចិនវិញ ដោយសារតែយើងអស់កូតា និងតម្លៃថាមពលនៅចិនទាបជាងនៅកម្ពុជា។ លើសពីនេះទៅទៀត កម្មករនៅចិនផ្តល់ផលិតភាពខ្ពស់ជាងនៅកម្ពុជា និងវត្ថុធាតុដើមមានស្រាប់ដោយមិនចាំបាច់នាំចូល នេះជាកត្តាដែលកាត់បន្ថយ ចំណាយលើការដឹកជញ្ជូន។ លោកក៏បានបន្ថែមទៀតថា ការចូលជាសមាជិករបស់កម្ពុជាក្នុងWTO នេះគឺ វាហាក់បីដូចជាឆាប់រហ័សពេក ព្រោះកម្ពុជាមិនទាន់បានត្រៀមខ្លួនឱ្យបានសមរម្យ និងពិបាកបត់បែនតាមសភាពការណ៍របស់ WTO។ កម្ពុជាមិនអាចប្រៀបធៀបជាមួយប្រទេសផ្សេងៗ បានទេ ដោយសារប្រទេសទាំងនោះបានត្រៀមខ្លួនរួចជាស្រេច ដូច្នេះ ការចូល WTO មិនមានផលលំបាកសម្រាប់គេឡើយ។ លោកបានលើកទៀតថា ការចូលជាសមាជិក WTO ត្រូវគិតលើចំណុចពីរសំខាន់ គឺគុណភាព និងតម្លៃ ដើម្បីធានាឱ្យបាននូវការប្រកួតប្រជែងលើឆាកអន្តរជាតិ។ ចំពោះប្រទេសកម្ពុជាយើងផលិតផលយើងនៅមិនទាន់មានបច្ចេកវិទ្យាខ្ពស់ ដូច្នេះ គុណភាព និង ផលិតផលរបស់យើងនៅទាប បើប្រៀបធៀបជាមួយប្រទេសដទៃទៀត លើសពីនេះ យើងមាន

បញ្ហាជាច្រើន ដែលធ្វើឱ្យផលិតផលកាត់ដេរកម្ពុជាមានតម្លៃថ្លៃ គឺកត្តាវត្ថុធាតុ ដើម និងបញ្ហាការិយាល័យធិបតេយ្យ។ ទាក់ទងនិងរោងចក្រដែលបិទទ្វារនៅកម្ពុជា កន្លងមក លោកបានមានប្រសាសន៍ថា ដោយសារតែរោងចក្រ ទាំងនោះបែរទៅរកស៊ីនៅ ប្រទេស ចិន ព្រោះក្នុងនាមជាសមាជិករបស់ WTO ចិនអាចនាំផលិតផលរបស់ខ្លួនដោយសេរី ទៅអាមេរិក និងសហគមន៍អឺរ៉ុប ដោយគ្មានកំណត់កូតា។ តែជាអកុសលគឺអាមេរិក និងសហគមន៍អឺរ៉ុបបានដាក់កូតា មកលើផលិតផលសម្លៀកបំពាក់របស់ចិនដែលបញ្ហានេះ ធ្វើឱ្យរោងចក្រមួយចំនួនត្រឡប់មកស្រុកខ្មែរវិញ តែរោងចក្រទាំងនេះមិនដាក់ឈ្មោះ ដូចដើមទេ គឺដាក់ឈ្មោះផ្សេង។ លោកបានបន្ថែមថា ភាគច្រើនរោងចក្រដែលបាន បិទ ហើយបើកវិញនេះគឺជារោងចក្រដដែល តែមានឈ្មោះថ្មី ហើយចំនួននេះគឺមាន ៤៥ រោងចក្រ ដែលអាចស្រូបយកកម្លាំងពលកម្មបាន ៩,០០០ នាក់។ ជាងនេះទៅទៀត លោកសង្ឃឹមថា កម្ពុជានឹងមានរោងចក្រថ្មីៗទៀត ចូលមករកស៊ីថែមទៀត ដោយសារ តែអាមេរិក និងសហគមន៍អឺរ៉ុបដាក់កូតាទៅលើប្រទេសចិន។

## III-មតិពិភាក្សារួម :

បន្ទាប់ពីវាគ្មិនទាំងពីរបានបញ្ចប់នូវការថ្លែងសុន្ទរកថារបស់ខ្លួនរួចមកអង្គវេទិកា ទាំងមូលបានបើកកិច្ចពិភាក្សា ដើម្បីផ្លាស់ប្តូរយោបល់ ផ្តល់នូវមតិ និងការយល់ដឹងព្រម ទាំងលើកឡើងនូវសំណួរជូនគណៈវាគ្មិន ក៏ដូចជាអង្គវេទិកា ទាំងមូលដើម្បីដោះស្រាយ។

លោក សេង សុវីរៈ អ្នកស្រាវជ្រាវនៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពបានលើកជា សំណួរថា តើមូលហេតុអ្វីខ្លះដែលសហរដ្ឋអាមេរិកដាក់កម្រិត កូតាដល់ប្រទេសចិន? តើការផ្លាស់រោងចក្រពីខ្មែរទៅចិន ហើយត្រឡប់មកខ្មែរវិញ នោះ

វាប៉ះពាល់ដល់អតីតភាពរបស់កម្មករដែរឬទេ? ព្រោះនៅកម្ពុជាមានរោងចក្រខ្លះ ដំណើការបាន៤-៥ឆ្នាំ ក៏បានបិទទ្វារទៅប្រទេសចិន ហើយត្រឡប់មកវិញដោយដាក់ឈ្មោះថ្មី។

ទាក់ទងនិងសំណួរនេះ លោក ជួន មុំថុល បានមានប្រសាសន៍ថា នៅពេលដែលរោងចក្របានបិទ គឺកម្មករ អស់អតីតភាព ហើយនៅពេលនោះ ថៅកែរោងចក្របានបង់លុយឱ្យកម្មករទាំងអស់ស្របតាមល័ក្ខខណ្ឌការងារ។ រោងចក្រដែលបានបិទហើយបើករកស៊ីនៅស្រុកខ្មែរវិញ គេបានផ្លាស់ឈ្មោះថ្មី ដូច្នេះ កម្មករដែលធ្វើការកន្លងមកត្រូវអស់អតីតភាព។ ចំពោះបញ្ហាដែលទាក់ទងការដាក់កម្រិតកូតា របស់សហរដ្ឋអាមេរិច និង សហគមន៍អឺរ៉ុបចំពោះផលិតផលកាត់ដេររបស់ចិន គណៈវាគ្មិនបានលើកឡើងថាដោយសារផលិតផលកាត់ដេររបស់ចិនមានតម្លៃថោកជាង ផលិតផលកាត់ដេររបស់សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបខ្លាំងពេក ដូច្នេះ បើមិនដាក់កម្រិតកូតាទេ សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបមិនអាចប្រកួតប្រជែងជាមួយចិនបានឡើយក្នុងវិស័យនេះ។

លោក ឡាំ សុវត្ថារា អ្នកសម្របសម្រួលការិយាល័យស៊ើបអង្កេត អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ លោកបានធ្វើការចាប់អារម្មណ៍ទាក់ទងនឹងប្រធានបទនេះ ថាតើកម្ពុជាត្រូវធ្វើអ្វីបន្ទាប់ពីចូលជាសមាជិករបស់ WTO? លោកបានលើកឡើងថា ចំណុចមួយចំនួនដែលប្រទេស យើងគួរយកចិត្តទុកដាក់ នោះគឺ :

- *ច្បាប់អាជ្ញាសាលា* : ច្បាប់នេះត្រូវចេញឱ្យបានឆាប់ ដើម្បីឱ្យមានស្ថាប័នមួយមាននីតិសម្បទាក្នុងការអនុវត្តន៍សាលក្រម ព្រោះដោយសារតុលាការខ្មែរពុំមានលក្ខណៈ យុត្តិធម៌គ្រប់គ្រាន់ ដើម្បីឱ្យអ្នកវិនិយោគទុនជឿទុកចិត្តក្នុងការដោះស្រាយបញ្ហា វិវាទពាណិជ្ជកម្ម។
- *តុលាការការងារ* : ដើម្បីដោះស្រាយរឿងវិវាទការងាររបស់កម្មករ និងថៅកែរោងចក្រ និងធ្វើឱ្យល័ក្ខខ័ណ្ឌ ការងារនៅក្នុងរោងចក្រមានភាពប្រសើរឡើង។

- *ប្រព័ន្ធធនាគារ* : កម្ពុជាត្រូវមានប្រព័ន្ធធនាគារមួយដែលរឹងមាំ និងអាចជឿទុកចិត្តបាន ដើម្បីផ្តល់ប្រាក់កម្ចីឱ្យអ្នកវិនិយោគទុន ក្នុងគ្រាណាដែលគេមានការខ្វះខាត ។
- *សន្តិសុខ និងស្ថិរភាពនយោបាយ* : នេះជាប្រការសំខាន់ ប្រសិនបើគ្មានសន្តិសុខក្នុងប្រទេសទេ អ្នកវិនិយោគគេ នឹងខ្លាចក្នុងការមករកស៊ីនៅស្រុកខ្មែរ គេនឹងបង្វែរទិសដៅជំនួញរបស់គេ ទៅកាន់ប្រទេសផ្សេងទៀតដែលមានសន្តិសុខ និងស្ថិរភាពនយោបាយល្អជាង ។
- *ធនធានមនុស្ស :* នេះជាបញ្ហាសំខាន់សម្រាប់កម្ពុជាក្នុង WTO បើសិនយើងក្រឡេកមើលធនធានមនុស្សនៅកម្ពុជា យើងឃើញថា នៅមានលក្ខណៈទន់ខ្សោយនៅឡើយ មិនអាចប្រកួតប្រជែងជាមួយប្រទេសផ្សេងទៀត ដែលជាសមាជិកនៃ WTO បានទេ។ ក្នុងសកលភាវូបនីយកម្មនេះ អ្វីៗក៏សេរីជាពិសេស កម្លាំងពលកម្មនៅប្រទេសមួយអាចទៅធ្វើការនៅប្រទេសណាមួយទៀតដោយសេរី ក្នុងករណីនេះ ហើយបើធនធានមនុស្សរបស់កម្ពុជាយើងទន់ខ្សោយ យើងមិនអាចប្រកួតប្រជែងជាមួយប្រទេសដទៃទៀតបានឡើយ ។

លោក ម៉ម សម្បត្តិ នាយកអង្គការស៊ីដសេ បានលើកឡើងពីបញ្ហាពាណិជ្ជកម្មសេរី ដោយចោទសួរថា *តើយើងមានយុទ្ធសាស្ត្រអ្វី ដើម្បីប្រលងប្រជែងជាមួយប្រទេសជិតខាង?* ទាក់ទងនឹងសំណួរ ពាណិជ្ជកម្មសេរីនេះ លោក យ៉ា ប៊ុនណា បានមានប្រសាសន៍ថា នៅក្នុង WTO មានច្បាប់គ្រប់គ្រាន់ក្នុងការធ្វើពាណិជ្ជកម្មក្របកដោយសមភាព ដូច្នេះ យើងទាំងអស់គ្នា ត្រូវខិតខំស្វែងយល់ពីច្បាប់ផ្សេងៗរបស់ WTO ឱ្យបានស៊ីជម្រៅ ដើម្បីឱ្យការធ្វើពាណិជ្ជកម្មមានលក្ខណៈសមភាព ព្រោះច្បាប់ជាគោល-ការណ៍សម្រាប់សមាជិកគ្រប់រូបគោរពក្នុងការធ្វើពាណិជ្ជកម្ម ។

លោក ហៀង ប៊ុនហាន មកពីនាយកដ្ឋានសេដ្ឋសាស្ត្រនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក បានចូលរួមជាយោបល់ទាក់ទងនឹងបញ្ហានានា ដែលកម្ពុជាជួបប្រទះក្នុងវិស័យកាត់ដេរ ក្នុងនាមជាសមាជិកភាពនៃ WTO ថា ការចូលជាសមាជិកនៃ WTO បញ្ហាសំខាន់ដែលវាត្និនយកចិត្តទុកដាក់នោះគឺ មានតែការប្រកួតប្រជែងប៉ុណ្ណោះ លោកបានចោទជាសំណួរថា *តើក្រៅពីការប្រកួតប្រជែងយើងមានបញ្ហាអ្វីខ្លះទៀត?* លោកបានបន្ថែមថា នៅក្នុង WTO មានកិច្ចព្រមព្រៀងជាច្រើនដូចជា :

SPS និង GBP Agreement ដែលទាក់ទង និងអនាម័យ និងភូតគាមអនាម័យ ជាពិសេសទាក់ទង និងសុវត្ថិភាពរបស់ផលិតផលចំពោះអ្នកប្រើប្រាស់។ រាល់ផលិតផលកាត់ដេរដែលនាំចេញពីប្រទេសមួយទៅប្រទេស មួយទៀតត្រូវមានការធ្វើ Treatment ពិសេសមួយ ហើយបញ្ហានេះបានកំណត់នៅក្នុង SPM លេខ ១៥ ជាស្តង់ដារ ដែលរៀបចំឡើងដោយ IPPC ដែលកម្ពុជាបានចូលជាសមាជិកតាំងពីថ្ងៃទី ១០ តុលា ១៩៨២។ ដូច្នេះ នៅពេលដែលកម្ពុជាចូលជាសមាជិក WTO ក៏ត្រូវតែគោរពតាម SPS និង GBP Agreement នេះផងដែរ។ លោកបានបន្ថែមទៀតថា យើងមិនគួរពឹងផ្អែកតែទៅលើ WTO ទាំងស្រុងក្នុងការធ្វើពាណិជ្ជកម្មនោះទេ គឺយើងត្រូវរកដៃគូទ្វេភាគី ជាមួយប្រទេសផ្សេងទៀត ក្នុងការធ្វើពាណិជ្ជកម្ម ដើម្បីឱ្យយើងមានស្ថិរភាព។

លោក វណ្ណារ៉ា មកពីអគ្គនាយកដ្ឋាន រដ្ឋបាលក្រសួងមហាផ្ទៃ លោកបានចោទជាសំណួរថា *ក្នុងរយៈពេល ៩ ឆ្នាំ ចាប់ពីពេលដែលកម្ពុជាចូលជាសមាជិក WTO គឺគេតម្រូវឱ្យយើងធ្វើច្បាប់ ៤០ ឱ្យហើយសព្វគ្រប់ តើមកដល់ពេលនេះយើងធ្វើច្បាប់*

*បានប៉ុន្មានហើយ? តើ WTO មានផលប៉ះពាល់ និងផលចំណេញអ្វីខ្លះ មកលើសហជីព នៅក្នុងប្រទេសកម្ពុជា?*

លោក ជួន មុំថុល បានមានប្រសាសន៍ថា សហជីពមានផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារតែរោងចក្រមួយចំនួនត្រូវបិទទ្វារ ហើយសមាជិក ៥០,០០០ បាត់បង់ការងារធ្វើ។ ចំពោះលក្ខណៈល្អរបស់ WTO មកលើកម្ពុជាវិញ លោកបានលើកឡើងថា វាមានសារៈសំខាន់ក្នុងការបង្កើតទីផ្សារសម្រាប់ប្រទេសកម្ពុជា បន្ទាប់ពីកម្ពុជាបានបញ្ចប់កូតាមក។ ចំពោះសំណួរថាតើច្បាប់ទាំង ៤០ ដែល WTO តម្រូវឱ្យកម្ពុជាយើងធ្វើនេះ លោក ឡុង កាន់ណាបុត្រ មកពីក្រសួងពាណិជ្ជកម្មបានមានប្រសាសន៍ថា យើងបានអនុម័តចំនួន ១៦ ច្បាប់ហើយ។

## IV-សេចក្តីសន្និដ្ឋាន

អង្គវេទិកាទាំងមូល បានធ្វើសេចក្តីសន្និដ្ឋានលើផលប៉ះពាល់វិជ្ជមាន និង អវិជ្ជមាន របស់ឧស្សាហកម្មកាត់ដេររបស់កម្ពុជាក្នុង WTO។ ការចូលជាសមាជិក WTO របស់កម្ពុជាវាជាការចាំបាច់ណាស់ ព្រោះ WTO ជាទីផ្សារមួយ ដ៏សំខាន់សំរាប់លក់ផលិតផលរបស់កម្ពុជា ជាពិសេសផលិតផលកាត់ដេរនេះ ក្រោយដែលកម្ពុជាត្រូវបានបញ្ចប់កូតា ដែលផ្តល់ដោយសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប។ លើសពីនេះទៅទៀត កម្ពុជាក៏មានឱកាសនាំចេញផលិតផលដទៃទៀត ក្រៅពីវិស័យកាត់ដេរទៅលក់ក្នុងទីផ្សារប្រទេសដែលជាសមាជិក WTO ផងដែរ។

ទន្ទឹមនឹងផលវិជ្ជមាន យើងក៏មានផលអវិជ្ជមាន និងផលវិបាកជាច្រើនដែលត្រូវដោះស្រាយនៅថ្ងៃអនាគត ដូចជាបញ្ហាការលើកកម្ពស់ធនធានមនុស្សការពង្រឹងប្រព័ន្ធតុលាការ ការបង្កើតឱ្យមានតុលាការពាណិជ្ជកម្ម ការលើកកម្ពស់គុណភាពទំនិញ

ការពង្រឹងប្រព័ន្ធធនាគារ និងការធានាឱ្យបាននូវសន្តិសុខ និងស្ថិរភាពនយោបាយ។ ទាំងអស់នេះជាបញ្ហា ដែលកម្ពុជាកំពុងជួបប្រទះ ហើយត្រូវដោះស្រាយឱ្យបានក្នុងពេលអនាគត បើមិនដូច្នោះទេ កម្ពុជាមិនអាចទាញផលប្រយោជន៍ពី WTO បានច្រើនទេ។

# របាយការណ៍សង្ខេបនៃវេទិកា ទី ៦

## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : មានផលប៉ះពាល់អ្វីខ្លះទៅលើកម្មវិធីកាត់បន្ថយភាពក្រីក្រ?

## I-សេចក្ដីផ្ដើម

ដោយអនុវត្តតាមកម្មវិធីប្រចាំឆ្នាំ ២០០៥ ជាបន្តបន្ទាប់គ្នាក្នុងរយៈពេលមួយខែម្ដង វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បានរៀបចំវេទិកាមួយទៀតដែលជាវេទិកាទី៦ កាលពីថ្ងៃទី២៨ កក្កដា ក្រោមប្រធានបទស្ដីពី "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : តើមានផលប៉ះពាល់អ្វីខ្លះ ទៅលើកម្មវិធីកាត់បន្ថភាពក្រីក្រ (Cambodia and WTO : Any Implications on Poverty Reduction Program?)។ កិច្ចពិភាក្សាលើកទី ៦ នេះ ដឹកនាំសម្របសម្រួលដោយលោកបណ្ឌិត **ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព។ ចូលរួមជាគណៈវាគ្មិនកិត្តិយសរួមមាន (១) ឯកឧត្តម **គឹម ផ្លែវិសិដ្ឋ** ទីប្រឹក្សាឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណរដ្ឋមន្ត្រី (២)-ឯកឧត្តម **ទូច ស៊ាងតាណា** សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (OBSES) ទីស្ដីការគណរដ្ឋមន្ត្រី (៣)-ឯកឧត្តម **អ៊ុំ ចន្ទ័តារារិទ្ធ** សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (OBSES) ទីស្ដីការគណៈរដ្ឋមន្ត្រី (៤)-ឯកឧត្តម **ម៉ាន់ ឈឿន** អភិបាលរងរាជធានីភ្នំពេញ

និងជាប្រធាន មូលនិធិអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រទីក្រុង (៥)-លោកស្រី **ហ្វូត រតនៈ** នាយិកាវេទិកាទូទៅនៃកម្ពុជា។ ចូលរួមជាសមាជិក សមាជិកានៃអង្គពិភាក្សា មានអ្នកដឹកនាំ និងតំណាងអង្គការសង្គមស៊ីវិល ផ្នែកឯកជន តំណាងស្ថាប័នរដ្ឋ និស្សិត បញ្ញវន្ត និង អ្នកសារពត៌មាន។

លោកបណ្ឌិត ចាប សុថារិទ្ធ ប្រធានអង្គប្រជុំ បានបើកកម្មវិធីវេទិកាទី ៦ ស្តីពី "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក មានផលប៉ះពាល់អ្វីខ្លះទៅលើកម្ម វិធីកាត់បន្ថយភាពក្រីក្រ" ដោយបានធ្វើការស្វាគមន៍ចំពោះ សមាជិក សមាជិកានៃអង្គ ពិភាក្សាទាំងមូល និងបានធ្វើការបញ្ជាក់ ពីគោលបំណងនៃអង្គវេទិកា គឺជាវេទិកា សាធារណៈ គ្រប់សមាជិក សមាជិកាមានសិទ្ធិបញ្ចេញមតិ ផ្ទាល់ដោយមិនចាំបាច់ឆ្លុះ បញ្ចាំង ឬតំណាងរដ្ឋាភិបាល ឬក៏អង្គការស្ថាប័ន ដែលខ្លួនកំពុងបម្រើការឡើយ ដូច្នេះ យើងមានសេរីភាពទាំងស្រុង ក្នុងការបញ្ចេញមតិស្របតាមរដ្ឋធម្មនុញ្ញរបស់ព្រះរាជា-ណាចក្រកម្ពុជាយើង។

## II- **ទស្សនៈរបស់វាគ្មិនកិត្តិយស :**

**វាគ្មិនទី១** ឯកឧត្តម គឹម រត្នវិសិដ្ឋ ទីប្រឹក្សាឯកឧត្តម សុខ អាន ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានលើកឡើងពីភាពក្រីក្រនៅលើ ពិភពលោក ដែលបច្ចុប្បន្នអ្នកក្រមានចំនួនច្រើនជាងអ្នកមាន បើតាមតួរលេខរបស់ ធនាគាពិភពលោកបង្ហាញថា ពិភពលោកយើងមានមនុស្សប្រហែល ៥០០០ លាននាក់ ក្នុងចំណោមមនុស្ស ៦០០០ លាននាក់ មានទ្រព្យសម្បត្តិតិចជាង ២០% នៃទ្រព្យ សម្បត្តិពិភពលោក។ ដូច្នេះ មនុស្សមួយរយពាន់លាននាក់ គាត់មានកម្មសិទ្ធមានទ្រព្យ សម្បត្តិប្រហែលជា ៨០% នៃទ្រព្យទាំងមូលរបស់ពិភពលោក។ នេះមាននយ័ថា វាមាន

ភាពខុសគ្នាយ៉ាងខ្លាំង ហើយថា តើភាពក្រីក្រទាំងនេះ គេអាចធ្វើការកាត់បន្ថយតាមរបៀបណា? ជាពិសេសនៅកម្ពុជាយើងជាង ៣០ % នៃប្រជាពលរដ្ឋ គឺរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។ ឯកឧត្តមក៏បានចោទជាសំណួរថា តើសមាជិកភាពកម្ពុជា នៅក្នុង WTO វាជួយប្រជាពលរដ្ឋយើងរុងរឿង ឬធ្វើឱ្យប្រជាពលរដ្ឋយើងលំបាកជាងមុន?

ការលើកជាសំណួររបស់លោកខាងលើនេះ គឺទាក់ទងនឹងការខ្វែងគំនិតគ្នាមួយចំនួន ស្តីពី សមាជិកភាពកម្ពុជា នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ មានមនុស្សជាច្រើនដែលយល់ថា ពាណិជ្ជកម្មជាម៉ាស៊ីនធ្វើឱ្យសេដ្ឋកិច្ចលូតលាស់ (Engine of Growth) ប៉ុន្តែក៏មានខ្លះ មិនយល់ស្របទាំងស្រុងទេ។ អ្នកដែលជឿលើតួនាទីសំខាន់របស់ពាណិជ្ជកម្មបើកចំហ ក្នុងកំណើនសេដ្ឋកិច្ចមានចំនួនច្រើន តែក៏មានមួយចំនួនតូចបានប្រឆាំង និងគំនិតខាងដើមនេះ ហើយយល់ថាពាណិជ្ជកម្មពិភពលោក ធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់ពាណិជ្ជកម្មក្នុងស្រុក និងសុខុមាលភាពនៃមនុស្សជាតិ។ ឯកឧត្តមក៏បានលើកឡើងបង្ហាញផងដែរ នូវភស្តុតាងនៃគំនិតប្រឆាំងទៅ និងពាណិជ្ជកម្មសេរី ដូចជា ការធ្វើបាតុកម្ម ប្រឆាំងទៅនិងកិច្ចប្រជុំ WTO កិច្ចប្រជុំស្តីពីជំនួយ ជាពិសេសគឺកិច្ចប្រជុំទាក់ទងទៅ និងសកលភាវូបនីយកម្ម។ ជាមួយគ្នានេះផងដែរ ឯកឧត្តមក៏បានបញ្ជាក់នូវគំនិតផ្ទាល់របស់ ឯកឧត្តម ដែលជាអ្នកគាំទ្រនូវគោលនយោបាយ ពាណិជ្ជកម្មសេរី ដោយលើកឡើងថា ពាណិជ្ជកម្មសេរី វាជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។ ជាក់ស្តែងតាមការសិក្សាស្រាវជ្រាវ (cross-country study) ១៣៣ ប្រទេស ដែលបានលើកឡើងនៅក្នុងអត្ថបទរបស់ Krueger នៅឆ្នាំ ២០០៤ បង្ហាញថា ប្រទេសដែលមានរបបពាណិជ្ជកម្មសេរី មានកំណើនសេដ្ឋកិច្ច ប្រចាំឆ្នាំប្រហែលជា ០.៥ % ខ្ពស់ជាងកាល ដែលប្រទេសទាំងនោះ ពុំទាន់បើកចំហពាណិជ្ជកម្ម។ ដូច្នេះ បង្ហាញថា ការចូលជាសមាជិក WTO មានកំណើន សេដ្ឋកិច្ចលឿនជាងកាលមិនទាន់ចូលជាសមាជិក។ ហើយកំណើន

នេះ មានការកើនឡើងខ្លាំងក្នុងអំឡុងទសវត្ស ទី ៩០ ដែលមានរហូតដល់ ២.៥ % នៅពេលដែលគេធ្វើការលុបបំបាត់នូវរាល់ឧបសគ្គពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះ មានការសិក្សាមួយដែលមានលក្ខណៈជា cross-country study ដែលធ្វើឡើងដោយ AUSAID ទៅលើប្រទេសចំនួន ៧៣ ដែលជាប្រទេសកំពុងអភិវឌ្ឍន៍រួមមានប្រទេស **ចិន ឥណ្ឌា ប្រេស៊ីល ម៉ិចស៊ីកូ ម៉ាឡេស៊ី** ឃើញថា ដោយសារការបើកចំហពាណិជ្ជកម្ម ធ្វើឱ្យកំណើនសេដ្ឋកិច្ច ប្រទេសទាំងនេះកើនលឿនជាងកាលមិនទាន់បើកចំហពាណិជ្ជកម្ម ហើយអាចកើនឡើងលឿនជាងប្រទេសអ្នកមានខ្លះផងដែរ។ ក្នុងនេះផងដែរ ការសិក្សារបស់ AUSAID ក៏បានលើកបង្ហាញពីកំណើនសេដ្ឋកិច្ចខុសគ្នារវាងប្រទេស ដែលបើកចំហពាណិជ្ជកម្ម និងប្រទេសមិនបើកចំហ ជាពិសេសគឺទាក់ទងទៅ និងពន្ធនាំចូល (Tariffs) ដោយលើកឡើងថា ប្រទេសដែលកំពុងវិវត្តន៍ ដូចបានលើកឡើងខាងលើ បានកាត់បន្ថយពន្ធ នាំចូលចំនួន ៣៤ % ហើយធ្វើអោយកំណើនសេដ្ឋកិច្ចរបស់គេកើនឡើង ៥ % បើធៀបទៅ និងប្រទេស មិនបើកចំហដែលមានការកើនឡើងតែ ១.៤ % តែប៉ុណ្ណោះ។ ចំពោះពាណិជ្ជកម្ម និងភាពក្រីក្រ ឯកឧត្តម គឹម រ័ត្នវិសិដ្ឋ ក៏បានបង្ហាញជូនផងដែលថា នៅក្នុងចន្លោះ ឆ្នាំ១៩៩៣ ដល់ ១៩៩៨ ប្រជាជននៅលើពិភពលោករស់នៅក្នុងភាពក្រីក្រទាំងស្រុង absolute poverty នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយក្រោយពីបើកអោយមានពាណិជ្ជកម្មសេរី ឃើញថា ភាពក្រីក្របានថយចុះអស់ ១៤% បើធៀបទៅ និងប្រទេសដែលកំពុងអភិវឌ្ឍន៍ដែរ តែពុំមានការបើកចំហពាណិជ្ជ-កម្ម ដោយភាពក្រីក្រមានការកើនឡើងចំនួន ៤% ទៅវិញក្នុងអំឡុងពេលដូចគ្នា។ ជាមួយគ្នាផងដែរ ភាពក្រីក្រជាសកល (Global poverty) មានការថយចុះ ហើយមនុស្សប្រហែល ២០០ លាននាក់ បានចុះឈ្មោះចូលរៀន និងជីវភាពរស់នៅមានការប្រសើរឡើង ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ។ ជាចុងបញ្ចប់ឯកឧត្តម បានលើក

យកស្ថិតិរបស់ធនាគារពិភពលោក ដែលប៉ាន់ស្មានថា ការដែលលុបរបាំង ពាណិជ្ជកម្មទាំងអស់អាចធ្វើឱ្យចំណូលជាសកល (Global Income) កើនប្រហែល ២.៨ ពាន់កោដ្ឋដុល្លា (USD2.8 Trillion) ក្នុងរយៈពេល ១០ឆ្នាំ ហើយអាចធ្វើឱ្យមានប្រយោជន៍ដល់មនុស្សប្រហែល ៣២០ លាននាក់ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដល់ឆ្នាំ ២០១៥។ ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ ឯកឧត្តមមាន គំនិតសុទិដ្ឋិនិយមថា កម្ពុជានិងបានចំណេញពីការចូលជាសមាជិក WTO ដោយឯកឧត្តមផ្តោតសំខាន់ទៅលើមីក្រូហិរញ្ញវត្ថុ និងជាពិសេសទៅលើការបន្ថយពន្ធនាំចូល（Tariffs）ឱ្យមកនៅកម្រិតអប្បរមា ដែលនាំឱ្យប្រជាពលរដ្ឋទទួលបាននៅសេវា និងទំនិញថោក។ ចំពោះផ្នែកម៉ាក្រូសេដ្ឋកិច្ចវិញនាំឱ្យប្រជាពលរដ្ឋមានការធ្វើ ដូចជា រោងចក្រកាត់ដេរជាដើម។ តែទន្ទឹមនឹងទទួលបានផលប្រយោជន៍ ពី WTO ឯកឧត្តម ក៏បានធ្វើកត់សំគាល់ផងដែលថា កាលណាយើងបើកសេដ្ឋកិច្ចទីផ្សារ គឺនិងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ ជាពិសេសឧស្សាហកម្មក្នុងស្រុក ដែលមានលក្ខណៈជា ឧស្សាហកម្មក្មេងខ្ចីទំហំផលិតនៅមានកម្រិត ។ល។

ឯកឧត្តម គឹម វ៉ាន្ធវិសិដ្ឋ ក៏បានលើកឡើងជាអនុសាសន៍មួយចំនួន ដើម្បីធ្វើឱ្យសេដ្ឋកិច្ចរឹងមាំ និងមានការរីកចម្រើន និងអាចប្រកួតប្រជែងជាមួយ និងបរទេសដូចជា ពង្រឹងសមត្ថភាពប្រកួតប្រជែង បង្កើនការផលិតដើម្បីនាំចេញ ដោយផ្អែកលើធនធានមនុស្ស និងពង្រឹងដើមទុនពង្រឹងរចនាសម្ព័ន្ធច្បាប់ និងប្រពន្ធតុលាការ ជាពិសេសធ្វើយ៉ាងណាឱ្យមានស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ច ជំរុញការវិនិយោគទៅលើវិស័យកសិកម្ម ឬវិស័យផ្សេងទៀត ចៀសវាងការពឹងផ្អែកទាំងស្រុងទៅលើឧស្សាហកម្មកាត់ដេរ ពង្រីកមូលដ្ឋានគ្រឹះក្នុងការនាំចេញ ដោយមិនអាចផ្តោតសំខាន់ទៅលើការនាំចេញសម្លៀកបំពាក់តែមួយមុខបានឡើយ។

**វាគ្មិន ទី ២** ឯកឧត្តម **ឡុច ស៊ាងតារាណា** សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (OBSES) ទីស្តីការគណៈរដ្ឋមន្ត្រី លោកបានបញ្ជាក់ថា តើ WTO មានសារៈសំខាន់យ៉ាងណាចំពោះភាពក្រីក្រ? លោកបានធ្វើការកត់សំគាល់ថា ប្រជាជនកម្ពុជាតិចតួចណាស់ ដែលយល់ច្បាស់ពី WTO មិនថាឡើយតែអ្នកក្រ អាជីវករ និសិត្ស សូម្បីតែក្រសួងស្ថាប័នរបស់រដ្ឋាភិបាលមួយចំនួនក៏ពុំយល់ពី WTO នេះច្បាស់ដែរ លើកលែងតែ មន្ត្រីថ្នាក់ខ្ពស់អ្នកជំនាញ ឬអ្នកដែលសិក្សាលើបញ្ហានេះផ្ទាល់តែប៉ុណ្ណោះ ។ ការកត់សំគាល់នេះគឺឯកឧត្តមចង់បង្ហាញថា បើរដ្ឋមួយមានបំណងអភិវឌ្ឍន៏លើផ្នែកអ្វីមួយ គឺទាមទារការយល់ និងចូលរួមពីសំណាក់ប្រជាជនគ្រប់ជាន់ថ្នាក់ ប្រសិនបើមិនមានការចូលរួមទេ បញ្ហានោះ និងនៅទ្រឹង ឬពុំមានការរីកចម្រើនឡើយ ។

បន្ទាប់មកឯកឧត្តមបានធ្វើការបង្ហាញពីអ្វីទៅ WTO? ហើយថាហេតុអ្វីកម្ពុជាត្រូវចូល WTO? តើមានការពាក់ព័ន្ធ ខ្លះទៅលើផលប៉ះពាល់របស់ WTO ទៅលើការកាត់ បន្ថយភាពក្រីក្រ? ។

១- អ្វីទៅ WTO ទាក់ទងចំណុចនេះ ឯកឧត្តមពុំបានធ្វើការបកស្រាយអ្វីអោយវែងឆ្ងាយឡើយ ព្រោះមានវាគ្មិនមុនៗបានលើកឡើងច្រើនរួចមកហើយ ដោយឯកឧត្តមគ្រាន់តែលើកឡើងជាបន្ថែមថា WTO កើតចេញពីការចរចារវាងរដ្ឋាភិបាលច្រើនបង្កើតជាកិច្ចព្រមព្រៀងរបបពាណិជ្ជកម្មមួយ ។

២- ហេតុអ្វីកម្ពុជាត្រូវចូលជាសមាជិក WTO ? ជាមួយគំនិតផ្ទាល់ ឯកឧត្តមមានសុទិដ្ឋិនិយម និងការចូលជាសមាជិក WTO ដោយបានលើឡើងថា ការចូលរបស់កម្ពុជាទៅក្នុង WTO ធ្វើឱ្យយើងទទួលបាននៅផលប្រយោជន៏ជាច្រើន ដូចជា ធានាបាននូវសន្តិភាពចៀសវាងបាន នូវសង្គ្រាមមហន្តរាយដោយឈរលើមូលដ្ឋានពាណិជ្ជកម្ម

(ឧទាហរណ៍ព្រឹត្តការណ៍វាយស្ថានទូតថៃ នាខែមករា ឆ្នាំ ២០០៣ យើងអាចចៀសបាន នូវទំនាស់ការទូត និងសង្គ្រាមប្រដាប់អាវុធ ដោយឈរលើមូលដ្ឋានពាណិជ្ជកម្ម ព្រោះថា កម្ពុជាជាទីផ្សារផលិតផលរបស់ថៃ ទំនិញថៃនាំចូលកម្ពុជាក្នុងមួយថ្ងៃ ប្រហែល ១៦០លានបាត ដូច្នេះ ប្រសិនបើថៃបង្កទំនាស់ជាមួយកម្ពុជា និងធ្វើឱ្យប៉ះពាល់ដល់ ការផលិតនៅស្រុកថៃ) ។ ពាណិជ្ជកម្មធ្វើឱ្យជីវិតរស់នៅមានការប្រសើរឡើង កាត់បន្ថយ ការចំណាយដោយសារពាណិជ្ជកម្ម ផ្តល់ជម្រើសជាច្រើនក្នុងការជ្រើសរើសទំនិញ ព្រោះ មានប្រភពនាំចូលច្រើន នាំឱ្យចំណូលគ្រួសារកើនឡើង (ការធ្វើពាណិជ្ជកម្មសេរីនាំឱ្យ មានការផ្លាស់ប្តូរទំនិញ ពីកន្លែងផលិតមួយទៅកន្លែងផលិតមួយ) ជំរុញសេដ្ឋកិច្ចឱ្យមាន ការអភិវឌ្ឍ ប្រកបដោយសក្តានុពលខ្លាំង កាត់បន្ថយអំពើពុករលួយ (ការបើកចំហ ពាណិជ្ជកម្ម នាំឱ្យមានការប្រកួតប្រជែងខាងការផលិត និងកាត់បន្ថយពន្ធនាំចូល ដែលជា កន្លែងប្រព្រឹត្តអំពើពុករលួយ) ។

៣- ផលប៉ះពាល់របស់ WTO ទៅលើការកាត់បន្ថយភាពក្រីក្រ លើបញ្ហានេះ ឯកឧត្តមបញ្ជាក់ថា ប្រជាជនកម្ពុជា ៨៥% គឺជាកសិករក្រីក្ររស់ពឹងផ្អែកលើវិស័យ កសិកម្ម ហើយក្នុងចំណោមនេះ ប្រហែលជិត ៤០% រស់ក្រោមបន្ទាត់នៃភាពក្រីក្រ ដែលពុំបានយល់ដឹងពីអ្វីទៅ WTO ហើយ តើ WTO មានទិសដៅយ៉ាងណា ។ ឯកឧត្តម បានសង្កត់ធ្ងន់ថា កត្តានេះអាចនាំឱ្យនយោបាយរបស់រដ្ឋាភិបាល ស្តីពី WTO ទទួល បរាជ័យ ឬពុំអាចដើរទៅមុខបាន ។

ជាអនុសាសន៍ ឯកឧត្តមបានលើកឡើងថា គួរជំរុញឱ្យមានការផ្សព្វផ្សាយ WTO ឱ្យដល់ស្រទាប់ប្រជាពលរដ្ឋ អាជីវករ បង្កើតវគ្គបណ្តុះបណ្តាលស្តីពី WTO ដល់ មន្ត្រីរាជការ ។

**វាគ្មិនទី ៣** ឯកឧត្តមអ៊ុង ចន្ទ័តារារិទ្ធ សមាជិកក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (OBSES) ទីស្ដីការគណៈរដ្ឋមន្ត្រីបានលើកឡើងថា ក្នុងចំណោមសមាជិកជិត១៥០ របស់អង្គការ WTO កម្ពុជាទើបតែបានចូលទេ។ ឯកឧត្តមបានសង្កត់ធ្ងន់ទៅលើការកសាងធនធានមនុស្សឱ្យមានសមត្ថភាព ដើម្បីបម្រើអង្គភាព ជាពិសេសស្នើឱ្យស្ថាប័នអប់រំ និស្សិតយកចិត្តទុកដាក់ធ្វើការបណ្ដុះបណ្ដាល និងខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវ ធ្វើយ៉ាងណាឱ្យមានគុណភាពអាចប្រកួតប្រជែង ជាមួយបណ្ដាលធនធានមនុស្សនៅប្រទេសជឿនលឿនបាន។ ឯកឧត្តមបានបន្ថែមទៀតថា កាលណាយើងមានចំណេះដឹងប្រកបដោយសមត្ថភាព យើងអាចផ្ដល់ជាយោបល់ អនុសាសន៍ ឬតម្រង់ទិសដៅជួយដល់ប្រទេសជាតិ ហើយអាចប្រកួតប្រជែងជាមួយធនធានមនុស្សនៅបណ្ដាលប្រទេសផ្សេងៗ និងទទួលបាននូវប្រាក់បៀវត្សរ៍ខ្ពស់ ដែលជាចំណែកមួយដល់ការកាត់បន្ថយភាពក្រីក្រផងដែរ។ ជាមួយគ្នានេះដែរ លោកក៏បានលើកឡើងពីកម្មវិធីនយោបាយរបស់រដ្ឋាភិបាលកម្ពុជាឈ្មោះ "ការសាងសមត្ថភាពខាងសេដ្ឋកិច្ច និងវិស័យសាធារណៈ (EPSCB)" ដែលបានខិតខំដើម្បីធ្វើការបណ្ដុះបណ្ដាលមន្ត្រីតាំងពីថ្នាក់ក្រោមមធ្យម និងកំពូលតាមរយៈក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (Council for Administrative Reform) បង្កើតវគ្គបណ្ដុះបណ្ដាលលើកម្មវិធី បី :

ទី ១- ថ្នាក់ជំនាញ (PDP)

ទី ២- ថ្នាក់ដឹកនាំគ្រប់គ្រង (MDP)

ទី៣- ថ្នាក់ដឹកនាំកំពូល (AEP)

ជាចុងក្រោយឯកឧត្តមបានផ្ដល់ជាអនុសាសន៍លើការបណ្ដុះបណ្ដាលជំនាញ និងពង្រឹងគុណភាពអប់រំប្រកបដោយសមត្ថភាពដល់មន្ត្រីរាជការ និងនិស្សិតកម្ពុជាអាចចូលបម្រើការងារក្នុងស្ថាប័នកំពូលរបស់ជាតិ ជាពិសេសស្ថាប័នអង្គការអន្តរជាតិធំៗ ដូចជា

WTO ជាដើម ព្រោះចៀសវាងការជួលបុគ្គលិកបរទេសមកបម្រើការនៅស្រុកខ្មែរ។ **ឯឧត្តម** បានសង្កត់ធ្ងន់ទៅលើការកសាងធនធានមនុស្សឱ្យទៅជាអ្នកមានសមត្ថភាព ចេះធ្វើការជាក្រុមជាអ្នកគ្រប់គ្រងល្អ និងអ្នកដឹកនាំដ៏អស្ចារ្យ។

**វាគ្មិនទី ៤** ឯកឧត្តម **ម៉ាន់ ឈឿន** អភិបាលរងរាជធានីភ្នំពេញ ជាប្រធានមូលនិធិអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រទីក្រុង លោកបានសង្កត់ធ្ងន់ទៅលើភាពក្រីក្ររបស់ប្រជាជននៅក្នុងទីក្រុងភ្នំពេញ ដែលតាំងលំនៅលើផ្លូវសាធារណៈ តាមដងទន្លេ តាមផ្លូវរថភ្លើង តាមដំបូលផ្ទះ តាមសួនច្បារដែលតាំងពី ឆ្នាំ ១៩៩៩ មានតែ ៣៧៥ សហគមន៍ ហើយបច្ចុប្បន្នមានរហូតដល់ ៥៦៩ សហគមន៍។ គោលការណ៍របស់សាលាក្រុង គឺជម្លៀសប្រជាជនតាមសំណង់អនាធិតេយ្យឱ្យទៅរស់នៅជាយក្រុង។ រហូតដល់ឆ្នាំ ២០០៣ គោលការណ៍រដ្ឋាភិបាលបានដាក់ចុះ គឺអភិវឌ្ឍន៍នៅនឹងកន្លែងផ្ទាល់តែម្តងដោយផ្តល់ជាឥណទានសម្រាប់ប្រជាពលរដ្ឋក្នុងកម្រិតការប្រាក់ទាបបំផុត។ លោកបានលើកឡើង ពីតួរលេខរបស់ក្រសួងអប់រំ ដែលបង្ហាញថាកុមារនៅរាជធានី ភ្នំពេញមានអត្រាចុះឈ្មោះចូលរៀនកើនឡើង ហើយលោកក៏បានបញ្ជាក់ ដោយក្តីមោទនភាពផងដែលថា អ្នកក្រនៅក្នុងទីក្រុងភ្នំពេញ មិនមានជីវភាពរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រឡើយ។ ចំពោះសមាជិកភាពកម្ពុជាក្នុង WTO វិញ លោកបញ្ជាក់ថា កម្ពុជាជាប្រទេសក្រីក្រ ដែលការប្រកួតប្រជែងមានភាពខុសគ្នាយ៉ាងខ្លាំងជាមួយសមាជិកអ្នកមាន។ ជាចុងបញ្ចប់លោកបានលើកជាអនុសាសន៍មួយចំនួន ដូចជាត្រូវពង្រឹងខ្លួនត្រូវរៀនធ្វើការប្រកួតប្រជែងក្នុងស្រុកជាមុនសិន។

**វាគ្មិនទី ៥** លោកស្រី **ហ្វូត រតនៈ នាយិកាវេទិកាទូទៅនៃកម្ពុជា** លោកស្រីបានបញ្ជាក់ពីមូលហេតុ នៃភាពក្រីក្ររបស់ប្រជាជនគឺមកពីភាពអវិជ្ជាដែលបន្សល់ ពីសង្គ្រាម។ ការកើនឡើងនៃភាពអត់ការងារធ្វើ ជាពិសេសការលក់នូវទ្រព្យសម្បត្តិដែល

ខ្លួនមានបន្តិចបន្តួច ដូចជាដីធ្លី ភាពក្រីក្រកើតឡើងពីអំពើពុករលួយ ការគ្រប់គ្រងគ្មានតម្លាភាព ម្យ៉ាងទៀតក៏មានការកេងប្រវ័ញ្ចនីពីបរទេសផងដែរ ទៅលើការនាំចូលទំនិញព្រោះតែកម្ពុជា គ្មានសមត្ថភាពផលិត។ លោកស្រីបានលើកឡើងពីគោលការណ៍របស់ WTO មាន ៤ សំខាន់ គឺ WTO មានច្បាប់ និងបញ្ញត្តិ ទាំងឡាយដែលមានតម្លាភាព មិនមានការរើសអើង គឺសមាជិកនីមួយៗមានសិទ្ធិស្មើគ្នាក្នុងការទទួលនូវបញ្ញត្តិ ឬច្បាប់ដែល WTO ដាក់ចេញមានប្រព្រឹត្តកម្ម ពិសេសចំពោះបណ្តាលប្រទេសកំពុងអភិវឌ្ឍន៍ ការមិនប្រើប្រាស់ប្រព័ន្ធគយសម្រាប់ការការពារទីផ្សារ និងការធ្វើសេរីភាវូបនីយកម្មទីផ្សារជាជំហានៗ។

ចំពោះផលប៉ះពាល់របស់ WTO មកលើការកាត់បន្ថយភាពក្រីក្រ គឺថាកម្ពុជាពុំទាន់ត្រៀមខ្លួន និងមានយុទ្ធសាស្ត្រសម្រាប់ចូល WTO។ ម្យ៉ាងវិញទៀតឧស្សាហកម្មយើងនៅក្មេងខ្ចី ហើយមានទំហំតូចងាយនឹងប៉ះពាល់ស្របពេលដែលយើងពុំទាន់មានផលិតផលណាសម្រាប់ដាក់ចូលទៅក្នុងទីផ្សារ ដើម្បីធ្វើការប្រកួតប្រជែងលើសពីនេះទៀត ការអនុវត្តច្បាប់របស់យើងនៅមានកម្រិត។ តែទន្ទឹមភាពអវិជ្ជមានក៏មានផលវិជ្ជមានផងដែរ ដល់យើងដែលជាប្រទេសក្រីក្រក្នុងការខិតខំបង្កើនគុណភាពផលិតផលរិះរកមធ្យោបាយ ដើម្បីស្វែងរកការងារសម្រាប់ពលរដ្ឋ និងរិះរកគំនិតកែច្នៃវត្ថុធាតុ ដើមកម្រិតបាននៅគុណភាពដើម្បីដាក់ចូលទៅក្នុងទីផ្សារអន្តរជាតិ ដែលនាំឱ្យបង្កើតការងារធ្វើសម្រាប់ពលរដ្ឋ និងនាំឱ្យមានចំណូលគ្រួសារកើនឡើង និងអាចកាត់បន្ថយភាពក្រីក្របានមួយចំណែក។

ជាអនុសាសន៍ លោកស្រីបានលើកឡើងថា គួរបង្កើនសមត្ថភាពជំនាញបង្កលក្ខណៈងាយស្រួលដល់ការធ្វើពាណិជ្ជកម្មដល់ពាណិជ្ជករ ក្នុងស្រុកបង្កើនយុទ្ធសាស្ត្រដល់ការផលិតសម្រួលបែបបទក្នុងការនាំចេញ និងការចំណាយ ។ល។

## III- មតិពិភាក្សារួម :

បន្ទាប់ពីសុន្ទរកថារបស់វាគ្មិនកិត្តិយស បានបញ្ចប់ការធ្វើអត្ថាធិប្បាយផ្ទាល់ខ្លួនលើប្រធានបទរួចមក អង្គវេទិកាទាំងមូលបានបើកកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ផ្តល់មតិ និងការពន្យល់ខ្លះៗ ដូចខាងក្រោមៈ

អំពីកង្វល់នៃការឡើងថ្លៃប្រេង ឯកឧត្តម គឹម រត្នវិសិដ្ឋ បញ្ជាក់ថា រឿងប្រេងឡើងថ្លៃនេះ ជារឿងទូទៅ ដែលកើតមាននៅលើពិភពលោក មិនចំពោះតែកម្ពុជានោះទេ។ បន្ថែមលើបញ្ហាប្រេងឡើងថ្លៃ លោកបណ្ឌិត ចាប សុថារិទ្ធ បានលើកឡើងថាហេតុអ្វីបានជាប្រេងនៅប្រទេសជិតខាងមានតម្លៃថោកជាងកម្ពុជា ព្រោះថារដ្ឋាភិបាលគេបានយកលុយជាតិទៅបំពេញបន្ថែម ដើម្បីរក្សាតម្លៃប្រេងឱ្យមានស្ថិរភាព។ តួយ៉ាងដូចជា រដ្ឋាភិបាលថៃបានចំណាយថវិកាជាតិជិត ២០០០ លានដុល្លារ ហើយវៀតណាមជាង ១២០០ លានដុល្លារ ដើម្បីទប់តម្លៃប្រេងក្នុងប្រទេសឱ្យមានស្ថិរភាព។ ម្យ៉ាងទៀតក្រុមហ៊ុនប្រេងដែលមាននៅក្នុងប្រទេសរបស់គេ គឺរដ្ឋមានភាគហ៊ុនយ៉ាងតិច ៥១ %។ ដោយឡែកកម្ពុជានៅក្រមិនអាចបំពេញបន្ថែមដូចប្រទេសគេបានទេ។

ចំពោះការពង្រីកទីផ្សារ ដូចជាទីប្រជុំជនប៉ោយប៉ែត ឯកឧត្តម អ៊ុង ចន្ទ័តារារិទ្ធ លើកឡើងថា តំបន់ប៉ោយប៉ែត ជាតំបន់ព្រំដែន ដូច្នេះទីផ្សារមានការប្រទាញប្រទង់គ្នាប្រសិនបើខាងណាអាចលក់ផលិតបានថ្លៃទំនោរ និងទៅរកខាងនោះ។ លើករណីនេះដែរលោកស្រី ហួត រតនៈ បានលើក ឡើងពីតំបន់ប៉ោយប៉ែត ថាហេតុអ្វីបានប្រជាជនខ្មែរមិននាំគ្នាលក់លើដីខ្មែរ? ព្រោះដោយសារតែលើដីខ្មែរគ្មានសុវត្ថិភាព សំបូរចោរលួច ហើយម្យ៉ាងទៀត អតិថិជនភាគច្រើន គឺជាជនជាតិថៃ។ ដោយសារនៅទឹកដីថៃគេអាចរក្សាសុវត្ថិភាពបានល្អជាងខ្មែរ ហើយនៅតាមផ្លូវឆ្លងកាត់ព្រំដែន គេដាក់ផ្លាកថា ពលរដ្ឋថៃ

ដែលឆ្លងព្រំដែនចូលកម្ពុជាមិនធានាសុវត្ថិភាពជូនឡើយ។ ដូច្នេះ គ្រាន់តែករណីនេះ ពលរដ្ឋគេញញើត មិនឆ្លងដែនចូលដីខ្មែរឡើយ ជាហេតុធ្វើឱ្យខ្មែរ ត្រូវតែបង្ខំចិត្តចូលទៅលក់ក្នុងដីថៃ។

ចំពោះការយកចំណេញជាអតិបរមារពីសមាជិក WTO ថាតើយើងត្រូវធ្វើដូម្តេច? ឯកឧត្តម ម៉ាន់ ឈឿន លើកឡើងថា ដោយផ្អែកលើសមត្ថភាព និងទីតាំងជាក់ស្តែង យើងមិនអាចឈានមួយជំហានឱ្យស្មើនឹងគេតែម្តងបានទេ គឺត្រូវធ្វើដោយសន្សឹម១ ហើយត្រូវរួមគ្នាអភិវឌ្ឍន៍។

មានសំណួរមួយលើកឡើងថា ក្រោយការចូល WTO កម្ពុជា ហាក់ដូចជាគ្មានការរីកចម្រើនហើយថា តើកម្ពុជាស្ថិតនៅទីណាក្នុង WTO? លើបញ្ហានេះ លោកបណ្ឌិត ចាប សុថារិទ្ធ បញ្ជាក់ថាកម្ពុជា ទើបតែក្លាយជាសមាជិក WTO មិនទាន់ដល់មួយឆ្នាំផងទេ ។ ពិតមែនតែយើងនិយាយពី WTO អស់ច្រើនឆ្នាំមកហើយក៏ដោយ គឺស្ថិតនៅក្នុងដំណាក់កាលនៃការចរចាតែប៉ុណ្ណោះ។

ម្យ៉ាងទៀត យើងក៏ទើបតែនឹងទទួលបានសន្តិភាពពេញលេញនៅឆ្នាំ ១៩៩៨ នេះដែរទេ ដូច្នេះ មិនទាន់មានអ្វីគួរឱ្យកត់សំគាល់ចំពោះការរីកចម្រើន លើផលប៉ះពាល់នៅឡើយទេ លើកលែងតែការអភិវឌ្ឍផ្នែកនយោបាយ ការទូត និងក្របខណ្ឌច្បាប់។ ជាមួយគ្នានេះដែរ ឯកឧត្តម អ៊ុង ចាន់តារារិទ្ធ ក៏បន្ថែមថា ក្នុងរយៈពេលជិតមួយឆ្នាំដែលកម្ពុជាចូលជាសមាជិក WTO នេះ រដ្ឋាភិបាលធ្វើការងារបានច្រើនណាស់ទាក់ទងនិងច្បាប់ ដូចជារៀបចំសេចក្តីព្រាងច្បាប់សំខាន់១ រួមមានច្បាប់ដឹកជញ្ជូន ច្បាប់ដីធ្លី ច្បាប់ក្ស័យធន ......។ល។

## IV- **សេចក្តីសន្និដ្ឋាន :**

ការចូលជាសមាជិក WTO ពិតជាមានឥទ្ធិពលល្អច្រើន ដល់ការកាត់បន្ថយភាពក្រីក្រ។ ព្រោះ WTO គឺជាឧបករណ៍ជំរុញឱ្យពាណិជ្ជកម្មរីកចម្រើន និងផ្តល់ការងារជាច្រើនដល់ប្រជាជន។

អង្គវេទិកាទី ៦ នេះ បានប្រព្រឹត្តទៅដោយជោគជ័យ ដោយមានការចូលរួមបញ្ចេញមតិ និងការពិភាក្សាយ៉ាងសកម្មក្នុងស្មារតីសាមគ្គីភាព និងរិះគន់ក្នុងន័យ ស្ថាបនា ដើម្បីរួមចំណែកកសាងប្រទេសយើងឱ្យសំបូរណ៏រុងរឿងទៅអនាគត។

# របាយការណ៍សង្ខេបនៃវេទិកា ទី ៧

## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ការប្រើប្រាស់ អង្គការពាណិជ្ជកម្មពិភពលោក ជាឧបករណ៍ជំរុញកំណែទម្រង់

## I- សេចក្តីផ្តើម

វេទិកា ទី ៧ ស្តីពី "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ការប្រើប្រាស់ WTO ជាឧបករណ៍ជំរុញកំណែទម្រង់"។ ប្រធាន និងអ្នកសម្របសម្រួលដោយលោកបណ្ឌិត **ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព។ វេទិកានេះ មានវាគ្មិនកិត្តិយសពីររូប គឺ (១)-ឯកឧត្តម **ខៅ ឃុនលី** អគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី និង(២)-លោក **ហៀវ វាស្នា** នាយកគ្រប់គ្រងមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម។ ក៏ប៉ុន្តែ លោក ហៀវ វាស្នា មានធុរៈជាចាំបាច់ត្រូវអាក់ខានក្នុងការចូលរួម តែលោកក៏បានផ្ញើបទអន្តរាគមន៍របស់លោកចែកជូនសមាជិក សមាជិកានៅក្នុងវេទិកា នេះដែរ។

មុនបើកវេទិកាលើកទី ៧ លោកបណ្ឌិត ចាប សុថារិទ្ធ បានផ្តួចផ្តើមបំផុសគំនិតដល់ជាសមាជិក សមាជិកានៃអង្គពិភាក្សា ពីកាលប្បវត្តិខ្លះរបស់កម្ពុជា រយៈពេល ១០ ឆ្នាំ ក្នុងការសុំចូលជាសមាជិក WTO។ ដំណាក់កាលនីមួយៗ ពោលគឺចាប់តាំងពី ឆ្នាំ ១៩៩៣ ដែលរាជរដ្ឋាភិបាលមានគោលបំណងរបស់ខ្លួនក្នុងការក្លាយជាសមាជិកWTO។

នៅថ្ងៃ ទី ០៨ ធ្នូ ឆ្នាំ ១៩៩៤ ប្រទេសកម្ពុជាបានដាក់ពាក្យជាផ្លូវការសុំចូលជាសមាជិក WTO ។ បន្ទាប់មកក្រុមការងារសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃសមាជិកភាពរបស់កម្ពុជា បានបង្កើតនៅ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ជាមួយឯកអគ្គរាជទូតអ៊ីតាលី ដែលជាប្រធានក្រុមការងារ WTO ។ ក្រុមចរចារបស់កម្ពុជា ស្តីពី WTO បានបង្កើតឡើងដោយអនុក្រិត្យរបស់រាជរដ្ឋាភិបាល (លេខ ៥៤ សសរ ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០០១) ស្តីពី បញ្ហាដែលទាក់ទងនឹងគោលនយោបាយសេរីភាវូនីយកម្មពាណិជ្ជកម្ម ។

តាមការពិតកម្ពុជាបានដាក់ជូននូវអនុស្សរណៈ ទៅ WTO នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលជាជំហានដ៏មានសារៈសំខាន់មួយឆ្ពោះទៅរកការធានាសមាជិកភាពនេះ ក្នុងស្ថាប័នពាណិជ្ជកម្មពិភពលោក ។

ចុងក្រោយ សមិទ្ធផលដែលកម្ពុជាទទួលបាននោះគឺ **កម្ពុជា** និង **នេប៉ាល់** បានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក នៅ ថ្ងៃទី ១១ កញ្ញា ឆ្នាំ ២០០៣ នៅក្នុងសន្និសីទថ្នាក់ រដ្ឋមន្ត្រី លើកទី ៥ នាទីក្រុងកានគុណ ប្រទេសម៉ិចស៊ិកូ ក្នុងឋានៈជាប្រទេសក្រីក្របំផុតដំបូង ក្នុងចំណោមប្រទេសក្រីក្រ របស់សមាជិក WTO នេះ ។

## II- **ទស្សនៈវាគ្មិន និងមតិពិភាក្សា** :

ក-ទស្សនៈវាគ្មិន :

ទាក់ទងទៅនឹងបញ្ហា WTO ឯកឧត្តម **ខៅ ម៉ុងលី** បានបញ្ជាក់ថា យើងត្រូវតែធ្វើកំណែទម្រង់ជាច្រើន ដូចជាកំណែទម្រង់ច្បាប់ និងតុលាការ កំណែទម្រង់យោធា នគរបាល កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ដីធ្លី ព្រៃឈើ . . .។ល។ លើសពីនេះទៀត គួរតែបង្កើតស្ថាប័នមួយចំនួន

បន្ថែមទៀត ដើម្បីពង្រឹង និងធានាវិស័យពាណិជ្ជកម្មយើងឱ្យមានស្តង់ដារអន្តរជាតិ រួមមានតុលាការពាណិជ្ជកម្ម តុលាការរដ្ឋបាលជាដើម។ កំណែទម្រង់រដ្ឋបាល គួរតែធ្វើការកែសម្រួលប្រព័ន្ធរដ្ឋបាលបច្ចុប្បន្នឱ្យមានអភិបាលកិច្ចល្អ កាត់បន្ថយភាពអសកម្មក្នុងជួររដ្ឋបាល ពោលគឺប្រព័ន្ធនៃការផ្តល់សេវា (សេវាបែបគួកជេរ) សំដៅយ៉ាងណាឱ្យប្រជាពលរដ្ឋ (ប្រជាជនកម្ពុជា អ្នកវិនិយោគ ជនបរទេសស្នាក់នៅកម្ពុជា ដោយស្របច្បាប់) មានភាពប្រសើរជាងមុន។

ឯកឧត្តមបាន លើកយកទិសដៅជាយុទ្ធសាស្ត្របួនចំណុចរបស់រដ្ឋាភិបាល ស្តីពី "កំណែទម្រង់រដ្ឋបាលសាធារណៈ" មកធ្វើការបង្ហាញជូន សមាជិកស មាជិកាចូលរួម។

***ទី១-កែលម្អប្រព័ន្ធសេវា*** **:** ត្រូវលុបបំបាត់សេវាគ្មានតម្លាភាព (យកចិត្តទុកដាក់ចំពោះតែអ្នកមានប្រាក់ ព្រងើយកន្តើយចំពោះប្រជាជនក្រីក្រ ឬហៅថាសេវាបែបរូបភាព) បំបាត់ទស្សនៈដែលយល់ថាអ្នកផ្តល់សេវា គឺជាអ្នកមានអំណាច និងអ្នកទទួលសេវា ត្រូវតែបង់ប្រាក់ចំពោះអ្នកមានអំណាចតាមឋានានុក្រម។ ធ្វើការបែងចែកឱ្យដាច់ពីគ្នារវាងសេវាទ្រទ្រង់ និងសេវាជូនប្រជាពលរដ្ឋ (ការឆ្លងឯកសារពីរដ្ឋបាលមួយទៅរដ្ឋបាលមួយទៀត ពុំមែនជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋទេគឺជាកិច្ចការផ្ទៃក្នុងរដ្ឋបាល)។ កាត់បន្ថយការិយាល័យធិបតេយ្យ បង្កើតឱ្យមានច្រកចេញចូលតែមួយ កាត់បន្ថយរយៈពេលបន្ថយតម្លៃសេវា (បើប្រជាពលរដ្ឋមានបំណងបើកអាជីវកម្មគាត់គ្រាន់តែដាក់ពាក្យសុំសិទ្ធិបើកអាជីវកម្ម នៅក្រុមប្រឹក្សាអភិវឌ្ឍន៍តែមួយកន្លែងគត់ មិនបាច់រត់ការទៅក្រសួងពាណិជ្ជកម្ម ទៅក្រសួងសុខាភិបាល ទៅប៉ូលីសអគ្គិភ័យ . . . ។ល។ នោះទេ ហើយគាត់ចាំទទួលលិខិតផ្តល់សិទ្ធិបើកអាជីវកម្ម ពីក្រុមប្រឹក្សាអភិវឌ្ឍន៍វិញតែប៉ុណ្ណោះ)។ ពង្រឹងសេវាតាមបែបរូបភាព ក្រុមហ៊ុនរដ្ឋ ឬសហគ្រាសសាធារណៈ។ សេវា

មួយចំនួនគួរប្រគល់ឱ្យឯកជនគ្រប់គ្រង ដូចជាក្រុមហ៊ុនចំការកៅស៊ូ វិស័យទូរគមនាគមន៍ជាដើម . . . .។ល។

**ទី ២- ការលើកទឹកចិត្តមន្ត្រី ដែលមានស្នាដៃល្អក្នុងការបំពេញការងារ**

មានពីរចំណុច :

***១-ការរៀបចំបៀវត្សរ៍*** គោលនយោបាយរបស់រដ្ឋាភិបាល ទាក់ទងនឹងការរៀបចំបៀវត្សរ៍ ឯកឧត្តម បានលើកឡើងថា ក្រោយឆ្នាំ ២004 មានគម្រោងដំឡើងពី ១0% ទៅ ១៥% តែឆ្នាំនេះបានឡើងលើស ១៥ % ការឡើងមានពីរដំណាក់ **ទី១** នៅខែ មករា ឆ្នាំ ២00៥ បានដំឡើង ១៥ % បៀវត្សរ៍មូលដ្ឋាន **ទី២** នៅខែសីហាថ្មីៗ នេះមានការដំឡើងប្រាក់បំណាច់មុខងារប្រមាណ ២0% ទៀត។ សព្វថ្ងៃនេះរដ្ឋាភិបាល បានផ្លាស់ប្តូរប្រព័ន្ធបៀវត្ស (ការដំឡើងបៀវត្សរ៍) ដោយផ្តោតទៅលើឋានន្តរសក្តិរបស់មន្ត្រី (កន្សោមអាទិភាព) ដែលពីមុនមានតែ ២ កាំ តែបច្ចុប្បន្នមានរហូតដល់ ១៤ កាំ ហើយដំណើរការនេះចាប់អនុវត្តពីឆ្នាំ ២00២ រហូតមកដល់ឥឡូវមានរយៈពេលជាង ៣ ឆ្នាំ។ ដោយសាររដ្ឋាភិបាលគ្មានថវិកាគ្រប់គ្រាន់សម្រាប់ដំឡើងជូនមន្ត្រីរាជការគ្រប់ប្រភេទក្នុងពេលព្រមគ្នាបាន ដូច្នេះ រាជរដ្ឋាភិបាលបានចាប់រៀបចំប្រព័ន្ធថ្មី ដោយអនុវត្តពីថ្នាក់លើចុះមកក្រោមគិតចាប់ពីរដ្ឋសភា បន្ទាប់មករដ្ឋាភិបាល ថ្នាក់អនុរដ្ឋលេខាធិការ បន្ទាប់មកប្រធាននាយកដ្ឋាន ហើយបច្ចុប្បន្នអនុវត្តបានមកដល់ថ្នាក់អនុប្រធាននាយកដ្ឋានប្រធានមន្ទីរខេត្តក្រុង។ ប្រសិនបើឆ្នាំក្រោយរដ្ឋាភិបាលមានថវិកាគ្រប់គ្រាន់ និងបន្តអនុវត្តមកដល់ប្រធានការិយាល័យ និងអនុប្រធានការិយាល័យទៀត។ ចំពោះប្រាក់បំណាច់ មុខងារឯកឧត្តមបានបញ្ជាក់ថា យោងទៅលើប្រសិទ្ធិភាពការងារផ្ទាល់អតីតភាពក្របខ័ណ្ឌផ្ទាល់ខ្លួន។

***២-គ្រប់គ្រងការងារមន្ត្រីរាជការឱ្យបានល្អប្រសើរជាងមុន*** : ចាប់ពីខែ កញ្ញា ឆ្នាំ២០០៥ រដ្ឋាភិបាលនឹងប្តូរប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការឡើងវិញទាំងអស់ ដោយប្រទេសប៊្រុយណេ សហការជួយក្នុងកំណែទម្រង់នេះ។ ជំហានដំបូងរៀបចំឱ្យមានកិច្ចប្រជុំអន្តរក្រសួង ដើម្បីឱ្យអន្តរក្រសួងពិនិត្យលើប្រព័ន្ធថ្មីនេះ។ ទាក់ទងនឹងប្រព័ន្ធថ្មីនេះ គឺពិនិត្យឡើងវិញចំពោះមន្ត្រីដែលសកម្មការងារ ដើម្បីងាយស្រួលដល់ការលើកទឹកចិត្ត ជាពិសេសចំពោះការដំឡើងប្រាក់បៀវត្សរ៍។ ការត្រួតពិនិត្យ និងការជ្រើសរើសមន្ត្រីជាភារកិច្ចរបស់ក្រសួងផ្ទាល់ ជាពិសេសនាយកដ្ឋានបុគ្គលិក។

**ទី៣-អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការឱ្យមានជំនាញប្រកបដោយសមត្ថភាព :** ពាក់ព័ន្ធ និងការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការមាន ៦ ចំណុចសំខាន់ៗ ដូចជា

- *អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការឱ្យមានចំណេះដឹងនិងជំនាញច្បាស់លាស់*
- *អភិវឌ្ឍសមត្ថភាពស្ថាប័ន (កន្លែងធ្វើការ) ឱ្យមានលទ្ធភាពគ្រប់គ្រាន់*
- *គ្រប់គ្រងធនធានមនុស្សបណ្តុះស្មារតីឱ្យឈរលើមូលដ្ឋានការងារ*
- *កែលម្អប្រព័ន្ធក្របខណ្ឌគ្រប់គ្រង នៃការងារអភិវឌ្ឍន៍សមត្ថភាព*
- *ក្រមសីលធម៌ និងការទទួលខុសត្រូវរបស់មន្ត្រី*
- *គិតគូរពីហានិភ័យ (ផលប៉ះពាល់ ពីការប្តូរប្រព័ន្ធគ្រប់គ្រង)*

**ទី ៤ - ការប្រើប្រាស់បច្ចេកវិជ្ជាពត៌មាន ( IT ):**

យើងបានប្រើប្រព័ន្ធពត៌មានវិទ្យា សម្រាប់គ្រប់គ្រងចំនួនមន្ត្រីរាជការពីតួរលេខ ពិតប្រាកដ ការចូលនិវត្តន៍ . . . ។ល។ ដើម្បីប្រើថវិកាជាតិឱ្យមានប្រសិទ្ធភាព (ចៀសវាងនៅតែបើកបៀវត្សឱ្យមន្ត្រីខ្មោច ឬមន្ត្រី ដែលមិនបានបំពេញការងារ) ងាយស្រួលដល់ការដំឡើងបៀវត្សបន្ថែម។ ប្រើប្រព័ន្ធពត៌មានវិទ្យាងាយស្រួលដល់ការ

គ្រប់គ្រងរចនាសម្ព័ន្ធថ្នាក់ខេត្តក្រុង ស្រុកខ័ណ្ឌ ឃុំសង្កាត់ ពីកង្វះខាតសាលារៀន កង្វះមន្ត្រីសម្រាប់បម្រើការតាមតំបន់នីមួយៗ ផងដែរ . . . ។ល។

ដូច្នេះ សមិទ្ធផលរបស់រដ្ឋាភិបាលទៅលើដំណើរការនៃការកំណែទម្រង់នេះ ជាពិសេសប្រព័ន្ធសេវា ដែលជាចំណុចមួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងនាំឱ្យមានការទាក់ទាញវិនិយោគធំៗ ដូចជា :

បញ្ហាកែលម្អប្រព័ន្ធសេវា រដ្ឋាភិបាលបានបង្កើត **ច្រកចេញចូលតែមួយ** *(One Stop Service)* ដោយ យកខេត្តពីរធ្វើជាគំរូ គឺខេត្តបាត់ដំបង ខេត្តសៀមរាប និងបានបង្កើតការិយាល័យប្រជាជនផងដែរ។ ប្រសិនបើប្រជាពលរដ្ឋមិនសុខចិត្តចំពោះការយកតម្លៃសេវាខុសប្រក្រតី គឺអាចប្តឹងទៅការិយាល័យនេះបាន។ ហើយនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏មាន *One Stop Service* ដែរ។ ម្យ៉ាងទៀត នៅក្នុងភ្នំពេញ ក៏ត្រៀមយកខ័ណ្ឌពីរមកអនុវត្តន៍ជំហានដំបូងផងដែរគឺ ខ័ណ្ឌចំការមន និងខ័ណ្ឌឫស្សីកែវ។

នៅទីស្តីការគណៈរដ្ឋមន្ត្រីមានជំនាញការ កំពុងតែបង្រៀនមន្ត្រីមកពីគ្រប់ក្រសួងបានជាង ៥០ នាក់ទៅលើការវិភាគមុខងារ និងប្រសិទ្ធិភាពនៃការផ្តល់សេវាផង។ រដ្ឋាភិបាលក៏បានចងក្រងបានបញ្ជី ចំនួន ៣០០ សេវាហើយដែរ។

ជាអនុសាសន៍ប្រសិនបើចង់ឱ្យកម្ពុជា ទទួលបានផលប្រយោជន៍ពីសមាជិក-ភាពក្នុង WTO ឬនយោបាយកាត់បន្ថយភាពក្រីក្រទទួលបានជោគជ័យ គឺត្រូវតែជំរុញការកែទម្រង់ធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ហើយត្រូវធ្វើការបែងចែកកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌។

ខ- មតិពិភាក្សារួម :

ដើម្បីបំផុសឱ្យមានការពិភាក្សាឡើង លោកបណ្ឌិត **ចាប សុថារិទ្ធ** បានសួរបីសំណួរទៅវាគ្មិន :

***សំណួរទី១*** *ហេតុអ្វីបានជានិស្សិតដែលរៀនចេញពីសាលាចង់ចូលបម្រើការងាររាជការជាងក្រុមហ៊ុនឯកជន ឬអង្គការក្រៅរដ្ឋាភិបាល នៅពេលដែលប្រាក់បៀវត្សរ៍មន្ត្រីរាជការទាបជាងក្រុមហ៊ុនឯកជន ឬអង្គការក្រៅរដ្ឋាភិបាល?*

***សំណួរទី២*** *តើមានផលប៉ះពាល់យ៉ាងណា ពេលនិស្សិត ឬមន្ត្រីរាជការមួយចំនួននៅពេលដែលរដ្ឋាភិបាលបញ្ជូនឱ្យទៅរៀនជំនាញ បន្ថែមនៅក្រៅប្រទេសពេលត្រឡប់មកវិញ មិនបានបម្រើក្រសួងស្ថាប័នសាម៉ី បែរជាទៅបម្រើការនៅក្រុមហ៊ុនឯកជន ឬអង្គការក្រៅរដ្ឋាភិបាលវិញ ?*

***សំណួរទី៣*** *ទាក់ទងនឹងកន្សោមអាទិភាព តើមានផលវិបាកយ៉ាងណា នៅពេលមន្ត្រីរាជការមានស្នាដៃល្អ តែមិនបានបម្រើការជិតដល់ ឬពេញម៉ោងជូនក្រសួងត្រូវបានជ្រើសរើសចូលក្នុងកន្សោមអាទិភាព ហើយចំណែកមន្ត្រីដែលធ្វើការគោរពពេលវេលាមិនត្រូវបានជ្រើសរើសចូលក្នុងកន្សោមអាទិភាព?*

**ចំលើយ** ចំពោះកន្សោមអាទិភាព ក៏បានគិតគូរដល់អតីតភាពផងដែររដ្ឋាភិបាល និងដំឡើងឋានន្តរសក្តិដល់ មន្ត្រីដែលមានប្រវត្តិធ្វើការយូរ តែក៏មិនខ្ចប់អ្នកដែលមានស្នាដៃល្អក្នុងការងារដែរ គឺឱ្យកាន់មុខងារប្រសើរជាងមុន។ ទៅថ្ងៃមុខរដ្ឋាភិបាល និងរៀបចំកំណត់ទិសដៅ តើធ្វើការងាររបៀបណារយៈពេលប៉ុន្មាន ហើយលទ្ធផលដូម្តេច ត្រូវដំឡើងឬរើសចូលក្នុងកន្សោមអាទិភាព (ការរើសចូលកន្សោមអាទិភាពទុកភារកិច្ចជូនក្រសួង)។

ចំពោះគោលការណ៍ នៃការជ្រើសរើសមន្ត្រីរាជការចូលក្នុងកន្សោមអាទិភាពគឺតម្រូវឱ្យមានតម្លាភាព និងការទទួលខុសត្រូវផ្ទាល់របស់ក្រសួងស្ថាប័ន (ឆ្លងកាត់គណៈកម្មការវាយតម្លៃរបស់ក្រសួង) ធ្វើការផ្សព្វផ្សាយនូវឈ្មោះ មន្ត្រីរាជការដែលត្រូវបានជ្រើសរើស (ឱ្យមន្ត្រី ចំណុះក្រសួង ដឹងឮ) និងជំរុញសមភាពយែនឌ័រ។

**ចំលើយ** ចំពោះសំណួរពីរទៀត ទី១ និស្សិតចេញពីសាលា មានចំណង់ចំណូលចិត្តបម្រើការងាររដ្ឋ និងទី២ មានជំនាញហើយ (ជំនាញបានមកពីរដ្ឋជំរុញ) រត់ទៅបម្រើការឯកជនបានប្រាក់ខែខ្ពស់ ។

បញ្ហានេះ ឯកឧត្តមបញ្ជាក់ថា សង្គមខ្មែរជាសង្គមគ្រួសារ ខុសពីអឺរ៉ុបដែលគេមានលក្ខណៈ ជាសង្គមបុគ្គល (សង្គមទទួលខុសត្រូវរៀង១ខ្លួន) ត្រង់នេះមានន័យថាក្នុងសង្គមខ្មែរប្រសិនបើ បុគ្គលម្នាក់គាត់ជាមេគ្រួសារ គាត់ត្រូវមានភារៈចិញ្ចឹមក្រុមគ្រួសាររបស់គាត់ ដូច្នេះ គាត់ត្រូវរត់រកការងារណាមួយដែលគាត់មានលទ្ធភាព ហើយទទួលបានប្រាក់ខែខ្ពស់។ ចំពោះអ្នកមានចំណូលចិត្ត បម្រើការងាររាជការហើយ ទទួលប្រាក់ខែទាប គឺអាចជាគ្រួសារធូរធារ មិនខ្វល់ខ្វាយពីបញ្ហាលុយកាក់ តែចង់បានកិត្តិយស (មុខមាត់) ឬអាចស្វែងរកអំណាច (ធ្វើជាខ្នងបង្អែក) សម្រាប់ការពារផលប្រយោជន៍ការធ្វើអាជីវកម្មរបស់ក្រុមគ្រួសារ។ ម្យ៉ាងទៀតឯកឧត្តមសង្កត់ធ្ងន់ថា មនុស្សមួយភាគធំ គាត់មានទស្សនៈថា ការចូលបម្រើរាជការអាចស្វែងរកលាភសក្ការៈ ឬចំណូលក្រៅពីប្រាក់ខែ ដែលអាចក្លាយទៅជាអ្នកមានលុយមានអំណាច។

*សំណួរ-តើពេលណារដ្ឋាភិបាលបំបាត់មន្ត្រីខ្មោចក្នុងជួររដ្ឋបាលឱ្យអស់?*

**ចំលើយ** ឯកឧត្តមលើកឡើងថា កន្លងមករដ្ឋាភិបាលបានលុបបំបាត់បានច្រើនហើយបច្ចុប្បន្នកំពុងតែរៀបចំ បំពាក់បច្ចេកវិទ្យាពតិមានសម្រាប់គ្រប់គ្រងដើម្បីលុបបំបាត់ឱ្យអស់។ ម្យ៉ាងទៀត កំពុងតែជំរុញការងាររដ្ឋបាលឱ្យទៅជាការងារយុទ្ធសាស្រ្ត (លុបបំបាត់ទស្សនៈដែលយល់ថា អ្នកធ្វើការរដ្ឋបាលជាកន្លែងគ្មានលាភសក្ការៈ ដែលបង្ករឱ្យមានការលាក់លៀមមន្ត្រីខ្មោច។ ម្យ៉ាងទៀត រដ្ឋាភិបាលបានរៀបចំសហការជាមួយប្រទេសផ្តល់ជំនួយ ដើម្បីធ្វើស្ថិតិមន្ត្រីរាជការ ដែលចេញទៅបម្រើការនៅតាមអង្គការសង្គមស៊ីវិល ឬតាមអង្គការអន្តរជាតិនានា ...។ល។

*សំណួរ តើរដ្ឋាភិបាលមានគោលការណ៍យ៉ាងណា ដើម្បីរុញផលប្រយោជន៍ពីសមាជិកភាពខ្លួនក្នុង **WTO** ដល់ដៃប្រជាពលរដ្ឋក្រីក្រប្រមាណជាង ៣០% ដែលរស់ក្រោមបន្ទាត់ក្រីក្រ? ហើយតើសព្វថ្ងៃប្រជាពលរដ្ឋទាំងនោះ ទទួលបានប៉ុន្មានភាគរយ?*

**ចំលើយ** ទាក់ទងនឹងសំណួរនេះ លោកបណ្ឌិត ចាប សុថារិទ្ធ បកស្រាយថា ចំពោះផលប្រយោជន៍ ដែលប្រជាពលរដ្ឋទទួលបាន ពេលខ្លះអាចជាផលប្រយោជន៍ដែលមើលពុំឃើញនិងភ្នែក។ ប៉ុន្តែជាទូទៅ គោលការណ៍របស់ WTO ថា ជាកត្តាលីករជំរុញពាណិជ្ជកម្មឱ្យដើរ ធ្វើឱ្យមានការផ្លាស់ប្តូរទំនិញ ជំរុញសកម្មភាពផលិតឱ្យមានការកើនឡើង (ប្រជាពលរដ្ឋអាចជាកម្លាំងផលិត ឬទទួលបានការងារពីការផលិត)។

*សំណួរ-ហេតុអ្វីបានជារដ្ឋាភិបាលមិនដំឡើងប្រាក់បំណាច់មូលដ្ឋាន បែរជាដំឡើង ប្រាក់បំណាច់មុខងារ? តើមានគុណសម្បត្តិ និងគុណវិបត្តិយ៉ាងណាលើបញ្ហានេះ?*

**ចំលើយ** ចំពោះសំណួរនេះ ឯកឧត្តមង៉ោ ហុងលី បកស្រាយថា តាមប្រព័ន្ធថ្មីមានការឡើងប្រាក់បំណាច់ តាមអតីតភាពតាមក្របខ័ណ្ឌផ្ទាល់ខ្លួន និងតាមប្រសិទ្ធិភាពការងារ។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ការឡើងតាមអតីតភាព ជាប្រព័ន្ធអាជីពនៅពេលក្លាយខ្លួនជាមន្ត្រីរាជការ ទោះបីអត់ការងារធ្វើ ក៏នៅតែធានាឱ្យដែរ តែមានការគោរពវិន័យធ្វើយ៉ាងណាកុំឱ្យតែមានការពិន័យ។ ការឡើងនេះអាចធ្វើ២ ឬ៣ ឆ្នាំម្តង រហូតដល់កាំទី ១ ហើយប្រសិនបើមានស្នាដៃ និងឡើងឋានន្តរសក្តិ ដែលនាំឱ្យទទួលបាននូវប្រាក់បំណាច់មុខងារ។ ម្យ៉ាងវិញទៀត ប្រសិនបើដំឡើងប្រាក់បៀវត្សរ៍មូលដ្ឋាន គឺថាមន្ត្រីរាជការមានចំនួនច្រើន ហើយអ្នកសកម្មការងារ អ្នកមានស្នាដៃល្អទទួលបានស្មើ និងមន្ត្រីខ្ចោច ឬស្មើ និងមន្ត្រីដែលមិនបានបម្រើការងារសកម្ម។

*សំណួរ- តើរដ្ឋាភិបាលមានគោលការណ៍ផ្សព្វផ្សាយបែបណា ចំពោះការដំឡើងឋានន្តរសក្តិមន្ត្រីរាជការនៅពេលដែល ៩៥ % នៃមន្ត្រីរាជការតាមស្ថាប័នរបស់រដ្ឋមិន*

*ទាន់របៀបចំត្រឹមត្រូវតាមមុខងារ? ហើយគ្រូបង្រៀនដែលបង្រៀន ៧ ទៅ ៨ ឆ្នាំ តែស្ថិតនៅកាំទាបដដែល?*

**ចំលើយ** ទាក់ទងនិងការផ្សព្វផ្សាយឯកឧត្តមបញ្ជាក់ថា បានធ្វើការណែនាំរួចហើយ។ ក្រសួងសុខាភិបាលបានធ្វើមុនគេ និងបញ្ចប់មុនដាច់ ឆ្នាំ ២០០៥ ក្រសួងអប់រំក៏បានណែនាំឱ្យធ្វើដែរ ឱ្យបញ្ចប់ការដាក់មន្ត្រីឱ្យត្រូវតាមអតីតភាពរបស់ខ្លួន ជាមួយប្រសិទ្ធិភាពការងារ និងជំនាញរបស់ខ្លួន ហើយក្រសួងបានទទួលសារាចរណែនាំរួចហើយដែរ។ បន្ថែមពីលើនេះទៀត ឯកឧត្តមបានសង្កត់ធ្ងន់ថា បញ្ហាកំណែទម្រង់ គឺតែងតែមានការប្រជុំជាមួយអន្តរក្រសួងយ៉ាងញឹកញាប់ ហើយឯកឧត្តម ក៏បានចុះផ្សាយទៅដល់ខេត្តក្រុងមួយចំនួនផងដែរ រួមផ្សំជាមួយវេបសាយ និងព្រឹត្តបត្រ័ពតិមាន។

***សំណួរ*** *តើរដ្ឋាភិបាលមានគោលការណ៍យ៉ាងណា ក្នុងការជំរុញយែនឌ័រទៅក្នុងកំណែទម្រង់រដ្ឋបាល ?*

**ចំលើយ** បញ្ហាយែនឌ័រ ឯកឧត្តមលើកឡើងថា ជារឿងស្មុគស្មាញ តែរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង។ កន្លងមកក្នុងវគ្គហ្វឹកហ្វឺន PDP (ថ្នាក់ជំនាញ)និង MDP (ថ្នាក់គ្រប់គ្រងដឹកនាំ) ក្នុងនោះល័ក្ខខ័ណ្ឌមួយគឺរើសនារីភេទ។ នៅក្នុងការប្រលងជ្រើសរើសមន្ត្រីចូលបម្រើការក្នុងក្របខណ្ឌ័ផ្សេងៗ គឺតែងតែដាក់គោលការណ៍រើសទាំងពីរភេទ ហើយច្បាប់ក៏គ្មានថែង ក្នុងការហាមឃាត់ស្ត្រីភេទមិនឱ្យចូលបម្រើការងារដែរ ចំពោះចំនួនស្ត្រីមានកម្រិតទាប (ចំនួនតិច) នៅក្នុងជួររដ្ឋបាលឯកឧត្តមសង្កត់ធ្ងន់ថា ជារឿងសង្គមគ្រួសារ និងសមត្ថភាពផ្ទាល់របស់ស្ត្រី។

***សំណួរ*** *ទាក់ទង និងការលើកទឹកចិត្តមន្ត្រីឱ្យមានប្រសិទ្ធិភាពការងារ ដំឡើងប្រាក់បៀវត្សរ៍ យោងលើកឡោមអាទិភាព ឃើញថាមន្ត្រីរាជការមានចំនួន ១៥០, ០០០*

*នាក់ តែហេតុអ្វីបានជារដ្ឋាភិបាលបញ្ចូលតែ ១២០០ នាក់? ចុះគ្រូបង្រៀនដែលជាមន្ត្រីសកម្ម និងការងារនោះ ហេតុអ្វីបានជាមិនស្ថិតនៅក្នុងកន្សោមអាទិភាព?*

**ចំលើយ** ចំពោះបញ្ហានេះ ឯកឧត្តមបញ្ជាក់ថា មកពីគ្មានថវិកាគ្រប់គ្រាន់ ទើបជ្រើសរើសវិធីបែបនេះ។ ប្រសិនបើយកថវិកាសម្រាប់បែងចែកឱ្យមន្ត្រីចំនួន ១២០០នាក់ ក្នុងកន្សោមអាទិភាព (ប្រហែល១.៥ លានដុលា្លរ អាមេរិកក្នុងមួយឆ្នាំ) មកធ្វើការបែងចែកដល់ចំនួនមន្ត្រីរាជការចំនួន ១៥០០០០ នាក់នោះ គឺអាចទទួលបន្ថែមបាន ប្រហែល ២០០០រៀល ប៉ុណ្ណោះ គឺតិចណាស់។ ដូច្នេះ រដ្ឋាភិបាលក៏សម្រេចយកគោល-ការណ៍រើសយកកន្សោមអាទិភាពមកអនុវត្ត ដោយមិនយកថវិកានោះ មកដំឡើងជូនមន្ត្រីរាជការទាំងអស់នោះទេ គឺធ្វើការពង្រឹងមន្ត្រីចំនួន ១២០០ នាក់ ក្នុងកន្សោមអាទិភាពឱ្យមានការងារល្អសិន។

ម្យ៉ាងទៀត ការអនុវត្តន៍បែបនេះ គឺលើកទឹកចិត្តមន្ត្រីសកម្មការងារគួរតែទទួលបានផលប្រយោជន៍ច្រើន ជាងមន្ត្រីដែលមិនសកម្ម ដូច្នេះ ជាមោទនភាពបំផុតដែលគម្រោងនេះ និងទទួលបានជោគជយ័មានប្រសិទ្ធិភាព និងគុណភាពការងារល្អ ប្រសិនបើការបញ្ចូលមន្ត្រីទៅក្នុងកន្សោមអាទិភាពត្រូវបានជ្រើសរើសប្រកបដោយតម្លាភាព។

**សំណួរនេះថា** ហេតុអ្វីបានជាមិនបញ្ចូលគ្រូបង្រៀនទៅក្នុងកន្សោមអាទិភាពនោះ លោកបណ្ឌិត ចាប សុថារិទ្ធ បានបកស្រាយបន្ថែមថា ដោយថវិកាមានកម្រិត ដូច្នេះត្រូវអនុវត្តអ្វីដែលជាស្នូលមុន។ ដោយសារតែក្រសួងជាក្បាលម៉ាស៊ីន រៀបចំផែនការអាទិភាពត្រូវអនុវត្តទៅលើមន្ត្រីធ្វើការនៅក្រសួងជាមុន។

***សំណួរ*** *គោលការណ៍រដ្ឋាភិបាល និងធ្វើការបែងចែកកំណើនសេដ្ឋកិច្ចឱ្យមានសមធម៌ ចុះហេតុអ្វីបានជាឱ្យប្រាក់ខែមន្ត្រីរាជការតែ ១២០០ នាក់ ចុះ ១៥០ ០០០ នាក់ទៀត គិតដូម្តេច? តើអាចមានទំនាស់ក្នុងជួរមន្ត្រីរាជការដែរឬទេ?*

**ចំលើយ** ឯកឧត្តម ង៉ោ ហុងលី បានលើកឡើងថា គោលការណ៍រដ្ឋាភិបាល គឺពង្រឹងសមត្ថភាពមន្ត្រីរាជការចំនួន ១២០០ នាក់ ធ្វើការងារល្អយកចិត្តទុកដាក់ចំពោះការងារជាជាងទទួលការរិះគន់ពីសំណាក់មន្ត្រីរាជការទាំង ១៥០ ០០០ នាក់ ក្រោយពីគាត់ទទួលបានការឡើងបៀវត្សរ៍តិចតួច (យកថវិកាសម្រាប់កន្សោមអាទិភាព ចំនួន ១២០០ នាក់ មកដំឡើងឱ្យដល់មន្ត្រីទាំង ១៥០ ០០០នាក់)។ គេមិនគួរបារម្ភថា អាចមានទំនាស់ក្នុងជួរមន្ត្រីរាជការទេ ព្រោះប្រាក់បៀវត្សរ៍ មិនអាចដូចគ្នាបានឡើយ។ មន្ត្រីរាជការមួយចំនួនបានទៅបម្រើការនៅអង្គការក្រៅរដ្ឋាភិបាល បានទទួលប្រាក់បៀវត្សរ៍រាប់រយ ហើយមានខ្លះដល់រាប់ពាន់ដុល្លារផង។

*សំណួរ ទាក់ទង និងនិស្សិត ដែលបញ្ចប់ការបណ្តុះបណ្តាលផ្នែកផ្សេងៗ ដូចជាទំនាក់ទំនងអន្តរជាតិ*(IR) *ពីបរទេស តើគេអាចជួយដល់គោលនយោបាយកំណែទម្រង់រដ្ឋាភិបាលកម្រិតណា?*

**ចំលើយ** ចំពោះនិស្សិត ឬមន្ត្រីដែលបណ្តុះបណ្តាលពីបរទេស គឺរដ្ឋាភិបាលមានសារាចរណែនាំឱ្យមន្ត្រី ដែលបានបញ្ជូនទៅបណ្តុះបណ្តាលនៅបរទេសពេលត្រឡប់មកវិញ មានលទ្ធភាពប្រើប្រាស់ចំណេះដឹងរបស់គាត់។ ហើយគោលការណ៍រដ្ឋាភិបាលទាក់ទងនិងការបញ្ជូនមន្ត្រីទៅហ្វឹកហ្វឺន បន្ថែមនៅបរទេសនេះ **ទី១** បំពេញបន្ថែមលើចំណុចខ្វះខាតចំពោះសមត្ថភាពធ្វើការងារ ដូច្នេះ ក្រោយពីសិក្សាបន្ថែមនៅបរទេសត្រឡប់មកវិញអាចធ្វើការងារល្អជាងមុន។ **ទី២** ត្រៀមលក្ខណៈចំពោះតម្រូវការជំនាញថ្មីទៅតាមការវិវត្តន៍របស់សង្គម។

## III - សេចក្តីសន្និដ្ឋាន

អង្គវេទិកាទាំងមូល បានធ្វើការជជែកវែកញែកប្រកបដោយភាពស្និតស្នាល អំពីការកែទម្រង់របស់រដ្ឋាភិបាល ក្រោយចូលជាសមាជិក WTO ។

ជារួមកិច្ចពិភាក្សាលើកទី ៧ បានបញ្ចប់ទៅនៅម៉ោង ១២ : 00 តាមកាលកំណត់ប្រកបដោយផ្លែផ្កា គួរជាទីគាប់ចិត្ត ទោះបីកិច្ចពិភាក្សាយើងមានវាគ្មិនតែមួយរូបក៏ដោយ ។ សមាជិក សមាជិកានៃអង្គពិភាក្សាលើកទី ៧ នេះបានទទួលនូវពត៌មាន ក៏ដូចជាចំណេះដឹងជាច្រើនពីវាគ្មិន និងអ្នកសម្របសម្រួល ដែលពោរពេញដោយសមត្ថភាពស្តីពី WTO ជាពិសេសបញ្ហាកំណែទម្រង់រដ្ឋបាលសាធារណៈ ។ នេះជាចំណែកមួយដ៏សំខាន់ ដែលអាចចាត់ទុកថាជាចំណើខួរក្បាលក្នុងការការស្តារ និងកែលម្អលើគ្រប់វិស័យ ដើម្បីធ្វើការប្រកួតប្រជែង ជាមួយបណ្តាប្រទេសដទៃទៀតនៅក្នុងតំបន់ ក៏ដូចជាពិភពលោកទាំងមូល ។

# របាយការណ៍សង្ខេបនៃវេទិកាទី ៨

## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់ពាណិជ្ជកម្ម និងការវិនិយោគទុន

### I -សេចក្តីផ្តើម :

លោក បណ្ឌិត **ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ធ្វើជាប្រធាន និងសម្របសម្រួលវេទិកាលើកទី ៨ ស្តីពី "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់ពាណិជ្ជកម្ម និងការវិនិយោគទុន" ។ វេទិកានេះរួមមានវាគ្មិនកិត្តិយសជំនាញពីររូប : (១)- ឯកឧត្តម បណ្ឌិត **ហ៊ីង ថូរ៉ាក់ស៊ី** ទីប្រឹក្សាផ្ទាល់ និងជានាយករងខុទ្ទកាល័យ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព។ (២)- លោក បណ្ឌិត **កង ចន្ទ័ដារ៉ារត្ន័** នាយកវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍ ។

មុនកិច្ចចាប់ផ្តើម លោកបណ្ឌិត ចាប សុថារិទ្ធ បានធ្វើការផ្តួចផ្តើមគំនិតខ្លះៗ សម្រាប់វេទិកាលើកទី ៨ ដែលជាវេទិកាដ៏មានសារៈសំខាន់ទាក់ទងទៅនឹងគោលការណ៍របស់ WTO ស្តីពី ការធ្វើពាណិជ្ជកម្មនិងវិនិយោគ។ ភាពចាំបាច់ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចចូលទៅក្នុងតំបន់ ក៏ដូចជា ពិភពលោកសម្រាប់ប្រទេសនីមួយៗ ដោយបញ្ជាក់ថា ក្រោយការបើកចំហពាណិជ្ជកម្ម សេដ្ឋកិច្ចមានកំណើនកើនឡើង ហើយ

ភាពក្រីក្របានថយចុះ ប្រជាពលរដ្ឋមានការងារធ្វើផលិតផលក្នុងស្រុកសរុប (GDP) មានការកើនឡើង... ។ល។

ដូច្នេះកម្ពុជាមិនអាចស្ថិតនៅក្នុងភាពឯកោតទៅទៀតទេ ទោះបីសេដ្ឋកិច្ចយើងនៅមានលក្ខណៈទន់ខ្សោយ បទដ្ឋានច្បាប់យើងនៅមានចន្លោះ ចំណេះដឹង ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយយ៉ាងណាក៏ដោយ ចាំបាច់យើងត្រូវតែធ្វើ សមាហរណកម្ម។

## II-ទស្សនៈទាក្ខិនកិត្តិយស :

(១)-ឯកឧត្តមបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី បានលើកឡើងពីស្ថាប័នគ្រប់គ្រង និងរៀបចំសេដ្ឋកិច្ចពិភពលោក ដែលរួមមានអង្គការពាណិជ្ជកម្មពិភពលោក (WTO) អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (WB)។ សមាជិកទាំងអស់នៃ WTO មានកម្លាំងសេដ្ឋកិច្ចធំបំផុតក្នុងពិភពលោក (លើកលែងប្រទេសរុស្ស៊ីដែលមិនទាន់ចូលជាសមាជិក)។ ក្នុងនោះបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ សុទ្ធតែជាសមាជិកនៃអង្គការ WTO លើកលែងតែប្រទេសឡាវ និងប្រទេសវៀតណាម។ ចំពោះកម្ពុជាបានក្លាយជាសមាជិកអង្គការនេះ ជាងមួយឆ្នាំមកហើយ (ក្លាយជាសមាជិក WTO នៅថ្ងៃទី ១១ កញ្ញា ឆ្នាំ ២០០៣)ក្នុងនាមជាប្រទេសមានការអភិវឌ្ឍន៍តិចតួច (LDC)។ ចំណែកសមារបាកម្មក្នុងតំបន់វិញ កម្ពុជាបានចូលជាសមាជិកអាស៊ាននៅខែមេសា ឆ្នាំ ១៩៩៩ ដែលប្រមូលផ្តុំប្រទេសចំនួន ១០ ហើយមានប្រជាពលរដ្ឋប្រមាណ ៥៥០ លាននាក់ និងមានផលិតផលក្នុងស្រុកសរុប (GDP) ប្រមាណ ៦០០ ពាន់លានដុល្លារអាមេរិក។ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ត្រៀមកាត់បន្ថយពន្ធលើទំនិញ សម្រាប់នាំចេញទៅកាន់ប្រទេសជិតខាងរបស់ខ្លួន នៅត្រឹមចន្លោះ 0 និង ៥% នៅឆ្នាំ ២០១០ នឹងលុបបំបាត់ទាំងស្រុងនៅឆ្នាំ ២០១៨។ ហើយតំបន់

ពាណិជ្ជកម្មសេរី អាស៊ាន-ចិន នឹងចូលជាធរមាននៅឆ្នាំ ២០១០ ដែលបង្កើតបានជាប្លុកពាណិជ្ជកម្មដែលមានប្រជាពលរដ្ឋប្រមាណ ១.៧ ពាន់លាននាក់។

កម្ពុជាស្ថិតក្នុងតំបន់សេដ្ឋកិច្ចបើកចំហជាបង្គួរ ក៏ប៉ុន្តែបើប្រៀបធៀបទៅនឹងប្រទេសជិតខាង កម្ពុជាមានសេដ្ឋកិច្ចបើកចំហបំផុត។ យោងតាមចំណាត់ថ្នាក់ប្រចាំឆ្នាំរបស់អង្គការមូនិធិមរតកនៅសហរដ្ឋអាមេរិក សន្ទស្សន៍នៃសេរីភាពសេដ្ឋកិច្ចរបស់កម្ពុជាក្នុងចំណោមប្រទេស ១៧០។ កម្ពុជាបានជាប់ក្នុងលំដាប់ទី ៣៥ ក្នុងឆ្នាំ ២០០៣ ប្រហាក់ប្រហែលប្រទេសជប៉ុន ហើយនាំមុខប្រទេសថៃ ដែលស្ថិតនៅលេខរៀងទី ៤០ និងនាំមុខប្រទេសក្នុងអាស៊ាន ដូចជា : ម៉ាឡេស៊ីទី ៧២ ឥណ្ឌូនេស៊ីទី ៩៩ វៀតណាមទី ១៣៥ និង ឡាវទី ១៥៣។ សន្ទស្សន៍នេះ គឺឆ្លុះបញ្ចាំងពីស្ថានភាពវិនិយោគ ដែលមានសក្តានុពល បន្ទុកសារពើពន្ធ ឧបសគ្គផ្នែកច្បាប់ទម្លាប់ ភាពមានកម្រិតនៃទីផ្សារ ពលកម្មគោលនយោបាយពាណិជ្ជកម្ម។ បច្ចុប្បន្ននេះ រដ្ឋាភិបាលបានខិតខំធ្វើការកែទម្រង់ជាច្រើន សំដៅធ្វើឱ្យបរិយាកាស វិនិយោគមានលក្ខណៈកាន់តែប្រសើរឡើង ដូចជាការធ្វើវិសោធនកម្មលើច្បាប់វិនិយោគ និងច្បាប់សារពើពន្ធ ដើម្បីធានាភាពបើកចំហ ការវិនិយោគផ្ទាល់ពីបរទេស។ ហើយថ្មីៗនេះ រដ្ឋាភិបាលបានអនុម័តអនុក្រិត្យ វិសោធ-នកម្មលើអនុក្រិត្យ ស្តីពី ការអនុវត្តន៍ច្បាប់វិនិយោគ ដែលមានគោលបំណងកាត់បន្ថយជាអតិបរមានូវបែបបទរដ្ឋបាល និងជួយសម្រួលកិច្ចការជាច្រើនសម្រាប់អ្នកវិនិយោគ។

ម្យ៉ាងទៀត រដ្ឋាភិបាល តែងតែរៀបចំវេទិការដ្ឋាភិបាល និងផ្នែកឯកជន ដើម្បីឱ្យផ្នែកឯកជនអាចបង្ហាញពីតម្រូវការឬកង្វះខាត និងសំណូមពរផ្សេងៗ ជូនរដ្ឋាភិបាលដើម្បីជួយដោះស្រាយ។ បន្ថែមលើនេះទៀត ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាមួយតំណាងក្រសួង និងនាយកដ្ឋានមួយចំនួនបាន និងកំពុងកែលម្អសេវាកម្ម សម្របសម្រួលរបស់ខ្លួនជាបណ្តើរៗ សម្រាប់អ្នកវិនិយោគ។ ឯកឧត្តមបានបញ្ជាក់ថា កម្ពុជាមានលក្ខណៈ

អនុគ្រោះច្រើនសម្រាប់អ្នកវិនិយោគទុន ដូចជា កម្ពុជាមានសេដ្ឋកិច្ចបើកចំហបំផុត នៅក្នុងតំបន់អាស៊ី និងមានបៀវត្សរ៍ទាបជាដើម ។

ម្យ៉ាងទៀត ដោយសារយើងជាប្រទេសមានការអភិវឌ្ឍន៍តិចតួចនាំឱ្យទទួលបានប្រព័ន្ធអនុគ្រោះបំផុត (MFN) និងប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) ពីសហរដ្ឋ-អាមេរិក សហគមអឺរ៉ុប និងបណ្តាប្រទេសមួយចំនួនទៀត នៅអាមេរិកខាងជើង .។ល។ ចំពោះកាលានុវត្តភាពនៃការវិនិយោគមាន ដូចជា វិស័យទេសចរណ៍ (សំបូរតំបន់ទេសចរណ៍ធម្មជាតិ) វិស័យឧស្សាហកម្ម (សំបូរវត្ថុធាតុដើម) វិស័យកសិកម្ម (ពលរដ្ឋ ៨៥% ជាកសិករ) ធនធានធម្មជាតិ មានរ៉ែត្បូងថ្ម ប្រេងកាត រ៉ែដែក . . . ។ល។

បន្ទាប់មកឯកឧត្តម បានលើកឡើងពីការខ្វះខាត និងកង្វល់មួយចំនួនរបស់កម្ពុជា ដូចជា កម្រិតយល់ដឹងរបស់ប្រជាជននៅទាប ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅមានក៏រិត ជាពិសេសនៅតំបន់ជនបទ អត្រាប្រើប្រាស់ថាមពលអគ្គសនី មានកម្រិតទាបបំផុតបើធៀបទៅនិងស្តង់ដារក្នុងតំបន់ និងអគ្គសនីមានតម្លៃខ្ពស់ កង្វះខាតនៃក្របខណ្ឌច្បាប់សម្រាប់ធ្វើការវិនិយោគជាឧបសគ្គមួយទៀត ការផ្លាស់ប្តូរច្បាប់ទម្លាប់យ៉ាងឆាប់រហ័សបានធ្វើឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរឡើង ទោះបីជាការផ្លាស់ប្តូរនេះ មានសារៈសំខាន់សម្រាប់កសាងបរិយាកាសទីផ្សារឱ្យល្អប្រសើរក៏ដោយ ។ ភាពទន់ខ្សោយនៃរដ្ឋបាល ភាពយឺតយ៉ាវដោយការិយាល័យធិបតេយ្យ . . . ។ល។

ដូច្នេះ ដោយសាររាជរដ្ឋាភិបាលមានទិសដៅ ក្នុងការទាក់ទាញអ្នកវិនិយោគ ដោយធ្វើការកែសម្រួលនូវច្បាប់ផ្សេងៗ ដែលទាក់ទងនឹងការធ្វើវិនិយោគ ការធ្វើកំណែទម្រង់រដ្ឋបាល ដើម្បីសម្រួលបែបបទផ្សេងៗ នោះស្ថានភាព វិនិយោគនៅកម្ពុជាអាចនាំឱ្យសេដ្ឋកិច្ចមានការជឿនលឿនក្នុងពេលខាងមុខដ៏ខ្លី ។

(២)-លោកបណ្ឌិត **កង ចំនួនដារ៉ារ័ត្ន័** បានលើកឡើងថា តាមការពិតកម្ពុជាយើងមិនមែនទើបតែទទួលការប៉ះពាល់នៅពេលចូល WTO ឆ្នាំ ២០០៤ នេះទេ ។ បើនិយាយពីទំហំនៃការប៉ះពាល់សេដ្ឋកិច្ចកម្ពុជា គឺមានចាប់តាំងពីឆ្នាំ ១៩៩៩ នៅពេលដែលយើងចូលជាសមាជិកអាស៊ានមកម្លេះ ។

ការចូលជាសមាជិក WTO ចែកចេញជាបីដំណាក់កាល :

ទី១- ក្រុមជំនាញសម្រាប់ទៅចរចាសម្រេចកិច្ចព្រមព្រៀងផ្សេងៗដែលនាំមុខដោយក្រសួងពាណិជ្ជកម្ម ។

ទី២- រដ្ឋសភាត្រូវបង្កើតច្បាប់ ឬធ្វើវិសោធនកម្មច្បាប់ផ្សេងៗ ឱ្យសមស្របសម្រាប់ការអនុវត្តន៍ក្នុងប្រទេស និងស្របតាមគោលការណ៍អង្គការពាណិជ្ជកម្មពិភពលោក ។

ទី៣- ផ្នែកឯកជនត្រូវស្វែងយល់ពីច្បាប់ទម្លាប់ផ្សេងៗ ក្រោយការចូលជាសមាជិក WTO ។

ដូច្នេះ កិច្ចព្រមព្រៀងដែលកម្ពុជាចុះហត្ថលេខាជាមួយ WTO កិច្ចព្រមព្រៀងខ្លះមានសារៈសំខាន់ចំពោះអ្នកវិនិយោគក្នុងស្រុកយ៉ាងខ្លាំង ។ ជាមួយនេះដែរ លោកបណ្ឌិតបានប៉ាន់ប្រមាណថា មានកិច្ចព្រមព្រៀងប្រហែល ២៧ ដែលកម្ពុជាបានចុះហត្ថលេខាជាមួយ WTO ។ បន្ទាប់មក លោកបណ្ឌិតបានលើកយកកិច្ច ព្រមព្រៀងសំខាន់ៗ មួយចំនួនមកធ្វើការបកស្រាយ ដូចជា :

តម្លាភាពនៃច្បាប់រាល់កិច្ចព្រមព្រៀង ឬច្បាប់ទាំងឡាយដែលកម្ពុជាចុះជាមួយ WTO ត្រូវតែមានតម្លាភាព ហើយតម្លាភាពនេះចែកចេញជារូបរាងពីរ : (១)-ខ្សែបណ្តោយពីលើចុះមកក្រោម គឺពីស្ថាប័នបង្កើតច្បាប់ ឬអ្នកបង្កើតច្បាប់រហូតដល់អ្នកអនុវត្តន៍ត្រូវតែដឹងពីគោលការណ៍នៃច្បាប់នីមួយៗ ជាពិសេសគឺច្បាប់ដែលទាក់ទង និង

ពាណិជ្ជកម្ម ឬច្បាប់វិនិយោគផ្សេងៗ. ។ល។ (២)-ខ្សែទទឹងពីក្រសួងមួយទៅក្រសួងមួយទៀត ឬពីរដ្ឋបាលមួយទៅរដ្ឋបាលមួយទៀតត្រូវតែដឹង និងស្វែងយល់ថា មានច្បាប់អ្វីខ្លះ ហើយក្រសួងណាធ្វើច្បាប់អ្វី ដើម្បីងាយស្រួលដល់ការបង្កើតច្បាប់ថ្មី ឬដើម្បីកុំឱ្យមានន័យផ្ទុយគ្នា។ ស្តង់ដារគុណភាពនៃផលិតផល យើងត្រូវតែគិតគូរឱ្យបានច្បាស់លាស់ពីគុណភាពរបស់ផលិតផល ព្រោះកន្លងមក នៅកម្ពុជាយើងសំបូរទៅដោយផលិតផលក្លែងក្លាយ។ វិញ្ញាបនបត្រនៃផលិតផលដើមត្រូវបញ្ជាក់ឱ្យច្បាស់ថា ជាផលិត-ផលរបស់ប្រទេសយើង ចៀសវៀងនៅការបន្លំដោយយកផលិតផលប្រទេសផ្សេងៗដាក់ថាផលិតនៅប្រទេសយើង ហើយនាំចេញទៅទីផ្សារដែលគេអនុគ្រោះចំពោះយើង។ យើងគ្មានការឧបត្ថម្ភធនពីរដ្ឋាភិបាលដល់វិស័យឯកជនឡើយ។ ចំណែកវិនិយោគទុនក៏មិនបានទទួលការឧបត្ថម្ភអ្វីពីរដ្ឋាភិបាល ទាំងផ្នែកបច្ចេកទេស និងផ្នែកផ្សេងៗ ឡើយ។

ដូច្នេះ បើនិយាយពីទីផ្សារក្នុងស្រុកឃើញថា ការប្រកួតប្រជែងទីផ្សារក្នុងស្រុកពុំមានតម្លាភាពឡើយ។ អាជីវករមួយចំនួនដែលមានដើមទុនធំ នៅពេលគេចង់ជំរុញផលិតផលគេឱ្យមាននៅលើទីផ្សារខ្លាំង គេដាក់លក់ដោយបញ្ចុះតម្លៃថោក ជាហេតុធ្វើឱ្យប៉ះពាល់ដល់ផលិតផលផ្សេងទៀត ឬអាចនាំឱ្យមានការបិទទ្វារសម្រាប់សហគ្រាសដែលផលិតនូវផលិតផលទាំងនោះផងដែរ។

ម្យ៉ាងទៀត កម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក គឺផ្តោតតែទៅលើការនាំចេញ ដូចជា ការនាំចេញផលិតផលសម្លៀកបំពាក់ ការនាំចេញផលិតផលកសិកម្ម ឬទេសចរណ៍តែប៉ុណ្ណោះ។ លោកបានលើកឡើងថា បច្ចុប្បន្ននេះយើងបានមើលរំលងទីផ្សារក្នុងស្រុកយ៉ាងខ្លាំង នៅពេលដែលការផលិតក្នុងស្រុកមិនអាចប្រកួតប្រជែងជាមួយផលិតផលនាំចូលពីក្រៅប្រទេសផងនោះ។ កិច្ចព្រមព្រៀងជាមួយ WTO អាចជះឥទ្ធិពលលើអាជីវករក្នុងស្រុកជាបីដំណាក់កាល រួមមាន :

- ការបង្កើតសហគ្រាសដែលចំណុចនេះគឺ វិនិយោគទៅលើផ្នែកអ្វីមួយដូច្នោះដែរ ថាតើអ្វីខ្លះដែលជួយសម្រួលដល់ការវិនិយោគ ។ កិច្ចព្រមព្រៀងជាមួយ WTO ជាចំណែកមួយជួយដល់ការវិនិយោគយ៉ាងច្រើន ជាពិសេសតម្លាភាពនៃច្បាប់ ។
- ប្រតិបត្តិការអាជីវកម្មប្រជាពលរដ្ឋ ដែលបើកធ្វើអាជីវកម្មមានការនឿយ-ណាយ នឹងសំណុំបែបបទរដ្ឋបាលយ៉ាងខ្លាំង ការិយាល័យធិបតេយ្យនាំឱ្យមានការចំណាយលុយខ្ជះខ្ជាយ ។
- ដំណាក់កាលពង្រីក ឬការលូតលាស់អាជីវកម្ម ដែលចំណុចនេះ លោកបានលើកឡើងថា ប្រជាពលរដ្ឋកម្ពុជានៅ ពេលគាត់បើកអាជីវកម្មអ្វីមួយគាត់ពុំបានគិតគូរច្រើនពីទីផ្សារឡើយ ។ ចំពោះប្រជាពលរដ្ឋកម្ពុជា គាត់ទទួលបានជោគ-ជយ័លើអាជីវកម្មក្នុងកម្រិតមួយហើយគាត់គ្មានគំនិត និងពង្រីកទីផ្សារបន្តទៀតទេ ។

ជារួមគោលការណ៍របស់ WTO សម្រាប់ប្រទេសជាសមាជិក គឺមានអត្ថប្រយោជន៏ដល់សេដ្ឋកិច្ចច្រើន ។ ចំពោះកម្ពុជាក្នុងការចូល WTO និងនាំមកនូវភាពចំណេញ តែយើងអាចសួរថា តើកម្ពុជាអាចឆ្លើយតប ឬបំពេញបានតាមគោល-ការណ៏ WTO បានទេ? ។

## III -មតិពិភាក្សារួម

បន្ទាប់ពីវាគ្មិនទាំងពីរបញ្ចេញនូវទស្សនៈ និងបទពិសោធន៏របស់ខ្លួនរួចមកអង្គសិក្ខាសាលាទាំងមូលបានបើក កិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ផ្តល់ចំណេះដឹងអោយគ្នាទៅវិញទៅមកព្រមទាំងលើកឡើងនូវសំណួរ ក៏ដូច ជាយកចំណុចដែលត្រូវពិភាក្សាដាក់ជូនអង្គសិក្ខាសាលាសម្រាប់ធ្វើការពិចារណា ។

**សំណួរ** *តើរាជរដ្ឋាភិបាលមានប្រតិកម្មដូចម្តេច ចំពោះតម្លៃការចុះបញ្ជីធ្វើពាណិជ្ជកម្មដែលមានតម្លៃ ១៥០០ ដុល្លារ ហើយឆ្នាំនេះធ្លាក់មកត្រឹមតែ ១០០០ ដុល្លារ? ហើយហេតុអ្វីបានជាការចុះបញ្ជីធ្វើពាណិជ្ជកម្មនៅកម្ពុជាមានតម្លៃថ្លៃជាងប្រទេសដទៃទៀត?*

**ចំលើយ** ចំពោះសំណួរនេះ លោកបណ្ឌិត ហ៊ុង ថូរ៉ាស៊ី បានមានប្រសាសន៍ថា យោងតាមការសិក្សា ការចុះបញ្ជីសុំធ្វើបែបបទពាណិជ្ជកម្ម នៅក្នុងប្រទេសកម្ពុជាពិតជាត្រូវចំណាយថវិកាច្រើនជាងបណ្តាលប្រទេសជិតខាង ដូចជា : វៀតណាម ថៃ ភូមា ឡាវ ពិតប្រាកដមែន។ មូលហេតុដែលធ្វើឱ្យចំណាយទៅលើការចុះបញ្ជីមានតម្លៃខ្ពស់វាពាក់ពន្ធ័ទៅនឹងរូបវន្តផង និងវិស័យច្បាប់ផង។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយរយៈពេលកន្លងមករាជរដ្ឋាភិបាលបានខិតខំកែលម្អ ដោះស្រាយ និងសម្រួលធ្វើយ៉ាងណាផ្តល់ភាពងាយស្រួល និងតម្រូវទៅតាមគោលបំណងរបស់អ្នកវិនិយោគដូចជា :

- រដ្ឋាភិបាលបានស្នើរសុំទៅ Word Bank ដើម្បីជួយក្នុងការសិក្សាស្រាវជ្រាវធ្វើយ៉ាងណាដើម្បីកាត់បន្ថយការចំណាយ ទៅលើការសុំចុះបញ្ជីធ្វើពាណិជ្ជកម្មនេះ។ ហើយក្នុងនោះបានបង្កើននូវកម្មវិធី “Facilitation Program” គឺគេបានធ្វើការសិក្សារតាំងពីគយ កាំកុងត្រូល ការដឹកជញ្ជូន កំពង់ផែ រហូតដល់គ្រប់បែបបទទាំងអស់ ហើយត្រូវធ្វើការអនុវត្តន៏កាត់បន្ថយពីផ្នែកណាទៅផ្នែកណាមុន។
- រដ្ឋាភិបាលបានបង្កើតជាវេទិកាពិភាក្សា រវាងវិស័យឯកជន និងវិស័យសាធារណៈជារៀងរាល់ ៦ខែម្តង ក្នុងគោលបំណងសែងរកនូវផលលំបាក និងភាពខ្វះខាតដែលកើតមានឡើង ដើម្បីធ្វើការដោះស្រាយបញ្ហាទាំងអស់ ជូនដល់អ្នកវិនិយោគទុនទាំងនោះ។
- ទន្ទឹមនឹងនេះដែរ រដ្ឋាភិបាលក៏បានរៀបចំវេទិកាជារៀងរាល់ខែ (មួយខែម្តង) ដើម្បីឱ្យអ្នកវិនិយោគទុន លើផ្នែកឧស្សាហកម្មនីមួយៗ ជួបជាមួយមន្ត្រីជំនាញ ឬក្រសួង

ដែលទទួលបន្ទុកលើឧស្សាហកម្មនោះផងដែរ ។ ឧទាហរណ៍ៈ ឧស្សាហកម្ម សណ្ឋាគារ គឺជួបជាមួយរដ្ឋមន្ត្រីទេសចរណ៍ មានរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ដើម្បីធ្វើការដោះស្រាយនូវបញ្ហាផ្សេងៗ ដែលទាក់ទង និងអាជីវកម្មរបស់ខ្លួន ។

ក្នុងការជំរុញវិស័យឯកជន រដ្ឋាភិបាលបានបង្កើតអនុគណៈកម្មាធិការចំនួន៣ទៀត

១- គណៈកម្មាធិការផ្នែកហេដ្ឋារចនាសម្ព័ន្ធ (ដូចជាៈ ទឹក ភ្លើង)

២- គណៈកម្មាធិការ SME គឺធ្វើការទៅលើសហគ្រាសធុនតូច និងធុនមធ្យម

៣- គណៈកម្មាធិការពាណិជ្ជកម្មនាំចេញនាំចូល ។

គណៈកម្មាធិការទាំងនេះ គឺដឹកនាំដោយរដ្ឋមន្ត្រីដែលជាអ្នកជំរុញ និងដោះស្រាយរាល់បញ្ហាទាំងអស់ ។

បន្ទាប់មកលោកបណ្ឌិត ក៏បានបង្ហាញជូន នូវសមិទ្ធផលរបស់រដ្ឋាភិបាល កន្លងមកលើកំណែទម្រង់នេះ ដូចជាការអនុម័តលើអនុក្រិត្យស្តីពី ការសម្រួលវិស័យវិនិយោគដែលអនុមតិថ្មីៗនេះ ដែលតម្លៃនៃការរត់ការសុំធ្វើបែបបទ វិនិយោគធ្លាក់មកនៅតម្លៃថោក គឺត្រឹមតែ ២000 (ពីរពាន់) ដុល្លារ ។ ដែលតម្លៃនេះកាលពីមុន ការសុំបែបបទបើករោងចក្រកាត់ដេរមួយ បើគិតទាំងបួងសាងសង់ទៀតមិនតិចជាង៣0000 (បីម៉ឺន) ដុល្លារទេ ។ ម្យ៉ាងទៀត រដ្ឋាភិបាលបានធ្វើវិមជ្ឈការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសំដៅយ៉ាងណាឱ្យមានបណ្តាញនៅតាមបណ្តាលខេត្តក្រុង ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកវិនិយោគមិនចាំបាច់មកចុះបញ្ជីពាណិជ្ជកម្មនៅភ្នំពេញទេ ។

**សំណួរ** *តើការចូលជាសមាជិក WTO មានផលលំបាក ឬផលប្រយោជន៍អ្វីខ្លះ? តើកត្តាអ្វីខ្លះដែលធ្វើឱ្យសេដ្ឋកិច្ច ប្រទេសកម្ពុជាមានការរីកចម្រើន?*

**ចំលើយ** ទាក់ទងនឹងសំណួរនេះ លោកបណ្ឌិត កង ចន្ទ័ដារ៉ារត្ន័ បានមានប្រសាសន៍ថា សារជាតិរបស់ WTO គឺល្អព្រោះវាបានផ្តល់នូវច្រកសម្រាប់ធ្វើពាណិជ្ជកម្ម ឱ្យយើងនាំ

ចេញផ្តល់លទ្ធភាពច្រើន ដល់វិស័យឯកជនសម្រាប់ការវិនិយោគ ទៅប្រទេសដទៃទៀត តាមរយៈការផ្លាស់ប្តូរហិរញ្ញវត្ថុ ធនធានវត្ថុធាតុដើម បច្ចេកវិទ្យា និងសេវាកម្មផ្សេងៗ ដូច្នេះ ការចូល WTO គឺល្អ។ ប៉ុន្តែបើសួរថា តើចំណេញឬខាតនោះគឺវាអាស្រ័យទៅលើការប្រកួតប្រជែង ហើយដើម្បីឱ្យការប្រកួតប្រជែងទទួលបានជោគជ័យ បើនិយាយអំពីការលក់ទំនិញវិញ គឺត្រូវលក់ឱ្យបានថោក និងទំនិញមានគុណភាពខ្ពស់។

*បញ្ហាដែលយើងត្រូវប្រឈមមុខសព្វថ្ងៃគឺ* : ការចំណាយលើអាជ្ញាបណ្ណ័ចុះបញ្ជីពាណិជ្ជកម្មនូវមានតម្លៃខ្ពស់ សេដ្ឋកិច្ចដុល្លាររូបនីយកម្ម ធនាគារ មានតែនៅក្នុងទីប្រជុំជនមិនមាននៅទីជនបទ ដូច្នោះ ឥណទានរបស់យើងគឺមានតម្លៃថ្លៃណាស់ ហើយខ្ចីបានតិចទៀតផង។ រដ្ឋាភិបាលត្រូវអភិវឌ្ឍ ដូចជា ផ្លូវ ធ្វើប្រពន្ធ័ដឹកជញ្ជូនគ្រប់បែបយ៉ាងទាំងអស់ ដើម្បីទាក់ទាញអ្នកវិនិយោគ និងជំរុញឱ្យប្រជាពលរដ្ឋបានចូលរួមនៅក្នុងវិស័យវិនិយោគដោយផ្ទាល់។

ជារួមលោកបណ្ឌិត កង ចន្ទ័ដារ៉ារត្ន បានបញ្ជាក់ថា សមាជិកភាពកម្ពុជាក្នុង WTO បច្ចុប្បន្ន មិនអាចចំណេញបានឡើយ ព្រោះ រួមផ្សំ ដី ទឹក ភ្លើង កំពុងឡើងថ្លៃ។ ជាមួយនេះដែរ លោកបណ្ឌិត ក៏បានអះអាងថា រយៈពេល ១០ ទៅ ១៥ ឆ្នាំទៀត បើយើងចាប់ធ្វើពីឥឡូវនេះទៅដោយខិតខំប្រឹងប្រែង មាននយ័ថា វិនិយោគសាធារណៈត្រូវផ្តោតទៅលើគោលធំៗជាចម្បង ជាពិសេសវិនិយោគទៅលើផ្លូវថ្នល់ ថាមពល និងវិស័យជំនួញឬ ឧស្សាហកម្ម គាំទ្រមួយចំនួនទៀត ដែលអាចឱ្យយើងប្រកួតប្រជែង និងទទួលបានផលចំណេញ។

**សំណួរ** *តើក្នុងនាមយើងជាវិសយ័ឯកជនគួរធ្វើដូចម្តេច ដើម្បីទាញយកផលប្រយោជន៍ពី WTO ឱ្យអស់លទ្ធភាព? តើទស្សនៈរបស់លោកបណ្ឌិតផ្ទាល់ ឬរដ្ឋាភិបាលគួរធ្វើយ៉ាងណា ដើម្បីផ្តល់ផលប្រយោជន៍ឱ្យវិស័យឯកជនទទួលបានអតិបរិមា?*

**ចំលើយ** សំណួរតើរដ្ឋាភិបាល គួរតែធ្វើយ៉ាងណាដើម្បីទាញយកផលប្រយោជន៍ពី WTO ឱ្យបានអតិបរមាដល់វិស័យឯកជន លោកបណ្ឌិត ហ៊ុង ថូវ៉ាស៊ី បានមានប្រសាសន៍ថា លោកបានឆ្លើយរួចទៅហើយ ដូចជា : កែលម្អ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ហេដ្ឋារចនាសម្ពន្ធ័ ផ្លូវច្បាប់ ដោះស្រាយបញ្ហានូវ ទឹក ភ្លើង និង ការបង្កើតវេទិកាវិស័យឯកជន និងសាធារណៈ ។

*ហើយទាក់ទងសំណួរថា តើវិស័យឯកជន គួរធ្វើដូចម្តេច? ដើម្បីទាញយកផលប្រយោជន៍ឱ្យអស់លទ្ធភាព ពី* WTO **លោកបណ្ឌិត កង ចន្ទ័ ដារ៉ារត្ន័** បានបកស្រាយថា សព្វថ្ងៃនេះ ទោះបីជាយើងខំប្រឹងយ៉ាងណា ក៏មិនឈ្នះគេដែរ ប៉ុន្តែជំហានជាយុទ្ធសាស្ត្រគឺរដ្ឋាភិបាល និងវិស័យសាធារណៈ ត្រូវតែខិតខំប្រឹងប្រែងធ្វើសកម្មភាពរបស់ខ្លួនឱ្យបានខ្លាំងក្លា មានន័យថា ហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗដែលនៅទន់ខ្សោយ ឬ អសកម្ម ត្រូវកែប្រែធានាឱ្យមានប្រពន្ធ័ច្បាប់ទម្លាប់ល្អ និងធានានូវសុវត្ថិភាព ទ្រព្យសម្បត្តិឯកជនទាំងឡាយ ។ល ។

បញ្ហាមួយចំនួនទៀត ប្រជាជនកម្ពុជាយើងគួរកែប្រែគឺៈ (១) -ចេះមានគំនិតស្វែងរកទីផ្សារដោយខ្លួនឯង, (២) -ត្រូវមានផែនការក្នុងការធ្វើអាជីវកម្ម, (៣) -ស្វែងយល់ពីឥណទាន និងរៀនប្រើប្រាស់ឥណទាន, (៤) -ត្រូវខិតខំស្វែងយល់នូវពត៌មានផ្សេងៗ ស្តីពី បច្ចេកវិទ្យាដែលទាក់ទង និងការធ្វើអាជីវកម្មរបស់ខ្លួនផ្ទាល់ ។

**សំណួរ ១**-តើពេលដែលកម្ពុជាចូលក្នុង WTO មានផលប៉ះពាល់ជាវិជ្ជមានយ៉ាងដូចម្តេច?

**២**-តើហេតុអ្វីបានជាគណៈរាត្និន ហ៊ានអះអាងថា អ្នកវិនិយោគ មិនមកវិនិយោគនៅក្នុងស្រុកខ្មែរ ព្រោះ តម្លៃពលកម្មនៅក្នុងស្រុកខ្មែរមានតម្លៃថ្លៃ បើប្រាក់ខែកម្មករបានទទួលតែ ៤០ដុល្លារអាមេរិកក្នុងមួយខែប៉ុណ្ណោះ?

៣-តើនៅពេលដែលវៀតណាមចូល ជាសមាជិក WTO វានឹងមានផលប៉ះពាល់ដល់កម្ពុជាយ៉ាង ដូចម្តេច?

**ចំលើយ** ទាក់ទងនឹងសំណួរទី១ លោកបណ្ឌិត កង ចន្ទ័ដារ៉ារត្ន័ បានបកស្រាយថា សារជាតិរបស់ WTO គឺវិជ្ជមាន (ផ្តល់ផលប្រយោជន៏)។ ក៏ប៉ុន្តែ ផលជាវិជ្ជមានប៉ុណ្ណានោះ វាអាស្រ័យលើការប្រកួតប្រជែង និងការខិតខំប្រឹងរបស់យើង។

*ចំពោះសំណួរទី២* លោកបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី បញ្ជាក់ថា កម្លាំងពលកម្មនៅកម្ពុជាពិតជាថ្លៃជាងប្រទេសបង់ក្លាដេស និងភូមា ដែលតម្លៃពលកម្មរបស់គេស្មើពាក់កណ្តាលនៃកម្លាំងពលកម្មក្នុងស្រុកខ្មែរ។ ហើយតំបន់ខ្លះនៃប្រទេស ចិនកម្លាំងពលកម្មរបស់គេមានតម្លៃថោកជាងកម្ពុជា ប៉ុន្តែនៅវៀតណាមគឺប្រហាក់ប្រហែលនឹងយើង។ ជាមួយ នេះដែរ លោកបណ្ឌិតបានអះអាងថា ការរួញរារបស់អ្នកវិនិយោគក្នុងការបណ្តាក់ទុននៅកម្ពុជា ទាក់ទងនិងច្បាប់ការងារផងដែរ។ ច្បាប់ការងារកម្ពុជាចែងថា ថ្លៃពលកម្មពេលយប់ត្រូវស្មើ ២ ដង នឹងថ្លៃពលកម្មធ្វើការពេលថ្ងៃ ប៉ុន្តែនៅប្រទេសគេធ្វើការយប់និងថ្ងៃតម្លៃពលកម្មស្មើគ្នា។

*ទាក់ទងនឹងសំណួរនេះផងដែរ* លោកបណ្ឌិត កង ចន្ទ័ដារ៉ារត្ន័ បានបកស្រាយថា តាមការសិក្សារបស់លោកជាមួយនឹងក្រុមហ៊ុនជាង ៣០ នៅក្នុងប្រទេសកម្ពុជា រកឃើញថា កម្លាំងពលកម្មដែលគេថាថ្លៃមានបី គឺ :

១- ប្រាក់ខែទទួលបានគិតជាសាច់លុយ

២- លទ្ធផលទទួលបានវាមានកម្រិតទាបបើធៀបទៅ និងប្រាក់ខែ

៣- ការផ្អាកសកម្មភាព ភាពរងគ្រោះនៃរោងចក្រ ដែលបង្កដោយកម្មករធ្វើបាតុកម្ម

*ទាក់ទងនឹងសំណួរទី៣* លោកបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី បានមានប្រសាសន៍ថា វៀតណាមមិនមែនជាផ្នែកមួយដែលយើងត្រូវព្រួយបារម្ភទេ គឺប្រទេសចិនទេដែលយើងត្រូវបារម្ភ ព្រោះចិន គឺជាប្រទេសដែលទាក់ទាញអ្នកវិនិយោគបានច្រើនជាងគេបំផុតនៅលើពិភពលោក។ ក៏ប៉ុន្តែលោកបណ្ឌិត ក៏បានទទួលស្គាល់ផងដែរថា នៅពេលដែលវៀតណាមចូលជាសមាជិក WTO វាពិតជាប៉ះពាល់ដល់កម្ពុជា ប៉ុន្តែទោះជាយ៉ាងណាក្តី បច្ចុប្បន្នយើងមានវិធានការពារ Safe Guard Measure ។

Safe Guard Measure គឺជារបាំងការពារដែលអឺរ៉ុបនឹងអាមេរិកមានវិធានការ មានន័យថា រាល់ទំនិញដែលចូលទៅអាមេរិកលើសពី ២% ឡើងទៅត្រូវដាក់កូតា ទោះជា WTO មានច្បាប់សេរីយ៉ាងណាក៏ដោយ ។

**សំណួរ** *១-តើការលាងលុយខ្មៅនៅកម្ពុជា មានផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាដែលឬទេ?*

*២-បើគេចោទថាកម្ពុជា ជាប្រទេសលាងលុយខ្មៅនឹងមានផលប៉ះពាល់អ្វីដល់ទីផ្សារក្នុងស្រុក ក៏ដូចជា ទីផ្សារអន្តរជាតិ?*

**ចំលើយ** *ទាក់ទងនឹងសំណួរទី១* លោកបណ្ឌិត ហ៊ីង ថូរ៉ាស៊ី បានមានប្រសាសន៍ថា បច្ចុប្បន្នយើងមិនទាន់មានអង្គការ ឬស្ថាប័ណាមួយធ្វើការសិក្សាឱ្យច្បាស់អំពីរឿងនេះនៅឡើយទេ។ តែលោកជឿជាក់ថា កម្ពុជាមិនមែនជាកន្លែងលាងលុយធំនោះទេ ព្រោះសេដ្ឋកិច្ចកម្ពុជាតូចណាស់ ហើយបច្ចុប្បន្នកម្ពុជាកំពុងតែបង្កើតច្បាប់ ស្តីអំពី ការការពារការលាងលុយនៅកម្ពុជា ដែលធនាគារជាតិកំពុងសហការជាមួយក្រសួងសេដ្ឋកិច្ច។

*ទាក់ទងនឹងសំណួរទី២* លោកបណ្ឌិត កង ចន្ទ័ដារ៉ារត្ន័ បានពន្យល់ថា ប្រសិនបើបរទេសចាត់ទុកប្រពន្ធ័ធនាគារយើង គ្រប់ដណ្តប់ដោយការលាងលុយខ្មៅ ពេលនោះនឹងគ្មានលុយស្អាតស្អំចូលមកប្រទេសយើងនោះទេ។ ដូច្នេះ ប៉ះពាល់ដល់ការវិនិយោគ

បរទេស និងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះធនាគារនៃប្រទេសកម្ពុជាយើងតែម្តង។ ព្រោះថាប្រទេសយើងប្រើប្រាស់លុយដុល្លារ ធនាគារជាតិយើងពុំមានលទ្ធភាពផ្តល់ឥណទានដល់ធនាគារពាណិជ្ជកម្មទេ ដូច្នេះ ធ្វើឱ្យធនាគារពាណិជ្ជកម្មត្រូវផ្អែកទៅលើប្រភពលុយពីបរទេស។ ឧទាហរណ៍ ប្រសិនបើយើងចង់ទៅខ្ចីលុយពីបរទេស ដូចជាធនាគារក្រុងឡុង (ប្រទេសអង់គ្លេស) គេត្រូវមើលថា តើប្រភពខ្ចីមកពីប្រភពណា។ ហើយបើគេដឹងថាមកពីកម្ពុជាដែលមានពាក់ពន្ធ័នឹងប្រព្វន័លាងលុយ នោះគេនឹងមិនរកស៊ីជាមួយយើងទេ។ ហើយសព្វថ្ងៃមានតែធានាគារអេស៊ីលីដាទេ ដែលមានកេរ្តិ៍ឈ្មោះ ហើយអាចទទួលយកបានឱ្យចូលទៅខ្ចីលុយនៅទីផ្សារបរទេស។

**សំណួរ ១** - ហេតុអ្វីបានជាអាជីវករយើង មិនមានគំនិតចង់ពង្រីកទីផ្សារ? ដោយសារហេតុអ្វី ឬដោយសារមិនមានតម្រូវការបន្ថែមសមត្ថភាពមានកំណត់ ឬមិនមានការពិគ្រោះយោបល់ពីរាជរដ្ឋាភិបាល?

**២**-បន្ទាប់ពីចូលជាសមាជិក WTO តើនឹងមានការប្រកួតប្រជែងរវាងក្រុមហ៊ុនតូចៗក្នុងស្រុក និងក្រុមហ៊ុនក្រៅស្រុកដែរឬទេ? តើក្រុមហ៊ុនតូចៗក្នុងស្រុកអាចមានសមត្ថភាពប្រកួតប្រជែងដែរឬទេ?

**ចំលើយ** *ទាក់ទងនឹងសំណួរនេះទី១* លោកបណ្ឌិត កង ចន្ទ័ដារ៉ារត្ន័ បានមានប្រសាសន៍ថា មិនមែនគាត់ (ប្រជាពលរដ្ឋ) មិនគិតទេ ប៉ុន្តែគាត់មិនដឹងថារឿងនេះជារឿងសំខាន់។ ហើយអ្វីដែលសំខាន់បំផុតសម្រាប់ពួកគាត់ គឺគាត់មិនដឹងថា តើត្រូវធ្វើដូចម្តេច ដើម្បីលក់ផលិតផលចេញ។ បញ្ហាមួយទៀតដែលអាជីវករយើងសព្វថ្ងៃជួបប្រទះ គឺខ្វះការតស៊ូស្វែងរកយុទ្ធសាស្ត្រ ដើម្បីប្រកួតឱ្យឈ្នះ និងចូលចិត្តគិតថា មុខរបររបស់គាត់គឺបន្ទាប់បន្សំ បើគាត់ប្រកួតមិនឈ្នះ គឺគាត់នឹងប្តូរមុខរបរថ្មី។

*ទាក់ទងនឹងសំណួរទី២* លោកបណ្ឌិត កង ចន្ទ័ដារ៉ារត្ន័ បានបកស្រាយថា ចង់មិនចង់សព្វថ្ងៃនេះ គឺយើងចាញ់គេរួចទៅហើយ ព្រោះក្រុមហ៊ុនធំៗគេលក់អ្វីក៏ថោកជាងយើងដែរ ហើយគុណភាពល្អថែមទៀតផង និងរួមទាំងធានានូវការផ្គត់ផ្គង់ទៀតផង។ ចំណែកឯក្រុមហ៊ុនក្នុងស្រុកតូចៗ គឺតម្លៃថ្លៃ គុណភាពអន់ និងមិនអាចធានាបរិមាណនៃការផ្គត់ផ្គង់បានទៀតផង។ ដូច្នោះ គេមិនចាំបាច់ប្រកួតប្រជែងជាមួយយើងទេ គឺគេគ្រាន់តែចេញមុខភ្លាម គឺយើងចាញ់គេរួចទៅហើយ។

ជាបន្ថែម លោកបណ្ឌិត ចាប សុថារិទ្ធិ បានធ្វើចំណាប់អារម្មណ៍ផងដែរថា ធាតុពិតរបស់ WTO គឺល្អណាស់ ប៉ុន្តែសួរថា តើវាល្អដល់កម្រិតណានោះវាអាស្រយ័ទៅលើលទ្ធភាពប្រកួតប្រជែងរបស់យើង។ ហើយវាជាការធម្មតាទេ ការចូលក្នុងWTO គឺជាការបើកទ្វារទៅវិញទៅមកដើម្បីធ្វើជំនួញទាំងអស់គ្នា និងទទួលបានការចំណេញទាំងអស់គ្នា។ ប៉ុន្តែ បើដំណើរការនៃការធ្វើជំនួញរបស់យើងមិនល្អ នោះគឺយើងនឹងទទួលបាននូវបរាជ័យជាក់ជាមិនខាន។ ហើយផលចំណេញនៃការចូល WTO គឺការផ្ទេរបច្ចេកវិទ្យាពតិមាន ដែលអាចធ្វើឱ្យកម្មករយើងទទួលបាននូវផលប្រយោជន៏បន្ថែមទៀត។

**សំណួរ** តាមប្រសាសន៏ លោកបណ្ឌិត កង ចន្ទ័ដារ៉ារត្ន័ ប្រទេសកម្ពុជាមានការលំបាកលើឥណទានគឺលំបាកខ្ចី និងការប្រាក់ខ្ពស់ ហេតុដូចនេះ តើធ្វើដូចម្តេចដើម្បីឱ្យ SME កើនឡើង ដើម្បីបង្កលក្ខណៈងាយស្រួលដល់អាជីវករយើង? តើប្រទេសកម្ពុជាមានផលចំណេញប្រៀបធៀប (comparative advantage) អ្វី? ហើយអ្វីទៅជាផលចំណេញដាច់ខាត (Absolute advantage)? សម្រាប់កម្ពុជាយើងដើម្បីប្រកួតប្រជែងនៅក្នុង WTO។

**ចំលើយ** ទាក់ទងនឹងសំណួរនេះ លោកបណ្ឌិត ចាបសុថារិទ្ធ បានពន្យល់ថា comparative advantage នៅកម្ពុជាមានច្រើន ក៏ប៉ុន្តែគ្រាន់តែផលចំណេញនោះ

យើងមិនទាន់យកមកប្រើជាឱកាស ដោយសារតែកម្ពុជានៅទន់ខ្សោយ និងមានការខ្វះខាត។ ក្នុងពេលនោះ លោកបណ្ឌិត បានលើកវិស័យកាត់ដេរ ដែលយើងកំពុងតែមានការលូតលាស់ បន្ទាប់ពីយើងចូល WTO និងត្រូវកាត់ផ្ដាច់កូតា។ តែក្រោយពីកម្ពុជាចូលក្នុង WTO វិសយ័កាត់ដេររបស់កម្ពុជា គឺមិនធ្លាក់ចុះ ហើយថែមទាំងមានការកើនឡើងទៀត។ ដូច្នោះ comparative advantage គឺវិស័យកាត់ដេរ និងតម្បាញ។ ហើយ absolute advantage គឺវិសយ័កសិកម្ម ព្រោះកម្ពុជាមានដីទំនេរសម្រាប់កសិកម្មច្រើនណាស់។

*ទាក់ទងនឹងសំណួរ តើធ្វើដូចម្ដេចដើម្បីលើកកម្ពស់* SME*? បើសិនការលំបាកក្នុងការខ្ចីលុយសម្រាប់វិនិយោគ ជាពិសេសការប្រាក់ខ្ពស់ ហើយច្រកនៃខ្ចីវាគ្មានទៅទៀត។* លោក បណ្ឌិត កង ចន្ទ័ដារ៉ារត្ន័ បានបកស្រាយថា អាជីវករយើងសព្វថ្ងៃគាត់អាចរីកលូតលាស់ ទោះបីជាគាត់គ្មានលុយក៏ដោយ ពីព្រោះគាត់មានសម្ថាធចង់បង្កើនជាអាជីវកម្ម ធំមួយលើសពីសមត្ថភាព ដោយមើលរំលងពីអាជីវកម្មធុនតូច ។ គ្រាន់តែគាត់បន្ថែមទុន និងបច្ចេកវិទ្យានោះ គាត់អាចពង្រីកអាជីវកម្ម និងមានលុយគ្រប់គ្រាន់។ ក្នុងនោះដែរ លោក បណ្ឌិតក៏បានបន្តទៀតថា មានតែច្រកមួយគត់សម្រាប់បច្ចុប្បន្ន គឺការបង្កើតជាសម្ពន្ធ័ អាជីវករ ដែលតំណាងឱ្យទឹកចិត្តអាជីវករទើបអាចដោះស្រាយនូវឥណទាន និងរហូតដល់ការកម្រិតនៃការធ្វើវិនិយោគប្រភេទណា ដែលអាចធ្វើទៅបាន។

**សំណួរ** *តើធនាគារអេស៊ីលីដា គួរធ្វើដូចម្ដេច? ដើម្បីឱ្យអត្រាការប្រាក់ដែលផ្ដល់ទៅឱ្យប្រជាកសិករមានតម្លៃទាបជាង ១៥ % ទៅ ១៨ % បើធនាគារបានទទួលកម្ចីក្នុងស្រុក ក៏ដូចជា ក្រៅស្រុកមានចំនួន ១២ % ទៅហើយនោះ។*

**ចំលើយ** ទាក់ទងនឹងសំណួរនេះ លោកបណ្ឌិត កង ចន្ទ័ដារ៉ារត្ន័ បានមានប្រសាសន៏ថា សំណួរនេះគួរសួរ ទៅខាងធនាគារអេស៊ីលីដា ប៉ុន្តែលោកយល់ថា ហេតុដូចម្តេចបានជាការប្រាក់ខ្ពស់? ព្រោះដោយសារហានិភ័យប្រទេសខ្ពស់។ ហើយប្រទេសដែលត្រូវបានកំណត់ជាប្រទេស ដែលមានហានិភយ័ខ្ពស់គេពិនិត្យលើបីចំណុច គឺ *១*-កំណើនសេដ្ឋកិច្ច, *២*-រដ្ឋបាលសាធារណៈ ឬអភិបាលកិច្ចល្អ ឬមិនល្អ *៣*-តើលទ្ធិប្រជាធិបតេយ្យមានកម្រិតណា?

**សំណួរ** *តើពីឥឡូវនេះទៅដល់ ៥ឆ្នាំ ទៅ ១០ ឆ្នាំទៀត តើសេដ្ឋកិច្ចកម្ពុជាអាចធ្លាក់ចុះជាគំហុកឬយ៉ាងណា? តើមានប៉ះពាល់ដល់ស្ថិរភាពសង្គម ឬ ទេ?*

**ចំលើយ** ទាក់ទងនឹងសំណួរនេះ បណ្ឌិត **កង ចន្ទ័ដារ៉ារត្ន** បានបកស្រាយថា វ៉ាមិន ធ្លាក់ជាកំហុកទេ ពីព្រោះយើងបានធ្លាក់រួចទៅហើយតាំងពីឆ្នាំ ១៩៩៩ មកម្លេះដោយ សារតែប្រែប្រួលខ្លះពីផ្នែកឯកជន។ ក៏ប៉ុន្តែឥឡូវនេះ រដ្ឋាភិបាលបានកំពុងចាប់ផ្តើមកសាងហេដ្ឋារចនាសម្ពន្ធ័គ្រប់ទីកន្លែង។ ក្នុងនោះយើងក៏បានឃើញថា ពិតជាមានការរីកចម្រើនជាងមុន គ្រាន់តែការរីកចម្រើននោះនៅមិនទាន់មានកម្រិតអាចប្រជែងជាមួយ និងបណ្តាប្រទេសផ្សេងទៀតបាននៅឡើយ។

*ទាក់ទងនឹងសំណួរនេះ* បណ្ឌិត ចាប សុថារិទ្ធិ បានធ្វើចំណាប់អារម្មណ៏ថា ពាក្យថាសេដ្ឋកិច្ចកម្ពុជា ធ្លាក់ចុះជាគំហុកនោះគឺមិនត្រឹមត្រូវទេ ព្រោះបើយើងពិនិត្យពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ចវិញ យើងឃើញថាល្អ គឺអាចធានាកំណើន GDP ជាមធ្យមប្រហែលជា ៦,៥ % ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ។ ជាមួយគ្នានេះ លោកបណ្ឌិតក៏បានលើកឡើងថា ដើម្បីធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនលើសនេះ លុះត្រាតែ GDP របស់យើងកើនឡើងប្រហែល ៩ % ទៅ ១០ % ក្នុង ១ឆ្នាំ។

**សំណួរ** ឥឡូវនេះ កម្ពុជាបានចូលក្នុងអង្គការ WTO ហើយបច្ចុប្បន្នយើងអស់កូតា ដូច្នេះ បញ្ហាធំគឺយើងត្រូវប្រជែង ប៉ុន្តែការប្រជែងនោះគឺយើងជួបប្រទះថ្លៃផលិត និងថ្លៃដើមខ្ពស់ តើរដ្ឋាភិបាលគួរធ្វើដូចម្តេច ដើម្បីឱ្យការប្រកួតប្រជែងនេះមានស្ថានភាពល្អ? ហើយប្រសិនបើ រដ្ឋាភិបាលចង់ជ្រើសរើសវិស័យដែលមានការប្រកួតប្រជែង តើគួរតែជ្រើសវិស័យមួយណា?

**ចំលើយ** ទាក់ទងនឹងសំណួរនេះ បណ្ឌិត ចាប សុថារិទ្ធបានមានប្រសាសន៍ថា ប្រសិនបើយើងនៅរក្សាឱ្យប្រហែលៗនេះ ដូចជាសព្វថ្ងៃបណ្តាក្រុមហ៊ុនទាំងនោះគេនឹងមិនរត់ទេ ពីព្រោះការផ្លាស់ប្តូរទីតាំង ដើម្បីធ្វើជំនួញសម្រាប់អ្នកវិនិយោគមិនមែនជាការងាយស្រួលនោះទេ។ *ហើយក្នុងចំណុចមួយទៀតដែលថា តើរដ្ឋាភិបាលគួរជ្រើសរើសយកវិស័យណានោះ?* លោកបណ្ឌិតបានបញ្ជាក់ថា វិស័យណាក៏បានដែរ ព្រោះយើងបានបើកចំហធំណាស់។ ដូចវាគ្មិនទាំងពីរបានលើករួមមកហើយ យើងមានវិស័យកសិកម្ម ឧស្សាហកម្មតម្បាញ និងសម្លៀកបំពាក់ និងទេសចរណ៍ដែលមានមូលដ្ឋានរឹងមាំ។ ក្នុងនោះយើងក៏ទទួលស្គាល់ដែលថា ការទាក់ទាញអ្នកវិនិយោគនៅកម្ពុជា ពិតជាមានការប្រឈមមុខខ្លាំង ក្រោយពេលចូល WTO ដូច្នេះ បញ្ហាចំពោះមុខគឺការដោះស្រាយការប្រកួតប្រជែងឱ្យទទួលបានដោយចីរភាព ទើបធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាដើរទៅមុខ។

## IV-សេចក្តីសន្និដ្ឋាន

អង្គវេទិកាទាំងមូលបានធ្វើសេចក្តីសន្និដ្ឋានថា ការចូល WTO គឺចំណេញដល់ប្រជាពលរដ្ឋ ប៉ុន្តែមានការប្រឈមមុខច្រើន។ ហើយមិនមែនតែរាជរដ្ឋាភិបាល ឬវិស័យសាធារណៈម្នាក់ឯងជាអ្នកទទួលខុសត្រូវនោះទេ គឺយើងទាំងអស់គ្នា។ ដូច្នេះ វិស័យ

ឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋត្រូវរួមដៃគ្នាដោះស្រាយ និងចូលរួមចំណែកធ្វើការជាមួយគ្នា។

ជាទីបញ្ចប់ បណ្ឌិត ចាប សុថារិទ្ធ បានបង្ហាញនូវទស្សនវិស័យរបស់លោកផ្ទាល់ថា សេដ្ឋកិច្ចកម្ពុជា នឹងមានការរីកចម្រើន ដោយលោកបានធ្វើចំណាប់អារម្មណ៍ទៅលើវិសយ័បី ដែលប្រទេសកម្ពុជាកំពុងពង្រឹង និងកែប្រែរួមមាន : **ទី១**-វិស័យទេសចរណ៍ **ទី២**-វិសយ័កាត់ដេរ និង **ទី៣**-វិសយ័កសិកម្ម និងឧស្សាហកម្មកែច្នៃ ជាពិសេសការកែច្នៃម្ហូបអាហារ។

# របាយការណ៍សង្ខេបនៃវេទិកា ទី ៩

## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា

## I-សេចក្តីផ្តើម

វេទិកាលើកទី ៩ ស្តីពី "អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា" ត្រូវបានដឹកនាំ និងសម្របសម្រួលដោយ លោកបណ្ឌិត **ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព។ គណៈវាគ្មិនកិត្តយសពីររូប គឺ (១)-លោក **ទី រតសាន** ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម, និង (២)-លោក **ជា សំណាង** អ្នកស្រាវជ្រាវ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា។

លោកបណ្ឌិត ចាប សុថារិទ្ធ បានផ្តួចផ្តើមគំនិតទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដែលសំដៅទៅដល់ការការពារទៅលើវត្ថុ ឬបច្ចេកវិទ្យាអ្វីមួយ ដែលរកឃើញដោយជនណាម្នាក់ ដើម្បីការពារសិទ្ធិស្របច្បាប់នៃស្នាដៃរបស់ជននោះ ពីការលួចចម្លងឬយកទៅធ្វើអាជីវកម្មដោយបំពានទៅលើម្ចាស់កម្មសិទ្ធិ។ ឧទាហរណ៍ ការនិពន្ធបទចម្រៀង និមិត្តសញ្ញា . .។ល។ ជាមួយគ្នានេះដែរ កាលណាយើងគិតពីកម្មសិទ្ធិបញ្ញាខ្លាំងពេក អាចធ្វើឱ្យយើងជួបប្រទះនូវការលំបាក ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដោយការប្រើ-ប្រាស់របស់ដើមមានតម្លៃខ្ពស់។

# II-ទស្សនៈខាងភាគីឯកជន

១ - លោក **ទាវ រតនសារ** លោកបានលើកឡើងថា ការចរចាជាមួយ WTO ផ្តោតសំខាន់ទៅលើចំណុចបីជាគោលចម្បង គឺ :

*ទី១-អត្រាពន្ធគយ* តើគួរកំណត់ពន្ធគយដូចម្តេច? តើត្រូវកំណត់តម្លៃអតិប្បរមា និងអប្បរមាក្នុងកម្រិតណា? ឧទាហរណ៍ ការកំណត់ពន្ធក្នុងការនាំឡានចូល។ ឧបមាថា កម្ពុជាកំណត់តម្លៃអតិប្បរមាលើការនាំឡានចូលកំណត់យក ២០០ % និងអប្បរមា ៨០ % តែប្រទេសដែលមានផលប្រយោជន៍លើការនាំឡានចូលកម្ពុជា ដូចជាជប៉ុន អាចធ្វើការចរចាជាមួយកម្ពុជាថា គួរតែយកតម្លៃអតិប្បរមាត្រឹម ១៥០ % និងអប្បរមានត្រឹម ៥០ % បានហើយ។ ពេលនោះ កម្ពុជាត្រូវធ្វើការចរចាជាមួយជប៉ុនបន្ទាប់មក បើភាគីទាំងពីរព្រមព្រៀងគ្នាលើតម្លៃណាមួយ ហើយទាំងអតិប្បរមា និងអប្បរមា គឺតម្លៃនោះនឹងយកប្រើជាទូទៅ មានន័យថា តម្លៃព្រមព្រៀងដែលកម្ពុជានឹងជប៉ុន បានធ្វើការចរចាជាមួយគ្នា នោះនឹងអាចយកទៅប្រើចំពោះប្រទេសដែលនាំឡានចូលកម្ពុជាផ្សេងទៀត ដូចជា កូរ៉េខាងត្បូង អាមេរិក បារាំង ផងដែរ។ ចំពោះទំនិញផ្សេងទៀត ដូចជា ថ្នាំពេទ្យ គ្រឿងបរិក្ខា . . . ។ល។ ក៏គេត្រូវធ្វើការចរចាដូចគ្នានេះផងដែរ។

*ទី ២ - សេវាកម្ម* ដូចជាទូរគមនាគមន៍ ទេសចរណ៍ . . .។ល។ សម្រាប់ប្រទេសណាដែលយល់ថា អាចមានអត្ថប្រយោជន៍លើវិស័យទាំងនេះគឺ អាចធ្វើការចរចាជាមួយកម្ពុជា។ ឧទាហរណ៍ មគ្គុទេសទេសចរណ៍សម្រាប់ខេត្តសៀមរាប ឧបមាថាប្រទេសកូរ៉េ គេមានចំណាប់អារម្មណ៍លើវិស័យនេះ គេចង់ចរចាជាមួយកម្ពុជាដោយស្នើសុំបម្រើសេវាកម្ម លើផ្នែកមគ្គុទេសចរណ៍ក្នុងខេត្តសៀមរាប ប្រសិនបើខាងភាគី

កម្ពុជា យល់ព្រមលើសំណើនេះ គឺត្រូវផ្ទេរសិទ្ធិផ្តាច់មុខលើផ្នែកនេះ ទៅឱ្យខាងភាគីកូរ៉េ។ តែបើកម្ពុជាយល់ថា សៀមរាបជាខេត្តរបស់កម្ពុជា ដូច្នេះប្រវត្តិសាស្ត្រកម្ពុជាមានតែជនកម្ពុជាទេ ដែលយល់ច្រើននោះគឺ អាចធ្វើការបដិសេធនៅសំណើរបស់កូរ៉េបាន។

***ទី ៣ - កម្មសិទ្ធិបញ្ញា*** ពុំមានភាពស្មុគស្មាញដូចចំណុចពីរខាងដើមនោះទេ គឺគេតម្រូវឱ្យយើងអនុវត្តទៅតាមកិច្ចព្រមព្រៀង ដែលពាក់ពន្ធ័នឹងពាណិជ្ជកម្មអំពីកម្មសិទ្ធិបញ្ញា ដែលហៅកាត់ជាភាសាអង់គ្លេសថា Trade Related Intellectual Property Rights (TRIPS) គឺបានហើយ។ ស្តង់ដារ និងរាល់ច្បាប់ផ្សេងៗ ដែលនិយាយពីកម្មសិទ្ធិបញ្ញា គឺត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀង TRIPS នេះតែម្តង។

លោកបានបន្ថែមទៀតថា ចំពោះកម្ពុជាការចរចាជាមួយ WTO ទាក់ទងនិងកម្មសិទ្ធិបញ្ញាមិនមែនជារឿងលំបាកនោះទេ ព្រោះ WTO មានគោលការណ៍រួចទៅហើយលើផ្នែកនេះ។ យើងគ្រាន់តែធ្វើច្បាប់ យើងឱ្យសបទៅតាមគោលការណ៍របស់គេទៅគឺបានហើយ។ លោកបានបន្ថែមទៀតថា មុនពេលយើងចូល WTO គេទាមទាឱ្យយើងបំពេញនូវតារាងមួយដែលហៅកាត់ថា ACC9 ដែលធ្វើការប្រៀបធៀបច្បាប់ឬពង្រាងច្បាប់យើង ដែលមានទៅនឹងមាត្រានីមួយៗនៃកិច្ចព្រម ព្រៀង TRIPS តើមានខុសគ្នាត្រង់ចំណុចណា ហើយស្របគ្នាត្រង់ចំណុចណា បើមិនច្បាស់ត្រង់ចំណុចណាគឺគេសួរយើង។ លើសពីនេះទៀត លោកបានលើកយកមាត្រា ៦១.១ និង ៦៦.១ ក្នុងកិច្ចព្រមព្រៀង TRIPS ដែលចែងថាប្រទេស LDC ត្រូវ អនុវត្តកិច្ចព្រមព្រៀង TRIPS នៅដើមឆ្នាំ ២០០៦ ឱ្យបាន។ តែមាត្រាដដែលនេះក៏បានចែងថា បើមានភាពចាំបាច់ប្រទេស LDC អាចសុំពន្យារពេលអនុវត្តកិច្ចព្រម ព្រៀង TRIPS នេះ។ ដោយសារប្រទេសយើងជាប្រទេស LDC លោកក៏បានផ្ញើលិខិតសុំពន្យារពេលអនុវត្តកិច្ចព្រមព្រៀង TRIPS នេះទៅទីស្នាក់ការរបស់អង្គការ WTO នៅទីក្រុងហ្សឺណែវ

កាលពីសប្តាហ៍មុន។ គោលបំណងក្នុងការពន្យាររនេះ គឺចង់យកកម្មសិទ្ធិបញ្ញាសម្រាប់ទាក់ទាញវិនិយោគ។ ចំពោះរយៈពេលនៃការសុំពន្យាររនេះ គឺប្រទេស LDC ទាំងអស់ត្រូវធ្វើការពិភាក្សាគ្នា តើគួរសុំពន្យារពេលអនុវត្តប៉ុន្មានឆ្នាំ? បន្ទាប់មកទើបបញ្ជូនលិខិតស្នើសុំពន្យារទៅក្រុមប្រឹក្សា TRIPS ដើម្បីពិចារណានិងសម្រេច។ លោកក៏បានធ្វើការបញ្ជាក់ផងដែរ អំពីកិច្ចព្រមព្រៀងដែលកម្ពុជា បានធ្វើជាមួយអាមេរិចនៅឆ្នាំ ១៩៩៦ ដែលទាក់ទងទៅនឹងការការពារកម្មសិទ្ធិបញ្ញា លើផលិតផលរបស់អាមេរិក ដើម្បីទទួលបានភាពអនុគ្រោះពីសហរដ្ឋអាមេរិក។ កិច្ចព្រមព្រៀងនោះចុះហត្ថលេខានៅថ្ងៃទី ០៤ -១០-១៩៩៦ ហើយកិច្ច ព្រមព្រៀងនោះចូល ជាធរមាននៅ ថ្ងៃទី ២៥-១០-១៩៩៦។ ហើយបន្ទាប់ពីចុះកិច្ចព្រមព្រៀងនោះមក យើងឃើញថា រោងចក្រកាត់ដេរជាច្រើនបានកើតឡើង នៅក្នុងប្រទេសកម្ពុជា ព្រោះតែ មានភាពអនុគ្រោះផ្នែកទីផ្សារពីសហរដ្ឋអាមេរិក។ ទន្ទឹមនឹងនេះ លោកក៏បានបន្ថែមទៀតថា ការចុះកិច្ចព្រមព្រៀងនេះ គឺអាមេរិកគេបានដាក់ល័ក្ខខណ្ឌជាមួយយើង គឺតម្រូវឱ្យយើងបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ២៤ ខែក្រោយមកកម្ពុជាត្រូវមានច្បាប់ កម្មសិទ្ធិបញ្ញាច្បាប់ម៉ាក. . . ? តែបើគិតទៅ ២៤ ខែក្រោយនៃការចូលជាធរមានរបស់ច្បាប់នេះគឺកម្ពុជាត្រូវមានច្បាប់ទាំងនេះ នៅឆ្នាំ ១៩៩៨។ តែនៅឆ្នាំ ១៩៩៨ កម្ពុជាពុំទាន់មានច្បាប់ទាំងនេះនៅឡើយទេ នេះសបញ្ជាក់ឱ្យឃើញថា សហរដ្ឋអាមេរិកបានជួយកម្ពុជាលើផ្នែកសេដ្ឋកិច្ចច្រើន។

២-លោក ជា សំណាង បានលើកឡើងថា តាមការចុះសម្ភាសន៍របស់លោកផ្ទាល់ជាមួយប្រជាពលរដ្ឋខ្មែរមានអ្នករត់ម៉ូតូឌុប អាជីវករថ្នាក់ទាប និងមធ្យម កសិករឃើញថា ប្រជាពលរដ្ឋទាំងនេះមួយភាគធំ គឺមិនស្គាល់អ្វីទៅ WTO? ហើយមួយភាគគ្រាន់តែបានលឺពាក្យ WTO តែមិនដឹងថា WTO មានគោលដៅអ្វីនោះទេ?

លោកបានបញ្ជាក់ថា បើគិតតាំងពីថ្ងៃដាក់ពាក្យជាផ្លូវការ សុំចូលជាសមាជិក រហូតដល់ក្លាយជាសមាជិកមានរយៈពេល ១០ ឆ្នាំ។ ក្នុងរយៈពេល ១០ ឆ្នាំនេះ ប្រជាពលរដ្ឋខ្មែរភាគច្រើនលោកពុំបានដឹងថា រដ្ឋាភិបាលបានធ្វើអ្វីខ្លះទាក់ទងនិង WTO។ ហើយថាតើខ្លួន (ប្រជាពលរដ្ឋខ្មែរ) អាចចូលរួមចំណែកជាមួយរដ្ឋាភិបាលកម្រិតណា ស្តីអំពី WTO? លោកបានសង្កត់ធ្ងន់លើចំណុចនេះថា វាជាបញ្ហាលំបាករបស់កម្ពុជា ព្រោះពលរដ្ឋកម្ពុជា ជាអ្នកត្រូវធ្វើការប្រកួតប្រជែងដោយផ្ទាល់ក្នុង WTO មិនបាន យល់ដឹងអ្វីច្រើនពីគោលការណ៍របស់ WTO។ ទាក់ទងនឹងបញ្ហាកម្មសិទ្ធិបញ្ញានេះ មានចំណុច ៤ រួមនោះគឺ :

### *១ -ប្រវត្តិកម្មសិទ្ធិបញ្ញា តើពាក្យកម្មសិទ្ធិបញ្ញាចេញមកពីណា?*

ប្រព័ន្ធនៃកម្មសិទ្ធិបញ្ញាត្រូវបានគេនិយាយ និងយកមកប្រើនៅដើមសតវត្សទី១៥ នៅបណ្តាប្រទេសអឺរុប ដូចជា អង់គ្លេស បារាំង ។ បន្ទាប់មកនៅឆ្នាំ ១៨៨៣ គេបានបង្កើតអនុសញ្ញាក្រុងប៉ារីស ដើម្បីការពារទ្រព្យសម្បត្តិដែលជាឧស្សាហកម្ម។ គេបានធ្វើការកែប្រែ ៦ ដង រហូតដល់ឆ្នាំ ១៩៦៧។ នៅឆ្នាំ ១៨៨៦ គេបង្កើតបានអនុសញ្ញា Berne មួយទៀត ដែលការពារទៅលើស្នាដៃនៃការចម្លាក់ ការតាក់តែងនិពន្ធជាដើម ហើយគេបានធ្វើការកែតម្រូវ ៨ ដងរហូតដល់ឆ្នាំ ១៩៧៩។ អនុសញ្ញាទាំងពីរនេះ ត្រូវបានគេបញ្ចូលគ្នានៅឆ្នាំ ១៨៩៣ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ហើយគេឱ្យឈ្មោះថា **ការិយាល័យអន្តរជាតិដើម្បីការពារកម្មសិទ្ធិបញ្ញា** (International Bureau for the Protection of Intellectual Property) (BIRPI) ។ ក្រោយមកនៅឆ្នាំ ១៩៧0 BIRPI បានប្តូរមកជា WIPO។

### *២ - ផលប៉ះពាល់នៃការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា*

ការអនុវត្តន៍កម្មសិទ្ធិបញ្ញា និងនាំឱ្យមានការឡើងថ្លៃ។ មានន័យថារាល់ទំនិញ ឬសម្ភារៈប្រើប្រាស់ និងភ្ជាប់មកជាមួយនូវការការពារ។ ឧទាហរណ៍ សៀវភៅអានមួយក្បាល ដែលពីមុនយើងអាចរកទិញបានក្នុងតម្លៃថោក ព្រោះជាសៀវភៅថតចម្លង តែដល់ពេលយើងអនុវត្តកម្មសិទ្ធិបញ្ញា សៀវភៅនោះមិនត្រូវបានអនុញ្ញាតឱ្យថតចម្លងឡើយ។ ដូច្នេះ សៀវនោះត្រូវលក់ក្នុងតម្លៃខ្ពស់ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេសផងដែរ។

*បន្ទាប់មកលោកបានលើកឡើង ពីការធ្វើសមាហរណកម្មចូលទៅក្នុងអង្គការអន្តរជាតិ ក៏ដូចជាក្នុងតំបន់ រួមមាន :*

- កម្ពុជាបានក្លាយជាសមាជិក WIPO នៅខែ កក្កដា ឆ្នាំ ១៩៩៥។
- នៅខែតុលា ឆ្នាំ ១៩៩៦ កម្ពុជាបានចុះកិច្ចព្រមព្រៀងទំនាក់ទំនងពាណិជ្ជកម្ម និងការការពារកម្មសិទ្ធិបញ្ញាជាមួយសហរដ្ឋអាមេរិក។
- នៅខែមីនា ឆ្នាំ ១៩៩៧ កម្ពុជាបានចុះហត្ថលេខា លើអនុស្សារណៈ យោគយល់ដើម្បីសហប្រតិបត្តិការលើផ្នែកកម្មសិទ្ធិបញ្ញាជាមួយថៃ ។
- នៅខែកញ្ញា ឆ្នាំ ១៩៩៨ កម្ពុជាបានក្លាយទៅជាសមាជិកនៃអនុសញ្ញាទីក្រុងប៉ារីស។
- នៅខែមេសា ឆ្នាំ ១៩៩៩ កម្ពុជាក្លាយជាសមាជិកអាស៊ាន។
- នៅខែ តុលា ឆ្នាំ ២០០៤ កម្ពុជាបានក្លាយជាសមាជិករបស់ WTO ។

ជាមួយនិងការក្លាយខ្លួនជាសមាជិក WTO កម្ពុជាបានសន្យាថានឹងអនុវត្តតាមកិច្ចព្រមព្រៀង TRIPS នៅដើមឆ្នាំ ២០០៧។

*នៅពេលដែលកម្ពុជាអនុវត្តគោលការណ៍* TRIPS *នេះ តើកម្ពុជាមានផលប៉ះពាល់ដូចម្តេចខ្លះ?*

លោកបានលើកយកបទពិសោធន៍ប្រទេសមួយចំនួន មកបង្ហាញជូនអង្គវេទិកាទាំងមូលបានយល់ថា ពេលអនុវត្តគោលការណ៍ TRIPS និងធ្វើឱ្យការហូរចូលនៅសម្ភារៈប្រើប្រាស់ផ្សេងៗ ត្រូវបានកាត់បន្ថយ ដែលជាកត្តានាំឱ្យប៉ះពាល់ដល់អ្នកប្រើប្រាស់។ ចំពោះប្រទេសកំពុងអភិវឌ្ឍសម្ភារៈប្រើប្រាស់ជាតម្រូវការចាំបាច់ តែចំពោះប្រទេសអភិវឌ្ឍ ជាប្រភពនៃកំណើនសេដ្ឋកិច្ច។ ឧទាហរណ៍ នៅឆ្នាំ ១៩៩៩ សហរដ្ឋអាមេរិកនាំចេញ ផលិតផលមានចំនួនទឹកប្រាក់ ៨០ ពាន់លានដុល្លារ ហើយដែលមានតម្លៃសរុបដល់ទៅ ២៦០ ពាន់លានដុល្លារ។ ដូច្នេះ បើធៀបមកកម្ពុជាបច្ចុប្បន្នមានការខុសគ្នាដូចម្ដេច នៅពេល GDP សរុបយើងមានតែ ៤ ពាន់លានដុល្លារ។ ដូច្នេះបានជាសហរដ្ឋអាមេរិក និងប្រទេសអ្នកមានមួយចំនួនខំប្រឹងជំរុញឱ្យប្រទេស កំពុងអភិវឌ្ឍ អនុវត្តនៅគោលការណ៍ទាំងនេះ ដើម្បីឱ្យប្រាក់ហូរចូលប្រទេសរបស់គេ។ តែលោកក៏បានលើកឡើងថា វាអាចមានផលចំណេញដល់ប្រទេសកំពុងអភិវឌ្ឍខ្លះដែរ។ ឧទាហរណ៍ ការលើកទឹកចិត្តឱ្យមានការច្នៃប្រឌិត។ ជាមួយនិងផលវិបាករបស់កម្ពុជា លោកបានលើកឡើងថា នៅពេលកម្ពុជាអនុវត្តនូវគោលការណ៍ TRIPS ការអភិវឌ្ឍធនធានមនុស្សនឹងរងប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ ភាពសម្បូរបែបនៃឯកសារស្រាវជ្រាវ និងកម្មវិធីកំព្យូទ័រផ្សេងៗ ត្រូវបានការពារមិនឱ្យមានការថតចម្លង ជាហេតុធ្វើឱ្យសម្ភារៈទាំងនេះឡើងថ្លៃ។ ចំពោះសុខុមាលភាពវិញ យើងដឹងថា បន្ទាប់ចាកផុតពីសង្គ្រាមកម្ពុជាត្រូវប្រឈមមុខ និងការប្រយុទ្ធប្រឆាំង និងជំងឺគ្រប់បែបយ៉ាង។ ភាពអត់ឃ្លានតម្រូវឱ្យប្រជាពលរដ្ឋស្វែងរកចំណីអាហារសម្រាប់បរិភោគ។ ភាពគ្មានអានាម័យនៃចំណីអាហារ បណ្ដាលឱ្យប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋយ៉ាងខ្លាំង។ សង្គមបច្ចុប្បន្នត្រូវប្រឈមមុខនឹងជំងឺជាច្រើន ដូចជា ជំងឺរបេង ជំងឺឃ្លង់ ជាពិសេសជំងឺអេដស៍ដែលកំពុងតែយាយី អាយុជីវិតប្រជាជនកម្ពុជាប្រហែល ២ សែននាក់។ ការព្យាបាល

និងថៃទាំអ្នកជំងឺទាំងនេះ ទាមទានូវការផ្គត់ផ្គង់ថ្នាំគ្រប់គ្រាន់។ ដូច្នេះ នៅពេលយើងអនុវត្តគោលការណ៍ TRIPS ថ្នាំមួយចំនួននឹងមិនត្រូវអនុញ្ញាតឱ្យផលិត។ លោកក៏បានធ្វើការប្រៀបធៀប ពីតម្លៃថ្នាំដែលប្រើប្រាស់នៅកម្ពុជា ទៅលើអ្នកជំងឺអេដស៍ជាមួយនឹងសហរដ្ឋអាមេរិកថា នៅកម្ពុជាថ្នាំដែលប្រើប្រាស់ពុំមែនជាថ្នាំដើមទេ ហើយតម្លៃប្រើប្រាស់ក្នុងមួយឆ្នាំ ៣៥០ដុល្លារ។ ចំណែកនៅសហរដ្ឋអាមេរិកវិញ គេប្រើប្រាស់ថ្នាំដើម ហើយតម្លៃប្រើប្រាស់ ក្នុងមួយឆ្នាំជាង ១០០០០ ដុល្លារ។ ដូច្នេះ បើគេតម្រូវឱ្យយើង ប្រើប្រាស់ថ្នាំដើមវិញ តើយើងនឹងត្រូវប្រឈមមុខយ៉ាងណា នៅពេលដែល GDP របស់ប្រជាជនម្នាក់ៗ មានប្រហែល ៤០០ ដុល្លារ។

**៣ - ភាពបត់បែនបាននៃ** TRIPS (TRIPS Flexibility)

ចំពោះរដ្ឋាភិបាល នៅពេលមានភាពចាំបាច់អាចផ្តល់សិទ្ធិឱ្យគេផលិតបាន ទោះបីជាទទួលគោរពសិទ្ធិប៉ាតង់ (Patent) យ៉ាងណាក៏ដោយ។ ភាពចាំបាច់ទាំងនោះរួមមានតម្រូវការបន្ទាន់ឬកើតវិបត្តិអ្វីមួយ។ រដ្ឋាភិបាលគ្រាន់តែលើកហេតុផលទៅម្ចាស់ Patent ដូចជាករណីអ្នកជំងឺអេដស៍ក្នុងប្រទេស មានការកើនឡើងរហូតដល់ ២.៣%នៃប្រជាជនសរុប . . . ។ល។ ការអនុញ្ញាតឱ្យផលិតនេះ រដ្ឋាភិបាលក៏ត្រូវបង់លុយទៅឱ្យម្ចាស់ Patent ផងដែរ តែបង់ក្នុងចំនួនតិច។ ក្នុងករណីមួយទៀត រដ្ឋាភិបាលអាចធ្វើអាជីវកម្មលើ Patent ដោយសេរីគ្រាន់តែឱ្យស្ថាប័នជំនាញណាមួយទទួលខុសត្រូវតែរដ្ឋាភិបាលត្រូវចាយលុយមួយចំនួនផងដែរ។

ចំពោះ Doha Declaration គឺធ្វើឡើងនៅសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី ៤ នៅប្រទេស Qatar។ លោកបានលើកឡើងថា ចាប់តាំងពី WTO បង្កើតឡើង គឺមានកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីចំនួន ៥ លើករួចមកហើយ។ ហើយកិច្ចប្រជុំលើកទី ៤ នេះប្រទេសកំពុងអភិវឌ្ឍន៍បានទទួលផលប្រយោជន៍ច្រើន គឺទទួលបាននូវភាពបត់បែនរបស់

TRIPS នេះតែម្តង។ ចំណែកប្រទេសកម្ពុជា ក៏ទទួលបានផលប្រយោជន៍ពី Doha Declaration នេះផងដែរ ព្រោះតាំងពី Doha Declaration នេះចេញមក គឺល្បឿននៃការចរចាមានសន្ទុះខ្លាំងជាងមុន។ Doha Declaration នេះបានអនុគ្រោះដល់ប្រទេសកំពុងអភិវឌ្ឍច្រើន ដូចជាអនុញ្ញាតឱ្យមានការផលិតដើម្បីបម្រើការប្រើ-ប្រាស់ក្នុងស្រុក ជាពិសេសខាងផ្នែកសុខភាពសាធារណៈច្រើន។

ឧទាហរណ៍ ដូចជាកម្ពុជាយើងមានគ្រឹះស្ថានផលិតឱសថចំនួន ៥។ ហើយគ្រឹះស្ថានមួយនោះមានផលិតថ្នាំអេដស៍។ ដូច្នេះ គ្រឹះស្ថានទាំង ៥ នេះ អាចផលិតនៅប្រភេទថ្នាំដើម្បីបម្រើសេចក្តីត្រូវការក្នុងស្រុកចំនួន ៥១% ហើយ ៤៩% ទៀតអាចនាំចេញទៅកាន់ប្រទេសផ្សេងទៀត ដែលគ្មានលទ្ធភាពផលិត ដូចជា ប្រទេសខាងអាហ្វ្រិចជាដើមបាន។ ហើយនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី ៥ នាទីក្រុងកានគូននៃប្រទេសម៉ិចស៊ិកូ គេអនុញ្ញាតឱ្យនាំចេញដោយសេរីនូវថ្នាំពេទ្យ ព្រោះតែតម្រូវការមានច្រើននៅប្រទេសកំពុងអភិវឌ្ឍន៍។ នៅមានភាពអនុគ្រោះជាច្រើនទៀត សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដូចជា ការសុំពន្យារពេលអនុវត្តគោលការណ៍របស់ TRIPS . . . ។ល។

### *៤-ការអភិវឌ្ឍន៍ថ្មីនៃកម្មសិទ្ធិបញ្ញា នៅក្នុងការចរចាកិច្ចព្រមព្រៀងពាណិជ្ជ-កម្មសេរី*

យើងធ្លាប់មានការចរចា ជាលក្ខណៈកិច្ចព្រមព្រៀងពាណិជ្ជកម្មកន្លងមកជាមួយអាមេរិក ប៉ុន្តែពុំមែនជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនោះទេ។ យើងធ្វើការបែងចែកកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឱ្យបានច្បាស់។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីគ្មានរបាំងអ្វីទាំងអស់។ ដូចជា ការចូលជាសមាជិកអាស៊ានគឺតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ដែលនៅឆ្នាំ ២០២០ និងលុបរបាំងចោលទាំងអស់។ លោកបានលើកឡើងថា តាំងពីដើមមកប្រទេសកំពុងអភិវឌ្ឍន៍ គ្មានចង់

គោរពកម្មសិទ្ធិបញ្ញានេះទេ ព្រោះប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍសង្គម។ សូម្បីតែប្រទេសអ្នកមានមួយចំនួនដែលកំពុងតែជំរុញឱ្យគេគោរពនេះ កាលដើមឡើយក៏ធ្លាប់មិនគោរពដែរ។ តែដល់ប្រទេសខ្លួនក្លាយជាប្រទេសអភិវឌ្ឍន៍ទៅ គឺខិតខំពង្រឹងជំរុញឱ្យគេអនុវត្តដើម្បីទទួលបានផលប្រយោជន៍ពីបញ្ហានេះ។ លោកបានបញ្ជាក់បន្ថែមទៀតថា បច្ចុប្បន្នការការពារកម្មសិទ្ធិបញ្ញាត្រូវបានពន្យារពី ៥០ ឆ្នាំ ទៅដល់ ៧០ ឆ្នាំ។ ឧទាហរណ៍ ដូចជាបទចម្រៀង លោក ស៊ីន ស៊ីសាមុត គឺត្រូវការពារពេញមួយជីវិតរបស់លោកហើយបូកថែម ៥០ ឆ្នាំទៀត តែបច្ចុប្បន្នត្រូវបូកថែមដល់ ៧០ ឆ្នាំ ។

*សរុបមកលោកបានបង្ហាញនូវគោលគំនិតផ្ទាល់របស់លោកពីរចំណុច : ប្រទេសកម្ពុជានឹងជាប់ជំពាក់នឹងការអនុវត្តកិច្ចព្រមព្រៀង ស្តីពី កម្មសិទ្ធិបញ្ញាទាំងអស់ ហើយលោកសង្កត់ធ្ងន់ថា កម្ពុជាគ្មានចំណេញអ្វីពីការអនុវត្តកម្មសិទ្ធិបញ្ញាទេ មានតែខាតបើប្រៀបជាមួយប្រទេសកំពុងផលិត ។*

*លោកចង់បង្ហាញថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងនាំមកនូវការការពារជាច្រើនដែលនាំឱ្យតម្លៃនៃការប្រើប្រាស់ឡើងខ្ពស់សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ។ ដូច្នេះពេលចរចាកិច្ចព្រមព្រៀងសេរីត្រូវប្រុងប្រយ័ត្នឱ្យបានខ្លាំង ។ លោកបន្ថែមទៀតថា ទោះបីជាសព្វថ្ងៃកម្ពុជា គ្មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតែកម្ពុជាជាសមាជិកអាស៊ាន ។ បច្ចុប្បន្ន អាស៊ានកំពុងតែធ្វើការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយប្រទេសជប៉ុន និងប្រទេសចិន ។*

## III-មតិពិភាក្សា

បន្ទាប់ពីទស្សនៈរបស់គណៈវាគ្មិនទាំងពីរត្រូវបានបញ្ចប់ លោកបណ្ឌិត ចាប សុថារិទ្ធ បានផ្តើមធ្វើកិច្ចពិភាក្សាដោយលោកបណ្ឌិត បានលើកយកបញ្ហាផ្សេងៗ ជុំវិញ

WTO មកដាក់នឹងធ្វើការចោទសួរ ក៏ដូចជា បំផុសឱ្យសមាជិកនៃអង្គវេទិកាទាំងមូលចូលរួមបញ្ចេញយោបល់ និងរួមចំណែកក្នុងការដោះស្រាយលើបញ្ហាទាំងនេះ។

**សំណួរ**-តើនៅពេលណា ទើបច្បាប់កម្មសិទ្ធិបញ្ញាយើងត្រូវបានបង្កើតឡើង? តើគួរចាត់វិធានការដូម្តេច ចំពោះការលួចថតចម្លងអត្ថបទ ក៏ដូចជា បទចម្រៀង នាពេលបច្ចុប្បន្ន?

**ចំលើយ**-ចំពោះសំណួរនេះ លោក វ៉ា រុតសាន បានមានប្រសាសន៍ថា ច្បាប់កម្មសិទ្ធិបញ្ញា គឺត្រូវបានគេបង្កើតរួចទៅហើយ តាំងពីថ្ងៃទី ០៥ ខែមីនា ឆ្នាំ ២០០៣ មកម្លេះ។ ដូច្នេះ កាលណាយើងមានច្បាប់រួចហើយ គឺយើងអាចដាក់ទោសទៅលើបុគ្គលណាដែលបានប្រព្រឹត្តខុស។ ប៉ុន្តែយើងនៅមានបញ្ហាត្រង់ថា ចៅក្រមរបស់យើងមិនទាន់យល់ច្បាស់ អំពីច្បាប់កម្មសិទ្ធិបញ្ញានៅឡើយ។ ហើយអ្វីដែលយើងកំពុងមានការលំបាកទៀតនោះ គឺនៅពេលដែលធ្វើការប្តឹងផ្តល់ម្ចាស់កម្មសិទ្ធិត្រូវចំណាយលុយ។ ហើយប្រទេសកម្ពុជាយើងមិនទាន់កំណត់ច្បាស់នៅឡើយ អំពីកម្រៃរដ្ឋបាល ថាតើម្ចាស់កម្មសិទ្ធិត្រូវបង់ថ្លៃប៉ុន្មាន?

**សំណួរ**-ទាក់ទងនឹងគោលការណ៍ នៅពេលកម្ពុជាចរចាជាមួយ WTO ជាពិសេសកម្មសិទ្ធិបញ្ញានេះ គឺថាអាចមានកិច្ចព្រមព្រៀងលើផ្នែកមគ្គុទេសទេសចរណ៍ជាមួយប្រទេសដែលមានចំណាប់អារម្មណ៍លើវិស័យនេះ។ តើយើងត្រូវធ្វើការដោះស្រាយដូម្តេច? នៅពេលមគ្គុទ្ទេសទេសចរណ៍បច្ចុប្បន្នភាគច្រើន គឺជាជនបរទេស ដូចជា កូរ៉េ ចិន ថៃ កំពុងតែ បម្រើការនៅតាមខេត្តទេសចរណ៍របស់ខ្មែរ ដូចជា ក្រុងព្រះសីហនុ និងខេត្តសៀមរាប។

**ចំលើយ**-ទាក់ទងនឹងសំណួរនេះ លោក វ៉ា រុតសាន បានធ្វើការបកស្រាយថាការបម្រើខាងផ្នែកមគ្គុទេសចរណ៍ នៅខេត្តសៀមរាបពុំមែនជាកិច្ចព្រមព្រៀង ឬជា

កម្មសិទ្ធិបញ្ញានោះទេវាជាសេវាកម្ម។ ហើយលោកបន្ថែមទៀតថា រដ្ឋាភិបាលពុំដែលចុះហត្ថលេខាលើកិច្ចព្រមព្រៀងឱ្យជនបរទេសមកបម្រើលើផ្នែកនេះទេ។

លោកសង្កត់ធ្ងន់ថា បញ្ហានេះត្រូវក្រសួង ឬស្ថាប័នដែលគ្រប់គ្រងផ្ទាល់ជាអ្នកត្រួតពិនិត្យ និងដោះស្រាយ ព្រោះយើងបានចរចាជាមួយ WTO រួចហើយ។ ហើយបើមានជនបរទេ សចង់បម្រើសេវាកម្មលើផ្នែកនេះ គេត្រូវធ្វើការចរចាជាមួយកម្ពុជាយើងជាមុនសិន។

**សំណួរ**-តើ WTO នឹង មានវិធានការយ៉ាងដូចម្តេច? នៅពេលយើងចង់ធ្វើការវិនិយោគទៅលើប្រទេសមួយ ដែលជាសមាជិក WTO ប៉ុន្តែផលិតផលរបស់យើងត្រូវបានគេថតចម្លង។ ហើយក្នុងនោះដែរ យើងបានធ្វើការប្តឹងទៅតុលាការ ប៉ុន្តែច្បាប់នៃប្រទេសនោះបានថែងថា ការលួចចម្លងនេះមិនមានខុសទៅនឹងច្បាប់ប្រទេសគេទេ។

**ចំលើយ**-ទាក់ទងនឹងសំណួរនេះ លោក វ៉ា រុតសាន បានស្រាយបំភ្លឺថា កិច្ចព្រមព្រេង TRIPS គឺជាកិច្ចព្រមព្រៀងស្តង់ដារអន្តរជាតិ ដូចអ្វីដែលលោកបានលើករួចមកហើយថា កាលណាប្រទេសទាំងអស់បានចូលជាសមាជិក WTO គឺប្រទេសទាំងនោះត្រូវតែធ្វើច្បាប់របស់ខ្លួនឱ្យស្របទៅនឹងស្តង់ដារនេះ។ ហើយក្នុងនោះ លោកក៏បានមានប្រសាសន៍បន្តទៀតថា វាជាការធម្មតាទេ កាលណាតែយើងចង់ធ្វើការវិនិយោគទៅក្នុងប្រទេសណាមួយបញ្ហាដំបូង គឺយើងត្រូវសិក្សាអំពីច្បាប់ និងសេដ្ឋកិច្ចរបស់ប្រទេសនោះ យើងមិនអាចធ្វើការវិនិយោគ ដោយមិនដឹងអំពីស្ថានភាពរបស់ប្រទេសនោះបានទេ។

**សំណួរ**-(១) តើរាជរដ្ឋាភិបាលគួរធ្វើការលើកទឹកចិត្តដល់កសិករយ៉ាងដូចម្តេចដើម្បីឱ្យពួកគាត់អាចនាំផលិតផលរបស់គាត់ចូលក្នុងទីផ្សារអន្តរជាតិ ? (២) - នៅពេល

ដែលយើងអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា តើវានឹងមានការប៉ះពាល់យ៉ាងដូចម្តេច ដល់សេដ្ឋកិច្ចកម្ពុជា ?

**ចំលើយ**-ទាក់ទងនឹងសំណួរទី១ លោក វ៉ា រុតសាន បានបកស្រាយថា ក្នុងការលើកទឹកចិត្តដល់កសិករគឺផ្អែកលើច្បាប់បង្ហាញភូមិសាស្ត្រទំនិញ (GI) ដែលបច្ចុប្បន្នអ្នកឯកទេសជំនាញកំពុងធ្វើការសិក្សាស្រាវជ្រាវទៅលើ ៣ មុខ ទំនិញ : រួមមានស្ករត្នោតខេត្តកំពង់ស្ពឺ សូត្រខ្មែរ អង្ករបាត់ដំបង។ នៅថ្ងៃទី ០៣ ខែ កញ្ញា ២០០៦ នាយកដ្ឋានរបស់លោកនឹងធ្វើការខុទ្ទេសនាម មុខទំនិញទាំងបី ដែលខាងលោកបានសិក្សា។ ក្នុងនោះលោក បានបកស្រាយពាក្យថាអង្ករបាត់ដំបង គឺត្រូវតែមានលក្ខណៈតាមក្បួនខ្នាតពីបុរាណ គេត្រូវធ្វើការដាក់ជីតាមលក្ខណៈយ៉ាងដូចម្តេច? ស្ថានជីយ៉ាងដូចម្តេច ទើបគេហៅថាអង្ករបាត់ដំបង? ហើយដែលសព្វថ្ងៃនេះក្រសួងពាណិជ្ជកម្មបានកំពុងសហការជាមួយក្រសួងកសិកម្ម ដើម្បីជួយដល់កសិករ ពីបញ្ហាកម្មសិទ្ធិបញ្ញានេះ ពីព្រោះថា កាលណាយើងអាចកំណត់ច្បាប់ (GI) រួចហើយ គឺផលិតផលកសិកម្មរបស់ប្រជាជនខ្មែរយើងនឹងមានតម្លៃ និងងាយស្រួលលក់នៅក្នុងទីផ្សារអន្តរជាតិ។

*ទាក់ទងសំណួរទី២* លោក ជា សំណាង បានបកស្រាយថា ក្នុងករណីដូចប្រទេសយើងសព្វថ្ងៃ ការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា គឺមានតែខាតទេ ពីព្រោះប្រទេសយើងគឺមិនមែនជាប្រទេសផលិត ដូច្នេះ យើងមានតែការស្រូបយកនូវបច្ចេកវិទ្យាថ្មីៗ ដែលគេទើបនឹងរកឃើញយកមកធ្វើការអភិវឌ្ឍន៍នៅក្នុងប្រទេសយើង។

ឆ្លើយតបទៅនឹងការបកស្រាយរបស់ លោក ជា សំណាង នេះ លោក វ៉ា រុតសាន បានលើកឡើងថា ការគោរពច្បាប់កម្មសិទ្ធិបញ្ញា វាមិនមែនធ្វើឱ្យកម្ពុជាខាតតែរហូតនោះទេ វាមានពេលចំណេញផងដែរ ដូចជាការទាក់ទាញអ្នកវិនិយោគ និងការលើកទឹកចិត្ត។

**សំណួរ**-តើនៅពេលដែលយើងចូលទៅក្នុង WTO នឹងមានផលប៉ះពាល់អ្វីខ្លះទៅលើទីផ្សារក្នុងស្រុក ហើយនឹងផ្តល់ផលចំណេញអ្វីខ្លះ ទៅទីផ្សារក្រៅស្រុក? ព្រោះថាកម្មករ កម្មការនីដែលទៅធ្វើការនៅក្រៅស្រុកភាគច្រើន ទទួលរងនូវការរំលោភសិទ្ធិមកលើពួកគាត់?

**ចំលើយ**-ទាក់ទងនឹងសំណួរនេះ លោក ជា សំណាង បានពន្យល់ថា បើពិនិត្យមើលការបើកទីផ្សាររបស់កម្ពុជា ក្នុងឆ្នាំ១៩៩៣ ក្នុងនោះយើងឃើញថា សេដ្ឋកិច្ចក្នុងឆ្នាំ ១៩៩៣ និង ១៩៩៤ មកដល់បច្ចុប្បន្ន GDP ជាមធ្យម កើនពី 6% ទៅ 7% ក្នុងមួយឆ្នាំ។ ហើយចំណូលអ្នកទីក្រុងឆ្នាំ ១៩៩៤ គឺ ៨00 ដុល្លារ ក្នុងមួយឆ្នាំសំរាប់មនុស្សម្នាក់ៗ ហើយចំណូលអ្នកនៅតាមខេត្ត គឺ ២00ដុល្លារ ក្នុងមួយឆ្នាំ។ ក្នុងនោះបន្ទាប់ពី ១០ ឆ្នាំ ក្រោយមកយើងឃើញថា ចំណូលរបស់អ្នកទីក្រុងកើនឡើងពី ៨00 ដុល្លារ ទៅ ១000ដុល្លារ ប៉ុន្តែ អ្នកនៅតាមបណ្តាខេត្តបានថយចុះពី ២00ដុល្លារ មក ១៨0 ដុល្លារ ក្នុង១ឆ្នាំ។ ដូចនេះវាបានបញ្ជាក់យ៉ាងច្បាស់ថា យើងបានជោគជ័យនៅក្នុងកំណើនសេដ្ឋកិច្ច 6% ទៅ 7% ក្នុងមួយឆ្នាំ ប៉ុន្តែជោគជ័យនេះនឹងមិនបានផ្សាភ្ជាប់ទៅនឹងការកាត់បន្ថយភាពក្រីក្រនោះទេ ព្រោះអង្គការ WTO មិនបានផ្សារភ្ជាប់កសិករទៅនឹងពាណិជ្ជកម្មអន្តរជាតិទេ។ ដូច្នោះ មធ្យោបាយមានតែមួយគត់គឺធ្វើដូចម្តេច ដើម្បីឱ្យប្រជាកសិករមានការយល់ដឹង អំពីការនាំផលិតផលចូលទៅដល់ទីផ្សារអន្តរជាតិ។

**សំណួរ**-តើនៅក្នុងទីក្រុងភ្នំពេញសព្វថ្ងៃ គេហៅថាការអភិវឌ្ឍន៏សេដ្ឋកិច្ច (Economic development) ឬការពង្រីកសេដ្ឋកិច្ច (Economic expansion) ពីព្រោះថា អតិផរណាក៏កើន ហើយ GDP ក៏កើន?

**ចំលើយ**-ទាក់ទងនឹងសំណួរនេះ លោក ជាសំណាង បានបកស្រាយថា បើពិនិត្យមើលលើអតិផរណា យើងឃើញថា ប្រទេសកម្ពុជានៅក្រោម ២ខ្ទង់ ហើយកន្លង

មកលើកលែងនៅក្នុងឆ្នាំ ១៩៩៧ ដែលប្រទេសយើងមានសង្គ្រាមបន្តិបន្តួច យើងឃើញថា អតិផរណាបានកើនឡើង ប៉ុន្តែក្រោយមកបានធ្លាក់ចុះទៅវិញជាធម្មតា។ តែនៅក្នុងឆ្នាំ ២០០៥ គឺអតិផរណាបានកើនឡើង 6% ប៉ុន្តែបើធៀបទៅនឹងប្រទេសដទៃ គឺយើង ឃើញថា 6% មិនមានការប៉ះពាល់ដល់សេដ្ឋកិច្ចទេ លុះត្រាតែឡើងដល់លើសពី១០% ទើបអាចមានបញ្ហា។ ហើយក្នុងនោះ លោកក៏បានបញ្ជាក់ថា អតិផរណាវាមកពីថ្លៃដើម នៃផលិតកម្ម ការនាំចេញនាំចូលអាចមកពីអត្រាប្តូរប្រាក់ ប៉ុន្តែតាមទស្សនៈរបស់លោកផ្ទាល់ គឺបញ្ហាអាចមកពីវត្ថុធាតុដើមដែលជំរុញមកពី កត្តាបីបួនជាពិសេសថ្លៃសាំង។ ទាក់ទងទៅនឹងការបកស្រាយរបស់លោក ជា សំណាង អំពីតួរលេខនៃ GDP របស់ ប្រជាជន លោក វ៉ា រុតសាន បានបដិសេធដោយសួរថា តើទិន្នន័យ ដែលលើកឡើងថា ១៩៩៤ អ្នកទីក្រុងចំណូល ៨០០ដុល្លារ អ្នកជនបទចំណូល ២០០ដុល្លារ ថាតើទិន្នន័យនេះ វាត្រឹមត្រូវដែលរឺទេ នៅពេលដែលយើងយកមកវិភាគ? ពីព្រោះកន្លងមកតួលេខរបស់ក្រសួងពាណិជ្ជកម្មគឺ មានតួរលេខខុសគ្នា ទៅនឹងតួលេខរបស់ IMF។ ហើយចំណុចមួយទៀត លោកសួរថា តើបងប្អូនដែលគាត់ខិតខំធ្វើការនោះ គាត់មិនបានយកប្រាក់ ដែលរកបានផ្ញើទៅស្រុកកំណើតគាត់ទេ ឬអី?

**សំណួរ**- តើច្បាប់កម្មសិទ្ធិបញ្ញា ដែលចេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ជាអនុក្រិត្យ ឬជាសារាចរ?

**ចំលើយ**-ទាក់ទងនឹងសំណួរនេះ លោក វ៉ា រុតសាន បានបញ្ជាក់ វាមិនមែនជាអនុក្រឹត្យ ឬសារាចរទេ តែវាជាច្បាប់កម្មសិទ្ធិបញ្ញា។

**សំណួរ**-ទាក់ទង នឹងច្បាប់កម្មសិទ្ធិបញ្ញា ដូចជាបទចម្រៀង លោក ស៊ិន ស៊ីសាម៉ុត ថាតើកម្មសិទ្ធិរបស់គាត់ នរណាជាអ្នកទទួល (កូនរបស់គាត់ ឬក្រុមហ៊ុនផលិតចម្រៀង ?

**ចំលើយ**-ទាក់ទងនឹងសំណួរនេះ លោក វ៉ា រុតសាន បានបកស្រាយថា រាល់បទចម្រៀងទាំងអស់របស់ លោក ស៊ីន ស៊ីសាម៉ុត អាចមិនមែនជាកម្មសិទ្ធិរបស់លោក ស៊ីន ស៊ីសាម៉ុតទេ តែជាក់ស្តែងជារបស់ក្រុមហ៊ុនផលិតកម្មបទចម្រៀងដែលគាត់មានកិច្ចសន្យាជាមួយ។ ដោយលោកបានលើកនូវឧទាហរណ៍ពីស្ថានភាព បច្ចុប្បន្ន ដូចជា លោក ព្រាប សុវត្ថិ រាល់បទចម្រៀងទាំងអស់របស់ លោកព្រាប សុវត្ថិ គឺជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ហង្សមាស។ ហើយក្នុងនោះ រាល់ឯកសារទាំងអស់ដែល ទាក់ទងនឹងបទចម្រៀងរបស់ លោក ស៊ីន ស៊ីសាម៉ុត បានបាត់បង់អស់ទៅហើយ ដូច្នោះយើងមិនអាចកំណត់បានទេថា តើបទចម្រៀងទាំងរបស់គាត់នោះជារបស់អ្នកណា។ ក្នុងនោះ លោក វ៉ា រុតសាន ក៏បានពន្យល់ពីពាក្យថា សិទ្ធិអ្នកនិពន្ធ គឺជាអ្នកបង្កើតស្នាដៃ ហើយគោលគំនិតរបស់ច្បាប់កម្មសិទ្ធិបញ្ញាមានចំណុចមួយពិសេស នោគឺគំនិតមិនត្រូវបានគេការពារទេ គឺការពារតែស្នាដៃ។

## IV-សេចក្តីសន្និដ្ឋាន

លោកបណ្ឌិត ចាប សុថារិទ្ធិ បានធ្វើការបូកសរុបនូវកិច្ចពិភាក្សារលើកទី៩ ដោយលោកបណ្ឌិតបានមានប្រសាសន៍ថា ជារួមយើងបានចំណេញថ្មីៗច្រើនទាក់ទងនឹងច្បាប់កម្មសិទ្ធិបញ្ញាដែលវាជារឿងថ្មី ហើយយើងជាប្រជាពលរដ្ឋ ជាមន្ត្រីរាជការ និងសង្គមស៊ីវិលត្រូវយល់នូវបញ្ហានេះ។ ក្នុងនោះបញ្ហាទាំងអស់វាជាកាំបិតមុខពីរ ដូចយើងបានស្តាប់មតិរបស់គណៈវាគ្មិន គឺវាអាចចំណេញ និងវាអាចខាត។ ប៉ុន្តែបញ្ហាសំខាន់ យើងជាប្រទេសក្រីក្រ យើងត្រូវការលួចបច្ចេកទេសថ្មីៗខ្លះពីគេ ដើម្បីយកមកកែច្នៃក្នុងគោលបំណងអភិវឌ្ឍប្រទេសជាតិយើង។ ដូច្នេះ កម្មសិទ្ធិបញ្ញាបើយើងគិតទាំងស្រុងតាមច្បាប់អន្តរជាតិ គឺយើងនឹងមានការលំបាក ក្នុងនោះយើងត្រូវរឹតបន្តឹងឱ្យមានប្រសិទ្ធិភាព

នូវច្បាប់ក្នុងស្រុក ដើម្បីអនុលោមទៅតាមច្បាប់កម្មសិទ្ធិបញ្ញាទូទៅ។ លោក បណ្ឌិតក៏បានបន្តទៀតថា អនុសញ្ញាអន្តរជាតិ គឺមានតម្លៃប្រហាក់ប្រហែលច្បាប់រដ្ឋធម្មនុញ្ញ មានន័យថា បើសិនជាយើងចុះកិច្ចសន្យាជាមួយគេហើយ តែអនុសញ្ញានោះវាផ្ទុយនិងគោលការណ៍របស់រដ្ឋធម្មនុញ្ញយើង គឺយើងអាចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់យើងនេះ ក្នុងករណីអនុសញ្ញានោះ វាផ្តល់អត្ថប្រយោជន៍ដល់សង្គមជាតិយើង។ ដូច្នេះ បានជារាជរដ្ឋាភិបាលបានកំពុងខិតខំការពារច្បាប់កម្មសិទ្ធិបញ្ញា ក្នុងគោលបំណងដើម្បីស្រូបយកអ្នកវិនិយោគទុនអន្តរជាតិ ចូលមកបណ្តាក់ទុននៅកម្ពុជា ដែលជាកត្តាយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ច ហើយសព្វថ្ងៃយើងក៏បានឃើញហើយថា វិស័យឯកជន គឺចាប់ផ្តើមមានភាពរស់រវើកជាបណ្តើរៗ ហើយក្នុងនោះលោកបណ្ឌិតក៏បានសង្ឃឹមផងដែរថា អនាគតសេដ្ឋកិច្ចកម្ពុជានឹងប្រសើរជាងនេះ។

# របាយការណ៍សង្ខេបនៃវេទិកា ទី ១០

## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : មេរៀនដែលទទួលបាន និងទិសដៅទៅអនាគត

## I – សេចក្តីផ្តើម

វេទិកាទី១០ ស្តីពី "**កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : មេរៀនដែលទទួលបាន និងទិសដៅទៅអនាគត**" ដែលជាវេទិកាចុងក្រោយនៃគម្រោង ឆ្នាំ ២០០៥ របស់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព។ **លោក ហម សំណាង** អ្នកស្រាវជ្រាវជាន់ខ្ពស់ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ធ្វើជាអ្នកសម្របសម្រួលតំណាងឱ្យ **លោកបណ្ឌិត ចាប សុថារិទ្ធ**។ វេទិកានេះមានវាគ្មិនកិត្តិយសបីរូបគឺ : (១)-**ឯកឧត្តម តែ ដួងតារា** អគ្គនាយកអាជ្ញាធរប្រេងកាតជាតិ, (២)-**លោក ប្រាក់ សេរីវឌ្ឍ** នាយកគ្រប់គ្រងមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា និង (៣)-លោក **ជា ហួត** អ្នកសេដ្ឋកិច្ចនៃធនាគារពិភពលោក។

មុនកិច្ចចាប់ផ្តើមបើកវេទិកា **លោក ហម សំណាង** ក៏បានផ្តួចផ្តើមថា រាល់លទ្ធផលកិច្ចពិភាក្សានៃវេទិកានីមួយៗ ដែលវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ផ្ញើជូនរាជរដ្ឋាភិបាលដើម្បីបានជាគោលគំនិត បទពិសោធន៍សម្រាប់ការ

ស្រាវជ្រាវជាយុទ្ធសាស្ត្រ ធ្វើការប្រកួតប្រជែងនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ បញ្ហាសំខាន់ទាក់ទងទៅនឹងផលប្រយោជន៍ជាតិជាចម្បង។

## II – **ឧបស្រ្ទះទាគ្និនកិត្តិយស**

### ១ ~ ឯកឧត្តម តែ ដួងតារា :

ជាកិច្ចស្វាគមន៍ឯកឧត្តមបានលើកឡើងពីជីវប្រវត្តិរបស់លោក ដូចជា លោកធ្លាប់បម្រើការនៅក្រសួងការបរទេស បន្ទាប់មកលោកទៅបម្រើការនៅ UNDP ក្រោយមកទៀតលោកបានបន្តការសិក្សានៅប្រទេសអូស្រ្តាលី ហើយពេលត្រលប់មកវិញលោក ចូលបម្រើការងាររាជការ **ជាអគ្គនាយក អាជ្ញាធរប្រេងកាតជាតិកម្ពុជា** រហូតដល់សព្វថ្ងៃ។

ជាមួយនឹងបទពិសោធន៍របស់លោកផ្ទាល់ លោកបានលើកយកប្រធានបទ ស្តីពីថាមពលឧសន្ធ័នៅក្នុងប្រទេសកម្ពុជា មកបង្ហាញជូនសមាជិកដែលចូលរួម។ លោកបានលើកឡើងថា ប្រទេសកម្ពុជាមានប្រេងកាត និងឧស្ម័ន ដែលមិនទាន់បានទាញយកមកប្រើប្រាស់នៅឡើយ ហើយស្ថិតនៅក្នុងជម្រៅ ៤ ទៅ ៥ គីឡូម៉ែត្រ។ ជាមួយនេះដែរលោកទទួលស្គាល់ថា តម្លៃនៃការប្រើប្រាស់ឧស្ម័ន និងប្រេងនៅកម្ពុជាសព្វថ្ងៃមានតម្លៃខ្ពស់ ជាហេតុនាំឱ្យតម្លៃភ្លើងក៏ខ្ពស់ទៅតាមនោះដែរ។ លោក បានធ្វើការប្រៀបធៀបតម្លៃភ្លើងនៅកម្ពុជាបច្ចុប្បន្នថា មានតម្លៃប្រហែលនៅប្រទេសជប៉ុន និងសាំងហ្គាពួរតែបើធៀបចំណូលប្រចាំថ្ងៃគឺមានការខុសគ្នាឆ្ងាយ។ លោកបានលើកឡើងថា បើនិយាយពីប្រេងកាតនៅកម្ពុជា គឺមានការរុករកតាំងពីឆ្នាំ ១៩៦០ ម្ល៉េះ ហើយមុនរបបខ្មែរក្រហមគ្រប់គ្រងប្រទេស គេបានខួងអណ្តូងចំនួនបីនៅក្នុងដែនសមុទ្រកម្ពុជា ហើយលទ្ធផល

ឃើញថា មានប្រេងកាតពិតប្រាកដមែន តែមិនមានលក្ខណៈជាពាណិជ្ជកម្មមានន័យថា ផលដែលទទួលបាននោះ គឺតិចជាងការចំណាយ ។ បើនិយាយពីការខួងយកប្រេងកាតនេះ គេត្រូវប្រើចំណេះដឹងផ្សំគ្នាជាច្រើន ដូចជា អ្នកបច្ចេកទេស មេកានិច វយៈសម្លេង ធរណីវិទ្យា ។ ពេលទទួលបានលទ្ធផល ហើយគេត្រូវធ្វើការវិភាគដោយប្រើប្រព័ន្ធ IT ។ គេត្រូវធ្វើការវិភាគទិន្នន័យថា កន្លែងណាអាចខួងបានហើយអាចទាញយកផលចំណេញ ។ លោកបញ្ជាក់ថា ការសិក្សាទៅលើអណ្តូងមួយអាចប្រើពេលពី ៥ ទៅ ៧ឆ្នាំ ។ កន្លងមក រដ្ឋាភិបាល បានអនុញ្ញាតឱ្យក្រុមហ៊ុនប្រេងអាមេរិក ឈ្មោះ Chaveron Texaco រុករកប្រេងកាតនៅក្នុងដែនសមុទ្រកម្ពុជា ។ ក្រុមហ៊ុននេះបានខួងអណ្តូងចំនួន ៦ ក្នុងនោះ ៤ ឃើញថាមានប្រេងកាត ហើយអណ្តូងទី ៥ ឃើញថា មានឧស្ម័ន នេះជាលទ្ធផលវិជ្ជមាន ។ លោកបានបញ្ជាក់ថា ការរុករករបស់ក្រុមហ៊ុនអាមេរិកនៅក្នុងដែនសមុទ្រនេះ គ្រាន់តែជាតំបន់មួយ ក្នុងចំណោមតំបន់ធំៗទាំង ៦ ដែលសំបូរប្រេងកាតនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ។ ឯកឧត្តមបញ្ជាក់បន្ថែមផងដែរថា ការអនុញ្ញាតឱ្យរុករកប្រេងមិនអាចចេះតែធ្វើទៅបាននោះទេ គឺត្រូវពិនិត្យពីគោលការណ៍របស់ក្រុមហ៊ុននោះ ឱ្យបានច្បាស់ជាមុន ។ កន្លងមកមានក្រុមហ៊ុនបរទេសជាច្រើនចង់បណ្តាក់ទុនលើផ្នែកនេះ តែដល់ពេលរដ្ឋាភិបាលហៅសួរទៅ គឺមិនមានលក្ខណៈតាមស្តង់ដារទេ ដូចច្នេះ រដ្ឋាភិបាលពុំបានអនុញ្ញាតឱ្យឡើយ ។ ជាមួយនិងការុករកបច្ចុប្បន្ន លោកសង្ឃឹមថា នៅឆ្នាំ ២០០៨ ឬ ២០០៩ កម្ពុជាអាចផលិតប្រេងកាតនៅក្នុងប្រទេសជាលើកទី ១ ។

## ២.លោក ច្រាក់ សេរីវឌ្ឍ

ជាមួយបទអន្តរាគមន៍របស់លោក លោកបានលើកយកផ្នែកកសិកម្មទូទៅ នៅលើពិភពលោក តាមរយៈបទពិសោធន៍របស់ប្រទេសមួយចំនួនភ្ជាប់ជាមួយ WTO មក

បង្ហាញជូនអង្គសិក្ខាសិលា។ ដំបូងលោកបញ្ជាក់ពី ការវិវត្តន៍របស់ GATT មកជា WTO ព្រោះតែទំហំពាណិជ្ជកម្មមានការរីកចម្រើននៅពាសពេញពិភពលោក។ បន្ទាប់មកលោកលើកឡើងថា កម្ពុជា និងនេប៉ាល់ ក្លាយជាសមាជិក WTO នៅក្នុងឆ្នាំ ២០០៣ ក្នុងនាមជាប្រទេស LDC។ ហើយគោលការណ៍របស់ WTO ចង់សំដៅដល់ អត្ថប្រយោជន៍ធៀប (Comparative Advantage) ព្រោះប្រទេសនីមួយៗ មានលក្ខណៈពិសេសផ្ទាល់ខ្លួន។ គំនិតដើមរបស់ WTO ដំបូងគេចង់ធ្វើការផ្លាស់ប្តូរទំនិញគ្នាពីតំបន់មួយទៅតំបន់មួយ។ ឧទាហរណ៍ តំបន់ដែលអនុគ្រោះចំពោះដំណាំស្រូវ គឺផលិតតែស្រូវទៅបានហើយ មិនបាច់រកវិធីក្នុងការផលិតដំណាំផ្សេងទៀតនោះទេ ហើយតំបន់ផ្សេងទៀត អនុគ្រោះចំពោះការចិញ្ចឹមសត្វ គឺចិញ្ចឹមតែសត្វបានហើយ។ គោលការណ៍របស់គេ គឺធ្វើដូចច្នេះហើយ តំបន់ផ្សេងៗគ្នានេះត្រូវធ្វើការផ្លាស់ប្តូរទំនិញគ្នា ដើម្បីឱ្យបានចំណេញទាំងអស់គ្នា។ ក៏ប៉ុន្តែ គោលការណ៍នេះមិនបានជោគជ័យឡើយ ព្រោះការអនុវត្តន៍នៅតែមានរបាំង។ លោកបានលើកឡើងថា នៅប្រទេសអភិវឌ្ឍន៍គេនៅតែការពារផលិតផលកសិកម្មជានិច្ច ដោយរដ្ឋាភិបាលបានទំនុកបម្រុងដល់កសិករប្រទេសគេ។ ការទំនុកបម្រុងនេះ ព្រោះគេយល់ថា បញ្ហាស្បៀងអាចប៉ះពាល់ដល់សន្តិសុខជាតិ ហេតុដូចនេះហើយ គេចង់បានឯករាជ្យភាពសម្រាប់ស្បៀងអាហារ។ លោកលើកយកឧទាហរណ៍ ដែលប្រទេសជប៉ុន និងអាមេរិកទាស់គ្នាលើផលិតផលកសិកម្ម។ ប្រទេសជប៉ុន អនុញ្ញាតឱ្យអាមេរិកនាំចូលស្រូវ តែមានការកម្រិតពន្ធនាំចូលខ្ពស់ ហេតុនេះហើយ អាមេរិកធ្វើការតវ៉ា ព្រោះថា ការធ្វើស្រូវនៅប្រទេសជប៉ុនត្រូវចំណាយលើសការធ្វើស្រូវនៅប្រទេសអាមេរិក ៧ ដង។ ហេតុនេះ អាមេរិកប្រាប់ជប៉ុនថា ដោយសារការចំណាយខ្ពស់ អ្នកឯងមិនចាំបាច់ផលិតទេ ចាំទទួលស្រូវនាំចូលពីអាមេរិកទៅបានហើយ។ តែសំណើនេះ ជប៉ុនមិនយល់ព្រម គេនៅតែការពារផលិតផលស្រូវរបស់គេ ព្រោះគេ

យល់ថា បើគេបើកឱ្យចូលកសិកររបស់គេនឹងជួបប្រទះនៅការលំបាក។ ហើយម្យ៉ាងទៀត ខ្លាចមានបញ្ហាទៅថ្ងៃក្រោយក្នុងករណី អាមេរិក និងជប៉ុន មានទំនាស់លើបញ្ហាផ្សេងៗ ជាហេតុនាំឱ្យអាមេរិកបញ្ឈប់ការនាំស្រូវចូលប្រទេសជប៉ុន ពេលនោះនឹងរឹតតែធ្វើឱ្យប៉ះពាល់កាន់តែធ្ងន់ធ្ងរលើបញ្ហាសន្តិសុខស្បៀង។

ជាមួយនឹងការចរចាមិនត្រូវគ្នាសព្វថ្ងៃនេះ គឺថាប្រទេសអភិវឌ្ឍ នៅតែប្រើវិធីក្នុងការទប់ផលិតផលពីខាងក្រៅដដែល គេបាននិយាយថាគេបន្ថយពន្ធលើការនាំចូលផលិតផលកសិកម្មពីក្រៅ តែបែរជាទៅទំនុកបម្រុងដល់កសិកររបស់គេវិញ។ ដូច្នេះមានន័យតែមួយដដែល ព្រោះថារដ្ឋសុខចិត្តចេញខាតជូនកសិករ។ ដូចដឹងហើយថានៅប្រទេសអភិវឌ្ឍមួយចំនួនការផលិតស្រូវត្រូវចំណាយខ្ពស់ ដូច្នេះ ពេលរដ្ឋចេញខាតជួសកសិករធ្វើឱ្យទំនិញនាំចូលពីខាងក្រៅពិបាកនឹងប្រកួតប្រជែងដដែល។ បច្ចុប្បន្ននេះប្រទេសអ្នកមានកំពុងតែសូមរក្សាការទំនុកបម្រុងនេះនៅដដែល តែប្រទេសក្រីក្រមិនយល់ព្រមដោយតម្រូវឱ្យលុបចោល។ ជាមួយគ្នានេះ លោកក៏បានលើកឡើងផងដែរថា ការមិនស្មើភាពគ្នាក្នុងការនាំទំនិញចេញ ក៏ជាបញ្ហាសម្រាប់ប្រទេសក្រីក្រផងដែរ ដូចជាទំនិញនាំចូលពីប្រទេសអ្នកមានមកប្រទេសអ្នកក្រ តាមរយៈការត្រួតពិនិត្យគុណភាពធ្វើមិនឱតដល់ប៉ុន្មានឡើយ ហើយការនាំចូលនេះមិនសូវមានបញ្ហាទេ។ តែសម្រាប់ការនាំចេញទំនិញពីប្រទេសអ្នកក្រទៅកាន់ប្រទេសអ្នកមានវិញ គឺថាការត្រួតពិនិត្យតែងតែមានបញ្ហាដោយគេយកលេសថាទំនិញគ្មានស្តង់ដារ។ ជាមួយ នឹងការបញ្ជាក់ជាចុងក្រោយ លោកបានលើកឡើងថា ក្រោយបរាជ័យក្នុងការពិភាក្សា គ្នានៅកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី ៥ ឃើញថាប្រទេសជាសមាជិក WTO ទាំងអស់មានការបែកខ្ញែកគ្នាជាក្រុមៗរួមមាន G33 មួយក្រុមដែលក្រុមនេះមានផលប្រយោជន៍ស្រដៀងគ្នា។ មួយក្រុមទៀត G20 ហើយមួយក្រុមទៀត LDC និងក្រុមមួយទៀត គេហៅ EU-US

ដែលក្រុមនេះមានទស្សនៈស្រដៀងគ្នា។ បច្ចុប្បន្ននេះ អាមេរិក និងអឺរ៉ុប ក៏មានការខ្វែងគំនិតគ្នាមួយចំនួនផងដែរ ជាពិសេស ជាមួយបារាំងទាក់ទាងទៅនឹងដំណាំភូមិសាស្ត្រ។ ឧទាហរណ៍ ដូចជាក្រូចពោធិសាត់ ឬបាត់ដំបងមានរស់ជាតិឆ្ងាញ់ពិសេសមួយ ទោះបីជាកន្លែងផ្សេងមានដាំក្រូចពោធិសាត់ដូចគ្នា ឬយកពូជក្រូចពោធិសាត់ ពីបាត់ដំបងទៅដាំក៏ដោយ ក៏ក្រូចពោធិសាត់ បាត់ដំបងនៅតែត្រូវបានលើកតម្លៃ ព្រោះថានៅខេត្តបាត់ដំបងមានអាកាសធាតុបរិយាកាសខុសពីតំបន់ផ្សេងទៀត។

ចំពោះប្រទេសកម្ពុជា លោកបានលើកឡើងថា កម្ពុជាមិនចូល WTO ក៏ដូចចូល WTO ដែរ ព្រោះយើងបើកចំហច្រើន ហើយប្រព័ន្ធពន្ធគយប្រទេសយើង គឺទាបជាមធ្យម ៧%។ ប្រព័ន្ធពន្ធគយប្រទេសយើងនៅចន្លោះ ពី ៥% ទៅ ៦០%។ ហើយ ៦០%នេះ គឺសំដៅទៅលើការនាំចូលបារី ស្រាបៀ តែប៉ុណ្ណោះ ។ បើធៀបទៅប្រទេសផ្សេងទៀត ឃើញថា ការយកពន្ធសរុបទៅលើការនាំចូលបារី គឺ ២០០%។

## ៣ ~ លោក ជា ហួត

លោកបានលើកឡើងថា ទោះនៅក្នុង WTO តែងតែមានទំនាស់ពាក្យសម្ដីគ្នារវាងប្រទេស LDC និង ប្រទេសអភិវឌ្ឍជាច្រើនលើកច្រើនសារ ព្រោះតែការធ្វើពាណិជ្ជកម្មមិនស្មើភាពគ្នា។ តែប្រទេសមួយចំនួនធំកាន់តែយល់ដឹងជ្រៅទៅៗ ពីការធ្វើពាណិជ្ជកម្មសេរីនេះ។ លោកបន្ថែមទៀតថា ប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចតែងតស៊ូយ៉ាងស្វិតស្វាញ ដើម្បីការពារផលិតផលប្រទេសរបស់ខ្លួន ជាពិសេសផ្នែកកសិកម្ម។ ជារួមពាណិជ្ជកម្មពិភពលោកមានការកើនឡើង បើធៀបទៅនឹងផលទុនសរុបរបស់ពិភពលោកដោយមានកើនឡើងពី ៣៣% ដល់ ៤១%។ លោកបានលើកឡើងថា ប្រទេសដែលផ្ដួចផ្ដើមគំនិតឱ្យមានការធ្វើពាណិជ្ជកម្មសេរីដំបូង គឺប្រទេស

ដែលមានការអភិវឌ្ឍន៍ខ្ពស់មិនមែនជាប្រទេសក្រីក្រតូចតាចទេ។ គេបានធ្វើការបញ្ចុះបញ្ចូលប្រទេសក្រីក្រឱ្យធ្វើការប្រកួតប្រជែងសេរីជាមួយគេ តែគេបានកេងចំណេញពីប្រទេសក្រីក្រជាច្រើន ជាពិសេសផ្នែកកសិកម្មជាបញ្ហាក្ដៅគគុក។ លោកបានលើកពីភាពជាក់ស្ដែងថា ដូចជានៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីនៅឆ្នាំ ២០០១ ទីក្រុងដូហានៃប្រទេសកាតាមានការបរាជ័យធំណាស់ ព្រោះតែប្រទេសក្រីក្របានដើរចេញពីតុប្រជុំ ព្រោះតែយល់ថា ប្រទេសអភិវឌ្ឍគ្មានបំណងជួយដល់ប្រទេសកំពុងអភិវឌ្ឍ ក្នុងការសម្រួលបែបបទនាំចេញផលិតផលកសិកម្ម។ មិនតែប៉ុណ្ណោះ គេថែមទាំងដាក់ល័ក្ខខ័ណ្ឌតឹងរ៉ឹងទៀតផង។ លោកបានលើកយកឧទាហរណ៍ ពីល័ក្ខខ័ណ្ឌដែលប្រទេសអភិវឌ្ឍមួយចំនួនបានធ្វើ ដូចជា សហគមអឺរុបអនុញ្ញាតឱ្យប្រទេសក្រីក្រនាំចូលកាហ្វេគ្រាប់ដោយសេរីក្រោមច្បាប់ WTO តែគេដាក់ល័ក្ខខ័ណ្ឌថា ប្រសិនបើនាំចូលកាហ្វេដែលមានការវេចខ្ចប់រួច គេយកពន្ធ ៣០%។ ចំពោះផលិតផលកាកាវក៏ដូច្នេះដែរ ប្រសិនបើនាំចូលកាកាវឆៅទៅគេមិនយកពន្ធទេ តែបើនាំចូលកាកាវដែលមានការវេចខ្ចប់ត្រឹមត្រូវគេយកពន្ធ១២%។ ចំពោះប្រទេសជប៉ុន នៅតែមានការកម្រិកឱ្យនាំចូលអង្ករតិចតួចបំផុត។ ឧទាហរណ៍ ជប៉ុនអនុញ្ញាតឱ្យនាំចូលអង្ករ ១០០ ០០០០ តោន ដោយមិនយកពន្ធ តែបើលើសពីចំនួននេះ គេនិងយកពន្ធ ៤០០ យ៉េនក្នុង១គីឡូក្រាម បើគិតទៅប្រហែលជាង ៣ ដុល្លារអាមេរិក។ ដូច្នេះ គ្រាន់តែពន្ធដែលគេយកវាថ្លៃជាងអង្ករស្រុកខ្មែរយ៉ាងច្រើន។ ដូចច្នេះ បើយើងគិតទៅ ឃើញថាប្រទេសអភិវឌ្ឍគេបានប្រើឱកាសនេះ ដើម្បីទប់ប្រទេសក្រីក្រ ដែលមានតែផលិតផលកសិកម្មដើម្បីនាំចេញ។ លើសពីនេះទៀត លោកក៏បានបញ្ជាក់ផងដែរថា ប្រទេសអភិវឌ្ឍន៍មួយចំនួនគេបានជួយដល់កសិកររបស់គេជាច្រើនលើផ្នែកកសិកម្ម។ គេជួយចំណាយខាតដើម្បីឱ្យកសិករគេអាចធ្វើការប្រកួតប្រជែង ហើយនាំទៅក្រៅប្រទេសបាន។ គ្រាន់តែប្រទេសសហគមអឺរុប និងអាមេរិក

គេជួយកសិករគេ ៣០០ ពាន់លានដុល្លារ។ ដូច្នេះ បើធៀបមកប្រទេសក្រីក្រវិញ តើរដ្ឋាភិបាលបានអ្វីជួយចំពោះកសិកររបស់ខ្លួន ហេតុដូច្នេះហើយ ធ្វើឱ្យកសិករប្រទេសក្រីក្រពិបាកនឹងធ្វើការប្រកួតប្រជែងណាស់។ មិនត្រឹមតែដាក់កម្រិតលើពន្ធទេ ថែមទាំងមានយុទ្ធសាស្ត្រទប់ផលិតផលរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាការមិនទទួលស្គាល់គុណភាព SBS ដែលសុទ្ធតែជាបញ្ហាស្មុគស្មាញសម្រាប់ប្រទេសក្រីក្រផងដែរ។ តែជាមួយគ្នានេះ លោកសង្ឃឹមថា ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៦ នៅទីក្រុងហុងកុង នាថ្ងៃទី ១៣ ដល់ ១៨ ធ្នូ ឆ្នាំ ២០០៥ បញ្ហាស្មុគស្មាញនានានឹងត្រូវបានដោះស្រាយ។

## II - **មតិពិភាក្សា :**

ជាការផ្តើមកិច្ចពិភាក្សា **លោក ហាម សំណាង** អ្នកសម្របសម្រួលកម្មវិធីបានបំផុសឱ្យសមាជិក សមាជិកាអាចសួរទៅគណៈវាគ្មិនកិត្តិយស ឬអាចលើកយក នូវបទពិសោធន៍ផ្សេងៗ ដែលបានជួបប្រទះមកបង្ហាញជូនអង្គសិក្ខាសិលាទាំងមូលបានជ្រាប ជាពតិមាន ឬទុកជាចំណេះដឹងផងដែរ។

**សំណួរ**-ជាមួយនឹងក្តីសង្ឃឹមថា ឆ្នាំ ២០០៨ ឬ ២០០៩ កម្ពុជាអាចផលិតប្រេងកាតបាន។ តើសក្តានុពលដែលអាចទាញយកនោះ បើគិតជាលុយប្រហែលប៉ុន្មានលានដុល្លារក្នុងមួយឆ្នាំ? ហើយអាចផលិតបានប៉ុន្មានឆ្នាំ?

**ចំលើយ**-ចំពោះសំណួរនេះ **ឯកឧត្តម តែ ដួងតារា** បញ្ជាក់ថា ការអនុញ្ញាតឱ្យរុករកប្រេងសព្វថ្ងៃនេះ គឺស្ថិតនៅក្នុងប្លុកធំមួយក្នុងចំណោមប្លុកធំៗ ទាំង ៦ (A B C D E F)ជាចំណុចសម្រាប់កំណត់តំបន់ ដែលសំបូរប្រេងកាតហើយស្ថិតនៅក្នុងទឹកដីកម្ពុជា ១០០ %) ដែលសំបូរប្រេងកាតនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ហើយប្លុក A (តំបន់អនុញ្ញាតឱ្យរុករកបច្ចុប្បន្ននេះ) មានទំហំ ៦២៧៨ គីឡូម៉ែត្រ។

ហើយតាមការប្រមាណមើលមានប្រហែល ៥០០ លានបារ៉ែល[3] barells គិតជាប្រេងបូកជាមួយឧស្ម័នធម្មជាតិប្រហែល ៥ TCS (Trillion Cubics )។ ហើយក្នុង ១០០.០០០.០០០.០០០.០០០ (មួយរយពាន់កោដ្ឋ) នៃឧស្ម័នអាចយកទៅប្រើសម្រាប់រោងចក្រអគ្គិសនីដែលដើរដោយឧស្ម័នបាន ២០ ឆ្នាំ ចំពោះរោងចក្រដែលមានកម្លាំង ១.០០០ មេកាវ៉ាត់។ ហើយសម្រាប់សំណួរថា យើងអាចប្រើបានប៉ុន្មានឆ្នាំ ត្រូវគិតតទៅទៀត។ ឯកឧត្តមបញ្ជាក់បន្ថែមទៀតថា សព្វថ្ងៃយើងមិនទាន់គិតចំពោះតំបន់ត្រួតស៊ីគ្នាជាមួយថៃ ដែលមាន ៤ តំបន់ ហើយបើគិតជាក្រលាផ្ទៃប្រហែល ៣០ ពាន់គីឡូម៉ែត្រការ៉េនោះផងទេ។ ហើយការប្រមាណគិតជាលុយ ចំពោះប្លុក A អាចបាន ពី ៥០០ លានដុល្លារអាមេរិក ទៅ ១០០០ លានដុល្លារអាមេរិក។

**សំណួរ**-កម្ពុជាធ្លាប់ចរចាជាមួយថៃ ដើម្បីទាញយកប្រេងកាតនៅដែនសមុទ្រត្រួតស៊ីគ្នា តែភាគីថៃមិនអនុញ្ញាតឱ្យយកទេ ព្រោះខាងដីកម្ពុជាប្រេងកាតស្ថិតនៅជម្រៅជ្រៅជាងខាងថៃ។ ដូច្នេះ ពេលកម្ពុជាទាញយកអាចធ្វើឱ្យប្រេងកាតខាងប្រទេសគេហូរចូលមកកម្ពុជា។ តើបញ្ហានេះ កម្ពុជាត្រូវដោះស្រាយយ៉ាងណា?

**ចំលើយ**-បញ្ហានេះ **ឯកឧត្តម តែ ដួងតារា** បានលើកឡើងថា កម្ពុជាមិនមែនមានតំបន់ត្រួតស៊ីគ្នាតែជាមួយថៃនោះទេ ជាមួយវៀតណាមក៏មានផងដែរ។ លើបញ្ហានេះ កម្ពុជាមានយន្តការដើម្បីដោះស្រាយគ្រប់កម្រិត ហើយកម្រិតខ្ពស់ជាងគេគឺថ្នាក់នាយករដ្ឋមន្ត្រី បន្ទាប់មកកម្រិតរដ្ឋមន្ត្រី។ ហើយចំពោះគោលការណ៍ក្នុងការចរចា

---

[3] បារ៉ែល សំដៅធុងឈើសម្រាប់ដាក់ស្រា ឬស្រាបៀ និង ប្រេងកាត ដែលត្រូវបានគេយកមកធ្វើជារង្វាស់រង្វាល់ចំណុះ ។១ បារ៉ែល មានចំណុះ ៤២ ហ្គាឡុង (អាមេរិចUS gallons) ឬ ៣៥ ហ្គាឡុង (អង់គ្លេស) ឬប្រហែល ជា ១៥៩ លីត្រ។

គឺផ្អែកលើច្បាប់អន្តរជាតិ ឬច្បាប់សមុទ្រ ការអនុវត្តន៍សម្រាប់រដ្ឋនីមួយៗ ប្រវត្តិសាស្ត្រ . . . ។ល។ ហើយចំពោះលក្ខណៈ អ្នកត្រូវធ្វើការចរចា គឺត្រូវមានស្មារតីរឹងប៉ឹងចេះអត់ធ្មត់ ហើយមានលក្ខណៈបត់បែន និងត្រូវរៀបយុទ្ធសាស្ត្រជាមុន។

**សំណួរ**-ការទាញយកឧស្ម័ន និងប្រេងកាតនៅឆ្នាំ ២០០៨ ឬ ២០០៩។ តើគេត្រូវប្រើធនធានមនុស្សជាជនជាតិខ្មែរប៉ុន្មានភាគរយ ហើយបរទេសប៉ុន្មានភាគរយ? ក្រោយពីចម្រាញ់ប្រេងកាត តើកាកសំណល់ដែលសល់រដ្ឋមានយុទ្ធសាស្ត្រកែច្នៃធ្វើអ្វីទៀត? ហើយការទាញយកនេះក្នុងរយៈពេលប៉ុន្មានឆ្នាំធនធានទាំងនោះនឹងអស់?

**ចំលើយ**-បញ្ហានេះ ឯកឧត្តមបញ្ជាក់ថា ធនធានមនុស្ស យើងចង់យកជនជាតិខ្មែរណាស់តែបញ្ហាសំខាន់ តើធនធានយើងមានជំនាញដែរឬទេ។ ឯកឧត្តមបន្ថែមទៀតថា ប្រសិនបើចង់ប្រើធនធានយើងទាល់តែទៅហ្វឹកហ្វឺនជំនាញ នៅក្រៅប្រទេសទើបអាចទៅរួច។ ជាមួយនេះ ឯកឧត្តមបានអំពាវនាវឱ្យនិស្សិត បញ្ញវន្តខ្មែរ ត្រូវខិតខំរៀនសូត្រឱ្យមានជំនាញពិតប្រាកដដើម្បីជួយអភិវឌ្ឍប្រទេសជាតិ។ ចំពោះប្រេងកាតដែលអាចទាញយកបាននេះ ដំបូងគេយកប្រេងឆៅ ហើយប្រេងឆៅនេះពុំមានចោលអ្វីនោះទេ គេអាចកែច្នៃទៅជាប្រេងសម្រាប់យន្តហោះ ប្រេងម៉ាស៊ីន ប្រេងម៉ាស៊ូត ប្រេងកាត ហើយចុងក្រោយអាចកែច្នៃទៅកៅស៊ូសម្រាប់ចាក់ថ្នល់ . . . ។ល។

**សំណួរ** - ការចរាចរប្រាក់ដុល្លាអាមេរិកនៅកម្ពុជាបច្ចុប្បន្នមានប៉ុន្មានភាគរយ?

**ចំលើយ-លោក ជា ហួត** បានបង្ហាញថា ការចរាចរលុយដុល្លានៅស្រុកខ្មែរបច្ចុប្បន្ន បើគិតសរុបមានប្រហែល ៩៦.៤% ។ ហើយលុយខ្មែរមានប្រហែល តែ ៤.៦% តែប៉ុណ្ណោះ។ តួរលេខនេះគឺ មានការទទួលស្គាល់ ពី IMF WB ហើយ ធនាគារជាតិនៃកម្ពុជាក៏ទទួលស្គាល់ផងដែរ។ លោកបានបន្ថែមទៀតថា មានទស្សនៈច្រើនយល់ខុសគ្នា

លើបញ្ហានេះ អ្នកខ្លះថាល្អហើយអ្នកខ្លះថាមិនល្អ។ តែចំពោះប្រទេសនៅអាមេរិកឡាទីន មួយចំនួនក៏គេប្រើដុល្លារច្រើនជាងលុយជាតិរបស់ខ្លួនផងដែរ ដូចជាអ៊ុយរូហ្គាយ . .។ល។

**សំណួរ**-នៅក្នុង WTO បញ្ហាក្តៅគគុកគឺកសិកម្ម។ ហើយនៅកម្ពុជាកសិកម្ម ជាផ្នែកមួយនៃផ្នែកទាំង ៤ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ តើរដ្ឋាភិបាលមានយុទ្ធ-សាស្ត្រ ក្នុងការធ្វើ Subsidy (ទំនុកបម្រុង) ដល់កសិករយ៉ាងណាដែរ?

**ចំលើយ**-ចំពោះបញ្ហានេះ លោក **ច្រាក់ សេរីវឌ្ឍ** លើកឡើងថា ដោយយើងជាប្រទេសក្រីក្រ ដូច្នេះ រដ្ឋាភិបាលទោះបីជាមានឆន្ទៈក្នុងការផ្តល់ Subsidy ក៏ដោយក៏គ្មានលទ្ធភាពដែរ។ តែជាមួយនេះលោកលើកបង្ហាញថា ពេលខ្លះក៏អាចថាជា Subsidy មួយរបស់រដ្ឋាភិបាលផងដែរ ដូចជាការស្ថាបនានូវប្រព័ន្ធស្រោចស្រពសម្រាប់ដំណាំកសិកម្មរបស់ប្រជាពលរដ្ឋដោយមិនប្រមូលកម្រៃមកវិញ ការផ្សព្វផ្សាយនូវវិធីសាស្ត្រក្នុងការថែទាំដំណាំ ឬផ្សព្វផ្សាយបច្ចេកវិទ្យាផ្សេងៗ គ្រាន់តែបច្ចុប្បន្នរដ្ឋាភិបាលមិនទាន់មានលទ្ធភាពផ្តល់ជាសាច់លុយសុទ្ធដល់កសិករ។ បន្ថែមពីលើនេះ លោកបានលើកឡើងផងដែរ ពីការជ្រោមជ្រែងកន្លងមករបស់រដ្ឋាភិបាល តែពុំមែនជា Subsidy ដូចជា កន្លងមកនៅពេលមានភាពរាំងស្ងួត ដែលបណ្តាលឱ្យប្រជាកសិករ អស់ស្រូវពូជ គឺឃើញមានរដ្ឋាភិបាលបានផ្តល់ជាស្រូវពូជឱ្យដល់កសិករ។

បន្ថែមលើសំណួរនេះ **លោក ហាម សំណាង** ក៏បានលើកឡើងផងដែរថា ចំពោះ Subsidy របស់រដ្ឋាភិបាលទៅលើកសិករ គឺមានគ្រាន់តែជាលក្ខណៈប្រយោល។ តែបញ្ហាសំខាន់មួយដែលលោកចង់លើកឡើងនោះ គឺការមិនយកពន្ធដី ពន្ធផលិតផលដែលកសិករធ្វើបានបើធៀបទៅប្រទេសគេ នេះគឺថារដ្ឋាភិបាលបានគិតគូរដកពន្ធរួចជាស្រេច។ នេះក៏ជាការបំពេញបន្ថែម ឬឧបត្ថម្ភធនមួយដែរ។

**សំណួរ**-ទោះបីបច្ចុប្បន្នកម្ពុជាមានទីផ្សារ WTO ក្តី។ តើរដ្ឋាភិបាលទិសដៅក្នុងការស្វែងរកទីផ្សារផ្សេងទៀត ក្រៅពីការចរចាស្វែងរកទីផ្សារជាមួយ WTO ដែរឬទេ?

**ចំលើយ**-លើបញ្ហានេះ **លោក ប្រាក់ សេរីវឌ្ឍ** បានលើកឡើងថា ប្រទេសមួយចំនួនដែលជាសមាជិក WTO បានងាកថយក្រោយមកធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី FTA ព្រោះតែមិនយល់ស្របគ្នាលើកិច្ចព្រមព្រៀងកសិកម្ម។ FTA មានលក្ខណៈខុសគ្នាពី WTO ព្រោះជាទូទៅការធ្វើពាណិជ្ជកម្មនៅក្នុង WTO គឺត្រូវតែអនុវត្តទូទៅ មានន័យថា ប្រសិនបើយើងធ្វើពាណិជ្ជកម្មជា អាមេរិកដូចម្តេចយើងត្រូវធ្វើពាណិជ្ជកម្មជា មួយប្រទេសផ្សេងទៀតដូច្នោះដែរ។ តែចំពោះ FTA វិញគឺជាកិច្ចព្រមព្រៀងរវាង ប្រទេសមួយនិងប្រទេសមួយ។ ឧទាហរណ៍ ដូចជាថ្មីៗនេះប្រទេសថៃ មានធ្វើ FTA ជាមួយអាមេរិក អូស្រ្តាលី និងជាមួយបណ្តាប្រទេសផ្សេងៗទៀតជាច្រើន នេះព្រោះតែមានការខ្វែងគំនិតគ្នានៅក្នុង WTO។ ចំពោះកម្ពុជាយើងវិញ កំពុងតែរៀបចំធ្វើ FTA ជាមួយសហរដ្ឋអាមេរិកជាមួយចិន . . . ។ល។ លោកបានបញ្ជាក់ថា តាមបទពិសោធន៍កន្លងមក FTA មានលក្ខណៈអាក្រក់ជាង WTO ទៅទៀត ព្រោះការធ្វើ FTA វានឹងបើកចំហទាំងអស់។ ដូច្នេះប្រទេសអ្នកមាននឹងគ្របដណ្តប់លើប្រទេសក្រីក្រជាដៃគូរ។

បន្ថែមលើសំណួរនេះ **លោក ជា ឃួត** បានបង្ហាញថា បច្ចុប្បន្នរដ្ឋាភិបាលបានចរចាជាទ្វេរភាគីជាមួយបណ្តាលប្រទេសមួយចំនួន មានប្រទេសជប៉ុនបានអនុញ្ញាតឱ្យកម្ពុជានាំចូលទំនិញ ២៧៦ មុខ ចំណែកចិន ២៩៦មុខ អត់យកពន្ធ អត់កំណត់បរិមាណ ហើយអាមេរិកអនុញ្ញាតឱ្យនាំចូល ៦000 មុខ។ តែយើងបាននាំចូលតែផលិតផល សម្លៀកបំពាក់ និងសាច់ក្រណាត់តែបន្តិចបន្តួចប៉ុណ្ណោះ និងជាមួយប្រទេស

កាណាដា គឺថាកាណាដាអនុញ្ញាតឱ្យយើង នាំចូលនូវទំនិញគ្រប់មុខទាំងអស់ លើកលែងតែសញ្ញវ៉ុធតែយើងមិនទាន់បាននាំចេញអ្វីគួរឱ្យកត់សំគាល់ឡើយ ។ ប៉ុន្តែបច្ចុប្បន្ន គេហាមនាំចូលសញ្ញវ៉ុធ និងចេក ។

**សំណួរ**-បើគិតពីការចូល WTO របស់កម្ពុជាបច្ចុប្បន្ន តើបានគុណវិបត្តិ ឬគុណសម្បត្តិច្រើនជាង?

**ចំលើយ**- សំណួរនេះ **លោក ជា ហួត** បានឆ្លើយថា យើងបានរងសំពាធដូច ប្រទេសក្រីក្រដទៃទៀត តែការចូលនេះល្អ ព្រោះអាចរយៈពេល ១០ឆ្នាំទៀត ការចរចា ជាមួយប្រទេសអ្នកមានកាន់តែធូរស្បើយឡើង និងនាំឱ្យមានការសម្រួល ក្នុងការនាំ ចេញផលិតផលកសិកម្មមិនមែនតែកម្ពុជាតែឯងទេ គឺប្រទេសក្រីក្រ ៥២ទៀត ដែល កំពុងតែពួតដៃគ្នាក្នុងការចរចា ។ ជារួមលោកបានបញ្ជាក់ថា បើមានឱកាសយើង ចូលពី ពេលឥឡូវក៏ល្អ ។ គ្រាន់តែយើមិនអាចទទួលបានលទ្ធផលភ្លាមៗឡើយ ។ លោកបាន បន្ថែមទៀតថា ការចូលនេះវាបានបើកចំហសេដ្ឋកិច្ចឱ្យឈានឡើងទៅរកការអភិវឌ្ឍ ។

**សំណួរ**-វិស័យទេសចរណ៍ គឺជាវិស័យមួយជួយដល់កំណើនសេដ្ឋកិច្ចជាតិផង ដែរ ។ ជាក់ស្តែង បើគិតពីជីវភាពរបស់ប្រជាពលរដ្ឋនៅតាមខេត្ត ដែលមានតំបន់ ទេសចរណ៍គឺនៅតែក្រីក្រ ឬថាមិនទទួលបាននូវអត្ថប្រយោជន៍ពីវិស័យនេះ ។ តើរដ្ឋា- ភិបាលមានគោលដៅយ៉ាងណាដើម្បីធ្វើឱ្យប្រជាពលរដ្ឋយើង ទទួលបានផលប្រយោជនពី វិស័យនេះ?

**ចំលើយ**-ចំពោះសំណួរនេះ **លោក ជា ហួត** បានបកស្រាយថា នៅឆ្នាំ ២00៤ យើងបានចំណូលពីវិស័យទេសចរណ៍ ជារួម ៥៦0 លានដុល្លារ គឺស្មើ ១២% នៃ ផលទុនជាតិសរុបរបស់យើង ។ ប៉ុន្តែតាមការស្រាវជ្រាវរបស់ CDRI បង្ហាញថា ក្នុង ចំណូលទាំងអស់នេះមានតែ ២៥ % ទេ ដែលនៅស្រុកខ្មែរ ។ ដូច្នេះយើងត្រូវតែជំរុញការ

ផលិត និងផ្តល់សេវាកម្មដើម្បីបម្រើវិស័យនេះ។ ការកសាងសមត្ថភាព និងធនធានមនុស្សនៅតាមខេត្តទាំងនោះគឺជាការចាំបាច់។

**សំណួរ-**បច្ចុប្បន្នមានប្រទេសជាច្រើន ដែលអនុគ្រោះចំពោះកម្ពុជាក្នុងការនាំទំនិញចេញ។ តើកត្តាអ្វីខ្លះដែលធ្វើឱ្យកម្ពុជា មិនអាចឆ្លើយតបទៅនឹងភាពអនុគ្រោះទាំងនោះបាន?

**ចំលើយ-លោក** ប្រាក់ សេរីវឌ្ឍ បានឆ្លើយថា បញ្ហាទី ១ គឺយើងមិនទាន់បានរៀបចំ តែជារួមបញ្ហាដែលមិនអាចទាន់ទៅរួច គឺយើងមិនទាន់អាចឆ្លើយតបទៅនឹងស្តង់ដារគេបាន។ កាលៈទេសៈខ្លះ មិនមែនផលិតផលយើងគ្មានគុណភាពនោះទេ គឺទាក់ទងនឹងមុខមាត់ និងឈ្មោះតែម្តង។ ឧទាហរណ៍ កៅស៊ូយើងល្អ តែគេថាមិនទាន់ត្រូវតាមស្តង់ដារ តែដល់ពេលវៀតណាមទិញពីយើងយកទៅ ហើយដាក់កេស និងដាក់ថា ផលិតនៅប្រទេសវៀតណាម គឺគេទទួលស្គាល់គុណភាពនោះ។ ហេតុដូចនេះ យើងត្រូវធ្វើការកែលម្អ តាំងពីបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រង។ ការគ្រប់គ្រងនេះមានលក្ខណៈសំខាន់ ព្រោះថាបើយើងចង់នាំចេញនូវផលិតផលអ្វីមួយ គឺត្រូវធានាទាំងបរិមាណ និងគុណភាពផលិតផលឱ្យបាន។

**សំណួរ-**តើយើងមានយុទ្ធសាស្ត្រអ្វី ដើម្បីទាញយកផលប្រយោជន៍ពីសមាជិកភាពរបស់ខ្លួននៅក្នុងWTO និងទប់បានពីការប្រកួតប្រជែងជាមួយសមាជិកដទៃទៀត?

**ចំលើយ-** លោក ជា ហួត បានបកស្រាយថា យុទ្ធសាស្ត្រក្នុងការទាញយកផលចំណេញពីសមាជិកភាពនៅក្នុង WTO ជាចម្បងគឺការសម្របសម្រួលពាណិជកម្ម។ ធនាគារពិភពលោកបានផ្តល់ជំនួយ ១០ លានដុល្លារអាមេរិក ដល់រដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំឱ្យមានការសម្របសម្រួលពាណិជ្ជកម្ម។ ការសម្របសម្រួលពាណិជ្ជកម្មមានលក្ខណៈសំខាន់ ព្រោះវាមិននាំឱ្យមានភាពយឺតយ៉ាវស្មុគស្មាញ បើយើងប្រៀបធៀបទៅ

នឹងប្រទេសក្នុងតំបន់ គឺយើងមានការយឺតយ៉ាវខ្លាំង។ ហើយក្រោមជំនួយរបស់ធនាគារពិភពលោក រដ្ឋាភិបាលបានកែទម្រង់លើតម្លៃនៃការចុះបញ្ជីពាណិជ្ជកម្ម ដែលពីមុនមានតម្លៃខ្ពស់។

លើសំណួរនេះ លោក ប្រាក់ សេរីវឌ្ឍ បានបន្ថែមថា ចំពោះការទាញយកផលប្រយោជន៍ពី WTO រដ្ឋាភិបាល ក៏ដូចជាសង្គមស៊ីវិលបាននឹងកំពុងជំរុញឱ្យមាន Organic Agriculture Product។ ចំពោះផលិតផលកសិកម្មយើង ដែលប្រើជីគីមីផ្សេងៗ គឺយើងមិនអាចធ្វើការប្រកួតប្រជែងជាមួយប្រទេសគេបានទេ ព្រោះបច្ចេកទេសរបស់គេ គឺដើរលឿនជាងយើងឆ្ងាយហើយ ហើយម្យ៉ាងទៀតជីនៅប្រទេសគេមានតម្លៃថោកជាងប្រទេសយើងផងដែរ។

**សំណួរ**-ជាមួយការយកចិត្តទុកដាក់របស់រដ្ឋាភិបាល គឺថារដ្ឋាភិបាលបានបង្ហាត់បង្រៀនបច្ចេកទេសដល់កសិករ។ ដូច្នេះ តើរដ្ឋាភិបាលមានកំណត់ដែលឬទេ ថាប្រជាពលរដ្ឋ ត្រូវមានដីទំហំប៉ុន្មាន ទើបរដ្ឋាភិបាលចុះទៅបង្រៀនបច្ចេកទេសនេះ?

**ចំលើយ**-**លោក** ប្រាក់ សេរីវឌ្ឍ បានលើកឡើងថា ការបង្រៀនបច្ចេកទេសនេះ គឺរដ្ឋាភិបាលមានអង្គការជាតិ និងអន្តរជាតិ តាមរយៈកម្មវិធីបណ្តុះបណ្តាលផ្សេងៗ តែមិនបានគ្របដណ្តប់ទូទាំងប្រទេសនោះទេ។ ហើយចំពោះអន្តរាគមន៍នេះមិនកំណត់ថាមានផ្ទៃដីប៉ុណ្ណេះ ឬប៉ុណ្ណោះបានជួយនោះទេ។ ជាទូទៅការអន្តរាគមន៍នេះគឺផ្តោតទៅលើគោលដៅដែលគេបានសិក្សាហើយកំណត់។ ភាគច្រើនគម្រោងកន្លងមកគឺច្រើនតែផ្តោតទៅលើប្រជាកសិករដែលក្រីក្រមែនទែន ហើយមានផ្ទៃដីតូចតាច។ នៅពេលខ្លះគម្រោងក៏មានធ្វើជាមួយប្រជាកសិករ ដែលផ្ទៃដីធំឬមានជីវភាពសមរម្យដើម្បីឱ្យគាត់យកបទពិសោធន៍ទាំងនោះ ទៅបង្ហាត់ដល់ប្រជាកសិករក្រីក្របន្តទៀត។

## សេចក្តីសន្និដ្ឋាន

អ្នកសម្របសម្រួលបានធ្វើការបូកសរុបលទ្ធផលកិច្ចពិភាក្សាថា ដោយផ្អែកទៅលើពតិមានពីវាគ្មិនកិត្តយសថា បច្ចុប្បន្ននេះ ទោះបីកម្ពុជាមានទីផ្សារនៅក្នុង WTO ក្តីក៏កម្ពុជានៅតែមានប្រព័ន្ធអនុគ្រោះ ពីទីផ្សារអន្តរជាតិច្រើនផងដែរ។ កម្ពុជាមានកិច្ចព្រមព្រៀងទ្វេរភាគី ជាមួយជប៉ុន កាណាដា ចិន និងអាមេរិក បើគិតទៅឃើញថា ជប៉ុនអនុញ្ញាតឱ្យកម្ពុជា នាំចូលមុខទំនិញ ប្រមាណ ២៧៦មុខ អាមេរិកប្រមាណ ៦០០០មុខ ចិន ២៩៦ មុខ ហើយកាណាដាបើកឱ្យនាំចូលដោយសេរី លើកលែងតែសព្វាវុធប៉ុណ្ណោះ។ ដូច្នេះ ប្រសិនបើយើងអាចដោះស្រាយនូវបញ្ហាមួយចំនួន ដូចជាពង្រឹងគុណភាព ក៏ដូចជាបរិមាណនៃផលិតផលរបស់ជាតិយើង ដើម្បីនាំចេញទៅកាន់ទីផ្សារអន្តរជាតិទាំងនោះបាន នោះសេដ្ឋកិច្ចប្រទេសយើងនឹងមានការជឿនលឿនឆាប់រហ័សកាត់បន្ថយភាពក្រីក្រសម្រាប់ប្រជាជន។ ចំពោះបញ្ហាឧសន្ទ័ធម្មជាតិវិញ គឺថាតាមរបាយការណ៍មាន៦ តំបន់ធំៗដែលយើងអាចទាញយកផល បើគិតជាលុយប្រមាណពី ៥០០ ទៅ ១០០០ លានដុល្លារក្នុងមួយឆ្នាំ នេះមិនគិតតំបន់ត្រួតស៊ីគ្នាជាមួយថៃ និងវៀតណាមផងទេ។

# ឧបសម្ព័ន្ធ ទី ១៖ កម្មវិធី ស្តីពី "ប្រទេសកម្ពុជាក្នុងការចូលជាសមាជិកភាព អង្គការពាណិជ្ជកម្មពិភពលោក"

នៅឆ្នាំ ២០០៥ នេះ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (Cambodian Institute for Cooperation and Peace) បានរៀបចំដឹកនាំ និងអនុវត្តគម្រោងកម្មវិធី ឆ្នាំ ទី ៦ របស់ខ្លួន ស្តីពី "**ប្រទេសកម្ពុជា ក្នុងការចូលជាសមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោក**" គម្រោងកម្មវិធីនេះ បានប្រមូលផ្តុំវេទិកាចំនួន ១០ លើក ទៅលើកប្រធានបទសំខាន់ៗ ទាំងឡាយដែលពាក់ព័ន្ធដល់វិស័យពាណិជ្ជកម្ម ដើម្បីលើកស្ទួយសមាហរណកម្មសេដ្ឋកិច្ចនៅប្រទេសកម្ពុជា។ គម្រោងនេះបានចាប់ផ្តើមពី ខែមករា ឆ្នាំ ២០០៥ បញ្ចប់ការបូកសរុបវាយតម្លៃទៅលើវេទិកាទាំង ១០ លើក ដោយការរៀបចំឱ្យមានអង្គសន្និសីទជាតិមួយ ខែធ្នូ ឆ្នាំ ២០០៥។ បន្ទាប់ពីអង្គសន្និសីទថ្នាក់ជាតិនេះទៅ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព និងធ្វើការចងក្រងនូវចំណេះដឹង ទស្សនៈ បទពិសោធន៍ និងអនុសាសន៍ទាំងអស់ ដែលប្រមូលផ្តុំពីវេទិកា ១០លើក និងសន្និសីទជាតិដើម្បីការបោះពុម្ពផ្សាយ។ ទស្សនៈ ចំណេះដឹង បទពិសោធន៍ និងអនុសាសន៍ទាំងនេះ នឹងបានជាមូលដ្ឋាននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា។

**ក-អំពីប្រធានបទ កាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងនៃវេទិកា :**

វេទិកាទាំង ១០ លើក ឆ្នាំ ២០០៥ ស្តីពី " **ប្រទេសកម្ពុជាក្នុងការចូលជាសមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោក**" ដែលបានប្រព្រឹត្តទៅជាបន្តបន្ទាប់គ្នា ពីម៉ោង ០៨:៣០ព្រឹក ដល់ម៉ោង ១១:៣០ថ្ងៃត្រង់ នៅបន្ទប់ប្រជុំ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (Cambodian Institute for Cooperation and Peace) ចាប់តាំងពី ខែមករា រហូតដល់ខែតុលា ឆ្នាំ ២០០៥ ដោយមានការឧបត្ថម្ភពីមូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (Friedrich-Ebert-Stiftung-FES) ។

*ប្រធានបទក្នុងវេទិកានីមួយៗមាន ដូចខាងក្រោម :*

***វេទិកាទី ១ ស្តីពី*** "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ទស្សនៈរួម (Cambodia and the World Trade Organization)" កាលបរិច្ឆទ : ខែកុម្ភៈ ឆ្នាំ ២០០៥ ។

***វេទិកាទី ២ ស្តីពី*** " តើមានផលវិបាកខាងច្បាប់ និងគោលនយោបាយអ្វីខ្លះ ដល់សមាជិកភាពរបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក? (What are the legal and policy implication of the WTO Membership for Cambodia)" កាលបរិច្ឆទ ខែមីនា ឆ្នាំ ២០០៥ ។

***វេទិកាទី ៣ ស្តីពី*** "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់កសិកម្មកម្ពុជា (Cambodia and WTO: Impact on Cambodian Agriculture)" កាលបរិច្ឆទ ខែមេសា ឆ្នាំ ២០០៥ ។

***វេទិកាទី៤ ស្តីពី*** "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់ពលកម្មកម្ពុជា (Cambodia and WTO: Impact on Cambodia Labor)" កាលបរិច្ឆេទ ខែឧសភា ឆ្នាំ ២០០៥។

***វេទិកាទី ៥ ស្តីពី*** ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : "តើមានផលប៉ះពាល់យ៉ាងណា ចំពោះសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា ទៅលើឧស្សាហកម្មកាត់ដេរ? (Cambodia and WTO: Impact on Cambodia Garment Industry)" កាលបរិច្ឆេទ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៥

***វេទិកាទី ៦ ស្តីពី*** "កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក មានផលប៉ះពាល់អ្វីខ្លះទៅលើកម្មវិធីកាត់បន្ថយភាពក្រីក្រ? (Cambodia and WTO: Any Implication on Poverty Reduction Program?)" កាលបរិច្ឆេទ ខែកក្កដា ឆ្នាំ ២០០៥។

***វេទិកាទី ៧ ស្តីពី*** " ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ប្រើប្រាស់អង្គការពាណិជ្ជកម្ម ជាឧបករណ៍ជំរុញកំណែទម្រង់ (Cambodia and WTO: using WTO as Instrument for accelerating Reform?) " កាលបរិច្ឆេទ ខែសីហា ឆ្នាំ ២០០៥

***វេទិកាទី ៨ ស្តីពី*** "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់ពាណិជ្ជកម្ម និងការវិនិយោគទុន (Cambodia and WTO: Impact on Trade and Investment) : កាលបរិច្ឆេទ ខែកញ្ញា ឆ្នាំ ២០០៥

***វេទិកាទី ៩ ស្តីពី*** " ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា (Implication on the intellectual property right) " កាលបរិច្ឆេទ ខែកញ្ញា ឆ្នាំ ២០០៥

***វេទិកាទី ១០ ស្តីពី*** " ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : មេរៀនដែលបានទទួល និងទិសដៅទៅអនាគត (Lessons and Learnt Future Direction) " កាលបរិច្ឆេទ ខែវិច្ឆកា ឆ្នាំ ២០០៥

## ខ. អំពីសន្និសីទជាតិ

ក្នុងបំណងបូកសរុប និងទិសដៅអនុវត្តចុងក្រោយ ស្តីពី "ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក" វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព បានរៀបចំសន្និសីទថ្នាក់ជាតិ ដែលមានប្រធានបទក្នុងសម័យប្រជុំនីមួយៗ ដ៏មានសារៈសំខាន់នេះ សម្រាប់រយៈពេលពីរថ្ងៃ នៅថ្ងៃទី ២១-២២ ខែធ្នូ ឆ្នាំ២០០៥ នេះ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ដោយមានអ្នកតំណាងគ្រប់ស្ថាប័ន ទាំងផ្នែកស្ថាប័នរដ្ឋ ទាំងផ្នែកសង្គមស៊ីវិល និងទាំងផ្នែកឯកជន ត្រូវបានអញ្ជើញចូលរួម ដើម្បីពិនិត្យពិចារណាទៅលើលទ្ធផលនៃវេទិកាទាំង ១០លើក ដែលបានប្រព្រឹត្តទៅ អស់រយៈពេលពេញមួយឆ្នាំកន្លងទៅនេះ ដើម្បីផ្តល់ការវាយតម្លៃជាចុងក្រោយមុននឹងផ្សព្វផ្សាយនូវលទ្ធផលទាំងនោះ។

សង្ឃឹមថា អង្គសន្និសីទជាតិនឹងសម្រេចបានជោគជ័យ ដើម្បីរួមចំណែកផ្តល់មតិយោបល់ ទស្សនៈ និងបទពិសោធន៍ល្អៗ ក៏ដូចជាអនុសាសន៍ជាច្រើនទៀត ដើម្បីជំរុញចរន្តសេដ្ឋកិច្ចនៅកម្ពុជានឹងវិវត្តទៅប្រកបដោយប្រសិទ្ធិភាព។

# ឧបសម្ព័ន្ធ ទី ២. កម្មវិធីវេទិកាទាំង ១០ លើក ស្តីពី "កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក"

## វេទិកាលើកទី ១ ស្តីអំពី

### កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ទស្សនៈរួម

"Cambodia and the World Trade Organization (WTO): An Overview"

ឧបត្ថម្ភដោយ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

**កម្មវិធី**

| | |
|---|---|
| ៨:៣០-៩:០០ | ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| ៩:០០-៩:២០ | **ប្រធានវេទិកា** |
| | **ឯកឧត្តម អ៊ុំ ហួត** ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា និងជាអនុប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (វ.ខ.ស.ស.) |
| | **អ្នកសម្របសម្រួលដោយ** |
| | **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| ៩:២០-១០:០០ | **គណៈអធិបតីកិត្តិយស** |

| | |
|---|---|
| | **ឯកឧត្តម គឹកវ៉េត សំរេច** ជំនួយការផ្ទាល់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី |
| | **លោក ចាន់ សេរី** ប្រធាននាយកដ្ឋានធនធានមនុស្សនៃធនាគារ អេស៊ីលីដា |
| ១០:០០-១០:១៥ | សម្រាកពិសារភេសជ្ជៈ |
| ១០:១៥-១១:១៥ | បើកកិច្ចពិភាក្សា |
| ១១:១៥-១១:៣០ | បូកសរុបលទ្ធផលវេទិកាលើកទី១ ដោយ **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |

---------------------------------------------------

## វេទិកាលើកទី ២ ស្តីអំពី

## តើមានផលវិបាកខាងច្បាប់ និងគោលនយោបាយអ្វីខ្លះ ដល់សមាជិកភាពរបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក?

"What Are the Legal and Policy Implication of The WTO Membership for Cambodia"

ឧបត្ថម្ភដោយ មូលនិធិ ហ្វ្រីឌ្រីច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

## <u>កម្មវិធី</u>

| | |
|---|---|
| ៨:១៥-៨:៣០ | ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| ៨:៣០-៨:៥០ | **ប្រធានវេទិកា និងសម្របសម្រួល ដោយ បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| ៨:៥០-៩:៤០ | **គណៈវាគ្មិនកិត្តិយស** **លោក តាន់ យុទ្ធរដ្ឋ** អនុប្រធានការិយាល័យ សេវាកម្ម នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម **លោក សុក សំអឿន** នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| ៩:៤០-១០:០០ | សម្រាកពិសារភេសជ្ជៈ |
| ១០:០០-១១:០០ | បើកកិច្ចពិភាក្សា |
| ១១:០០-១១:៣០ | បូកសរុបលទ្ធផលវេទិកាលើកទី២ ដោយ **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិ-បត្តិការ និងសន្តិភាព |

---

## វេទិកាលើកទី ៣ ស្តីអំពី

## កម្ពុជានិងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់កសិកម្មកម្ពុជា

" Cambodia and WTO: Impact on Cambodia Agriculture"

ឧបត្ថម្ភដោយមូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

## កម្មវិធី

| | |
|---|---|
| ៨:១៥-៨:៣០ | ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| ៨:៣០-៨:៥០ | **ប្រធានវេទិកា និងសម្របសម្រួល ដោយ បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| ៨:៥០-៩:៤០ | **គណៈវាគ្មិនកិត្តិយស**<br>**លោក ឡុត សារ៉ាវុធ** អនុប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ<br>**លោកស្រី ប្រ៊ុក ម៉ាន់នី** អ្នកឯកទេស យេនឌ័រ និងសង្គមនៃកម្មវិធីអភិវឌ្ឍន៍ ផ្នែកកសិកម្ម ប្រចាំក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ |
| ៩:៤០-១០:០០ | សម្រាកពិសារភេសជ្ជៈ |
| ១០:០០-១១:០០ | **បើកកិច្ចពិភាក្សា** |
| ១១:០០-១១:៣០ | បូកសរុបលទ្ធផលវេទិកាលើកទី៣ ដោយ **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |

# វេទិកាលើកទី ៤ ស្តីអំពី

# កម្ពុជានិងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ចំពោះពលកម្មកម្ពុជា

" Cambodia and WTO: Impact on Cambodia Labor "

ឧបត្ថម្ភដោយ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

## កម្មវិធី

| | |
|---|---|
| ៨:១៥-៨:៣០ | ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| ៨:៣០-៨:៥០ | **ប្រធានវេទិកា និងសម្របសម្រួល ដោយ** **ឯកឧត្តម អ៊ឹង ហួត** អនុប្រធានក្រុមប្រឹក្សាភិបាល វ.ខ.ស.ស. |
| ៨:៥០-៩:៤០ | **គណៈវាគ្មិនកិត្តិយស** **ឯកឧត្តម អ៊ុំ មាន** អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **លោក សេង ផល្លី** នាយកប្រតិបត្តិ អង្គការការងារកម្ពុជា |
| ៩:៤០-១០:០០ | សម្រាកពិសារភេសជ្ជៈ |
| ១០:០០-១១:០០ | **បើកកិច្ចពិភាក្សា** |

១១:០០-១១:៣០ បូកសរុបលទ្ធផលវេទិកាលើកទី៤ ដោយ **ឯកឧត្តម អ៊ុំ ហួត** អនុប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

---------------------------------------

## វេទិកាលើកទី៥ ស្តីអំពី

## តើមានផលប៉ះពាល់យ៉ាងណា ចំពោះសមាជិក WTO របស់កម្ពុជា ទៅលើឧស្សាហកម្មកាត់ដេរ?

“ Cambodia and WTO: Impact on Cambodia Garment Industry ”

ឧបត្ថម្ភដោយ មូលនិធិ ហ្វ្រីឌ្រីច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

### កម្មវិធី

៨:១៥-៨:៣០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៨:៣០-៨:៥០ **ប្រធានវេទិកា និងសម្របសម្រួល ដោយ ឯកឧត្តម អ៊ុន នឹង** សមាជិកក្រុមប្រឹក្សាភិបាល វ.ខ.ស.ស. និងជាអនុប្រធានគណៈកម្មការកិច្ចការ បរទេស សហប្រតិបត្តិការអន្តរជាតិ និងពត៌មាននៃរដ្ឋសភា

៨:៥០-៩:៤០ **គណៈអធិបតីកិត្តិយស**

| | |
|---|---|
| | **លោក យ៉ា ម៉ុនណា** អនុប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្មនិងជាប្រធានអង្គភាពផលិតភាពអាស៊ី |
| | **លោក ជួន មុំថុល** ប្រធានសហព័ន្ធសហជីពខ្មែរ |
| ៩:៤០-១០:០០ | សម្រាកពិសារភេសជ្ជៈ |
| ១០:០០-១១:០០ | **បើកកិច្ចពិភាក្សា** |
| ១១:០០-១១:៣០ | បូកសរុបលទ្ធផលវេទិកាលើកទី៥ ដោយ **ឯកឧត្តម អ៊ុន នឹង** សមាជិកក្រុមប្រឹក្សាភិបាល វ.ខ.ស.ស. និងជាអនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងពតិមាន នៃរដ្ឋសភា |

-------------------------------

## វេទិកាលើកទី ៦ ស្តីអំពី

## កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក តើមានផលប៉ះពាល់អ្វីខ្លះ ទៅលើកម្មវិធីកាត់បន្ថយភាពក្រីក្រ?

“ Cambodia and WTO: Any Implications on Poverty Reduction Program? ”

ឧបត្ថម្ភដោយ មូលនិធិ ហ្វ្រីឌ្រីច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

# កម្មវិធី

| | |
|---|---|
| ៨:១៥-៨:៣០ | ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| ៨:៣០-៨:៥០ | **ប្រធានវេទិកា និងសម្របសម្រួល ដោយ បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| ៨:៥០-៩:៤០ | **គណៈអធិបតីកិត្តិយស** |
| | **ឯកឧត្តម គឹម រ័ត្នពិសិដ្ឋ** ទីប្រឹក្សា ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី |
| | **ឯកឧត្តម ទូច ស៊ាងតាណា** សមាជិកក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (OBSES) ទីស្តីការគណៈរដ្ឋមន្ត្រី |
| | **ឯកឧត្តម អ៊ុង ច័ន្ទដារិទ្ធ** សមាជិកក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (OBSES) ទីស្តីការគណៈរដ្ឋមន្ត្រី |
| | **ឯកឧត្តម ម៉ាន់ ឈឿន** អភិបាលរង រាជធានីភ្នំពេញ និងជាប្រធានមូលនិធិអភិវឌ្ឍន៍ កាត់បន្ថយភាពក្រីក្រទីក្រុង |
| | **លោកស្រី ហួត រតនៈ** នាយិកា វេទិកាទូទៅនៃកម្ពុជា |
| ៩:៤០-១០:០០ | សម្រាកពិសារភេសជ្ជៈ |
| ១០:០០-១១:០០ | **បើកកិច្ចពិភាក្សា** |

១១:០០-១១:៣០ បូកសរុបលទ្ធផលវេទិកាលើកទី៦ ដោយ **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វ.ខ.ស.ស

---

## វេទិកាលើកទី៧ ស្តីអំពី

## កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក-ការប្រើប្រាស់ WTO ជាឧបករណ៍ជំរុញកំណែទម្រង់

" Cambodia and WTO: Using WTO as an Instrument to Accelerate Reform? "

ឧបត្ថម្ភដោយ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

### កម្មវិធី

៨:១៥-៨:៣០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៨:៣០-៨:៥០ **ប្រធានវេទិកា និងសម្របសម្រួល ដោយ បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

៨:៥០-៩:៤០ **គណ:វាគ្មិនកិត្តិយស**

**ឯកឧត្តម ង៉ោ ហុងលី** អគ្គលេខាធិការ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ទីស្តីការគណ:រដ្ឋមន្ត្រី

| | |
|---|---|
| ៩:៤០-១០:០០ | សម្រាកពិសារភេសជ្ជៈ |
| ១០:០០-១១:០០ | **បើកកិច្ចពិភាក្សា** |
| ១១:០០-១១:៣០ | បូកសរុបលទ្ធផលវេទិកាលើកទី៧ ដោយ **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វ.ខ.ស.ស. |

---

## វេទិកាលើកទី ៨ ស្តីអំពី

## កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់ដល់ពាណិជ្ជកម្ម និងការវិនិយោគទុន

“ Cambodia and WTO: Impact on Trade and Investment ”

ឧបត្ថម្ភដោយ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

### កម្មវិធី

| | |
|---|---|
| ៨:១៥-៨:៣០ | ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| ៨:៣០-៨:៥០ | **ប្រធានវេទិកា និងសម្របសម្រួល ដោយ បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព |
| ៨:៥០-៩:៤០ | **គណៈវាគ្មិនកិត្តិយស** |

| | |
|---|---|
| | **ឯកឧត្តមបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី** ទីប្រឹក្សាផ្ទាល់ និងជានាយករងខុទ្ទកាល័យ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អម វ.ខ.ស.ស. |
| | **បណ្ឌិត កុង ច័ន្ទដារារ័ត្ន** នាយកវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍ |
| ៩:៤០-១០:០០ | សម្រាកពិសារភេសជ្ជៈ |
| ១០:០០-១១:០០ | **បើកកិច្ចពិភាក្សា** |
| ១១:០០-១១:៣០ | បូកសរុបលទ្ធផលវេទិកាលើកទី៨ ដោយ **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វ.ខ.ស.ស. |

---

## វេទិកាលើកទី ៩ ស្តីអំពី

## កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា

“Cambodia and WTO: Implications on the Intellectual Property Rights ”

ឧបត្ថម្ភដោយ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

## កម្មវិធី

| | |
|---|---|
| ៨:១៥-៨:៣០ | ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| ៨:៣០-៨:៥០ | **ប្រធានវេទិកា និងសម្របសម្រួល ដោយ បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| ៨:៥០-៩:៤០ | **គណៈអធិបតីកិត្តិយស** **លោក ម៉ា រតនសាន** ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម **លោក ជា សំណាង** អ្នកស្រាវជ្រាវ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| ៩:៤០-១០:០០ | សម្រាកពិសារភេសជ្ជៈ |
| ១០:០០-១១:០០ | **បើកកិច្ចពិភាក្សា** |
| ១១:០០-១១:៣០ | បូកសរុបលទ្ធផលវេទិកាលើកទី៩ ដោយ **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វ.ខ.ស.ស. |

---

## វេទិកាលើកទី ១០ ស្តីអំពី

## កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : មេរៀនដែលបានទទួល និង ទិសដៅទៅអនាគត

“ Cambodia and WTO: Lessons Learnt and Future Direction ”

ឧបត្ថម្ភដោយ មូលនិធិ ហ្វ្រីឌ្រីច អេប៊ែត (Friedrich-Ebert-Stiftung) (FES)

**ទីកន្លែង:** បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

## កម្មវិធី

| | |
|---|---|
| ៨:១៥-៨:៣០ | ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| ៨:៣០-៨:៥០ | **ប្រធានវេទិកា និងសម្របសម្រួល ដោយ លោក ហាម សំណាង** អ្នកស្រាវជ្រាវជាន់ខ្ពស់ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និង សន្តិភាព |
| ៨:៥០-៩:៤០ | **គណៈអាធិបតីកិត្តិយស**<br>**ឯកឧត្តម តែ ដួងតារា** អគ្គនាយក អាជ្ញាធរប្រេងកាតជាតិកម្ពុជា<br>**លោក ប្រាក់ សេរីវឌ្ឍ** នាយកគ្រប់គ្រងមជ្ឈមណ្ឌល-សិក្សា និងអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា<br>**លោក ជា ហួត** អ្នកសេដ្ឋកិច្ច នៃធនាគារពិភពលោក |
| ៩:៤០-១០:០០ | សម្រាកពិសារភេសជ្ជៈ |
| ១០:០០-១១:០០ | **បើកកិច្ចពិភាក្សា** |
| ១១:០០-១១:៣០ | បូកសរុបលទ្ធផលវេទិកាលើកទី១០ ដោយ **លោក ហាម សំណាង** អ្នកស្រាវជ្រាវជាន់ខ្ពស់ វ.ខ.ស.ស. |

-----------------------------------------------------------

# ឧបសម្ព័ន្ធ ទី ៣ កម្មវិធីសន្និសីទជាតិ

## សន្និសីទជាតិ ស្តីអំពី
## ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក :
## អត្ថប្រយោជន៍ ការប្រឈម និង ទស្សនវិស័យសម្រាប់អនាគត

**សហការរៀបចំដោយ**

**វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព** (CICP) **និង**

**ឧបត្ថម្ភដោយមូលនិធិហ្វ្រីឌ្រីចអេប៊ែត** Friedrich-Ebert Stiftung (FES)

***ថ្ងៃ ពុធ-ព្រហស្បតិ៍ ទី ២១-២២ ខែ ធ្នូ ឆ្នាំ ២០០៥***

**ទីកន្លែង:** ***ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** (CDC)

### ក-មូលប្រវត្តិ :

វាជាការឆាប់ពេកក្នុងការទស្សន៍ទាយ ពីអត្ថប្រយោជន៍ដែលប្រទេសកម្ពុជានឹងទទួលបានពីសមាជិកភាពរបស់ខ្លួន ក្នុងអង្គការពាណិជ្ជកម្មពិភពលោក ពីព្រោះវាទើបតែមានរយៈពេលជាងមួយឆ្នាំប៉ុណ្ណោះ ចាប់តាំងពីប្រទេសកម្ពុជា ត្រូវបានទទួលជាសមាជិកទី ១៤៨ នៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០០៤ កន្លងទៅនេះ ។

ប្រទេសកម្ពុជា ជាប្រទេសមានសេដ្ឋកិច្ចតូចមួយនៅក្នុងតំបន់ ដែលមូលដ្ឋានផលិតកម្មនៅមានកម្រិតនៅឡើយ ។ ប្រទេសកម្ពុជាជាប្រទេសនាំចូលច្រើនជាងខ្លួន

នាំចេញ។ មុននឹងក្រោយពេលប្រទេសកម្ពុជា បានចូលជាសមាជិកពេញសិទ្ធិនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) មានអ្នកទិតៀនជាច្រើនបានចង្អុលបង្ហាញថា ប្រទេសកម្ពុជា ហាក់ដូចជា មិនបានត្រៀមខ្លួនប្រកួតពេញលេញ នៅក្នុងប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ ដោយផ្អែកលើការពិតដែលថា ប្រទេសកម្ពុជានៅជាប្រទេសក្រីក្រ ហើយផលិតកម្មកសិកម្មរបស់ខ្លួនមិនទំនើប ដែលពិបាកក្នុងការប្រកួតប្រជែង ហើយថាប្រទេសនេះមានតែផលិតផលសម្លៀកបំពាក់សម្រាប់នាំចេញ។ កត្តាទាំងអស់នេះ នឹងជាការលំបាកសម្រាប់ប្រទេសកម្ពុជា ដើម្បីយកឈ្នះនៅក្នុងការដណ្តើមទីផ្សារអន្តរជាតិ។ លើសពីនេះ ប្រទេសកម្ពុជានឹងត្រូវចំណាយសម្រាប់កិច្ចប្រជុំជាច្រើន និងការបង្កើតស្ថាប័នដើម្បីសម្របសម្រួលពាណិជ្ជកម្ម និងបាត់បង់ថវិកាដោយហេតុផលថា នឹងមានការកាត់បន្ថយតារាងពន្ធគយ។

ទោះយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជាមានសុទិដ្ឋិនិយមថា ការធ្វើសមាហរណកម្មរបស់ប្រទេសកម្ពុជា ចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក គឺជាឧបករណ៍រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងជាកម្លាំងដ៏ខ្លាំងក្លាសម្រាប់ជំរុញការកែទម្រង់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងសង្គម។

ទោះបីជាការចូលរួមរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក មានរយៈពេលខ្លីក៏ពិតមែន ក៏មានទទ្បឹករណ៍រួចមកហើយថា ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីសម្រេចឱ្យបាននូវអត្ថប្រយោជន៍ ដ៏គួរឱ្យកត់សំគាល់ខ្លះ។

ទោះយ៉ាងនេះក្តី វិថីទៅកាន់ជោគជ័យស្ថិតនៅឆ្ងាយ ហើយទន្ទឹមនឹងនោះការប្រឈមមុខនានាបានស្ថិតនៅចំពោះមុខ។ វាត្រូវការពេលវេលា និងថាមពលដើម្បីធ្វើឱ្យដំណើររបស់ប្រទេសកម្ពុជា ទៅរកជោគជ័យក្លាយជាការពិត។

ក្នុងន័យនេះ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព និងមូលនិធិ ហ្វ្រីឌ្រីច អេប៊ែត (FES) នឹងសហការគ្នារៀបចំអង្គសន្និសីទជាតិ រយៈពេល ២ ថ្ងៃ ស្តីអំពី **"ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្ម ពិភពលោក** (WTO) **: អត្ថប្រយោជន៍ ការប្រឈម និងទស្សនវិស័យសម្រាប់អនាគត "** ។ អង្គសន្និសីទជាតិនេះ គឺជាការបូកសរុបលទ្ធផលវេទិកាតុមូលទាំង ១០ លើក ដែលរៀបចំឡើងដោយវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ដោយមានការគាំទ្រហិរញ្ញវត្ថុពីមូលនិធិ (FES) អស់រយៈពេលមួយឆ្នាំ ២០០៥ កន្លងមកនេះ ។

## **២_គោលបំណង :**

សន្និសីទមានគោលបំណងដូចតទៅ :

១- ដើម្បីអភិវឌ្ឍការយល់ដឹង និងទាក់ទាញការយកចិត្តទុកដាក់ឱ្យបានច្រើនថែមទៀតរបស់ប្រជាជនកម្ពុជា ជាពិសេសភាគីពាក់ព័ន្ធនានា អំពីសមាជិកភាពរបស់កម្ពុជាក្នុង (WTO)

២- ដើម្បីវាយតម្លៃអត្ថប្រយោជន៍ដែលប្រទេសកម្ពុជា ទទួលបានក្នុងឆ្នាំកន្លងមក

៣- ដើម្បីវាយតម្លៃផលប៉ះពាល់អវិជ្ជមាន និងការប្រឈមនានាក្នុងពេលអនុវត្តដំណើរការ និង

៤- ដើម្បីស្វែងរកវិធានការ និងយុទ្ធសាស្ត្រ ដើម្បីធ្វើឱ្យកម្ពុជាទទួលបានផលប្រយោជន៍ កាន់តែធំធេងក្នុងការចូលរួម WTO ។

**គ. ការចូលរួម** :

សន្និសីទជាតិនេះនឹងមានអ្នកចូលរួមប្រមាណ ៣០០ នាក់ មកពីស្ថាប័នផ្សេងៗ ដូចជា អង្គទូត មន្ត្រី រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា អង្គការក្រៅរដ្ឋាភិបាល សមាគម ផ្នែកឯកជន ក្រុមបញ្ញវន្ត និស្សិត និង អ្នកសារពត៌មាន,, ។ល។

**កម្មវិធី**

**ថ្ងៃពុធ ទី២១ ខែធ្នូ ឆ្នាំ ២០០៥**

| | |
|---|---|
| ៧:៣០-៨:០០ | ចុះឈ្មោះអ្នកចូលរួម |
| ៨:០០-៨:៣០ | ការយាង និងការអញ្ជើញរបស់គណៈអធិបតី |
| ៨:៣០-១០:០០ | **ការបើកអង្គសន្និសីទជាតិ** |

- ព្រះសុន្ទរកថាស្វាគមន៍ដោយ **សម្តេច នរោត្តម សិរីវុឌ្ឍ** ព្រះប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព
- សុន្ទរកថាស្វាគមន៍បើកអង្គសន្និសីទជាតិដោយ **លោក អាក់ស៊ីល ស្មិត** ប្រធានការិយាល័យសសម្រាប់សហប្រតិបត្តិការភូមិភាគអាស៊ីអាគ្នេយ៍នៃមូលនិធិហ្វ្រីឌ្រីច អេប៊ែត សឹង្ហបូរី
- សុន្ទរកថាសារៈសំខាន់បើកអង្គសន្និសីទជាតិដោយ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាស្តីអំពី "**ប្រទេសកម្ពុជា និងអង្គការ**

| | |
|---|---|
| | **ពាណិជ្ជកម្មពិភពលោក : អត្ថប្រយោជន៍ ការប្រឈម និងទស្សនវិស័យសម្រាប់អនាគត”** |
| ១០:០០-១០:១៥ | សម្រាកពិសាភេសជ្ជៈ |
| ១០:១៥-១១:១៥ | **សម័យប្រជុំទី១ កម្ពុជា និង** WTO: **ការវាយតំលៃសុីជំរៅខ្លះៗ** |
| | **ប្រធានៈ** |
| | **ឯកឧត្តម អ៊ុន នឹង** អនុប្រធានគណៈកម្មាការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ និងពតិមាននៃរដ្ឋសភា និងសមាជិកក្រុមប្រឹក្សាភិបាល វ.ខ.ស.ស. |
| | **វាគ្មិនៈ** |
| | **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| | **បណ្ឌិត Hank Lim** នាយកស្រាវជ្រាវ វិទ្យាស្ថានសិង្ហបូរី ដើម្បីការសិក្សាអន្តរជាតិ |
| ១១:១៥-១២:០០ | បើកកិច្ចពិភាក្សា |
| ១២:០០-១៤:០០ | សម្រាកពិសាអាហារថ្ងៃត្រង់ |
| ១៤:០០-១៥:៤៥ | **សម័យប្រជុំទី២ កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ទស្សនៈរួម លើភាពលានុវត្តភាព និងការប្រឈម** |
| | **ប្រធានៈ** |

**ឯកឧត្តមបណ្ឌិត កៅ គីមហួន** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង សមាជិកក្រុមប្រឹក្សាភិបាល វ.ខ.ស.ស.

**ខាត្តិនៈ**

**ឯកឧត្តម សុន គន្ធរ** ប្រធានអគ្គនាយកធនាគារ អភិវឌ្ឍន៍ជនបទ

**លោក សុខ សុភ័ក្រ្ត** អគ្គនាយករង អគ្គនាយកដ្ឋាន បច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម

**ឯកឧត្តម ទូច ស៊ានតាណា** សមាជិកក្រុមសង្កេត ការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទីស្តីការគណៈ រដ្ឋមន្ត្រី

កិច្ចពិភាក្សា

១៥:៤៥-១៦:០០ សម្រាកពិសាភេសជ្ជៈ

១៦:០០-១៧:៤៥ **សម័យប្រជុំទី៣ : ប្រទេសកម្ពុជា និងអង្គការ ពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់លើ កសិកម្ម និងឧស្សាហកម្មកាត់ដេរនៅកម្ពុជា**

**ប្រធានៈ**

**ឯកឧត្តម អ៊ុំង ហួត** អនុប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

**ខាត្តិនៈ**

**លោក ឡូត សារ៉ាវុធ** ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងកសិកម្ម និងរុក្ខាប្រម៉ាញ់ និងនេសាទ

**លោក ប្រាក់ សេរីវឌ្ឍ** នាយកគ្រប់គ្រងមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្ម

**លោក សោម អូន** ប្រធានសម្ព័ន្ធសហជីពកម្មករកម្ពុជា

សំណួរ និង ចម្លើយ

<u>ថ្ងៃទី ២ *ព្រហស្បតិ៍* ទី ២២ ខែធ្នូ ឆ្នាំ ២០០៥</u>

៨:០០-១០:០០ **<u>សម័យប្រជុំទី៤</u>: កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលប៉ះពាល់លើពលកម្មការងារពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា**

**<u>ប្រធាន</u>:**

**បណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី** ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី

**<u>វាគ្មិន</u>:**

**ឯកឧត្តម ម៉ៅ ថូរ៉ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

**ឯកឧត្តម អ៊ុំ មាន** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**បណ្ឌិត ទង់ សន្ធាប់** ប្រធាន អគ្គនាយក ក្រុមហ៊ុនធានារ៉ាប់រងជាតិកម្ពុជា

**បណ្ឌិត កង ចាន់ដារ៉ារ័ត្ន** នាយកប្រតិបត្តិ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍

សំណួរ និង ចម្លើយ

១០:០០-១០:១៥ សម្រាកពិសាភេសជ្ជៈ

១០:១៥-១២:០០ **សម័យប្រជុំទី៥: កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក : ផលវិបាកផ្នែកច្បាប់ និងផលប៉ះពាល់លើកម្មសិទ្ធិបញ្ញា**

**ប្រធាន:**

**បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

**វាគ្មិន:**

**លោក ម៉ៅ ទីហុង** សកលវិទ្យាធិការរងនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

**ឯកឧត្តម ស៊ឹម សារ៉ាក់** អគ្គនាយក អគ្គអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**លោក សុក សំអឿន** នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

**លោក ឌៅ រតនសាន** ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម

**លោក ជា សំណាង** អ្នកស្រាវជ្រាវវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា

**បណ្ឌិត ហង្ស ពុទ្ធា** ប្រធាន សមាគមវិចិត្រសិល្បៈ

សំណួរ និង ចម្លើយ

១២:00-១៤:00 សម្រាកពិសាអាហារថ្ងៃត្រង់

១៤:00-១៦:00 **<u>សម័យប្រជុំទី៦</u>: ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក: ការប្រើប្រាស់ WTO ជាឧបករណ៍ជំរុញកំណែទម្រង់ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា**

**<u>ប្រធាន</u>:**

**បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព

**<u>វាគ្មិន</u>:**

**ឯកឧត្តម គង់ សុភី** អគ្គលេខាធិការរង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី

**ឯកឧត្តម ម៉ាន់ ឈឿន** អភិបាលរងរាជធានីភ្នំពេញ និងជាប្រធានមូលនិធិកាត់បន្ថយ ភាពក្រីក្រក្នុងទីក្រុង

**លោក តឹកវ៉េត សំរេច** ជំនួយការផ្ទាល់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**លោក ជា ហួត** អ្នកសេដ្ឋកិច្ច នៃធនាគារពិភពលោក បើកកិច្ចពិភាក្សា

១៦:០០-១៦:១៥ សម្រាកពិសាភេសជ្ជៈ

១៦:១៥-១៧:៣០ **ពិធីបិទអង្គសន្និសីទជាតិ**

**ប្រធាន:**

**ឯកឧត្តម អ៊ុន នឹង** អនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងពតិមាននៃរដ្ឋសភា និងជាសមាជិកក្រុមប្រឹក្សាភិបាល វ.ខ.ស.ស

- សរុបលទ្ធផលអង្គសន្និសីទជាតិដោយ **បណ្ឌិត ចាប សុជាតិរិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព
- ចំណាប់អារម្មណ៍ ក្នុងពិធីបិទអង្គ សន្និសីទជាតិដោយ **លោក អាក់ស៊ីល ស្ទីត** ប្រធានការិយាល័យសំរាប់សហប្រតិបត្តិការភូមិភាគ អាស៊ីអាគ្នេយ៍នៃមូលនិធិហ្វ្រីឌ្រីចអេប៊ែតប្រចាំសឹង្ហបុរី

- សុន្ទរកថាគន្លឹះ នឹងការប្រកាសបិទអង្គសន្និសីទជាតិ ស្តីពី "**កម្ពុជា និងអង្គការ ពាណិជ្ជកម្មពិភពលោក : អត្ថប្រយោជន៍ ការប្រឈម និងទស្សនវិស័យនៅអនាគត**" ដោយ ឯកឧត្តម **ម៉ៅ ថូរ៉ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# ឧបសម្ព័ន្ធ ទី ៤ បញ្ជីរាយនាមអ្នករួមចំណែកក្នុងវេទិកា និងសន្និសីទជាតិ

| | |
|---|---|
| **សម្តេច ហ៊ុន សែន** | នាយករដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា |
| **សម្តេច នរោត្តម សិរីវុឌ្ឍ** | ព្រះប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| **ឯកឧត្តម អ៊ឹង ហួត** | សមាជិកព្រឹទ្ធសភា និងជាអនុប្រធានក្រុម ប្រឹក្សាភិបាលវិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការ និងសន្តិភាព (វ.ខ.ស.ស.) |
| **ឯកឧត្តម អ៊ុន នឹង** | អនុប្រធានគណៈកម្មាការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ និងពត៌មាននៃរដ្ឋសភា និងសមាជិកក្រុមប្រឹក្សាភិបាល វ,ខ,ស,ស, |
| **ឯកឧត្តម សុន គន្ធរ** | ប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ |
| **ឯកឧត្តមបណ្ឌិតកៅ គីមហួន** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសមាជិកក្រុមប្រឹក្សាភិបាល វ,ខ,ស,ស, |
| **ឯកឧត្តម ងៅ ហុងលី** | អគ្គលេខាធិការក្រុមប្រឹក្សា កំណែទម្រង់រដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី |
| **ឯកឧត្តម គង់ សុភី** | អគ្គលេខាធិការរង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ទីស្តី |

| | |
|---|---|
| | ការគណៈរដ្ឋមន្ត្រី |
| **ឯកឧត្តម ទូច សៀងតាណា** | សមាជិកក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (OBSES) ទីស្តីការគណៈរដ្ឋមន្ត្រី |
| **ឯកឧត្តម អ៊ុង ច័ន្ទដារិទ្ធ** | សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (OBSES) ទីស្តី ការគណៈរដ្ឋ មន្ត្រី |
| **ឯកឧត្តម តែ ដួងតារា** | អគ្គលេខាធិការ អាជ្ញាធរប្រេងកាតជាតិកម្ពុជា |
| **ឯកឧត្តម ហ៊ីង ថូរ៉ាក់ស៊ី** | ទីប្រឹក្សាផ្ទាល់ និងជានាយករង ខុទ្ទកាល័យ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រីនិងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវ.ខ.ស.ស. |
| **ឯកឧត្តម អ៊ុំ មាន** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ |
| **ឯកឧត្តមបណ្ឌិត ចាប សុចារិទ្ធិ** | នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| **ឯកឧត្តមបណ្ឌិត គឹម វ័ឌ្ឍពិសិដ្ឋ** | ទីប្រឹក្សា ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី |
| **ឯកឧត្តម ម៉ៅ ថូរ៉ា** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម |
| **ឯកឧត្តម ម៉ាន់ ឈឿន** | ប្រធាន មូលនិធិអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រទីក្រុង |
| **ឯកឧត្តមបណ្ឌិត គុណ ញឹម** | នាយករងទីចាត់ការគយ និងរដ្ឋាករ |
| **ឯកឧត្តម ស៊ឹម សារ៉ាក់** | អគ្គនាយក អគ្គអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| **ឯកឧត្តមបណ្ឌិត វង់ សន្តាប់** | អគ្គនាយកក្រុមហ៊ុនធានារ៉ាប់រងជាតិកម្ពុជា |

| | |
|---|---|
| លោក សុខ សុភ័ក្រ្ត | អគ្គនាយករង អគ្គនាយកដ្ឋាន បច្ចេកទេសនៃក្រសួងពាណិជ្ជកម្ម |
| លោក ម៉ៅ ធីហុង | សកលវិទ្យាធិការរងនៃសកលវិទ្យាភូមិន្ទវិចិត្រសិល្បៈ |
| លោក វ៉ា វុតសាន | ប្រធាន នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម |
| លោក ទូត សារ៉ាវ៉ុធ | ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ |
| លោក តឹករ៉េត សំរេច | ជំនួយការ ផ្ទាល់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី |
| លោក ចាន់ សេរី | ប្រធាននាយក ដ្ឋានធនធានមនុស្សនៃធនាគារអេស៊ីលីដា |
| លោក តាន់ យុវរដ្ឋ | អនុប្រធានការិយាល័យសេវាកម្ម នាយកដ្ឋានអាស៊ាននិងអង្គការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម |
| លោក សុក សំអឿន | នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| លោកស្រី ប្រុក វ៉ាន់នី | អ្នកឯកទេសយេនឌ័រ និងសង្គមនៃកម្មវិធីអភិវឌ្ឍន៍ ផ្នែកកសិកម្ម |
| លោក សេង ផល្លី | នាយកប្រតិបត្តិ អង្គការការងារកម្ពុជា |
| លោក យ៉ា ប៊ុនណា | អនុប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម និងជាប្រធានអង្គភាពផលិតភាពអាស៊ី |
| លោក ជួន មុំថុល | ប្រធាន សហព័ន្ធសហជីពខ្មែរ |
| លោកស្រី ហួត រតនៈ | នាយិកា វេទិកាទូទៅនៃកម្ពុជា |
| បណ្ឌិត កង ចំនេដារារ័ត្ន | នាយក វិទ្យាស្ថានសិក្សាស្រាវជ្រាវ និង ការអភិវឌ្ឍន៍ |
| លោក ជា សំណាង | អ្នកស្រាវជ្រាវវិទ្យាស្ថានសេដ្ឋកិច្ច |

| | |
|---|---|
| **លោក ហម សំណាង** | អ្នកជ្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| **លោក ប្រាក់ សេរីវុឌ្ឍ** | នាយកគ្រប់គ្រងមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា |
| **លោក ផា ហ្វួត** | អ្នកសេដ្ឋកិច្ចនៃធនាគារពិភពលោក |
| **លោក អាក់ស៊ីល ស្មិត** | ប្រធានការិយាល័យសម្រាប់សហប្រតិបត្តិការភូមិភាគអាស៊ីអាគ្នេយ៍នៃមូល និធិហ្វ្រិឌ្រិច អេប៉ែត សឹង្ហបុរី |
| **បណ្ឌិត** Hank Lim | នាយកស្រាវជ្រាវវិទ្យាស្ថាន ដើម្បីការសិក្សាអន្តរជាតិសិង្ហបុរី |
| **លោក សោម អួន** | ប្រធានសម្ព័ន្ធសហជីពកម្មករកម្ពុជា |
| **បណ្ឌិត ហង្ស ពុទ្ធា** | ប្រធានសមាគមវិចិត្រសិល្បៈ |

# អំពីអ្នករៀបរៀង

ឯកឧត្តមបណ្ឌិត **ចាប សុថារិទ្ធ** ជានាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការនិងសន្តិភាព ។ ឯកឧត្តមបណ្ឌិត បានធ្វើការក្នុងស្ថាប័នរដ្ឋាភិបាល និងអង្គការអន្តរជាតិជាច្រើន រួមមានជាជំនួយការផ្ទាល់រដ្ឋមន្ត្រីក្រសួងផែនការ ប្រធាននាយកដ្ឋានអាស៊ាននៃទីស្តីការគណៈរដ្ឋមន្ត្រី នាយកគម្រោងកម្មវិធីអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ (UNDP) នៅភ្នំពេញ និងធ្លាប់ធ្វើជាផ្នែកមួយនៃទីប្រឹក្សា និងជំនាញការជូនអង្គការអន្តរជាតិជាច្រើន រួមមាន FAO, UNCTAD, និង World Bank ជាដើម។ បច្ចុប្បន្ន ឯកឧត្តមបណ្ឌិតក៏ជាទីប្រឹក្សារបស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ។ ឯកឧត្តមបណ្ឌិត **ចាប សុថារិទ្ធ** ដែលបានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតសេដ្ឋកិច្ច ពីសកលវិទ្យាល័យស៊ីដនីយ ប្រទេសអូស្ត្រាលី បានសរសេរនិងរៀបរៀងអត្ថបទ និងសៀវភៅជាច្រើន ស្តីអំពី សេដ្ឋកិច្ច សង្គមកិច្ច កិច្ចការអាស៊ាន គោលនយោបាយការបរទេស សន្តិសុខ និងទំនាក់ទំនងអន្តរជាតិ ហើយលោកក៏បានចូលរួមធ្វើជាវាគ្មិន និងអ្នកវិភាគ ឯករាជ្យក្នុងវេទិកាជាតិ តំបន់ និងអន្តរជាតិនានា។ ក្នុងអំឡុងឆ្នាំ ២០០២-២០០៦ ឯកឧត្តមបណ្ឌិត បានធ្វើបឋកថា និងបង្រៀននៅតាមមហាវិទ្យាល័យ ខ្លះក្នុងទីក្រុងភ្នំពេញ ដូចជា សកលវិទ្យាល័យបច្ចេកវិទ្យា និងគ្រប់គ្រង (UTM) សាលាភូមិន្ទរដ្ឋបាល និងវិទ្យាស្ថានអន្តរជាតិកម្ពុជា (IIC) ហើយក៏បានធ្វើជាសាស្ត្រាចារ្យ ណែនាំសរសេរនិក្ខេបបទថ្នាក់អនុបណ្ឌិត ជូននិសិត្សសកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) ផងដែរ។

# អំពីវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និង សន្តិភាព

វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) គឺជាស្ថាប័នវិភាគី ស្ថាបនាគោលនយោបាយឈានមុខមួយ ដែលបាន បង្កើតឡើង ក្នុងឆ្នាំ១៩៩៤ ដើម្បីរួមវិភាគទានក្នុងការលើកកម្ពស់ ការយោគយល់គ្នា ឱ្យកាន់តែប្រសើរឡើង អំពីបញ្ហាជាតិ បញ្ហាតំបន់ និងអន្តរជាតិ ដែលជះឥទ្ធិពលមកលើប្រទេសកម្ពុជា។

ដើម្បីបំពេញបេសកកម្មនេះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បានរៀបចំបង្កើតឱ្យមានបឋកថា សិក្ខាសាលា វេទិកាសាធារណៈ សន្និសីទជាតិ និងអន្តរជាតិ ស្តីអំពីទំនាក់ទំនងអន្តរជាតិ គោលនយោបាយការបរទេស សេដ្ឋកិច្ច និងនយោបាយ។ វិទ្យាស្ថាន ក៏ជាវិទ្យាស្ថានស្រាវជ្រាវ និងបោះពុម្ព ផ្សាយដ៏សកម្មមួយ នៅលើវិស័យសំខាន់ៗ ដើម្បីផ្សព្វផ្សាយ ចំណេះដល់សធារណជន និងជួយផ្តល់យោបល់ ដល់អ្នកធ្វើនយោបាយ លើវិស័យជាច្រើន ដើម្បីរួមចំណែក អភិវឌ្ឍជាតិ តំបន់ និងពិភពលោក។